# ការរីកចម្រើននៃដំណើររបស់ពួកបរិសុទ្ធ

*ពីពិភពលោកនេះទៅកាន់ការដែលនឹងត្រូវមក*

**ផ្នែកទី១**




ត្រូវបានសរសេរមកនៅក្រោមភាពស្រដៀងគ្នាទៅនឹងការយល់សប្តិដោយ

លោក John Bunyan

អនុសាសន៍ White Young Jeon

អ្នកបកប្រែ ស្រីល័ក្ខ ខន (Sreyleak Kohn)

**Cambodia Reformed Faith Fellowship**

# អារម្ភកថា

 គោលបំណងដែលខ្ញុំបានអធិស្ឋានសុំអោយព័ន្ធកិច្ចសម្រាប់ការសរសេរនេះនឹងត្រូវបានបង្កើតឡើងនៅក្នុងក្រុមជំនុំក្នុងប្រទេសកម្ពុជាជាយូរយារណាស់មកហើយ ហើយវាត្រូវបានជោគជ័យដោយផែនការណ៍របស់ព្រះ។ ខ្ញុំមានអារម្មណ៍រីករាយដែលបានបោះពុម្ពសៀវភៅចំនួន ៣ ក្បាលក្នុងប្រភេទកំរិតខ្ពស់ ហើយជាផលដំបូងសម្រាប់ការសេរនៃព័ន្ធកិច្ចរបស់ CEMFយើង។ ជាបឋម ខ្ញុំសូមសរសើរតម្កើងដល់ព្រះអម្ចាស់ដោយអស់ពីចិត្តចំពោះការបោះពុម្ពផ្សាយទាំងនេះដែលនិពន្ធដោយ John Bunyan ដែលបានបម្រើព្រះអម្ចាស់ជាគ្រូអធិប្បាយដ៏បរិសុទ្ធនៅឆ្នាំ ១៦៧៨ ទៅជាភាសាខ្មែរសំរាប់បេសកកម្មនៅប្រទេសកម្ពុជា។ នៅក្នុងប្រវត្តិសាស្រ្តពួកជំនុំ សៀវភៅនេះត្រូវបានអានជាសៀវភៅបន្ទាប់ពីបទគម្ពីរ។

 ដោយសារភាសាខ្មែរពិបាកខ្លាំងពេក ខ្ញុំមិនហ៊ានធ្វើទេ ប៉ុន្តែព្រះបានរៀបចំក្រុមបកប្រែ CEMF សម្រាប់បេសកកម្មនេះ ហើយទីបំផុតតាមរយៈការលះបង់របស់គេ សៀវភៅនេះត្រូវបានបោះពុម្ពក្នុងឆ្នាំនេះ ក្នុងការរំលឹកខួប ១០០ ឆ្នាំចាប់តាំងពីក្រុមជំនុំកម្ពុជាបានទទួលដំណឹងល្អ ( ១៩២៣) ជាពិសេស កញ្ញា ស្រីល័ក្ខ ខន ដែលបម្រើការងារជាគ្រូបង្រៀនភាសាអង់គ្លេសនៃអនុវិទ្យាល័យ និងជាបុគ្គលិក CEMF ហើយនាងបានបញ្ចប់ការបកប្រែសៀវភៅដោយស៊ូទ្រាំទោះបីគាត់កំពុងសំរាកព្យាបាលរបួសដោយគ្រោះថ្នាក់របស់គាត់ក៏ដោយ។ ខ្ញុំកោតសរសើរនាងចំពោះទឹកចិត្តស្មោះត្រង់របស់នាងដែលស្រឡាញ់ព្រះអម្ចាស់និងដំណឹងល្អ។

ជាទូទៅផ្នែកមួយមានចំនួនច្រើន (៣៦៣ ទំព័រ); ខ្ញុំចែកវាជាបីភាគសម្រាប់ជួយអ្នកអានខ្មែរយើង។ សូមឱ្យព្រះគុណរបស់ព្រះនៅជាមួយពួកគេរហូតទៅ។

នៅក្នុងព្រះគ្រីស្ទ

ថ្ងៃទី ២២ ខែតុលាឆ្នាំ ២០២១

ដោយ: លោកគ្រូបណ្ឌិត វ៉ាយ យ៉ុងចុន  ( ប្រធាន CRFI & CEMF)

# អារម្ភកថា

អារម្ភកថា/ 3

សេចក្តីបញ្ជាក់ការពាររបស់អ្នកនិពន្ធសម្រាប់សៀវភៅនេះ/ 5

សេចក្តីផ្តើម /6

អ្នកផ្សាយដំណឹងល្អផ្តល់នូវទិសដៅ /16

អ្នកជិតខាង៖ លោកមានៈ និងលោកងាយបត់បែន/ 19

អ្វីដែលត្រូវសម្លឹងមើល / 22

លោកអ្នកប្រាជ្ញខាងលោកិយ / 30

ផ្លូវតែមួយ /38

បំណងល្អ៖ អ្នកយាមឃ្លោងទ្វារទុច្ចរិត / 46

អ្នកបកស្រាយ /57

ឈើឆ្កាង /64

អ្នកផ្លូវការ និង សេចក្តីកំពុត /88

ភ័យខ្លាច និង មិនទុកចិត្ត /94

ដេកនៅពេលថ្ងៃ /100

ការចូលទៅកាន់វិមាន "ស្រស់ស្អាត" /103

ភាពកម្រនៃ "ស្រស់ស្អាត" /107

ចាកចេញពីភ្នំ/119

អាប៉ូឡៀអុង/121

ជ្រលងភ្នំនៃម្លប់សេចក្តីស្លាប់ / 130
សាំញ៉ាំ / 142
ការជម្រុញលើកទឹកចិត្តនិងការទស្សទាយន៍របស់អ្នកផ្សាយដំណឹងល្អ / 161
ពិព័រណ៍នៃការឥតប្រយោជន៍ / 166
ការលំបាកវេទនា / 177
លោកដល់ទីបញ្ចប់ / 192
ដេម៉ាស់ / 212
ចូរចងចាំពីប្រពន្ធឡុត / 222
លសម្រាក/ 223
ផ្លូវក្បែរវាលស្មៅ / 227
យក្សនៃកាអស់សង្ឃឹម / 231
ភ្នំដែលគួរគាប់ចិត្ត / 241
ភាពល្ងង់ខ្លៅចេញពីអំណួត /249
អ្នកបញ្ឆោរ /269
មនុស្សមិនជឿថាមានព្រះ /275
ល្ងង់ខ្លៅបង្ហាញភាពល្ងង់ខ្លៅរបស់ខ្លួន /306
សេចក្តីកោតខ្លាចដែលត្រឹមត្រូវ / 320
ប្រទេសនៃអ្នកដែលមានប្តី /331
ស្វាគមន៍ /343
សេចក្តីសរុប /355

# សេចក្តីបញ្ជាក់ការពាររបស់អ្នកនិពន្ធសម្រាប់សៀវភៅនេះ

នៅគ្រាដំបូងដែលខ្ញុំបានយកប៊ិចមកកាន់នៅក្នុងដៃរបស់ខ្ញុំមកសម្រាប់សរសេរ ខ្ញុំមិនបានយល់ទាល់តែសោះថាខ្ញុំគួរតែសរសេរសៀវភៅតូចមួយបែបនេះ។ ហើយខ្ញុំក៏មិនបានចាប់យកអ្វីមួយក្រៅពីនោះផងដែរ ជាជាងអ្វីដែលខ្ញុំបានចាប់ផ្តើមហើយស្ទើរតែចប់សព្វគ្រប់អស់ហើយ។

ហើយសៀវភៅនេះត្រូវបានសរសេរឡើងអំពីផ្លូវនៃការរត់ប្រណាំងរបស់ពួកបរិសុទ្ធ នៅក្នុងគ្រានៃដំណឹងល្អរបស់យើង ដែលត្រូវបានធ្លាក់ចូលនៅក្នុងបែបបទដូចជាកំណាព្យពីដំណើររបស់ពួកគេ និងពីផ្លូវទៅកាន់សិរីរុងរឿងដែលមានច្រើនជាងម្ភៃបែបដែលខ្ញុំបានលើកយកមក។ ខ្ញុំបានបញ្ចប់ដោយមានម្ភៃបែបនៅក្នុងមកុដរបស់ខ្ញុំ។ ហើយការនោះក៏បានកើនឡើងប្រៀបបីដូចជាកំទេចភ្លើងនៃធ្យូងដែលហោះឡើងដែរ។ ខ្ញុំមិនបានគិតថា ប្រសិនបើអ្នកបង្កាត់យ៉ាងរហ័ស នោះខ្ញុំនឹងទុកអ្នកចោលតែឯង បើពុំនោះអ្នកនឹងធ្វើឲ្យឃើញថានៅតែដដែលៗ ហើយនឹងស៊ីសៀវភៅដែលខ្ញុំសរសេរ។

ដូច្នេះខ្ញុំក៏បានសរសេរសៀវភៅនេះឡើងមក។ ប៉ុន្តែខ្ញុំមិនទាន់បានគិតថានឹងបង្ហាញទៅកាន់ពិភពលោកនូវប៊ិចនិងសៀវភៅរបស់ខ្ញុំបែបនោះទេ។ ខ្ញុំគ្រាន់តែគិតថាខ្ញុំមិនបានដឹងអ្វីទាំងអស់។ ហើយខ្ញុំក៏មិនបានស្រវ៉ាចាប់ដើម្បីនឹងផ្គាប់ចិត្តអ្នកជិតខាងរបស់ខ្ញុំនោះដែរ។ ទេ មិនមែនខ្ញុំទេ។ ខ្ញុំធ្វើវាឡើងដោយខ្លួនខ្ញុំដើម្បីនឹងគាប់ដល់ចិត្ត។

ខ្ញុំគ្រាន់តែចំណាយពេលមួយរដូវកាលនៅក្នុងការសរសេរនូវសៀវភៅយ៉ាងរហ័សនេះ ហើយខ្ញុំមានបំណងនឹងជម្រុញខ្លួនឯងឱ្យធ្វើបែបនេះ ដោយចេញពីគំនិតដែលមិនល្អ ដែលធ្វើឲ្យខ្ញុំមានអារម្មណ៍ថាមិនត្រូវ។

ដូច្នេះខ្ញុំក៏បានដាក់ប៊ិចមកលើស្លឹកសៀវភៅដោយអំណរ ហើយភ្លាមនោះខ្ញុំមានគំនិតទាំងសទាំងខ្មៅ ដោយទីបំផុតខ្ញុំមានវិធីធ្វើរបស់ខ្ញុំ។ នៅពេលដែលខ្ញុំទាញវាមក នោះវាក៏ចេញមក ហើយខ្ញុំក៏សរសេរវាចុះ ហើយរហូតទាល់តែវាចេញមកនៅពេលចុងក្រោយ ដែលមានបណ្ដោយមានទទឹងនិងទំហំដែលអ្នកបានឃើញនេះឯង។

មែនហើយ ពេលដែលខ្ញុំផ្គុំវាជាមួយនឹងសេចក្ដីបញ្ចប់ ខ្ញុំបានបង្ហាញវាទៅកាន់អ្នកផ្សេងទៀត ដើម្បីឱ្យខ្ញុំដឹងថាអ្នកណានឹងកាត់ទោសវា ហើយអ្នកណាដែលយល់ស្រប។ ហើយអ្នកខ្លះនិយាយថា "យ៉ូហាន ចូរព្រីនវាចេញមក" ហើយអ្នកខ្លះទៀតក៏និយាយថា "កុំព្រីនវាធ្វើអី" អ្នកខ្លះនិយាយថា "វានឹងជួយបានជាច្រើន" ហើយអ្នកខ្លះទៀតនិយាយថា "មិនល្អទេ"។

ឥលូវតើខ្ញុំមានភាពស្រពិចស្រពិល ដោយមិនដឹងថាអ្វីជាអ្វីដែលខ្ញុំសម្រេចបានតើមែនទេ? ជាចុងក្រោយខ្ញុំបានគិតថា ក្នុងកាលដែលអ្នកតែងតែបែងចែកគ្នា នោះខ្ញុំនឹងព្រីនវាចេញមក។ ហើយវាជាសេចក្ដីដែលខ្ញុំបានសម្រេចចិត្ត ដោយខ្ញុំបានឃើញថាមនុស្សមួយចំនួនចង់ឱ្យខ្ញុំព្រីនវាចេញមក បើទោះជាអ្នកផ្សេងទៀតដែលនៅក្នុងចរន្តនោះមិនព្រមធ្វើក៏ដោយ។ ដើម្បីបញ្ជាក់ថាអ្នកណាដែលបានផ្ដល់យោបល់ដ៏ល្អ នោះខ្ញុំក៏បានដាក់ធ្វើការសាកល្បងមើល។

ខ្ញុំក៏បានគិតបន្ថែមទៀតថា ប្រសិនបើពេលនេះខ្ញុំបានបដិសេធអ្នកដែលចង់ធ្វើវាឱ្យបានគាប់ចិត្ត ខ្ញុំមិនដឹងថាខ្ញុំបែរជាអាចរារាំងពួកគពីអ្វីដែលនឹងធ្វើឲ្យពួកគេកាន់តែអំណរនោះដែរទេ។

សម្រាប់អ្នកដែលមិនចង់ឃើញវាព្រើនចេញមក នោះខ្ញុំនិយាយទៅកាន់ពួកគេថា "ខ្ញុំមិនចង់ធ្វើឲ្យអ្នកមានចិត្តរកាំរកុះនោះទេ តែក្នុងកាលដែលបងប្អូនប្រុសស្រីរបស់អ្នកចូលចិត្តវា នោះសូមអ្នកស៊ូទ្រាំទ្រសិនទម្រាំទាល់តែអ្នកអាចមើលឃើញលើសពីនេះ"

ប្រសិនបើអ្នកមិនព្រមអានទេ នោះក៏ទុកវាចោលទៅ។ អ្នកខ្លះចូលចិត្តញ៉ាំសាច់ ហើយខ្លះទៀតក៏ជ្រើសយកឆ្អឹង។ បាទ ខ្ញុំគួរតែធ្វើវាឱ្យបានសមរម្យដោយខ្ញុំបានសរសេរដោយមានទាំងការបកស្រាយផង។

ខ្ញុំអាចនឹងមិនសរសេរនៅក្នុងទម្រង់ និងវិធីសាស្ត្រនេះ តែខ្ញុំមិនខាននឹងធ្វើអ្វីដែលល្អសម្រាប់អ្នកនោះទេ។ ហេតុអ្វីដែលការសរសេរនេះមិនគួរសម្រេចចេញមក? ពពកខ្មៅនាំភ្លៀងមក តែពពកភ្លឺថ្លាគ្មានភ្លៀងសោះ។ ពិតណាស់ទោះងងឹតឬភ្លឺ ប្រសិនបើពួកគេធ្វើឲ្យប្រាក់របស់គេធ្លាក់ចុះមក ដោយមានបង្កើតផលផ្លែ នោះចូរសរសើរដល់ទាំងពីរនោះ ហើយក៏មិនបានត្រើពីខាងណានោះទេ តែបានផ្ទុកនូវកំណាប់ដែលជាផលផ្លែដែលពួកគេបង្កើតមកជាមួយគ្នានោះ។ ដូច្នេះក៏បញ្ចូលទាំងពីរចូលគ្នា ដើម្បីឲ្យផលផ្លែរបស់នាងមិនអាចនឹងកាត់ផ្តាច់ចេញពីគ្នាបាន ហើយវានឹងល្អបំផុតនៅពេលដែលអ្នកឃ្លាន។ ប៉ុន្តែប្រសិនបើនាងឆ្អែតហើយ នាងនឹងខ្ជាក់ចេញទាំងពីរ ហើយធ្វើឲ្យព្រះពររបស់វាទៅជាឥតប្រយោជន៍។

អ្នកបានដឹងពីរបៀបដែលអ្នកនេសាទធ្វើដើម្បីនឹងបានត្រីហើយ តើពួកគេបានប្រើឧបករណ៍អ្វីខ្លះ។ មើលពីរបៀបដែលគាត់ប្រើនូវភាពវ័យឆ្លាតរបស់គាត់ទាំងប៉ុន្មាន រួមទាំងអន្ទាក់របស់គាត់ ខ្សែសៃ ជ្រុង សន្ទូច និងមងរបស់គាត់។ តែគាត់មិនបានសូចឬដាក់វាយនៅទីនោះ មិនមានអន្ទាក់ មិនមានមង មិនមានឧបករណ៍អ្វីដែលអ្នកធ្វើ។ ត្រូវតែស្ទាស់ស្វែងរករបស់ទាំងនោះ ហើយចាក់រកផងដែរ មិនដូច្នោះទេអ្នកនឹងមិនចាប់បានអ្វីទាំងអស់ មិនថាអ្នកធ្វើយ៉ាងណានោះទេ។

ព្រានព្រៃនឹងចាប់បានសត្វព្រៃបាន ដោយវិធីសាស្ត្រផ្សេងៗ ដែលរាប់ឈ្មោះមិនអស់។ មានទាំងកាំភ្លើង សំណាញ់ មែកក្រូច ភ្លើង និងកណ្ដឹង។ គាត់ដើរលបៗ គាត់ដើរទៅ គាត់ឈរ។ ហើយតើអ្នកណាអាចនឹងរៀបរាប់ពីសភាពរបស់គាត់បាន? ប៉ុន្តែមិនមានរបស់ណាមួយដែលអាចនឹងធ្វើឲ្យគាត់ក្លាយជាម្ចាស់លើសត្វណាដែលគាត់ចូលចិត្តនោះទេ។ គាត់ត្រូវតែផ្លុំសម្លេង ហើយហួចដើម្បីនឹងចាប់វាបាន តែប្រសិនបើគាត់ធ្វើអីចឹង គាត់នឹងមិនចាប់បានសត្វស្លាបនោះទេ។

ប្រសិនបើគុជនៅក្នុងក្បាលគីង្គក់ ហើយក៏មាននៅក្នុងស្នូករបស់សត្វអយស្ទ័រ។ ប្រសិនបើការណាដែលមិនប្រាកដប្រជាថានឹងបានមាសទេ តើអ្នកណានឹងមិនសួរអើពើនឹងមើលថាអាចនឹងមានវានៅទីនោះ ដែលគេនឹងរកឃើញមែន? ឥលូវនេះសៀវភៅតូចរបស់ខ្ញុំនេះ (បើទោះជាមិនមានការផាត់ពណ៌ទាំងនោះដែលនឹងធ្វើឡើងដោយនេះ ឬអ្នកផ្សេងទៀតយក) ក៏វាមិនខ្លះនូវការដែលលេចធ្លោរជាងអ្វីដែលគ្រាន់តែក្លាហានហើយមិនមានទំនោរនោះទេ។ ពិតណាស់ ខ្ញុំមិនទាន់ស្អប់ចិត្តពេញលេញនោះទេនៅពេលដែល

សៀវភៅនេះនឹងឈរនៅពេលដែលត្រូវបានសាកល្បងយ៉ាងត្រឹមត្រូវ "ហេតុអ្វី តើជាបញ្ហាអ្វីទៅ?" "វាងងឹត" "តើវាជាអ្វីទៅអីចឹង?" "ប៉ុន្តែវាធ្វើពុតដូចជាឈើ" "ហើយវាយ៉ាងម៉េចចោះ?" ខ្ញុំtrow មនុស្សមួយចំនួនដោយពាក្យពុតដូចពាក្យរបស់ខ្ញុំដែរ ដែលធ្វើឲ្យសេចក្ដីពិតបានតុបតែងស្រស់ស្អាត ហើយឲ្យពន្លឺរបស់វាបានចែងចាំងមក។ "ប៉ុន្តែពួកគេត្រូវការភាពរឹងមាំ" "ចូរអ្នកនិយាយអ្វីដែលចេញពីគំនិតមក" "នោះពួកគេនឹងចុះខ្សោយ ពាក្យប្រៀបប្រដូចធ្វើឲ្យយើងខ្វាក់"

ភាពរឹងមាំពិតណាស់ក្លាយជាប៊ិចរបស់អ្នកដែលសរសេរការអំពីព្រះទៅកាន់មនុស្ស ប៉ុន្តែតើខ្ញុំត្រូវការភាពរឹងមាំដែរទេ ដោយសារខ្ញុំនិយាយពាក្យប្រៀបប្រដូច? តើក្រឹត្យវិន័យរបស់ព្រះមិនមែនជាច្បាប់នៃដំណឹងល្អ ដែលនៅក្នុងគ្រាពីដើមដែលមានទម្រង់ជាប្រភេទផ្សេងៗ ជាស្រមោល និងជាការប្រៀបប្រដូចទេឬយ៉ាងណា? តែមិនមានមនុស្សណាដែលអាចរកកំហុសពីការទាំងនោះបានឡើយ មិនដូច្នោះគាត់នឹងត្រូវរកឃើញថាបានប្រមាថដល់ប្រាជ្ញាដ៏ខ្ពស់បំផុតហើយ។ ទេ គាត់គួរតែបង្អង់មើល ហើយស្វែងរកនូវអ្វីដែលភ្ជាប់និងផ្តក់ដែលភ្ជាប់ទៅ ដោយការកូនគោនិងចៀម ដោយគោញី និងដោយចៀមឈ្មោល ដោយបក្សីនិងរុក្ខជាតិ ហើយដោយឈាមរបស់ចៀមឈ្មោលនោះព្រះមានបន្ទូលទៅគាត់។ ហើយគាត់សប្បាយចិត្តដែលបានរកឃើញពន្លឺនិងព្រះគុណនៅក្នុងរបស់ទាំងនោះ។

ដូចនេះសូមកុំសរុបសេចក្ដីត្រង់ពេកថាខ្ញុំចង់បានភាពរឹងមាំ ដែលថាខ្ញុំឈ្លើយ។ គ្រប់ការទាំងអស់ដែលបង្ហាញមកមិនរឹងមាំនោះទេ។ គ្រប់ការទាំងអស់

ជាប្រស្នាដែលយើងមិនមើលស្រាល បើមិនដូច្នោះយើងនឹងទទួលបានការដែលអាក្រក់វិញ ហើយនឹងការដែលធ្វើឱ្យព្រលឹងរបស់យើងខាតបង់វិញ។

ពាក្យដែលងងឹតនិងពេញដោយពពករបស់ខ្ញុំ ជាពាក្យដែលកាន់ជាប់សេចក្តីពិតប្រៀបបីដូចជាទូរដែលស្រោបដោយមាសផងដែរ។

ហោរាបានប្រើប្រាស់ការប្រៀបប្រដូចជាច្រើន ដើម្បីបង្ហាញប្រាប់ពីសេចក្តីពិត។ ជាការដែលទាក់ទងនឹងព្រះគ្រីស្ទ សាវករបស់ទ្រង់ផងដែរ នឹងមើលឃើញយ៉ាងច្បាស់ថាសេចក្តីពិតមកសព្វថ្ងៃនេះជាការចម្បង។

តើខ្ញុំក្លាចនឹងនិយាយថាព្រះគម្ពីរបរិសុទ្ធដែលមានបែបបទនិងឃ្លោងឃ្លារបស់ខ្លួន ត្រូវបានសរសេរចុះដោយច្បាស់លាស់ តើគ្រប់ទីកន្លែងសុទ្ធតែពេញទៅដោយការទាំងនេះឬ ដែលជារូបភាពងងឹត ជាអត្ថប្បដិរូប (ដូចជាកំណាព្យ ឬរូបភាពដែលមានបង្កប់ន័យ) តែវាបានរីកសាយចេញពីសៀវភៅតែមួយ ដែលនៅជាប់ ហើយរស្មីនៃពន្លឺទាំងនោះដែលបានប្រែយប់ដ៏ងងឹតនៅថ្ងៃនេះផងឬ?

ចូរមកហើយមើលមកកាន់ការលោតត្រដាងរបស់ខ្ញុំទៅនឹងជីវិតរបស់គាត់ ហើយស្វែងរកបន្ទាត់ដែលងងឹតជាងអ្វីដែលនៅក្នុងសៀវភៅរបស់ខ្ញុំនៅទីនោះ។ គាត់នឹងរកឃើញអ្វីមួយចំនួន ហើយគាត់នឹងដឹងថាទោះជានៅក្នុងការដ៏ល្អបំផុតរបស់គាត់ ក៏នៅតែមានបន្ទាត់ដែលអាក្រក់ផងដែរ។ សូមឲ្យយើងអាចឈរនៅចំពោះមនុស្សដែលមិនលំអៀង ទៅកាន់អ្នកដែលក្រ ខ្ញុំហ៊ានផ្សងព្រេងដប់ ថាពួកគេនឹងយល់អត្ថន័យនៅក្នុងល្បះនេះ ប្រសើរជាងការកុហករបស់គាត់នៅក្នុងអាស្រមប្រាក់ទៅទៀត។ ចូរមក សេចក្តីពិត បើ

ទោះជានៅក្នុងសំបករុំដ៏រឹងក៏ដោយ ខ្ញុំនៅតែរកឃើញវាប្រាប់ថាមានការកាត់ទោស វាកែតម្រូវការគិត វាគាប់ចិត្តនឹងចំណេះដឹង វាធ្វើឲ្យមានចិត្តចុះចូល ការចង់ចាំក៏ពេញដោយអ្វីដែលការស្រមើស្រម៉ៃពេញចិត្តដែរ។ ដូច្នេះវានឹងធ្វើឲ្យបញ្ហារបស់យើងបានរសាយទៅ។

ពាក្យដែលត្រឹមត្រូវដែលខ្ញុំដឹងថាធីម៉ូថេត្រូវតែប្រើ និងរឿងព្រេងរបស់ប្រពន្ធចាស់ៗដែលគាត់ត្រូវបដិសេធ។ ប៉ុន្តែលោកប៉ុលមិនបានថែងថាមិនឲ្យប្រើប្រាស់ប្រស្នា ដែលស្រោបទុកនូវមាស គុជ និងថ្មដែលមានតម្លៃទាំងនោះ ដែលសាកសមនឹងការជីកស្វែងរក ទាំងមានការប្រុងប្រយត្នដ៏ខ្ពស់ផងដែរ។

សូមឲ្យខ្ញុំបានបន្ថែមពាក្យមួយថែមទៀតថា ឱមនុស្សរបស់ព្រះអម្ចាស់អើយ តើអ្នករកាំចិត្តមែនទេ? តើអ្នកសង្ឃឹមថាខ្ញុំនឹងទាញបញ្ហារបស់ខ្ញុំមកនៅក្នុងសំលៀកបំពាក់ផ្សេងឬយ៉ាងណា? ឬក៏ថាខ្ញុំមានអ្វីលើសពីនោះដែលត្រូវពន្យល់បង្ហាញ? មានការបីយ៉ាងដែលខ្ញុំចង់ពន្យល់បកស្រាយ បន្ទាប់មកខ្ញុំនឹងផ្តល់ដល់អ្នកទាំងនោះដែលប្រសើរជាងខ្ញុំបើសមរម្យ។

1. ខ្ញុំរកឃើញថាខ្ញុំត្រូវបានបដិសេធនូវការប្រើប្រាស់វិធីសាស្ត្ររបស់ខ្ញុំ ដូច្នេះខ្ញុំមិនបានបំភ្លៃ តែបានសរសេរជាពាក្យពេចន៍ រឿងរ៉ាវ អ្នកអាន ហើយខ្ញុំមិនបានឈ្លើយនៅក្នុងការទប់ទល់រូបភាពនិងភាពដែលស្រដៀងនោះ នៅក្នុងការដាក់អនុវត្តនោះទេ។ ប៉ុន្តែគ្រប់ទាំងអ្វីដែលខ្ញុំនឹងស្វែងរកនោះគឺជាសេចក្តីពិតដែលជ្រៅថែមទៀតដោយវិធីនេះឬវិធីនោះ។ តើខ្ញុំបាននិយាយបដិសេធដែរទេ? ទេ ខ្ញុំបានទុកចោល (ឧទាហរណ៍ផងដែរ ហើយអ្វីចេញពីនោះដែលព្រះសព្វព្រះទ័យជាង

ដោយពាក្យសំដី និងរបៀបរបស់ពួកគេជាងអ្នកណាទាំងអស់ដែលដកដង្ហើមសព្វថ្ងៃនេះ) ដូច្នេះគឺដើម្បីនឹងបង្ហាញគំនិតរបស់ខ្ញុំ ដែលប្រកាសការទាំងនោះទៅកាន់អ្នកដោយឥតខ្ចោះបំផុត។

2. ខ្ញុំរកឃើញថាមនុស្ស (ដែលខ្ពស់ដូចជាដើមឈើ) នឹងសរសេរការសន្ទនា តែគ្មានអ្នកណានឹងធ្វើបន្តិចបន្តួចដើម្បីនឹងសរសេរបែបនោះបាននោះទេ។ ពិតណាស់ ប្រសិនបើពួកគេបំភ្លៃសេចក្តីពិត នោះពួកគេនិងរបស់ប្រើប្រើរបស់ពួកគេនឹងត្រូវបណ្តាសា តែចូរឲ្យសេចក្តីពិតមានសេរីភាពនៅក្នុងការធ្វើឲ្យឱជារសរបស់នាងបានមកកាន់អ្នកនិងខ្ញុំនៅក្នុងបែបបទដែលព្រះសព្វព្រះហឫទ័យ ដោយសារតើមានអ្នកណាទៀតដែលដឹងប្រសើរជាងទ្រង់ ដែលអ្នកដែលបង្រៀនការទាំងនោះឲ្យចេះភ្ជួរដី ដែលបានដឹកនាំគំនិតរបស់យើងនិងប៉ិចសម្រាប់ការឆ្នៃប៉ាន់របស់ទ្រង់ ហើយទ្រង់បានធ្វើឲ្យការដែលជាគ្រឹះសម្រាប់ជំនួយដល់ការរបស់ព្រះ។
3. ខ្ញុំរកឃើញថាព្រះគម្ពីរនៅក្នុងកន្លែងជាច្រើនមានលក្ខណៈស្រដៀងទៅនឹងវិធីសាស្ត្រនេះ ដែលមានការមួយចំនួនប្រាប់ពីការមួយដើម្បីនឹងបង្ហាញបីការមួយទៀត។ ខ្ញុំបានប្រើប្រាស់វា តែមិនមានអ្វីដែលធ្វើឲ្យគែមពីមាសរបស់សេចក្តីពិតត្រូវរង្គើរនោះទេ។ ដោយសារវិធីសាស្ត្រនេះបានធ្វើឲ្យរស្មីរបស់សេចក្តីពិតបានចែងចាំងមកភ្លឺដូចជាថ្ងៃ។

ហើយពេលនេះមុនពេលខ្ញុំដាក់ប៊ិចរបស់ខ្ញុំ ខ្ញុំនឹងបង្ហាញពីផលប្រយោជន៍នៃសៀវភៅរបស់ខ្ញុំ ហើយបន្ទាប់មកនឹងដាក់ទាំងអ្នកនិងវាទៅក្នុងដៃដែលអ្នកដែលខ្លាំងចុះ ហើយនឹងធ្វើឲ្យអ្នកដែលទន់ខ្សោយបានឈរឡើង។

សៀវភៅនេះសរសេរចេញនៅចំពោះភ្នែករបស់អ្នក ជាអ្នកដែលស្វែងរករង្វាន់ដែលនៅអស់កល្ប។ វាបង្ហាញអ្នកពីពេលដែលគេមក ទីកន្លែងដែលគេទៅ អ្វីដែលគេធ្វើមិនទាន់រួច អ្វីដែលគេធ្វើ វាក៏បង្ហាញអ្នកពីរបៀបដែលគេរត់ ហើយរត់រហូតដល់គេបានទៅដល់ឃ្លោងទ្វារនៃសិរីល្អបានមកដល់។ វាបង្ហាញផងដែរនវណាដែលចេញទៅរកជីវិតជាចម្បង ដែលហាក់ដូចជាមកុដដែលនៅអស់កល្បដែលគេនឹងទទួលបាន។ នៅទីនេះអ្នកនឹងឃើញផងដែរនូវហេតុផលថាហេតុអ្វី ដែលពួកគេបាត់បង់ការខំប្រឹងប្រែងដូចជាមនុស្សល្ងង់ដែលត្រូវស្លាប់។

សៀវភៅនេះនឹងធ្វើឲ្យការធ្វើដំណើររបស់អ្នក ប្រសិនបើអ្នកត្រូវបានគ្រប់គ្រង់ដោយយោបល់របស់វា វានឹងចង្អុលបង្ហាញអ្នកទៅកាន់ទឹកដីបរិសុទ្ធ។ ប្រសិនបើអ្នកអ្នកយល់ពីការដឹកនាំរបស់វា នោះវានឹងធ្វើឲ្យអ្នកខ្ជិលទៅជាសកម្មវិញ ហើយអ្នកខ្វាក់នឹងមើលឃើញការដែលពេញដោយអំណរផង។

តើអ្នកទន្ទឹងចង់បានការដែលកម្រនិងមានប្រយោជន៍មែនទេ? តើអ្នកមើលឃើញសេចក្ដីពិតនៅក្នុងរឿងព្រេងឬយ៉ាងណា? អ្នកពូកែភ្លេចមែនទេ? តើអ្នកអាចចង់ចាំពីថ្ងៃចូលឆ្នាំថ្មីរហូតដល់ថ្ងៃចុងក្រោយនៃខែធ្នូដែរទេ? ដូច្នេះចូរអានការសរសេររបស់ខ្ញុំ នោះវានឹងនៅជាប់ដូចជាជ័រការដូចជាអ្នកជួយរំលែកទុក្ខដល់អ្នកដែលខ្វះជំនួយផង។

សៀវភៅនេះត្រូវបានសរសេរឡើងនៅក្នុងភាសាបែបនេះ ដែលមានឥទ្ធិពលដល់គំនិតរបស់មនុស្សរាប់មិនអស់។ វាប្រៀបបីដូចជារឿងប្រលោមលោក តែវាមិនផ្ទុកអ្វីក្រៅពីដំណឹងល្អដ៏ត្រឹមត្រូវនិងស្មោះត្រង់តែប៉ុណ្ណោះ។

តើអ្នកនឹងបង្វែរខ្លួនរបស់អ្នកចេញពីភាពស្រងេះស្រងោចទេ តើអ្នកនឹងពេញចិត្តនៅឆ្ងាយពីភាពល្ងង់ខ្លៅដែរទេ? តើអ្នកនឹងអានប្រស្នា និងសេចក្ដីពន្យល់របស់វា ហើយបើមិនពុំនោះទេនឹងត្រូវលង់នៅក្នុងការសញ្ជឹងគិតរបស់អ្នកឬ? តើអ្នកចូលចិត្តរើសយកសាច់ឬ? ឬអ្នកចង់មើលទៅកាន់បុរសម្នាក់នៅក្នុងពពក ហើយស្ដាប់សម្លេងរបស់ទ្រង់និយាយមកកាន់អ្នក? តើអ្នកចង់នៅក្នុងការយល់សប្ដិ តែមិនបានដេកលក់ដែរទេ? ឬអ្នកចង់នៅក្នុងពេលមួយដែលមានការយំសោកផងនិងសើចផងឬ? តើអ្នកចង់បាត់បង់ខ្លួនអ្នកហើយមិនមានគ្រោះថ្នាក់អ្វីទាំងអស់ដែរទេ? ហើយរកឃើញខ្លួនឯងម្ដងទៀតដែលមិនមានមន្តស្នេហ៍សោះដែរទេ? ដែលស្គាល់ខ្លួនឯងនិងអានហើយមិនដឹងអ្វីសោះ តែដឹងថាអ្នកមានពរឬអត់ ដោយអាននៅជួរតែមួយ? អូរួចមក ចូរមកនេះហើយដាក់សៀវភៅរបស់ខ្ញុំនៅក្នុងចិត្តនិងក្បាលផង។

**JOHN BUNYAN.**

## សេចក្តីផ្តើម

នៅពេលដែលខ្ញុំដើរកាត់វាលរហោស្ថាននៃពិភពលោកនេះ ខ្ញុំបានដុតបំភ្លឺទៅកន្លែងមួយដែលមានរូងសត្វ (ជាគុក) ហើយខ្ញុំបានផ្តេកខ្លួនខ្ញុំដេកនៅទីនោះ។ ហើយនៅពេលដែលខ្ញុំដេក ខ្ញុំបានយល់សុបិន្តមួយ។ ខ្ញុំសុបិន្តឃើញខ្ញុំសម្លឹងមើលទៅឃើញបុរសម្នាក់ស្លៀកពាក់កន្ទបឈរនៅកន្លែងមួយ ដោយមុខរបស់គាត់បែរទៅកាន់ផ្ទះរបស់គាត់ ដៃគាត់មានសៀវភៅមួយ ហើយមានបន្ទុកមួយយ៉ាងធំនៅលើខ្នងរបស់គាត់។ ខ្ញុំបានមើលទៅ ហើយ

ឃើញគាត់បើកសៀវភៅ ហើយក៏អាន។ ហើយនៅពេលដែលគាត់អាន គាត់យំទួញ ហើយភ័យញ័រ។

"ដ្បិតអំពើទុច្ចរិតរបស់ទូលបង្គំ បានឡើងលិចក្បាលទូលបង្គំហើយ ក៏ដូចជាបន្ទុកយ៉ាងធ្ងន់ ដែលទូលបង្គំទ្រាំមិនបាន។" ទំនុកដំកើង 38:4

"ដ្បិតយើងទាំងអស់គ្នាបានត្រឡប់ទៅដូចជាមនុស្ស ដែលមិនស្អាត ហើយអស់ទាំងអំពើសុចរិតរបស់យើងខ្ញុំ ក៏ដូចជាអាវកខ្វក់ហើយ យើងខ្ញុំរាល់គ្នាស្វិតក្រៀមទៅដូចជាស្លឹកឈើ ហើយអំពើទុច្ចរិតរបស់យើងខ្ញុំ ក៏ផាត់យកយើងទៅដូចជាខ្យល់។" អេសាយ 64:6

"ដូច្នេះ អស់អ្នកណាក្នុងពួកអ្នករាល់គ្នាដែលមិនលះអាល័យពីរបស់ទ្រព្យខ្លួនទាំងអស់ នោះធ្វើជាសិស្សខ្ញុំមិនបានទេ។" លូកា 14:33

"ដ្បិតបើសិនជាគ្រប់ទាំងព្រះបន្ទូលដែលពួកទេវតាបានពោលនោះ បានឃើញថាពិតមែន ហើយគ្រប់ទាំងអំពើរំលង និងសេចក្តីរឹងចចេសក៏ត្រូវទោសចំពោះ នោះធ្វើដូចម្តេចឱ្យយើងរួចបាន បើយើងធ្វេសនឹងសេចក្តីសង្គ្រោះដ៏ធំម្ល៉េះ ដែលព្រះអម្ចាស់បានចាប់ផ្តើមផ្សាយមក រួចពួកអ្នកដែលឮ ក៏បានបញ្ជាក់មកយើងរាល់គ្នាដែរ។" ហេព្រើរ 2:2, 3

ហើយរហូតទាល់តែគាត់ទ្រាំលែងបាន គាត់ក៏ស្រែកទ្រហោរយំហើយនិយាយថា "តើខ្ញុំត្រូវធ្វើយ៉ាងណា?"

"កាលគេបានឮ នោះគេមានសេចក្តីចាក់ចុចក្នុងចិត្ត ក៏សួរពេត្រុស និងពួកសាវកឯទៀតថា បងប្អូនអើយ តើយើងត្រូវធ្វើដូចម្តេច" កិច្ចការ 2:37

ដូច្នេះនៅក្នុងសភាពដ៏សោកសៅនេះ គាត់បានត្រឡប់ទៅផ្ទះ ហើយគាត់បញ្ឈប់ខ្លួនគាត់ដោយមិនបង្ហាញដល់គេតាមដែលគាត់អាចធ្វើបាន ដើម្បីកុំឲ្យប្រពន្ធនិងកូនៗរបស់គាត់ដឹងពីទុក្ខលំបាករបស់គាត់ ប៉ុន្តែគាត់មិនអាចនៅស្ងៀមយូរនោះទេ ដោយសារទុក្ខលំបាករបស់គាត់កាន់តែកើនឡើង។ ដូច្នេះគាត់បានបង្ហាញគំនិតរបស់គាត់ទៅកាន់ប្រពន្ធកូន។ ដូច្នេះគាត់ក៏ចាប់ផ្តើមនិយាយជាមួយពួកគេ "ឱប្រពន្ធសំឡាញ់បងអើយ" "ហើយកូនៗនៃពោះវៀនពោះតាំងរបស់អញអើយ ខ្ញុំនេះដែលជាសំឡាញ់របស់អ្នកនឹងត្រូវវិនាសហើយ ដោយហេតុថាមានបន្ទុកដែលធ្លាក់មកលើខ្ញុំ។ លើសពីនោះទៀត ខ្ញុំបានឮថា ទីក្រុងរបស់យើងនឹងត្រូវដុតបំផ្លាញដោយភ្លើងមកពីស្ថានសួគ៌ ដែលទាំងខ្ញុំផ្ទាល់និងអ្នកទាំងអស់គ្នាដែលជាប្រពន្ធនិងកូនត្រូវបោះទំលាក់ទៅ ហើយនឹងត្រូវវិនាសយ៉ាងវេទនា។ លើកលែងតែ (ការដែលខ្ញុំមិនបានឃើញ) ផ្លូវមួយចំនួនសម្រាប់នឹងគេចខ្លួនត្រូវបានរកឃើញ នោះទើបយើងនឹងត្រូវបានរំដោះឲ្យរួច។" ដោយការនោះទំនាក់ទំនងរបស់គាត់ត្រូវបានមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ពួកគេបានជឿថាអ្វីដែលកាត់បាននិយាយថាជាការពិតមិនមែនដោយការនោះនោះទេ ប៉ុន្តែដោយសារពួកគេបានគិតថាគាត់មានជំងឺវក់នៅក្នុងក្បាលរបស់គាត់។ ដូច្នេះ យប់ក៏ជិតមកដល់ហើយពួកគេសង្ឃឹមថាការដេកនឹងជួយឲ្យខួរក្បាលរបស់គាត់បានសំរាក

ពួកគេក៏ប្រញាប់នឹងនាំគាត់ទៅដេកសម្រាក ប៉ុន្តែពេលយប់នៅតែធ្វើឲ្យមានបញ្ហាដល់គាត់ដូចជាពេលថ្ងៃដែរ។ ដូច្នេះជំនួសឲ្យការដេក គាត់បានចំណាយពេលនឹងដកដង្ហើមធំលាយនឹងទឹកភ្នែក។ ដូច្នេះ នៅពេលព្រឹកមកដល់ ពួកគេបានដឹងនូវអ្វីដែលគាត់បានធ្វើ។ គាត់បានប្រាប់ពួកគេថា "កាន់តែអាក្រក់ឡើងៗ" គាត់បានព្យាយាមនិយាយទៅកាន់ពួកគេម្តងទៀត

ហើយពួកគេក៏កាន់តែចចេសឡើង។ ពួកគេក៏បានគិតថានិងបណ្ដេញនូវជំងឺពីគាត់ចេញ ដោយប្រើពាក្យអាក្រក់ៗនិងកាយវិការគំរោះគំរើយទៅកាន់គាត់។ ជួនកាលពួកគេមើលងាយ ជួនកាលស្ដីបន្ទោស ហើយពេលខ្លះទៀតពួកគេធ្វើមិនដឹងមិនឮពីគាត់។ ដូច្នេះគាត់ក៏ចាប់ផ្ដើមសម្រាកនៅក្នុងបន្ទប់របស់គាត់ ដើម្បីនឹងអធិស្ឋាននិងអាណិតអាសូរដល់ពួកគេ ហើយដើម្បីនឹងបានរំសាយខ្លួនគាត់ពីទុក្ខលំបាក់របស់គាត់។ គាត់ក៏បានដើរតែឯងនៅឯវាលជួនកាលអាន ជួនកាលអធិស្ឋាន ហើយគាត់បានចំណាយពេលជាច្រើនថ្ងៃធ្វើការបែបនោះ។

## អ្នកផ្សាយដំណឹងល្អផ្ដល់នូវទិសដៅ

### Evangelist Provides Direction

ពេលនេះខ្ញុំបានឃើញ ពេលមួយដែលគាត់កំពុងដើរនៅទីវាល ដែលកាត់កំពុងអានសៀវភៅរបស់គាត់ ហើយដែលមានពេញដោយទុក្ខលំបាកនៅក្នុងគំនិតរបស់គាត់ផង។ ហើយនៅពេលដែលគាត់អាន គាត់ក៏បានស្រែករហោរយំឡើងដូចសព្វដង ដោយនិយាយថា "តើខ្ញុំត្រូវធ្វើដូចម្ដេចដើម្បីបានសង្គ្រោះ?"

**"គាត់បាននាំគេចេញទៅក្រៅសួរថា លោកម្ចាស់អើយ តើត្រូវឱ្យខ្ញុំធ្វើដូចម្តេចឱ្យបានសង្គ្រោះផង។ គេក៏ប្រាប់គាត់ថា ចូរជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទទៅ នោះនឹងបានសង្គ្រោះហើយ ព្រមទាំងគ្រួសារលោកផង។" កិច្ចការ 16:30, 31**

ខ្ញុំក៏បានឃើញថាគាត់បានសម្លឹងទៅផ្លូវនេះផ្លូវនោះ ដូចគាត់បម្រុងនឹងរត់អីចឹង។ តែគាត់បានឈរនៅស្ងៀម ដោយសារ (តាមដែលខ្ញុំយល់ឃើញ) គាត់មិនដឹងថានឹងត្រូវទៅផ្លូវណានោះទេ។ ខ្ញុំក៏មើលទៅមើលឃើញបុរសម្នាក់ឈ្មោះ អ្នកផ្សាយដំណឹងល្អដើរមកកាន់គាត់ ហើយសួរថា "តើអ្នកយំធ្វើអ្វី?" គាត់បានឆ្លើយថា "លោកអើយ ខ្ញុំបានដឹងតាមរយៈសៀវភៅនៅក្នុងដៃរបស់ខ្ញុំថា ខ្ញុំនឹងត្រូវទទួលការដាក់ទោសឱ្យត្រូវស្លាប់ ហើយបន្ទាប់មកទទួលការជំនុំជំរះ"

**"ហើយដោយព្រោះបានដំរូវ ត្រូវឱ្យមនុស្សទាំងអស់ស្លាប់មួយដង រួចសឹមជាប់សេចក្តីជំនុំជំរះ" ហេព្រើរ 9:27**

ហើយខ្ញុំបានយល់ឃើញថាខ្ញុំមិនស្ម័គ្រចិត្តនឹងធ្វើការទីមួយនោះទេ

**"កូនចៅរបស់គេមានកិត្តិយសឡើង តែគេមិនដឹងទេ វាត្រូវបន្ទាបចុះ តែគេមិនសំគាល់ដឹងអ្វីសោះ។ គេដឹងឈឺតែចំពោះខ្លួនគេ ហើយមានសេចក្តីទុកព្រួយតែចំពោះចិត្តខ្លួនប៉ុណ្ណោះ។" យ៉ូប 14:21, 22**

ហើយក៏មិនអាចនឹងធ្វើការទីពីរបានដែរ។"

**"តើចិត្តឯងនឹងធន់នៅបាន ហើយដៃឯងនឹងមានកំលាំង នៅថ្ងៃដែលអញធ្វើទោសដល់ឯងបានឬ អញគឺព្រះយេហូវ៉ានេះ អញបានចេញវាចាហើយ ក៏នឹងសម្រេចតាមផង។" អេសេគាល 22:14**

អ្នកផ្សាយដំណឹងល្អ៖ អ្នកផ្សាយដំណឹងល្អក៏និយាយថា "ហេតុអ្វីបានជាមិនស្ម័គ្រចិត្តស្លាប់ ក្នុងកាលដែលជីវិតនេះពោរពេញទៅដោយការអាក្រក់ជាច្រើន?" បុរសនោះក៏ឆ្លើយថា "ពីព្រោះខ្ញុំភ្លាចថាបន្ទុកមួយនេះដែលនៅលើខ្នងរបស់ខ្ញុំនឹងធ្វើឲ្យខ្ញុំលង់កាន់តែជ្រៅជាងផ្នូរខ្មោច ហើយខ្ញុំនឹងធ្លាក់ទៅក្នុងស្ថាននរក។"

**"ដ្បិតទីដុតខ្មោចត្រៀមទុកតាំងពីបុរាណមក អើ ទីនោះបានរៀបចំសម្រាប់ស្តេចនោះឯង ជាទីយ៉ាងជ្រៅ ហើយធំទូលាយ មានឧសគរឡើងជាច្រើនពេញហើយដោយភ្លើង គឺជាអស្សាសៈនៃព្រះយេហូវ៉ា ដែលដូចជាជ្រោះស្ពាន់ធ័រហូរមកបង្កាត់ភ្លើងនោះ។" អេសាយ 30:33**

ហើយលោកប្រុសអើយ ប្រសិនបើខ្ញុំមិនសាកសមនឹងទៅក្នុងគុក នោះខ្ញុំនឹងមិនសមទេ ខ្ញុំដឹងប្រាកដណាស់ថានឹងត្រូវទទួលការជំនុំជំរះ ហើយចេញពីនោះមកនឹងមានការធ្វើទោស ហើយគ្រាន់តែគិតពីការនេះធ្វើឱ្យខ្ញុំយំ។"

បន្ទាប់មកអ្នកផ្សាយដំណឹងល្អបាននិយាយថា "ប្រសិនបើនេះជាសភាពរបស់អ្នក ហេតុអ្វីបានជានៅឈរស្ងៀម?" គាត់ក៏ឆ្លើយថា "ពីព្រោះខ្ញុំមិនដឹងថានឹងត្រូវទៅណា" បន្ទាប់មកគាត់បានឱ្យក្រាំងស្បែកដែលមូរទៅគាត់

ហើយនៅក្នុងនោះមានសរសេរថា "ចូរគេចចេញពីសេចក្តីក្រោធដែលនឹងត្រូវមកដល់!"

**"តែកាលគាត់ឃើញពួកផារីស៊ី និងពួកសាឌូសី មកទទួលបុណ្យជ្រមុជពីគាត់ជាច្រើនដែរ នោះក៏សួរគេថា ឱពូជពស់វែកអើយ តើអ្នកណាបានប្រាប់ឱ្យអ្នករត់ចេញពីសេចក្តីក្រោធដែលត្រូវមកដូច្នេះ?" ម៉ាថាយ 3:7**

ដូច្នេះបុរសនោះបានអានសៀវភៅនោះ ហើយបានមើលទៅកាន់គ្រប់យ៉ាងដែលអ្នកផ្សាយដំណឹងល្អបាននិយាយដោយប្រុងប្រយត្ន ហើយនិយាយថា "តើខ្ញុំត្រូវរបោះទៅទីណា?" បន្ទាប់មកអ្នកផ្សាយដំណឹងល្អបាននិយាយ ហើយចង្អុលទៅកាន់ទីវាលដ៏ធំល្វឹងល្វើយថា "តើអ្នកមើលឃើញឃ្លោងទ្វារទុច្ចរិតដែរទេ?"

**"តែឯទ្វារដែលនាំទៅឯជីវិត នោះតូច ហើយចង្អៀតវិញ ក៏មានមនុស្សតិចណាស់ដែលរកផ្លូវនោះឃើញ។" ម៉ាថាយ 7:14**

បុរសនោះក៏និយាយថា "អត់ទេ" បន្ទាប់មកម្នាក់ទៀតនិយាយទៀតថា "តើអ្នកមើលឃើញពន្លឺដែលចាំងចែងនោះទេ?"

**"ព្រះបន្ទូលនៃទ្រង់ ជាចង្កៀងដល់ជើងទូលបង្គំ ហើយជាពន្លឺបំភ្លឺផ្លូវរបស់ទូលបង្គំ។" ទំនុកដំកើង 119:105**

**"ហើយយើងខ្ញុំមានពាក្យទំនាយដ៏ពិតជាង ដែលគួរឱ្យអ្នករាល់គ្នាយកចិត្តទុកដាក់តាម ដូចជាតាមចង្កៀង ដែលភ្លឺក្នុងទីងងឹត ទាល់តែថ្ងៃភ្លឺឡើង ហើយផ្កាយព្រឹករះឡើងក្នុងចិត្តអ្នករាល់គ្នា។" ពេត្រុស ទី២ 1:19**

គាត់បាននិយាយថា "ខ្ញុំគិតថាខ្ញុំមើលឃើញ។" បន្ទាប់មកអ្នកផ្សាយដំណឹងល្អបាននិយាយថា "ចូររក្សាពន្លឺនោះនៅក្នុងភ្នែករបស់អ្នក ហើយដើរត្រង់ទៅមុខ។ ដូច្នេះអ្នកនឹងឃើញឃ្លោងទ្វារ ជាទ្វារដែលអ្នកនឹងគោះ ហើយវានឹងប្រាប់អ្នកនូវអ្វីដែលអ្នកត្រូវធ្វើ។"

ដូច្នេះខ្ញុំបានឃើញនៅក្នុងសុបិន្តថាបុរសនោះចាប់ផ្តើមរត់ទៅ។ ពេលនេះគាត់មិនទាន់បានរត់ឆ្ងាយចេញពីទ្វាររបស់គាត់នូវឡើយ តែប្រពន្ធនិងកូនៗរបស់គាត់បានដឹងពីការនោះ ពួកគេក៏យំស្រែកហៅគាត់ឱ្យត្រឡប់មកវិញ។

**"បើអ្នកណាមកឯខ្ញុំ ដោយមិនបានលះអាល័យពីឪពុកម្តាយ ប្រពន្ធកូន បងប្អូនប្រុសស្រី និងជីវិតខ្លួនឯងផង អ្នកនោះនឹងធ្វើជាសិស្សខ្ញុំមិនបានទេ។" លូកា 14:26**

ប៉ុន្តែបុរសនោះបានយកម្រាមដៃបិទត្រចៀករបស់គាត់ ហើយបន្តរត់ទៅទៀត ទាំងស្រែកឡើងថា "ជីវិត! ជីវិត! ជីវិតអស់កល្បជានិច្ច!" ដូចនេះគាត់មិនបានមើលមកក្រោយទេ តែគាត់បានរត់គេចទៅត្រង់រហូតដល់ពាក់កណ្តាលនៃទីវាល។

"កាលបាននាំចេញផុតទៅក្រៅហើយ នោះទេវតាប្រាប់ថា ចូររត់ទៅឱ្យបានរួចជីវិតចុះ កុំឱ្យមើលមកក្រោយឡើយ ក៏កុំឱ្យឈប់នៅស្រុកវាលឯណានីមួយផង ចូររត់ទៅឯភ្នំវិញ ក្រែងឯត្រូវវិនាសដែរ។" លោកុប្បត្តិ 19:17

**អ្នកជិតខាង៖ លោកមានៈ និងលោកងាយបត់បែន**

អ្នកជិតខាងក៏បានចេញមកក្រៅមកមើលគាត់រត់ទៅ ហើយនៅពេលដែលគាត់រត់នោះ មានអ្នកខ្លះសើចចំអកឱ្យ

**"ដ្បិតទូលបង្គំបានឮពាក្យបង្កាច់របស់មនុស្សជាច្រើនរបស់មនុស្សជាច្រើន ហើយមានសេចក្ដីស្ញែងខ្លាចនៅព័ទ្ធជុំវិញ អស់ទាំងសំឡាញ់ស្និទ្ធស្នាលរបស់ទូលបង្គំ គេជាពួកអ្នកដែលចាំមើលតែទូលបង្គំដួលដែរ គេថា ចូរសប្រាប់ចុះ**

**នោះយើងនឹងសប្រាប់ដូចគ្នា ប្រហែលជាយើងនឹងបញ្ចុះបញ្ចូលវាបានទេដឹង ដូច្នេះយើងនឹងឈ្នះវាបាន នោះយើងនឹងសងសឹកនឹងវា។" យេរេមា 20:10**

មានអ្នកផ្សេងទៀតបានគំរាមកំហែង ហើយខ្លះទៀតបានយំស្រែកហៅគាត់ឱ្យត្រលប់។ ហើយនៅក្នុងចំណោមអ្នកទាំងនោះ មានពីរនាក់ដែលបានសម្រេចថានឹងដេញតាមគាត់ដោយប្រើកម្លាំងបាយ។ ម្នាក់មានឈ្មោះថា លោកមានះ ហើយម្នាក់ទៀតឈ្មោះថា លោកងាយបត់បែន។ ពេលនេះ បុរសនោះបាននៅចម្ងាយឆ្ងាយគ្រាន់បើដែរពីពួកគេ តែយ៉ាងណាក៏ដោយ ពួកគេបានសម្រេចថានឹងដេញតាមគាត់ហើយ ហើយពួកគេបានដេញតាមគាត់មែន មិនយូរប៉ុន្មាននោះពួកគេក៏ទាន់គាត់។ បន្ទាប់មកបុរសនោះបាននិយាយថា "ឱអ្នកជិតខាងអើយ តើហេតុអ្វីបានជាអ្នកមកនេះ?" ពួកគេនិយាយថា "មកដើម្បីនឹងបបួលអ្នកឱ្យត្រឡប់ទៅជាមួយយើងវិញ" ប៉ុន្តែគាត់បាននិយាយថា "ការនោះមិនអាចកើតឡើងបានទេ។ អ្នករស់នៅក្នុងទីក្រុងដែលនឹងត្រូវវិនាសអន្តរាយជាទីដែលខ្ញុំបានកើតនៅទីនោះ។ ខ្ញុំឃើញថាវានឹងត្រូវវិនាសមែន ហើយនឹងត្រូវស្លាប់នៅទីនោះយូរឬឆាប់ អ្នកនឹងត្រូវលិចចុះទៅជ្រៅជាងផ្នូរខ្មោចទៅកាន់កន្លែងមួយដែលឆេះដោយភ្លើងនិងស្ពាន់ធ័រ។ ចូរចេះឆ្អែតចិត្តឡើងអ្នកជិតខាងអើយ ហើយមកជាមួយខ្ញុំមក។"

លោកមានះ៖ "យ៉ាងម៉េច?" ហើយគាត់និយាយថា "ហើយចាកចេញពីមិត្តភក្តិនិងទីដែលស្រុកស្រួលរបស់យើងផង"

គ្រីស្ទាន៖គ្រីស្ទានបាននិយាយថា "មែនហើយ" ដោយសារវាជាឈ្មោះរបស់គាត់ "ដោយការនោះជាអ្វីដែលអ្នកត្រូវតែបោះបង់ចោល ហើយវាមិនមានតម្លៃស្មើនឹងរបស់បន្តិចបន្តួចដែលកំពុងតែស្វែងរកនោះផង។"

**"ដោយយើងខ្ញុំមិនរាប់អានរបស់ដែលមើលឃើញឡើយ គឺរាប់អានតែរបស់ដែលមើលមិនឃើញវិញ ដ្បិតរបស់ដែលមើលឃើញ នោះស្ថិតស្ថេរមិនយូរប៉ុន្មានទេ តែឯរបស់ដែលមើលមិនឃើញ នោះស្ថិតស្ថេរអស់កល្បជានិច្ចវិញ។" កូរិនថូស ទី២ 4:18**

ហើយប្រសិនបើអ្នកមកជាមួយខ្ញុំ ហើយកាន់តាមវា អ្នកនឹងត្រូវបង់ថ្លៃដូចជាខ្ញុំដែរ ដោយសារកន្លែងដែលខ្ញុំទៅគឺគ្រប់គ្រាន់និងបរិបូរ។

**"កាលវាភ្ញាក់ដឹងខ្លួន នោះក៏គិតថាឪពុកអញ មានជើងឈ្នួលប៉ុន្មានៗ សុទ្ធតែមានអាហារបរិបូរគ្រប់គ្នា តែនៅទីនេះអញជិតដាច់ពោះស្លាប់ហើយ។" លូកា 15:17**

ចូរមក ហើយបញ្ជាក់ពីពាក្យរបស់ខ្ញុំចុះ"

លោកមានៈ៖ តើអ្វីទៅជាការដែលអ្នកស្វែងរក ក្នុងកាលដែលអ្នកលះចោលលោកិយនេះទៅដើម្បីស្វែងរកវា?

គ្រីស្ទាន៖ ខ្ញុំស្វែងរកមរតកដែលមិនចេះពុករលួយ មិនខូចបង់ ហើយមិនរលាយសាបសូនទៅទេ។

**"ហើយឱ្យយើងបានមរតក ដែលមិនចេះពុករលួយ ក៏ឥតសៅហ្មង ហើយមិនដែលស្រពោនឡើយ ជាមរតកដែលបម្រុងទុកឱ្យយើងរាល់គ្នានៅស្ថានសួគ៌។" ពេត្រុស ទី១ 1:4**

ហើយវាបានដាក់នៅស្ថានសួគ៌ ហើយមានសុវត្ថិភាពនៅទីនោះ ដើម្បីនឹងផ្តល់ឱ្យ នៅពេលកំណត់ទៅអ្នកដែលស្វែងរកវាដោយឧស្សាហ៍។

**"តែឥឡូវនេះ គេសង្វាតចង់បានស្រុកមួយដែលប្រសើរជាង គឺខាងស្ថានសួគ៌វិញ បានជាព្រះទ្រង់គ្មានសេចក្តីខ្មាស ដោយគេហៅទ្រង់ជាព្រះនៃគេនោះឡើយ ដ្បិតទ្រង់បានរៀបចំទីក្រុងមួយឱ្យគេហើយ។" ហេព្រើរ 11:16**

ចូរអានការនេះនៅក្នុងសៀវភៅរបស់ខ្ញុំទៅ

លោកមានះ៖ លោកមានៈបាននិយាយថា "នៅស្ងៀម" "ហើយយកសៀវភៅរបស់អ្នកចេញទៅ តើអ្នកនឹងត្រឡប់ទៅវិញជាមួយពួកយើងដែរទេ?"

គ្រីស្ទានៈ គាត់និយាយថែមទៀតថា "ទេ ខ្ញុំមិនទៅទេ" "ពីព្រោះខ្ញុំបានដាក់ដៃរបស់ខ្ញុំកាន់នង្គ័លហើយ។"

**"ទ្រង់មានបន្ទូលទៅអ្នកនោះថា អ្នកណាដែលដាក់ដៃកាន់នង្គ័ល ហើយងាកបែរទៅមើលក្រោយ អ្នកនោះមិនគួរនឹងនគរព្រះទេ។" លូកា 9:62**

លោកមានះ៖ តោះមកអ្នកជិតខាងងាយបត់បែន ចូរយើងត្រឡប់ទៅវិញ ហើយទៅផ្ទះតែយើងបានហើយ។ មានអ្នកទៅជាមួយមនុស្សឆ្កួតឥត

ប្រយោជន៍ ដែលនៅពេលដែលពួកគេទទួលរបស់មានតម្លៃនៅគ្រាចុងក្រោយ នោះពួកគេឆ្លាតជាងនៅក្នុងក្រសៃភ្នែករបស់ពួកគេ ជាជាងបុរសប្រាំពីរនាក់ដែលចេះផ្តល់ហេតុផលទៅទៀត។

លោកងាយនឹងបត់បែន៖ នោះលោកងាយបត់បែនបាននិយាយថា "ចូរកុំប្រមាថឡើយ ប្រសិនបើអ្វីដែលគ្រីស្ទានល្អបាននិយាយពិតមែននោះ នោះការដែលគាត់ស្វែងរកនោះពិតជាប្រសើរជាងរបស់ពួកយើងផង។ ចិត្តរបស់ខ្ញុំទោរទៅជាមួយអ្នកជិតខាងរបស់ខ្ញុំហើយ។"

លោកមានះ៖ យ៉ាងម៉េចហ្នឹង? កាន់តែល្ងង់ហើយមែនទេ? ចូរមកតាមខ្ញុំហើយត្រឡប់ទៅវិញ។ តើអ្នកណាអាចដឹងបាន ថាមនុស្សមានបញ្ហាខួរក្បាលនេះនឹងនាំអ្នកទៅណា? ចូរត្រឡប់ទៅវិញ ត្រឡប់ទៅវិញ ហើយចូរមានប្រាជ្ញាឡើង!

គ្រីស្ទាន៖ អត់ទេ។ តែអ្នកមកជាមួយអ្នកជិតខាងលោកងាយបត់បែន។ ការដែលខ្ញុំបាននិយាយពិតជាមានមែន ហើយមានទាំងសិរីល្អនៅជុំវិញផង។ ប្រសិនបើអ្នកមិនជឿខ្ញុំទេ ចូរអាននៅក្នុងសៀវភៅនេះចុះ ដើម្បីឱ្យបានដឹងពីសេចក្តីពិតដែលចែងនៅក្នុងសៀវភៅនេះ។ មើលគ្រប់ការទាំងអស់ត្រូវបានអះអាងដោយឈាមរបស់ព្រះអង្គដែលធ្វើសម្រេចនូវការនោះផង។

**"ដូច្នេះ សេចក្តីសញ្ញាចាស់ក៏មិនបានតាំងឡើង ដោយឥតឈាមដែរ ពីព្រោះកាលលោកម៉ូសេបានមានប្រសាសន៍ ប្រាប់ពីបញ្ញត្តទាំងប៉ុន្មាន តាមក្រឹត្យវិន័យ ដល់ប្រជាជនទាំងឡាយហើយ នោះលោកក៏យកឈាមកូនគោ និង**

ឈាមពពែ ព្រមទាំងទឹក និងរោមចៀមជ្រលក់ក្រហម ហើយនិងមែកហ៊ីសុប មកប្រោះលើគម្ពីរនោះឯង ព្រមទាំងលើប្រជាជនទាំងអស់ដែរ។ ដោយមានប្រសាសន៍ថា «នេះជាឈាមនៃសញ្ញា ដែលព្រះទ្រង់បង្គាប់មកអ្នករាល់គ្នា»។ លោកក៏ប្រោះឈាមទៅលើរោងឧបោសថ និងគ្រឿងប្រដាប់ដែលសម្រាប់ការងារទាំងប៉ុន្មានបែបដូច្នោះដែរ។ ហើយតាមក្រឹត្យវិន័យ សឹងតែគ្រប់របស់ទាំងអស់បានស្អាត ដោយសារឈាម បើគ្មានខ្ចាយឈាមទេ នោះគ្មានផ្លូវណាឲ្យបានរួចពីបាបឡើយ។ ដូច្នេះ អស់ទាំងគំរូពីរបស់នៅស្ថានសួគ៌បានត្រូវសម្អាត ដោយសាររបស់ទាំងនោះ តែរបស់នៅស្ថានសួគ៌វិញ នោះត្រូវសម្អាតដោយយញ្ញបូជាប្រសើរជាងទៅទៀត។ ដ្បិតព្រះគ្រីស្ទទ្រង់មិនបានយាងចូលទៅក្នុងទីបរិសុទ្ធធ្វើដោយដៃ ដែលជាគំរូពីទីបរិសុទ្ធពិតនោះទេ គឺបានចូលទៅក្នុងស្ថានសួគ៌នោះឯង ដើម្បីនឹងលេចមកក្នុងពេលឥឡូវនេះ នៅចំពោះព្រះភ័ក្ត្រនៃព្រះ ជំណាងយើងរាល់គ្នា។ ក៏មិនមែននឹងថ្វាយព្រះអង្គទ្រង់ជាញឹកញយ ដូចជាសម្តេចសង្ឃ ដែលចូលទៅក្នុងទីបរិសុទ្ធរាល់តែឆ្នាំ ទាំងយកឈាមដទៃនោះដែរ។ ដ្បិតបើយ៉ាងដូច្នោះ នោះត្រូវឲ្យទ្រង់រងទុក្ខជាច្រើនដងតាំងពីកំណើតលោកីយ៍មក តែជាន់ឥឡូវនេះ ដែលជាចុងបំផុតអស់ទាំងកល្បនោះទ្រង់បានលេចមក១ដង ដើម្បីនឹងលើកអំពើបាបចោល ដោយថ្វាយព្រះអង្គទ្រង់វិញ ទុកជាយញ្ញបូជា។ ហើយដោយព្រោះបានតម្រូវឲ្យមនុស្សទាំងអស់ស្លាប់១ដង រួចសឹមជាប់សេចក្តីជំនុំជម្រះ។ ដូច្នេះ ព្រះគ្រីស្ទក៏បែបយ៉ាងនោះដែរ ដែលទ្រង់បានថ្វាយព្រះអង្គទ្រង់១ដងហើយ ដោយព្រោះបាបរបស់មនុស្សជាច្រើន នោះទ្រង់នឹងលេចមកម្តងទៀត ក្រៅពីរឿងអំពើបាប គឺសម្រាប់នឹងជួយសង្គ្រោះដល់អស់អ្នកដែលរង់ចាំទ្រង់។” ហេព្រើរ 9:18-28

លោកងាយបត់បែនបាននិយាយថា "ពិតណាស់ អ្នកជិតខាងមានៈអើយ ខ្ញុំបានមកដល់ចំណុចមួយ ដែលខ្ញុំមានបំណងទៅជាមួយនឹងបុរសល្អនេះ ហើយដើម្បីនឹងបានរង្វាន់ជាមួយនឹងគាត់ តែសំឡាញ់ដ៏ល្អរបស់ខ្ញុំអើយ តើអ្នកស្គាល់ផ្លូវទៅកាន់កន្លែងដែលអ្នកប្រាថ្នាចង់ទៅដែរទេ?"

គ្រីស្ទានៈ ខ្ញុំមានម្នាក់ដែលចង្អុលបង្ហាញផ្លូវដល់ខ្ញុំ ដែលមានឈ្មោះថា អ្នកផ្សាយដំណឹងល្អ ដើម្បីនឹងជម្រុញខ្ញុំឱ្យទៅដល់ឃ្លោងទ្វារតូចមួយដែលនៅខាងមុខយើងនេះ ជាកន្លែងដែលយើងនឹងទទួលបានការណែនាំអំពីផ្លូវទៅ។

លោកងាយបត់បែនៈ អីចឹងអ្នកជិតខាងល្អអើយ ចូរយើងចេញទៅ។

បន្ទាប់មកពួកគេទាំងពីរបានចេញទៅជាមួយគ្នា

លោកមានៈៈ លោកមានៈបាននិយាយថា "ហើយខ្ញុំនឹងត្រឡប់ទៅកន្លែងរបស់ខ្ញុំវិញ ខ្ញុំនឹងមិនមានអ្នកមកជាមួយដែលនាំទៅផ្លូវខុស ជាសំឡាញ់ដ៏អស្ចារ្យអីនោះទេ។"

## អ្វីដែលត្រូវសម្លឹងមើល

ឥលូវខ្ញុំបានឃើញនៅក្នុងសុបិន្តរបស់ខ្ញុំ ថានៅពេលដែលលោកមានៈបានត្រឡប់ទៅវិញ គ្រីស្ទាននិងលោកងាយនឹងបត់បែនបានធ្វើដំណើរទៅដោយ

ជជែកគ្នានៅតាមវាលផង។ ហើយពួកគេក៏បានចាប់ផ្ដើមការជជែកវែកញែកគ្នា។

គ្រីស្នាន៖ ចូរមកអ្នកជិតខាងងាយនឹងបត់បែនអើយ តើអ្នកយ៉ាងម៉េចហើយ? ខ្ញុំអរណាស់ដែលអ្នកចាប់អារម្មណ៍នឹងមកជាមួយខ្ញុំ។ ប្រសិនបើលោកមានៈអាចដឹងនូវអារម្មណ៍ដែលខ្ញុំទទួលបាននូវអំណាចនិងការភ័យខ្លាចនៅអ្វីដែលមើលមិនឃើញនោះ នោះគាត់នឹងមិនបានបែរខ្នងដាក់យើងដូច្នេះទេ។

លោកងាយនឹងអូសទាញ៖ ចូរមកអ្នកជិតខាងគ្រីស្នានអើយ ក្នុងកាលដែលមានតែយើងពីនាក់នៅទីនេះ សូមអ្នកប្រាប់ខ្ញុំពីរឿងនោះថែមទៀត ហើយពីវិធីដែលអាចនឹងធ្វើឱ្យយើងមានអំណរចំពោះការនោះ គឺពីកន្លែងដែលយើងកំពុងទៅនេះផង។

គ្រីស្នាន៖ ខ្ញុំអាចយល់ឃើញពីការទាំងនោះជាមួយនឹងគំនិតរបស់ខ្ញុំ ជាងការដែលនិយាយដោយអណ្ដាតរបស់ខ្ញុំ តែបើអ្នកចង់ដឹងទៅហើយនោះ ខ្ញុំនឹងអានពីការទាំងនោះនៅក្នុងសៀវភៅរបស់ខ្ញុំ។

អ្នកងាយអូសទាញ៖ តើអ្នកគិតថាពាក្យនៅក្នុងសៀវភៅរបស់អ្នកប្រាកដជាពិតដែរទេ?

គ្រីស្នាន៖ បាទពិតណាស់។ ដោយសារសៀវភៅនេះបានបង្កើតឡើងមកដោយទ្រង់ដែលមិនចេះកុហកសោះ។

**"ដោយសេចក្តីសង្ឃឹមដល់ជីវិតដ៏នៅអស់កល្បជានិច្ច ដែលព្រះដ៏មិនចេះភូត ទ្រង់បានសន្យាមុនអស់ទាំងកល្ប។" ទីតុស 1:2**

លោកងាយអូសទាញ៖ និយាយបានល្អណាស់។ តើការទាំងនោះជាអ្វីខ្លះទៅ?

គ្រីស្ទាន៖ មាននគរដែលមិនចេះចប់មួយ ដែលនឹងត្រូវក្លាយទៅជាមរតក។ ហើយជីវិតអស់កល្បជានិច្ចនឹងត្រូវផ្តល់មកយើង ដែលយើងនឹងគ្រងមរតកនៅនគរនោះអស់កល្បជានិច្ច។

**"ដ្បិតមើលអញនឹងបង្កើតផ្ទៃមេឃថ្មី ហើយនឹងផែនដីថ្មី ឯរបស់ពីមុនៗ នោះនឹងគ្មានអ្នកណានឹកចាំទៀត ក៏មិនដែលចូលក្នុងគំនិតឡើយ។" អេសាយ 65:17**

**"ចៀមខ្ញុំទាំងប៉ុន្មានវាស្តាប់ខ្ញុំ ហើយមកតាមខ្ញុំ ខ្ញុំក៏ស្គាល់វាដែរ ខ្ញុំឱ្យជីវិតអស់កល្បជានិច្ចដល់វា វាមិនត្រូវវិនាសនៅអស់កល្បរៀងទៅ ក៏គ្មានអ្នកណាឆក់យកវាពីដៃខ្ញុំបានទេ។ ព្រះវរបិតានៃខ្ញុំ ដែលប្រទានវាមកខ្ញុំ ទ្រង់ធំលើសជាងទាំងអស់ គ្មានអ្នកណាអាចនឹងឆក់យកវាចេញពីព្រះហស្តរបស់ព្រះវរបិតាខ្ញុំបានឡើយ។" យ៉ូហាន 10:27, 29**

លោកងាយអូសទាញ៖ និយាយបានល្អ។ ហើយមានអ្វីទៀតដែរទេ?

គ្រីស្ទាន៖ មានមកុដនៃសិរីល្អដែលនឹងត្រូវផ្តល់ដល់យើង។ ហើយនឹងសំលៀកបំពាក់ដែលធ្វើឲ្យយើងចែងចាំងដូចព្រះអាទិត្យនៅលើគ្រឹះនៃស្ថានសួគ៌។

**"គ្រានោះ ពួកសុចរិតនឹងភ្លឺដូចជាថ្ងៃនៅក្នុងនគររបស់ព្រះវរបិតានៃគេ អ្នកណាមានត្រចៀកសំរាប់ស្តាប់ ឱ្យស្តាប់ចុះ។" ម៉ាថាយ 13:43**

**"ពីនេះទៅមុននឹងមានមកុដនៃសេចក្តីសុចរិត បម្រុងទុកឱ្យខ្ញុំ ដែលព្រះអម្ចាស់ដ៏ជាចៅក្រមសុចរិត ទ្រង់នឹងប្រទានមកខ្ញុំនៅថ្ងៃនោះ មិនមែនដល់តែខ្ញុំម្នាក់ប៉ុណ្ណោះ គឺដល់អស់អ្នកណា ដែលចូលចិត្តនឹងដំណើរទ្រង់យាងមកវិញនោះដែរ។" ធីម៉ូថេ ទី២ 4:8**

**"ប៉ុន្តែនៅក្រុងសើដេស ឯងក៏មានអ្នកខ្លះដែលមិនបានធ្វើឲ្យសំលៀកបំពាក់ខ្លួនស្មោកគ្រោកដែរ អ្នកទាំងនោះនឹងស្លៀកពាក់ស ដើរជាមួយនឹងអញ ដ្បិតគេបានគួរហើយ។" វិវរណៈ 3:4**

លោកងាយនឹងទាក់ទាញ៖ នេះគួរឱ្យពេញចិត្តណាស់។ មានអ្វីទៀតទេ?

គ្រីស្ទាន៖ នឹងមិនមានការទួញសោកសង្រេងទៀតឡើយ ដោយសារទ្រង់ជាម្ចាស់នៅទីនោះនឹងជូតទឹកភ្នែកទាំងអស់ចេញពីភ្នែករបស់យើង។

**"ទ្រង់នឹងបំផ្លាញសេចក្តីស្លាប់ឱ្យសូន្យបាត់បង់ទៅជាដរាប នោះព្រះអម្ចាស់យេហូវ៉ា ទ្រង់នឹងជូតទាំងទឹកភ្នែកពីមុខមនុស្សទាំងអស់ ហើយទ្រង់នឹងសេច**

**ក្តីត្មះតិះដៀលចំពោះរាស្ត្រទ្រង់ ពីផែនដីទាំងមូលចេញ ដ្បិតព្រះយេហូវ៉ាទ្រង់បានមានបន្ទូលដូច្នេះហើយ។" អេសាយ 25:8**

"គេនឹងមិនឃ្លាន ឬស្រេកទៀត ក៏មិនត្រូវថ្ងៃចាំងមកលើគេ ឬចំហាយណាទៀតឡើយ។ ពីព្រោះកូនចៀមដែលនៅកណ្តាលបល្ល័ង្ក ទ្រង់នឹងឃ្វាលហើយនាំគេ ទៅដល់រន្ធទឹកនៃជីវិត ហើយព្រះទ្រង់នឹងជូតអស់ទាំងភ្នែកពីភ្នែកគេចេញ។"

**"ព្រះទ្រង់នឹងជូតអស់ទាំងទឹកភ្នែក ពីភ្នែកគេចេញ និងគ្មានសេចក្ដីស្លាប់ ឬសេចក្តីសោកសង្រេង ឬសេចក្តីយំទួញ ឬទុក្ខលំបាកណាទៀតឡើយ ដ្បិតសេចក្តីមុនទាំងប៉ុន្មាន បានកន្លងបាត់ទៅហើយ។" វិវរណៈ 21:4**

លោកងាយអូសទាញ៖ តើយើងនឹងមានសំឡាញ់អ្វីនៅទីនោះ?

គ្រីស្ទាន៖ នៅទីនោះយើងនឹងទៅជាមួយនឹង សេរ៉ាផីម និងចេរ៉ូប៊ីម ជាសត្វដែលនឹងធ្វើឲ្យភ្នែករបស់អ្នកសម្លឹងទៅមើលពួកគេ។

**"នៅឆ្នាំដែលស្តេចអ៊ូសៀសទ្រង់បានសុគត នោះខ្ញុំឃើញព្រះអម្ចាស់ទ្រង់គង់លើបល្ល័ង្កនៅទីខ្ពស់ ហើយបានដំកើងឡើង ឯរំភាយព្រះពស្ត្រទ្រង់សាយមកពេញក្នុងព្រះវិហារ។" អេសាយ 6:1**

**"ព្រះអម្ចាស់ទ្រង់នឹងយាងចុះពីស្ថានសួគ៌មក ដោយស្រែកបង្គាប់មួយព្រះឱស្ឋទាំងមានឮសម្លេងមហាទេវតា និងត្រែរបស់ព្រះផង នោះពួកស្លាប់ក្នុងព្រះគ្រីស្ទនឹងរស់ឡើងវិញជាមុនបង្អស់។ រួចយើងរាល់គ្នាដែល កំពុងតែរស់នៅ ក៏**

**នឹងបានលើកឡើងទៅក្នុងពពកជាមួយគ្នាទាំងអស់ ដើម្បីឱ្យបានជួបជុំនឹងព្រះអម្ចាស់នៅនាអាកាស យ៉ាងនោះ យើងនឹងនៅជាមួយនឹងព្រះអម្ចាស់ជាដរាបទៅ។" ថែស្សាឡូនិច ទី១ 4:16-17**

**"នោះខ្ញុំឃើញ ហើយក៏ឮសម្លេងទេវតាជាច្រើននៅជុំវិញបល្ល័ង្ក ព្រមទាំងតួមានជីវិត និងពួកចាស់ទុំផង ឯចំនួននៃទេវតានោះ មានទាំងម៉ឺនទាំងសែន ហើយទាំងពាន់រាប់ជាពាន់។" វិវរណៈ 5:11**

នៅទីនោះអ្នកនឹងជួបមនុស្សរាប់ពាន់ រាប់ម៉ឺនដែលបានទៅដល់មុនយើងនៅទីនោះ។ ហើយមិនមាននរណាម្នាក់នឹងត្រូវរងគ្រោះ តែពេញដោយការស្រឡាញ់និងបរិសុទ្ធ។ គ្រប់គ្នានឹងដើរនៅមុខព្រះអម្ចាស់ ហើយឈរនៅក្នុងព្រះវត្តមានទ្រង់ដោយមានការទទួលជានិច្ច។ និយាយទៅ យើងនឹងមើលឃើញពួកចាស់ទុំដែលមានមកុដមាស។

**"នៅព័ទ្ធជុំវិញបល្ល័ង្កនោះ ក៏មានបល្ល័ង្ក២៤ទៀត ហើយខ្ញុំឃើញអ្នកចាស់ទុំ២៤នាក់ អង្គុយលើបល្ល័ង្កទាំងនោះ ទាំងស្លៀកពាក់ស ហើយមានមកុដមាសនៅលើក្បាល។" វិវរណៈ 4:4**

នៅទីនោះយើងនឹងឃើញក្រមុំបរិសុទ្ធដែលមានកាន់ចាប់ស៊ុង

"ខ្ញុំក្រឡេកទៅឃើញកូនចៀម ឈរនៅលើភ្នំស៊ីយ៉ូន ហើយមានមនុស្ស១សែន៤ម៉ឺន៤ពាន់នាក់ ដែលមានព្រះនាមទ្រង់ និងព្រះនាមព្រះវរបិតាទ្រង់កត់លើថ្ងាស គេបានឈរជាមួយដែរ។ រួចខ្ញុំឮសំឡេងមកពីលើមេឃ ដូចជាសូរទឹកច្រើន ហើយដូចផ្គរលាន់យ៉ាងខ្លាំង រីឯសំឡេងដែលខ្ញុំឮនោះ ក៏ដូចជាសូរ

សព្ទរបស់ពួកតន្ត្រីដែលកំពុងតែចាប់ស៊ុង។គេច្រៀងបទ១ថ្មី នៅមុខបល្ល័ង្ក ហើយមុខតួមានជីវិតទាំង៤ និងពួកចាស់ទុំដែរ គ្មានអ្នកណាអាចនឹងរៀនបទនោះបានទេ មានតែមនុស្ស១សែន៤ម៉ឺន៤ពាន់នាក់ ដែលទ្រង់លោះពីផែនដីចេញប៉ុណ្ណោះ។នោះជាពួកព្រហ្មចារី ដែលមិនបានបង្ខូចខ្លួននឹងស្រី ឡើយ គេតាមកូនចៀមទៅគ្រប់កន្លែងដែលទ្រង់យាងទៅ ទ្រង់បានលោះគេចេញពីពួកមនុស្សលោក ទុកជាផ្លែដំបូងថ្វាយដល់ព្រះ ហើយនិងកូនចៀម។មិនឃើញមានសេចក្តីភូតភរ នៅក្នុងមាត់គេឡើយ ដ្បិតគេឥតសៅហ្មង។" **វិវរណៈ 14:1-5**

នៅទីនោះយើងនឹងឃើញមនុស្សដែលត្រូវគេកាត់ជាចំណែកៗដោយសារព្រះបន្ទូល ត្រូវដុតនៅក្នុងអណ្តាតភ្លើង ត្រូវសត្វសាហាវស៊ី ត្រូវលង់នៅក្នុងសមុទ្រ ដោយសារសេចក្តីស្រឡាញ់របស់គេមានចំពោះព្រះអម្ចាស់ដែលនៅទីនោះ ជាកន្លែងដែលល្អហើយមានគ្រងដោយភាពមិនចេះសាបសូន្យប្រៀបដូចជាសំលៀកបំពាក់។

"អ្នកណាដែលស្រឡាញ់ជីវិតខ្លួន នោះនឹងបាត់ជីវិតទៅ តែអ្នកណាដែលស្អប់ជីវិតខ្លួន នៅលោកីយ៍នេះវិញ នោះនឹងរក្សាជីវិតទុក ដរាបដល់អស់កល្បរៀងទៅ" **យ៉ូហាន 12:25**

"ដ្បិតនៅក្នុងត្រសាលនេះ យើងខ្ញុំតែងតែថ្ងូរ ដោយសង្វាតនឹងចង់ប្រដាប់ខ្លួនដោយទីលំនៅរបស់យើងខ្ញុំ ជាទីលំនៅដែលមកពីស្ថានសួគ៌ណាស់។ ឲ្យតែយើងខ្ញុំបានប្រដាប់ខ្លួនចុះ ដើម្បីកុំឲ្យមានឃើញយើងខ្ញុំនៅអាក្រាតឡើយ។ ដ្បិតយើងខ្ញុំដែលនៅក្នុងត្រសាលនេះ យើងថ្ងូរមែន ដោយមានបន្ទុក

**យ៉ាងធ្ងន់ ពីព្រោះយើងមិនចង់ដោះសម្លៀកបំពាក់នេះចេញទេ គឺចង់តែស្លៀកពាក់វិញ ដើម្បីឲ្យជីវិតបានលេបរបស់ ដែលតែងតែស្លាប់ ឲ្យបាត់ទៅនោះ” កូរិនថូស ទី២ 5:2-4**

លោកងាយអូសទាញ៖ គ្រាន់តែស្ដាប់ពីការនេះ គ្រប់គ្រាន់នឹងចាប់យកចិត្តរបស់មនុស្សទៅហើយ។ តែតើការទាំងនោះសុទ្ធតែអាចឲ្យមនុស្សរីករាយទេ? តើយើងអាចមានចំណែកនោះបានដោយរបៀបណា?

គ្រីស្ទាន៖ ព្រះអម្ចាស់ ដែលជាអ្នកគ្រប់គ្រងលើប្រទេសបានកត់ត្រានៅក្នុងសៀវភៅនេះ។ ជាធាតុដែលយើងនឹងចង់មានចង់បាន ដែលទ្រង់នឹងផ្ដល់មកកាន់យើងដោយឥតបង់ថ្លៃ។

**“ហ៏ស អស់អ្នកដែលស្រេកអើយ ចូរមកឯទីទឹកចុះ ឯអ្នកដែលគ្មានប្រាក់អើយ ចូរមកទិញ ហើយបរិភោគទៅ អើ ចូរមកទិញស្រាទំពាំងបាយជូរ និងទឹកដោះគោឥតបង់លុយ ឥតថ្លៃទេ។ហេតុអ្វីបានជាចាយប្រាក់ឲ្យបានតែរបស់ដែលមិនមែនជាអាហារ ហើយបង់កម្លាំងឲ្យបានតែរបស់ដែលមិនស្កប់ចិត្តដូច្នេះ ចូរស្ដាប់តាមអញឲ្យអស់ពីចិត្តចុះ នោះឯងនឹងបានបរិភោគយ៉ាងឆ្ងាញ់ ដើម្បីឲ្យព្រលឹងឯងបានស្កប់ស្កល់ ដោយម្ហូបយ៉ាងថ្លៃវិសេស” អេសាយ 55:1-2**
**“អស់អ្នកណាដែលព្រះវរបិតាប្រទានមកខ្ញុំ នោះនឹងមកឯខ្ញុំ ហើយអ្នកណាដែលមកឯខ្ញុំ ខ្ញុំក៏មិនដែលចោលទៅក្រៅឡើយ។” យ៉ូហាន 6:37**

“ទ្រង់ក៏មានព្រះបន្ទូលមកខ្ញុំថា ស្រេចហើយ អញជាអាលផា និងអូមេកា គឺជាដើម ហើយជាចុង បើអ្នកណាស្រេក អញនឹងឲ្យអ្នកនោះផឹកពីរន្ធទឹកនៃជីវិតឥតយកថ្លៃ” **វិវរណៈ 21:6**

“ព្រះវិញ្ញាណ និងប្រពន្ធថ្មោងថ្មីពោលថា អញ្ជើញមក ហើយអ្នកណាដែលឮក៏ថា អញ្ជើញមកដែរ អ្នកណាដែលស្រេក នោះមានតែមក ហើយអ្នកណាដែលចង់បាន មានតែយកទឹកជីវិតនោះចុះ ឥតចេញថ្លៃទេ។” **វិវរណៈ 22:17**

លោកងាយអូសទាញ៖ ពិតជាល្អណាស់ សំលាញ់ល្អរបស់ខ្ញុំ ខ្ញុំរីករាយណាស់ដែលបានស្ដាប់ការទាំងអស់នេះ។ មកយើងប្រញាប់ដើរលឿនឡើង។

គ្រីស្ទាន៖ ខ្ញុំមិនអានទៅឆ្ងាយបានតាមដែលខ្ញុំចង់នោះទេ ដោយហេតុថាខ្ញុំមិនបន្ទុកនៅលើខ្នងរបស់ខ្ញុំ។

## លោកអ្នកប្រាជ្ញខាងលោកិយ

នៅពេលនេះ កាលដែលគ្រីស្ទានកំពុងតែដើរតែម្នាក់ឯង គាត់បានសម្លឹងឃើញមានម្នាក់កំពុងតែឆ្លងកាត់ផ្លូវវាលនោះមកជួបគាត់ ហើយពួកគេបានប្រទះឃើញគ្នានៅពេលដែលកំពុងឆ្លងកាត់ផ្លូវ។ ឈ្មោះរបស់សុភាពបុរសដែលបានជួបគាត់នោះគឺ អ្នកប្រាជ្ញខាងលោកិយ។ គាត់រស់នៅក្នុងទីក្រុងគោលការណ៍ខាងសាច់ឈាម ជាទីក្រុងមួយយ៉ាងធំអស្ចារ្យ ហើយវាក៏ពិបាកដែរនៅពេលដែលគ្រីស្ទានចេញមក។ បុរសម្នាក់នេះបានជួបជាមួយគ្រីស្ទាន ហើយមានការសង្ស័យទៅលើគាត់ ដោយសារគ្រីស្ទានបានចាកចេញពីទីក្រុងនៃសេចក្តីវិនាសអន្តរាយដែលបង្កឱ្យមានសម្លេងលេចឮទៅខាងក្រៅយ៉ាងខ្លាំង មិនមែនតែនៅក្នុងក្រុងដែលគាត់នៅប៉ុណ្ណោះ តែគេចាប់ផ្តើមនិយាយប្រាប់ទៅកាន់តំបន់ផ្សេងៗទៀត។ ហេតុនេះហើយបានជាលោកម្ចាស់អ្នកប្រាជ្ញនៃលោកិយបានប៉ាន់ស្មានពីគាត់ ដោយក្រលេកទៅមើលការខិតខំធ្វើដំណើររបស់គាត់ ដោយពិនិត្យមើលការដកដង្ហើមធំនិងការត្អូញត្អែររបស់គាត់ និងការស្រដៀងនោះ គាត់ក៏ចាប់ផ្តើមជជែកគ្នាជាមួយគ្រីស្ទាន។

អ្នកប្រាជ្ញនៃលោកិយ៖ យ៉ាងម៉េចហើយពេលនេះសំឡាញ់អើយ? ហេតុអ្វីបានជាទៅដោយមានបន្ទុកបែបនេះ?

គ្រីស្ទាន៖ គឺជាផ្លូវដែលមានបន្ទុកពិតមែន ដែលខ្ញុំតែងតែគិតថាគ្រប់ទាំងភាវៈទាំងអស់ត្រូវតែមាន។ ហើយហេតុអ្វីបានជាអ្នកសួរមកខ្ញុំបែបនៀក? ខ្ញុំប្រាប់អ្នកទៅចុះ ខ្ញុំកំពុងតែសំដៅទៅកាន់ឃ្លោងទ្វារទុច្ចរិតដែលនៅខាងមុខ

ខ្ញុំនោះ ដោយនៅទីនោះដូចដែលគេបានប្រាប់ខ្ញុំមក ថាខ្ញុំនឹងត្រូវទៅកាន់ផ្លូវមួយដែលនឹងដកបន្ទុកដ៏ធ្ងន់ចេញពីខ្នងរបស់ខ្ញុំបាន។

អ្នកប្រាជ្ញខាងលោកិយ៖ តើអ្នកមានប្រពន្ធកូនទេ?

គ្រីស្ទាន៖ បាទមាន។ តែដោយសារខ្ញុំមានបន្ទុកនេះ នោះខ្ញុំមិនអាចនឹងមានការអរសប្បាយដោយប្រពន្ធនិងកូនដូចពីមុនទៀតឡើយ។ ខ្ញុំគិតមកខ្លួនថាដូចជាខ្ញុំមិនមានប្រពន្ធកូនសោះ។

**"បងប្អូនអើយ ខ្ញុំប្រាប់សេចក្តីនេះថា ពេលវេលាចង្អៀតណាស់ហើយ ពីនេះទៅមុខ គួរតែឱ្យពួកអ្នកដែលមានប្រពន្ធ បាននៅដូចជាគ្មានវិញ។" កូរិនថូស ទី១ 7:29**

អ្នកប្រាជ្ញខាងលោកិយ៖ តើអ្នកនឹងស្តាប់តាមខ្ញុំទេ ប្រសិនបើខ្ញុំផ្តល់ការព្រឹក្សាដល់អ្នក?

គ្រីស្ទាន៖ បើវាល្អ នោះខ្ញុំនឹងស្តាប់ ដោយសារខ្ញុំត្រូវការយោបល់ល្អៗ។

អ្នកប្រាជ្ញខាងលោកិយ៖ អីចឹងខ្ញុំនឹងផ្តល់យោបល់ដល់អ្នក នោះអ្នកនឹងឆាប់បានយកបន្ទុករបស់អ្នកចេញ ដ្បិតអ្នកនឹងមិនបានសម្រាកនៅក្នុងគំនិតរបស់អ្នកទាល់តែអ្នកបានយកវាចេញ ហើយអ្នកក៏មិនអាចនឹងរីករាយនឹងផលប្រយោជន៍ចេញពីព្រះពរដែលព្រះបានប្រទានមកអ្នកទាល់តែអ្នកយកវាចេញផងដែរ។

គ្រីស្ទាន៖ នោះជាអ្វីដែលខ្ញុំស្វែងរក គឺដើម្បីយកបន្ទុកធ្ងន់នេះចេញពីខ្ញុំ តែខ្ញុំមិនអាចយកវាចេញដោយខ្លួនខ្ញុំឡើយ។ ហើយក៏មិនមានមនុស្សណាម្នាក់នៅក្នុងប្រទេសរបស់យើងអាចយកវាចេញពីស្មារបស់ខ្ញុំបានឡើយ។ ដូច្នេះខ្ញុំកំពុងទៅតាមផ្លូវនេះដូចដែលខ្ញុំបានប្រាប់ហើយ ថាខ្ញុំអាចនឹងយកបន្ទុករបស់ខ្ញុំចេញ។

អ្នកប្រាជ្ញខាងលោកិយ៖ តើអ្នកណាប្រាប់អ្នកឲ្យទៅផ្លូវនេះដើម្បីយកបន្ទុករបស់អ្នកចេញនោះ?

គ្រីស្ទាន៖ បុរសម្នាក់ដែលមកកាន់ខ្ញុំដែលមើលទៅហាក់បីដូចជាបុគ្គលម្នាក់ដែលអស្ចារ្យនិងមានកិត្តិយសណាស់ បើតាមដែលខ្ញុំចាំគាត់មានឈ្មោះថាអ្នកផ្សាយដំណឹងល្អ។

អ្នកប្រាជ្ញខាងលោកិយ៖ ចូរគេចចេញពីយោបល់របស់គាត់ទៅ! គ្មានផ្លូវណាដែលគ្រោះថ្នាក់និងពេញដោយបញ្ហានៅលើលោកនេះជាជាងផ្លូវដែលគាត់ណែនាំដល់អ្នកនោះទេ ប្រសិនបើអ្នកស្តាប់តាមយោបល់របស់គាត់ នោះអ្នកនឹងឃើញហើយ។ អ្នកបានជួយនឹងអ្វីមួយដូចដែលខ្ញុំបានដឹងរួចទៅហើយ ដោយសារខ្ញុំបានឃើញភក់ល្បាប់មកពីរណ្តៅនៃការធ្លាក់ចុះនៅលើខ្លួនរបស់អ្នកនោះ។ តែរណ្តៅនោះគ្រាន់តែជាការចាប់ផ្តើមនៃសេចក្តីទុក្ខលំបាក ដែលកើតមានដល់អស់អ្នកដែលដើរតាមផ្លូវនោះ។ ចូរស្តាប់ខ្ញុំវិញ ដោយសារខ្ញុំចាស់ជាងអ្នក។ អ្នកនឹងត្រូវជួបភាពនឿយណាយ ការឈឺចាប់ សេចក្តីស្រេកឃ្លាន គ្រោះថ្នាក់ សេចក្តីអាក្រាត ដាវ សត្វតោ សត្វនាគ សេចក្តីងងឹត ហើយនិយាយឱ្យខ្លីទៅ ជាសេចក្តីស្លាប់។ ការទាំងនេះសុទ្ធតែជាការពិត

ដោយសារត្រូវបានបញ្ជាក់អះអាងដោយទីបន្ទាល់ជាច្រើន។ ហេតុដូចម្ដេចបានជាគេត្រូវបោះបង់ខ្លួនរបស់គេទៅស្ដាប់មនុស្សចម្លែកបែបហ្នឹងនោះ?

គ្រីស្ទានៈ ឱលោក ហេតុអ្វីបានជាបន្ទុកនៅខ្នងរបស់ខ្ញុំវាពិបាកជាងការទាំងប៉ុន្មានដែលលោកបានរៀបរាប់នេះម្ល៉េះ? ខ្ញុំមិនខ្វល់ពីអ្វីដែលខ្ញុំនឹងជួបនៅតាមផ្លូវនោះទេ បើមានក៏មានចុះ នោះខ្ញុំនឹងបានជួបនឹងការរំដោះឱ្យរួចពីបន្ទុករបស់ខ្ញុំនេះ។

អ្នកប្រាជ្ញខាងលោកិយៈ អ្នកមកជាមួយបន្ទុកនេះទាំងពីដំបូងមកបានយ៉ាងដូចម្ដេច?

គ្រីស្ទានៈ ដោយបានអានសៀវភៅដែលនៅក្នុងដៃរបស់ខ្ញុំនេះ។

អ្នកប្រាជ្ញខាងលោកិយៈ ខ្ញុំក៏គិតអីចឹងដែរ។ វាបានកើតឡើងទៅកាន់អ្នកដូចដែលបានកើតឡើងទៅកាន់អ្នកខ្សោយៗផ្សេងទៀតផងដែរ សុទ្ធតែជាអ្នកដែលយករឿងដែលខ្ពស់ហួសកម្លាំងមកដាក់ខ្លួន ហើយពួកគេនឹងធ្លាក់ចូលសេចក្តីអន្តរាយមួយរំពេច ជាសេចក្តីរំខានដល់មនុស្ស (ដូចជារូបអ្នកដែលខ្ញុំបានដឹង) តែពួកគេបានធ្លាក់ចូលទៅក្នុងការបោកបញ្ឆោត ដើម្បីទទួលបានអ្វីដែលគេមិនដែលស្គាល់សោះ។

គ្រីស្ទានៈ ខ្ញុំស្គាល់ពីអ្វីដែលខ្ញុំនឹងទទួលបាន ហើយវាជួយសម្រាលដល់បន្ទុកដ៏ធ្ងន់របស់ខ្ញុំនេះ។

អ្នកប្រាជ្ញខាងលោកិយ៖ តែហេតុអ្វីបានជាអ្នកស្វែងរកដើម្បីសម្រាលដល់បន្ទុកតាមរបៀបនេះ ទាំងជួបជាមួយគ្រោះថ្នាក់ជាច្រើនដូចនេះ? ជាពិសេសពេលដែលអ្នកអត់ធ្មត់នឹងស្ដាប់មកខ្ញុំ ខ្ញុំអាចនាំអ្នកទៅកាន់អ្វីដែលអ្នកប្រាថ្នាចង់បាន ដោយមិនមានគ្រោះថ្នាក់ដូចដែលអ្នកនឹងជួបនៅតាមផ្លូវនេះនោះឡើយ។ ហើយវិធីសាស្ត្រនោះក៏នៅមិនឆ្ងាយ។ លើសពីនោះទៀត ខ្ញុំនឹងបន្ថែមទៀតថា ជំនួសឱ្យសេចក្ដីគ្រោះថ្នាក់ទាំងនោះ នោះអ្នកនឹងជួបនឹងសុវត្ថិភាព មិត្តភាព និងភាពស្កប់ស្កល់វិញ។

គ្រីស្ទាន៖ ឱលោក! សូមលោកបើកបង្ហាញការសំងាត់នេះដល់ខ្ញុំផង!

អ្នកប្រាជ្ញាខាងលោកិយ៖ ហេតុអ្វី នៅភូមិខាងមុខ (ភូមិដែលហៅថាសីលធម៌) មានបុរសម្នាក់រស់នៅទីនោះឈ្មោះលោក ស្របច្បាប់ ជាមនុស្សធ្វើដោយស្របច្បាប់ម្នាក់ ហើយជាមនុស្សដែលមានឈ្មោះល្អ ដែលមានជំនាញជួយដល់មនុស្សដែលមានបន្ទុកដូចដែលនៅលើស្មារបស់អ្នកនេះឯង។ ចំពោះខ្ញុំ គាត់បានធ្វើការល្អយ៉ាងខ្លាំង ក្រៅពីនោះគាត់មានជំនាញក្នុងការព្យាបាលអ្នកដែលឆ្កួតនៅក្នុងគំនិតរបស់គេដោយសារបន្ទុករបស់ពួកគេ។ សម្រាប់គាត់ដូចដែលខ្ញុំបាននិយាយហើយ អ្នកអាចទៅកាន់គាត់បានហើយទទួលជំនួយក្នុងពេលនេះ។ ផ្ទះរបស់គាត់នៅមិនដល់មួយយោជពីនេះផង។ ហើយប្រសិនបើគាត់ផ្ទាល់មិនបាននៅផ្ទះទេ នោះគាត់មានបុរសក្មេងម្នាក់ជាកូនរបស់គាត់ឈ្មោះថា ថ្លៃថ្នូរ ដែលគាត់ក៏អាចធ្វើបានដូចគ្នាទៅនឹងបុរសចាស់ផងដែរ។ នៅទីនោះដូចដែលខ្ញុំនិយាយហើយថា អ្នកនឹងបានសម្រាលពីបន្ទុករបស់អ្នក ហើយប្រសិនបើអ្នកមិនមានគំនិតនឹងត្រឡប់ទៅរកមុខរបស់ពីមុនរបស់អ្នកទេនោះ ហើយខ្ញុំក៏មិនប្រាថ្នាដូចនោះដែរ។ អ្នក

អាចផ្តាំប្រាប់ប្រពន្ធកូនរបស់អ្នកឲ្យមកកាន់អ្នកនៅភូមិនេះ ជាទីដែលមានផ្ទះដែលមិនទំនេរច្រើន ដែលអ្នកអាចនឹងមានផ្ទះមួយនៅក្នុងតម្លៃសមរម្យ ការផ្គត់ផ្គង់នៅទីនោះក៏ថោកហើយល្អដែរ ហើយវានឹងធ្វើឲ្យជីវិតអ្នកសប្បាយជាងមុនជាប្រាកដ ដោយសារអ្នកនឹងរស់នៅក្បែរអ្នកជិតខាងដែលស្មោះត្រង់ មានមុខមាត់ និងឥរិយាបថល្អ។

គ្រីស្ទាន៖ ឱលោក! តើផ្លូវមួយណាដែលទៅកាន់ផ្ទះរបស់មនុស្សស្មោះត្រង់នោះ?

អ្នកប្រាជ្ញខាងលោកិយ៖ តើអ្នកឃើញភ្នំដែលនៅពីចម្ងាយនោះទេ? (ភ្នំស៊ីយ៉ូន)

គ្រីស្ទាន៖ បាទ មើលឃើញច្បាស់ណាស់។

អ្នកប្រាជ្ញាខាងលោកិយ៖ អ្នកត្រូវតែទៅក្បែរភ្នំនោះ ហើយផ្ទះទីមួយដែលអ្នកទៅដល់នោះជាផ្ទះរបស់គាត់ហើយ។

ដូច្នេះគ្រីស្ទានបានបែរចេញពីផ្លូវរបស់គាត់ដើរទៅកាន់ផ្ទះរបស់លោកស្របច្បាប់ដើម្បីសុំជំនួយ។ តែមើល នៅពេលដែលគាត់មានការលំបាក់នៅក្បែរភ្នំនោះ ដោយវាហាក់បីដូចជាខ្ពស់ខ្លាំង ហើយចំហៀងរបស់វាដែលនៅក្បែរផ្លូវនោះឡើងទៅកាន់តែខ្ពស់ វាបានធ្វើឲ្យគ្រីស្ទានភិតភ័យនៅក្នុងការបន្តដំណើរទៅមុខ មិនដូច្នោះកំពូលភ្នំអាចនឹងធ្លាក់កិនក្បាលរបស់គាត់។ ដូច្នេះគាត់បានឈរស្ងៀមនៅទីនោះ ហើយមិនដឹងថាត្រូវធ្វើយ៉ាងណាទេ។ ពេលនេះបន្ទុករបស់គាត់ក៏ដូចជាកាន់តែធ្ងន់ឡើងសម្រាប់គាត់ ជាជាងកាលដែល

គាត់ដើរតាមផ្លូវរបស់គាត់ទៅទៀត។ នៅទីនោះក៏មានភ្លើងចាំងចេញពីកំពូលភ្នំមកដែលធ្វើឱ្យគ្រីស្ទានខ្លាចថានឹងដុតបញ្ឆេះគាត់ទៅ។

**"លុះដល់ព្រឹកឡើងថ្ងៃទីបី នោះក៏មានឮសូរផ្គរមានផ្លេកបន្ទោរ និងពពកយ៉ាងក្រាស់នៅលើភ្នំ ព្រមទាំងឮសូរផ្លុំស្នែងយ៉ាងខ្លាំងក្រៃលែង រួចបណ្ដាជនទាំងឡាយដែលនៅក្នុងទីដំឡើងត្រសាល ក៏ញ័ររន្ធត់ទាំងអស់គ្នា។ នោះម៉ូសេលោកនាំគេចេញពីទីតំឡើងត្រសាលទៅជួបនឹងព្រះ គេឈរតំរៀបគ្នានៅទីជើងភ្នំ។ ឯភ្នំស៊ីណាយក៏ហុយផ្សែងឡើងពេញទាំងអស់ ដ្បិតព្រះយេហូវ៉ាទ្រង់យាងចុះមកពីលើភ្នំគង់ក្នុងភ្លើង ផ្សែងនោះហុយឡើងដូចជាផ្សែងនៃគុកភ្លើង តួភ្នំទាំងមូលក៏កក្រើករំពើកយ៉ាងខ្លាំង។" និក្ខមនំ 19:16-18**

ម្ល៉ោះហើយនៅទីនេះគាត់បានបែកញើសហើយញ័យដោយភិតភ័យ

**"ហើយការដែលគេឃើញនោះ ក៏គួរស្ញែងខ្លាចណាស់ ដល់ម្ល៉េះបានជាម៉ូសេលោកមានប្រសាសន៍ថា ខ្ញុំភ័យញ័រជាខ្លាំង។" ហេព្រើរ 12:21**

ឥលូវនេះគាត់ចាប់ផ្ដើមស្ដាយក្រោយដែលគាត់បានស្ដាប់តាមការព្រឹក្សារបស់អ្នកប្រាជ្ញខាងលោកិយ។ នោះគាត់ក៏ឃើញអ្នកផ្សាយដំណឹងល្អដើរមកជួបគាត់ ដោយឃើញដូចនោះគាត់ក៏ឡើងទឹកមុខក្រហមដោយអាម៉ាស។ ដូច្នេះអ្នកផ្សាយដំណឹងល្អបានចូកកាន់តែជិត ហើយមកកាន់កាត់ ទាំងមើលមកគាត់ដោយទឹកមុខស្មើហើយគួរឱ្យខ្លាច ហើយគាត់បានចាប់ផ្ដើមនិយាយហេតុផលជាមួយគ្រីស្ទាន។

## ផ្លូវតែមួយ

អ្នកផ្សាយដំណឹងល្អ៖ គាត់បាននិយាយថា "តើអ្នកធ្វើអ្វីនៅទីនេះ គ្រីស្ទាន? ហើយគ្រីស្ទានមិនមានពាក្យអ្វីនឹងតបនោះទេ ដូច្នេះក៏ឈរស្ងៀមនៅមុខគាត់ទៅ។ បន្ទាប់មកអ្នកផ្សាយដំណឹងល្អនិយាយថែមទៀតថា "តើអ្នកមិនមែនជាបុរសម្នាក់ដែលខ្ញុំបានឃើញយំនៅក្រៅជញ្ជាំងនៃទីក្រុងដែលត្រូវវិនាសទេឬអី?"

គ្រីស្ទាន៖ បាទ មែនហើយលោក! ខ្ញុំជាបុរសម្នាក់នោះ។

អ្នកផ្សាយដំណឹងល្អ៖ តើខ្ញុំមិនបានប្រាប់អ្នកឱ្យទៅកាន់ឃ្លោងទ្វារទុច្ចរិតតូចនោះទេឬអី? ដោយសារពេលនេះអ្នកកំពុងចេញខុសពីផ្លូវហើយ។

គ្រីស្ទាន៖ ខ្ញុំបានជួបជាមួយនឹងសុភាពបុរសម្នាក់នៅរំពេចដែលខ្ញុំបានចេញរួចពីរណ្ដៅនៃការធ្លាក់ចុះនោះ គាត់បានញុះញង់ខ្ញុំ ឱ្យទៅរកបុរសម្នាក់ដែលនៅភូមិខាងមុខខ្ញុំ ដើម្បីនឹងដកបន្ទុករបស់ខ្ញុំចេញ។

អ្នកផ្សាយដំណឹងល្អ៖ តើគាត់ជាអ្វីដែរ?

គ្រីស្ទាន៖ គាត់មើលទៅដូចជាសុភាពបុរសម្នាក់ ហើយគាត់និយាយជាច្រើនមកកាន់ខ្ញុំ ហើយចុងក្រោយខ្ញុំក៏ធ្វើតាម។ ដូច្នេះខ្ញុំក៏បានមកទីនេះ តែនៅពេលដែលខ្ញុំមើលទៅកាន់ភ្នំនេះ ហើយកាលដែលវានៅព្យួរលើផ្លូវដើរ ភ្លាមនោះខ្ញុំក៏ឈរស្ងៀម ពុំនោះវានឹងធ្លាក់សង្កត់ក្បាលខ្ញុំ។

អ្នកផ្សាយដំណឹងល្អ៖ តើសុភាពបុរសនោះនិយាយអ្វីមកអ្នក?

គ្រីស្ទាន៖ គាត់បានសួរខ្ញុំថាទៅណា ហើយខ្ញុំក៏បានប្រាប់គាត់។

អ្នកផ្សាយដំណឹងល្អ៖ ហើយបន្ទាប់មកគាត់និយាយយ៉ាងម៉េចដែរ?

គ្រីស្ទាន៖ គាត់បានសួរថាខ្ញុំមានគ្រួសារដែរទេ ហើយខ្ញុំបានប្រាប់គាត់ទៅ។ តែខ្ញុំនិយាយថាខ្ញុំមិនបន្ទុកដែលនៅលើខ្នងរបស់ខ្ញុំយ៉ាងខ្លាំង ដែលខ្ញុំមិនអាចនឹងសប្បាយនឹងការពីមុនទៀតនោះទេ។

អ្នកផ្សាយដំណឹងល្អ៖ ហើយបន្ទាប់មកតើគាត់និយាយអ្វី?

គ្រីស្ទាន៖ គាត់បានបង្ខំខ្ញុំឱ្យដើរលឿនដើម្បីនឹងដល់បន្ទុករបស់ខ្ញុំចេញ ហើយខ្ញុំបានប្រាប់គាត់ថាស្រួលហើយដែលខ្ញុំរកវាឃើញនោះ។ ខ្ញុំនិយាយថា ដូច្នេះខ្ញុំនឹងទៅកានឃ្លោងទ្វារខាងមុខដើម្បីទទួលបានការណែនាំបន្ថែមទៀតដើម្បីរកវិធីឱ្យបានទៅដល់កន្លែងដែលដោះឱ្យរួច។ ដូច្នេះគាត់បាននិយាយថា គាត់នឹងបង្ហាញផ្លូវដែលប្រសើរជាង និងខ្លីជាងដល់ខ្ញុំ ហើយជាផ្លូវដែលមិនសូវមានការលំបាកដូចដែលផ្លូវដែលលោកប្រាប់ឱ្យខ្ញុំដើរនោះទេ។ គាត់និយាយថាផ្លូវខ្លីនេះនឹងនាំខ្ញុំទៅកាន់ផ្ទះរបស់សុភាពបុរសម្នាក់ ដែលគាត់មានជំនាញក្នុងការដកយកបន្ទុកចេញ។ ខ្ញុំក៏បានជឿតាមគាត់ ហើយបានងាយចេញពីផ្លូវមកកាន់ទីនេះ ដោយគិតថាខ្ញុំអាចនឹងសម្រាលបន្ទុករបស់ខ្ញុំបានរហ័ស។ ប៉ុន្តែនៅពេលដែលខ្ញុំមកទីកន្លែងនេះ ហើយមើលឃើញសភាពជាក់ស្តែង ខ្ញុំបានឈប់នឹងថ្កល់ដោយផិតភ័យនូវគ្រោះថ្នាក់ដូចដែលខ្ញុំបាននិយាយនោះ តែពេលនេះខ្ញុំមិនដឹងថាត្រូវធ្វើអ្វីទេ។

អ្នកផ្សាយដំណឹងល្អ៖ បន្ទាប់មកអ្នកផ្សាយដំណឹងល្អបាននិយាយថា "សូមឈរនៅស្ងៀមមួយភ្លែត នោះខ្ញុំនឹងបង្ហាញព្រះបន្ទូលរបស់ព្រះ។" ដូច្នេះគាត់បានឈរដោយញាប់ញ័រ។ បន្ទាប់មកអ្នកផ្សាយដំណឹងល្អនិយាយថា "មើលទៅ ថាអ្នកនឹងមិនបដិសេធម្នាក់ដែលនិយាយនេះ។ ដ្បិតប្រសិនបើពួកគេមិនអាចគេចរួចបាន គឺអ្នកដែលបដិសេធម្នាក់ដែលនិយាយនៅលើផែនដីនោះគេកាន់តែមិនអាចគេចរួចបានឡើយ ប្រសិនបើយើងបែរចេញពីម្នាក់ដែលមានបន្ទូលមកពីស្ថានសួរ។"

**"ចូរប្រយ័ត្ន កុំឱ្យប្រកែកមិនព្រមស្តាប់តាមព្រះអង្គ ដែលទ្រង់មានបន្ទូលឡើយ ដ្បិតបើសិនជាអ្នកទាំងនោះ ដែលមិនព្រមស្តាប់តាមលោកម៉ូសេ ក្នុងកាលដែលលោកសម្តែងព្រះបន្ទូល ឱ្យស្តាប់នៅលើផែនដី គេមិនបានរួចទោសទៅហើយ នោះចំណង់បើយើងរាល់គ្នាដែលងាកបែរចេញពីព្រះ ដែលមានបន្ទូលពីស្ថានសួគ៌មក តើតឹងជាងយ៉ាងណាទៅ?" ហេព្រើរ 12:25**

គាត់បាននិយាយទៀតថា "ឥលូវនេះអ្នកសុចរិតនឹងរស់នៅដោយសេចក្តីជំនឿ ប៉ុន្តែបើអ្នកណាដែលថយក្រោយវិញ នោះព្រលឹងរបស់ខ្ញុំនឹងមិនអរសប្បាយឡើយ។"

**"តែពួកមនុស្សសុចរិតនឹងរស់នៅ ដោយអាងសេចក្តីជំនឿ បើអ្នកណាថយទៅវិញ នោះចិត្តអញគ្មានសេចក្តីអំណរចំពោះអ្នកនោះទេ។" ហេព្រើរ 10:38**

គាត់ក៏យកពាក្យទាំងនោះមកប្រើ "អ្នកជាមនុស្សដែលកំពុងរត់ទៅក្នុងសេច

ក្ដីអាក្រក់នេះ។ អ្នកចាប់ផ្ដើមបដិសេធក្រឹត្យវិន័យរបស់ព្រះដ៏ខ្ពស់បំផុត ហើយបានដកជើងរបស់អ្នកចេញពីផ្លូវនៃសេចក្ដីសុខសាន្ត ហើយស្ទើរតែប្រថុយនឹងស្ថាននរកផង។"

បន្ទាប់មកគ្រីស្ទានបានដួលចុះនៅបាតជើងរបស់គាត់ដូចស្លាប់ហើយយំស្រែកថា "ខ្ញុំត្រូវបណ្ដាសាហើយដ្បិតខ្ញុំមិនទាន់ធ្វើសម្រេចនូវឡើយ!" ដោយឃើញដូច្នោះអ្នកផ្សាយដំណឹងល្អបានចាប់ដៃស្ដាំរបស់គាត់ហើយនិយាយថា "គ្រប់ទាំងអំពើបាបនិងការប្រមាថ ត្រូវបានអត់ទោសឱ្យដល់មនុស្ស សូមកុំអត់សេចក្ដីជំនឿ តែចូរជឿវិញ។"

**"ហេតុនេះបានជាខ្ញុំប្រាប់អ្នករាល់គ្នាថា អស់ទាំងបាប ហើយពាក្យប្រមាថ និងអត់ទោសឱ្យមនុស្សលោកបាន តែពាក្យប្រមាថដល់ព្រះវិញ្ញាណវិញ នោះមិនដែលបានអត់ទោសដល់មនុស្សឡើយ។" ម៉ាថាយ 12:31**

**"រួចទ្រង់មានបន្ទូលទៅថូម៉ាស់ថា ចូរលូកម្រាមដៃអ្នកមក ស្ទាបមើលដៃខ្ញុំងណេះ ហើយលូកដៃមកចំហៀងខ្ញុំផង កុំឱ្យមានចិត្តមិនជឿឡើយ ត្រូវឱ្យជឿចុះ។" យ៉ូហាន 20:27**

បន្ទាប់មកគ្រីស្ទានក៏បានធូរស្បើយឡើង ហើយបានក្រោកឈរដោយញាប់ញ័រនៅចំពោះអ្នកផ្សាយដំណឹងល្អ។

បន្ទាប់មកអ្នកផ្សាយដំណឹងល្អបន្តនិយាយទៀត "សូមផ្ទៀងស្ដាប់ដោយយកចិត្តទុកដាក់ថែមទៀតទៅលើការដែលខ្ញុំនឹងប្រាប់ដល់អ្នក។ ពេលនេះខ្ញុំនឹងប្រាប់ដល់អ្នកថាអ្នកណាដែលបានបោកបញ្ឆោតអ្នក ហើយតើអ្នកណាជា

ម្នាក់ដែលគាត់បានបញ្ជូនអ្នកឱ្យទៅជួប។ អ្នកដែលបានជួបអ្នកនោះឈ្មោះ ថា អ្នកប្រាជ្ញខាងលោកិយ ហើយឈ្មោះនោះត្រូវនឹងគាត់ហើយ ដោយសារគាត់តែងតែផ្សំគ្រឿងពីគោលការណ៍ខាងលោកិយតែមួយប៉ុណ្ណោះ។"

**"ពួកនោះមកពីលោកិយទេ ដោយហេតុនោះបានគេនិយាយតាមភាពលោកិយ ហើយលោកិយក៏ស្តាប់គេដែរ។" យ៉ូហាន ទី១ 4:5**

(ដូច្នេះគាត់តែងតែទៅទីក្រុងសីលធម៌ទៅកាន់ក្រុមជំនុំ) ហើយដោយផ្នែកគាត់ស្រឡាញ់គោលលិទ្ធិនោះណាស់ ដោយសារវាបានជួយគាត់ឱ្យរួចចេញពីឈើឆ្កាង។

**"អស់អ្នកណាដែលចង់បានឫកពាល្អខាងសាច់ឈាម នោះគេបង្ខំឱ្យអ្នករាល់គ្នាទទួលការកាត់ស្បែក ដើម្បីឱ្យតែខ្លួនគេបានរួចពីសេចក្តីបៀតបៀនដោយព្រោះឈើឆ្កាងនៃព្រះគ្រីស្ទ។" កាឡាទី 6:12**

ហើយដោយសារតែកាត់មានចិត្តកំហឹងខាងសាច់ឈាមដូច្នេះ គាត់ក៏ស្វែងរកនឹងបង្វែរផ្លូវរបស់ខ្ញុំបើទោះជាវាត្រូវក៏ដោយ។ ពេលនេះមានការបីយ៉ាងនៅក្នុងក្រឹត្យវិន័យរបស់បុរសម្នាក់នេះ ដែលអ្នកត្រូវស្អប់ជាទីបំផុត៖

"1. គាត់បែរអ្នកឱ្យចេញពីផ្លូវ

"2. គាត់ខិតខំប្តូរឈើឆ្កាងឱ្យទៅជាគួរឱ្យស្អប់ដល់អ្នក

‶3. ហើយគាត់រៀបចំជើងរបស់អ្នកទៅកាន់ផ្លូវដែលដឹកនាំទៅកាន់ទិសដៅនៃសេចក្តីស្លាប់។

‶ដំបូងអ្នកគួរតែស្អប់ការដែលបែរអ្នកចេញពីផ្លូវ ពិតណាស់ចេញពីការយល់ស្របរបស់អ្នក ដោយសារវាជាការបដិសេធគំនិតដែលមកពីព្រះហើយរើសយកយោបល់របស់អ្នកប្រាជ្ញខាងលោកិយ។ ព្រះអម្ចាស់មានបន្ទូលថា ត្រូវខំចូលទៅតាមឃ្លោងទ្វារដែលនៅត្រង់។″

**‶ចូរខំប្រឹងយ៉ាងអស់ពីចិត្ត ឱ្យបានចូលទៅតាមទ្វារចង្អៀត ដ្បិតខ្ញុំប្រាប់អ្នករាល់គ្នាថា នឹងមានមនុស្សជាច្រើនខំប្រឹងរកចូលដែរ តែចូលមិនបានទេ។″ លូកា 13:24**

ឃ្លោងទ្វារដែលខ្ញុំប្រាប់អ្នកឱ្យទៅ ដោយសារផ្លូវដែលតូចហើយចង្អៀតនោះនាំទៅកាន់ជីវិត ហើយមានមនុស្សតិចទេដែលរកឃើញវា។

**‶ចូរឱ្យចូលតាមទ្វារចង្អៀត ដ្បិតទ្វារដែលនាំទៅឯសេចក្តីហិនវិនាស នោះធំហើយទូលាយផង ក៏មានមនុស្សជាច្រើនដែលចូលតាមទ្វារនោះ។ តែឯទ្វារដែលនាំទៅឯជីវិត នោះតូច ហើយចង្អៀតវិញ ក៏មានមនុស្សតិចណាស់ដែលរកផ្លូវនោះឃើញ។″ ម៉ាថាយ 7:13-14**

ចាប់ពីឃ្លោងទ្វារទុច្ចរិតតូចមួយនេះ ហើយពីផ្លូវនោះ មានមនុស្សទុច្ចរិតម្នាក់ដែលអ្នកបានបែរទៅរក ដែលស្ទើរតែទាញអ្នកទៅក្នុងសេចក្តីវិនាសអន្តរាយ។ ដូច្នេះចូរស្អប់ការដែលគាត់បង្វែអ្នកចេញពីផ្លូវ ហើយខ្ពើមខ្លួនអ្នកដែលស្តាប់ទៅកាន់គាត់។

“អ្នកត្រូវស្អប់ការខិតខំរបស់គេដែលធ្វើឱ្យឈើឆ្កាងបែរជាគួរឱ្យស្អប់ដល់អ្នក ដោយអ្នកប្រាថ្នាចង់បានសម្បត្តិនៅអេស៊ីបទៅវិញ។”

**“ដោយបានរាប់សេចក្ដីដំនៀល ដែលគេតិះដៀលដល់ព្រះគ្រីស្ទ ទុកជាទ្រព្យសម្បត្តិប្រសើរជាងអស់ទាំងថ្លៃវិសេសនៅស្រុកអេស៊ីព្ទ ដ្បិតលោកសម្លឹងចំទៅឯរង្វាន់វិញ។” ហេព្រើរ 11:26**

ក្រៅពីនោះ ស្ដេចនៃសិរីល្អបានប្រាប់អ្នកថា អ្នកដែលនឹងសង្គ្រោះជីវិតរបស់ខ្លួននឹងត្រូវបាត់បង់វាទៅ ហើយអ្នកដែលមកតាមទ្រង់ ហើយមិនស្អប់ឪពុកម្ដាយ កូន បងប្អូនប្រុសស្រីខ្លួន និងជីវិតរបស់ខ្លួនទេនោះ នោះគេមិនអាចក្លាយជាសិស្សរបស់ទ្រង់បានឡើយ។

**“អ្នកណាដែលរកបានជីវិតខ្លួន នោះនឹងត្រូវបាត់ជីវិតទៅ តែអ្នកណាដែលបាត់ជីវិតដោយយល់ដល់ខ្ញុំ អ្នកនោះនឹងបានជីវិតវិញ។” ម៉ាថាយ 10:39**

**“ដ្បិតអ្នកណាដែលចង់ឱ្យរួចជីវិត នោះនឹងបាត់ជីវិតទៅ តែអ្នកណាដែលបាត់ជីវិត ដោយព្រោះយល់ដល់ខ្ញុំ ហើយនិងដំណឹងល្អ នោះនឹងបានជីវិតវិញ។” ម៉ាកុស 8:35**

**“បើអ្នកណាមកឯខ្ញុំ ដោយមិនបានលះអាល័យពីឪពុកម្ដាយ ប្រពន្ធកូន បងប្អូនប្រុសស្រី និងជីវិតខ្លួនឯងផង អ្នកនោះនឹងធ្វើជាសិស្សខ្ញុំមិនបានទេ។” លូកា 14:26**

**"អ្នកណាដែលស្រឡាញ់ជីវិតខ្លួន នោះនឹងបាត់ជីវិតទៅ តែអ្នកណាដែលស្អប់ជីវិតខ្លួន នៅលោកិយនេះវិញ នោះនឹងរក្សាជីវិតទុកដរាបដល់អស់កល្បរៀងទៅ។" លូកា 12:25**

ដូច្នេះខ្ញុំនិយាយថា សម្រាប់មនុស្សដែលខំញុះញង់អ្នកថានឹងជាសេចក្ដីស្លាប់របស់អ្នក ដែលសេចក្ដីពិតមិនបាននិយាយ នោះអ្នកមិនអាចមានជីវិតអស់កល្បជានិច្ចបានឡើយ ការបង្រៀនបែបនេះអ្នកត្រូវតែស្អប់។

ទីបី អ្នកត្រូវស្អប់កាលដែលគាត់តម្រូវឱ្យជើងរបស់អ្នកនៅក្នុងផ្លូវដែលនាំទៅកាន់សេចក្ដីវិនាសអន្តរាយ។ ដោយបែបនេះអ្នកត្រូវតែពិចារណាពីម្នាក់ដែលគាត់បានបញ្ជូនអ្នកទៅជួប ហើយថាបុរសម្នាក់នោះមិនមានសម្មត្ថភាពនឹងដោះអ្នកឱ្យរួចពីបន្ទុករបស់អ្នកបានទាល់តែសោះ។

"បុគ្គលដែលអ្នកត្រូវបានបញ្ជូនទៅជួបដើម្បីសម្រាលបន្ទុកនោះ មានឈ្មោះថា លោកស្របច្បាប់ ដែលជាកូនរបស់ស្ត្រីម្នាក់ដែលជាប់ចំណង ដែលពេលនេះនាងកំពុងនៅជាប់ចំណងជាមួយនឹងកូនៗរបស់នាង។"

**"ដ្បិតមានសេចក្ដីចែងទុកមកថា លោកអ័ប្រាហាំមានកូន២ មួយកើតពីបាវស្រី ហើយមួយពីស្រីអ្នកជា។ តែកូនដែលកើតពីបាវស្រី នោះបានកើតតាមសាច់ឈាម ហើយមួយដែលកើតពីអ្នកជា បានកើតតាមសេចក្ដីសន្យាវិញ។ នោះជាសេចក្ដីប្រៀបធៀបគឺស្ត្រីទាំងពីរនេះជាគំរូ ពីសេចក្ដីសញ្ញាពីរច្បាប់ មួយមកពីភ្នំស៊ីណាយ ក៏បង្កើតភាពជាបាវបម្រើ នោះគឺជានាងហាការ។ ដ្បិតនាងហាការទុកដូចជាភ្នំ ស៊ីណាយនៅស្រុកអារ៉ាប់ ហើយក៏ត្រូវនឹងក្រុងយេរូសាឡិម**

**សព្វថ្ងៃនេះ ជាក្រុងដែលជាប់បម្រើជាមួយនឹងកូនចៅផង។ តែក្រុងយេរូសាឡិមដែលនៅស្ថានលើ នោះជាស្រីអ្នកជាវិញ ដែលជាម្ដាយយើងទាំងអស់គ្នា ។ ដ្បិតមានសេចក្តីចែងមកថា ឱនាងហាការអើយ យើងរាល់គ្នាជាកូនតាមសេចក្តីសន្យា ដូចជាលោកអ៊ីសាក់ដែរ។" ហេព្រើរ 4:22-27**

ហើយភ្នំស៊ីណាយដែលអ្នកភ័យខ្លាចនេះនឹងធ្លាក់មកកិនក្បាលរបស់អ្នក។ ឥលូវនេះ ប្រសិនបើនាងហើយនិងកូនរបស់នាងនៅក្នុងភាពជាអ្នកបម្រើ តើអ្នកអាចសង្ឃឹមថាពួកគេអាចធ្វើឱ្យមានសេរីភាពបានយ៉ាងដូចម្ដេច? ដូច្នេះលោកស្របច្បាប់ម្នាក់នេះមិនអាចដោះអ្នកឱ្យមានសេរីភាពចេញពីបន្ទុករបស់អ្នកបានឡើយ។ គាត់មិនដែលដោះមនុស្សណាម្នាក់ឱ្យរួចពីបន្ទុករបស់គេបានឡើយ។ វាមិនដែលមាន ហើយក៏មិនអាចកើតមានបានដែរ។ អ្នកមិនបានទៅជាសុចរិតដោយខំធ្វើតាមក្រិត្យវិន័យនោះឡើយ ព្រោះដោយកិច្ចការខាងក្រិត្យវិន័យ គ្មានមនុស្សរស់ណាដែលអាចដល់បន្ទុករបស់ខ្លួនចេញរួចនោះឡើយ។ ដូច្នេះអ្នកប្រាជ្ញខាងលោកិយជាមនុស្សចម្លែក ហើយលោកស្របច្បាប់ជាមនុស្សបោក ហើយសម្រាប់កូនរបស់គាត់លោកថ្លៃថ្នូវិញ បើទោះជាគាត់មានមុខស្រស់ប្រិមប្រិយក៏ដោយ តែគាត់មនុស្សកំពុត ហើយមិនអាចជួយអ្នកបានឡើយ។ ចូរជឿខ្ញុំចុះថាសម្លេងដែលអ្នកបានឮពីបុរសដែលមានសម្លេងខ្សឹបខ្សៀវនេះគឺគ្មានអ្វីទាំងអស់ ប៉ុន្តែធ្វើឡើងដើម្បីនឹងល្បួងអ្នកចេញពីសេចក្តីសង្គ្រោះរបស់អ្នក ដោយបង្វែអ្នកចេញពីផ្លូវដែលខ្ញុំបានប្រាប់ឱ្យអ្នកទៅ។ បន្ទាប់ពីនេះមកអ្នកផ្សាយដំណឹងល្អបានស្រែកយំទៅកាន់ស្ថានសួគ៌ដើម្បីនឹងបញ្ជាក់អះអាងនូវអ្វីដែលគាត់បាននិយាយ នោះក៏មានព្រះបន្ទូលនិងភ្លើងចេញពីភ្នំពីខាងក្រោមកន្លែងដែលគ្រីស្ទានបានឈរ

ហើយវាបានធ្វើឱ្យភ័យបាស់រោម។ ព្រះបន្ទូលនោះត្រូវបានប្រកាសថា "មនុស្សជាច្រើនដែលនៅក្រោមកិច្ចការខាងក្រិត្យវិន័យ ក៏នៅក្រោមបណ្តាសាដែរ ដ្បិតមានចែងថា ត្រូវបណ្តាសាហើយដល់អស់អ្នកណាដែលបន្តធ្វើគ្រប់ការទាំងប៉ុន្មានដែលមានសរសេរនៅក្នុងក្រិត្យវិន័យ និងធ្វើតាមវាផង។"

**"តែអស់អ្នកដែលអាងដល់ការប្រព្រឹត្តតាមក្រឹត្យវិន័យ នោះត្រូវបណ្តាសាវិញ ដ្បិតមានសេចក្តីចែងទុកមកថា ត្រូវបណ្តាសាហើយ អស់អ្នកណាដែលមិនកាន់ខ្ជាប់តាមគ្រប់ទាំងសេចក្តី ដែលកត់ទុកក្នុងគម្ពីរក្រិត្យវិន័យ ដើម្បីនឹងប្រព្រឹត្តតាម។" កាឡាទី 3:10**

ពេលនេះគ្រីស្ទានមិនបានស្វែងរកអ្វីក្រៅពីសេចក្តីស្លាប់នោះឡើយ ហើយក៏ចាប់ផ្តើមយំទួញសោកយ៉ាងខ្លាំង ទាំងដាក់បណ្តាសាថ្ងៃដែលគាត់បានជួយជាមួយនឹងលោកប្រាជ្ញខាងលោកិយ នៅតែខ្លួនឯងថាមនុស្សល្ងង់មួយពាន់ដែលដែលស្តាប់តាមយោបល់របស់វា។ គាតមានសេចក្តីអាម៉ាស់យ៉ាងខ្លាំងនៅពេលដែលគិតពីការវែកញែករបស់សុភាពបុរសនេះ ដែលវាហូរចេញមកតែពីខាងសាច់ឈាម ហើយបានយកឈ្នះលើគាត់ ឱ្យគាត់បដិសេធផ្លូវត្រឹមត្រូវ។ បន្ទាប់មក គាត់បានដាក់ខ្លួនដើម្បីនឹងស្តាប់ ព្រមទាំងដើរតាមអ្នកផ្សាយដំណឹងល្អដូចខាងក្រោមនេះ៖

គ្រីស្ទាន៖ ឱលោកអើយ តើលោកគិតអ្វី? តើមានសង្ឃឹមអ្វីសេសសល់ដែរទេ? តើពេលនេះខ្ញុំអាចត្រលប់ទៅវិញ ហើយធ្វើដំណើរទៅកាន់ឃ្លោងទ្វារទុច្ចរិតបានដែរទេ? តើខ្ញុំមិនត្រូវបានបំបរបង់ចោល ហើយត្រូវបញ្ជូនទៅវិញ

ដោយអាម៉ាស់ដោយសារការនេះទេឬអ្វី? ខ្ញុំសោកស្តាយដែលបានស្តាប់តាមយោបល់របស់មនុស្សនេះ តែបាបរបស់ខ្ញុំអាចអត់ទោសឱ្យបានទេ?

អ្នកផ្សាយដំណឹងល្អ៖ បន្ទាប់មកអ្នកផ្សាយដំណឹងល្អបាននិយាយទៅគាត់ថា "អំពើបាបរបស់អ្នកធ្ងន់ណាស់ ដោយសារអ្នកបានប្រព្រឹត្តអំពើបាបពីរ គឺបានបដិសេធផ្លូវដែលល្អ ហើយដើរតាមផ្លូវដែលហាមឃាត់។ តែបុរសដែលនៅឃ្លោងទ្វារនឹងទទួលអ្នក ដោយសារគាត់មានតែបំណងល្អសម្រាប់មនុស្ស" គាត់និយាយថា "ចូរស្តាប់ចុះ ហើយកុំឱ្យអ្នកត្រូវបែរចេញម្តងទៀត មិនពុំនោះអ្នកនឹងវិនាសចេញពីផ្លូវនៅពេលដែលសេចក្តីក្រោធរបស់ទ្រង់ឆេះ។"

**"បានជា ឱពួកស្ងួនភ្ងាអើយ ចូរបង្ហើយសេចក្ដីសង្គ្រោះរបស់អ្នករាល់គ្នា ដោយកោតខ្លាច ហើយញាប់ញ័រចុះ ដូចជាបានស្តាប់បង្គាប់ជាដរាបរៀងមកដែរ មិនមែនតែកាលខ្ញុំនៅជាមួយប៉ុណ្ណោះទេ សូម្បីឥឡូវនេះដែលខ្ញុំមិននៅជាមួយនោះក៏ចូរខំប្រឹងឱ្យលើសទៅទៀតផង។" ភីលីព 2:12**

បន្ទាប់មកគ្រីស្ទានបានត្រឡប់ទៅវិញ ហើយអ្នកផ្សាយដំណឹងល្អក៏បានថើបគាត់ ញញឹមដាក់គាត់ ប្រាប់គាត់ឱ្យទៅរកព្រះ។

## បំណងល្អ៖ អ្នកយាមឃ្លោងទ្វារទុច្ចរិត

ដូច្នេះគាត់បានបន្តដំណើរដៅដោយប្រញាប់ មិននិយាយជាមួយនរណាសោះនៅតាមផ្លូវ ហើយគាត់ក៏មិនបានឆ្លើយទៅកាន់អ្នកដែលសួរផង។ គាត់ដើរទៅដូចជាម្នាក់ដែលដើរនៅលើដីដែលគេហាមឃាត់ ហើយមិនអាចគិតថាគាត់នឹងមានសុវត្ថិភាពនោះឡើយ រហូតទាល់តែគាត់បានទៅដល់ផ្លូវដែលគាត់បានបែរចេញដើម្បីដើរតាមការព្រឹក្សារបស់អ្នកប្រាជ្ញខាងលោកិយ។ ដូច្នេះ មួយរយៈក្រោយមកគ្រីស្ទានបានទៅដល់ឃ្លោងទ្វារ។ ពេលនេះនៅលើឃ្លោងទ្វារសរសេរថា "ចូរគោះ នោះនឹងបានបើកដល់អ្នក។"

**"ចូរសូម នោះនឹងឱ្យមកអ្នក ចូររក នោះតែងនឹងឃើញ ចូរគោះ នោះតែងនឹងបើកឱ្យអ្នក។" ម៉ាថាយ 7:7**

ដូច្នេះគាត់បានគោះម្តង ពីរដង ដោយនិយាយថា

"តើពេលនេះខ្ញុំអាចចូលទីនេះបានទេ?" តើអ្នកខាងក្នុងនឹងបើកទ្វារមកអាណិតខ្ញុំដែរទេ បើទោះជាខ្ញុំជាអ្នកបះបោរមិនសាកសមក៏ដោយ? បន្ទាប់មកខ្ញុំនឹងមិនខាននឹងច្រៀងបទសរសើរនៅស្ថានដ៏ខ្ពស់បំផុតឡើយ។"

ជាចុងក្រោយមានមនុស្សសំខាន់ម្នាក់មកកាន់ឃ្លោងទ្វារ ឈ្មោះលោកបំណងល្អ គាត់សួរថាតើអ្នកណានៅទីនោះ? ហើយតើគាត់មកពីពេលណា? ហើយតើគាត់ចង់បានអ្វី?

គ្រីស្ទាន៖ នេះជាមនុស្សមានបន្ទុកដោយបាបកំសត់ម្នាក់។ ខ្ញុំបានមកពីទីក្រុងនៃសេចក្ដីហិនវិនាស តែខ្ញុំកំពុងទៅកាន់ភ្នំស៊ីយ៉ូន ដើម្បីឱ្យរួចពីសេចក្ដីក្រោធដែលនឹងមកដល់។ ដូច្នេះ ក្នុងកាលដែលគេប្រាប់ខ្ញុំថា នៅឃ្លោងទ្វារនេះជាផ្លូវទៅទីនោះ ក៏ឱ្យដឹងថាតើអ្នកនឹងឱ្យខ្ញុំចូលទៅខាងក្រុងដែរទេ។

បំណងល្អ៖ គាត់និយាយថា ខ្ញុំមានបំណងនេះចេញពីចិត្តរបស់ខ្ញុំ។ ដោយការនោះគាត់ក៏បានបើកឃ្លោងទ្វារ។

ដូច្នេះនៅពេលដែលគ្រីស្ទានបានឈានជើងចូល ម្នាក់ទៀតបានទាញគាត់។ រួចមកគ្រីស្ទាននិយាយថា "តើវាមានន័យដូចម្ដេចដែរ?" ម្នាក់ទៀតបានប្រាប់គាត់ថា "ឆ្ងាយពីនេះបន្តិចមានឃ្លោងទ្វារមួយដែលបង្កើតវិមានដ៏រឹងមាំមួយជាកន្លែងដែលបីលសេបូលធ្វើជាមេបញ្ជាការ បន្ទាប់មកទាំងគាត់និងអស់អ្នកដែលនៅជាមួយគាត់បានបាញ់ព្រួញទៅកាន់អ្នកដែលព្យាយាមឡើងមកកាន់ឃ្លោងទ្វារនោះ ដ្បិតពួកគេអាចស្លាប់បាន មុនពេលដែលគេអាចចូលទៅក្នុងបាន។" បន្ទាប់មកគ្រីស្ទាននិយាយថា "ខ្ញុំមានអំណរហើយញាប់ញ័រ។" ដូច្នេះនៅពេលដែលគាត់បានចូលខាងក្នុង អ្នកដែលនៅឃ្លោងទ្វារបានសួរគាត់ថានរណាដែលជាអ្នកដឹកនាំគាត់នៅទីនោះ។

គ្រីស្ទាន៖ អ្នកផ្សាយដំណឹងល្អបានប្រាប់ខ្ញុំឱ្យមកនេះហើយគោះទ្វារដូចដែលខ្ញុំបានធ្វើហើយ។ ហើយគាត់បាននិយាយថាលោកនឹងប្រាប់ខ្ញុំថានឹងត្រូវធ្វើអ្វី។

បំណងល្អ៖ ទ្វារដែលចំហរក៏នៅមុខអ្នកហើយ ហើយមិនមានអ្នកណាដែលអាចបិទបានឡើយ។

គ្រីស្ទាន៖ ឥលូវនេះខ្ញុំអាចប្រមូលផលនៃការប្រថុយគ្រោះថ្នាក់របស់ខ្ញុំហើយ។

បំណងល្អ៖ ហេតុអ្វីបានជាអ្នកមកតែឯងបែបនេះ?

គ្រីស្ទាន៖ ពីព្រោះគ្មានអ្នកជិតខាងណាបានមើលឃើញពីគ្រោះថ្នាក់របស់គេដូចដែលខ្ញុំឃើញគ្រោះថ្នាក់របស់ខ្ញុំឡើយ។

បំណងល្អ៖ តើមានអ្នកណាម្នាក់បានដឹងថាអ្នកមកទេ?

គ្រីស្ទាន៖ បាទ មានប្រពន្ធ និងកូនៗខ្ញុំបានឃើញខ្ញុំមកមុនគេ ហើយពួកគេបានហៅខ្ញុំឱ្យត្រឡប់ទៅវិញ។ ហើយក៏មានអ្នកជិតខាងរបស់ខ្ញុំ គេបានយំទាំងហៅខ្ញុំឱ្យត្រឡប់ទៅវិញ តែខ្ញុំបានដាក់ម្រាមដៃរបស់ខ្ញុំបិទត្រចៀក ហើយក៏មកតាមផ្លូវរបស់ខ្ញុំ។

បំណងល្អ៖ តើមិនមានអ្នកណាម្នាក់មកតាមអ្នក ដើម្បីនឹងបបួលអ្នកឱ្យត្រឡប់ទៅវិញទេឬអី?

គ្រីស្ទាន៖ បាទមាន គឺមានទាំងលោកមានៈ និងលោកងាយអូសទាញ តែនៅពេលពួកគេបានឃើញថាពួកគេមិនអាចយកឈ្នះបាន លោកមានៈបាន

ត្រឡប់ទៅវិញដោយក្រៀមក្រំ តែលោកងាយអូសទាញបានមកជាមួយខ្ញុំបានឆ្ងាយបន្តិចដែរ។

បំណងល្អ៖ តែហេតុអ្វីបានជាគាត់មកមិនរួចអីចឹង?

គ្រីស្ទាន៖ ពិតណាស់ពួកយើងបានមកជាមួយគ្នារហូតដល់រណ្ដៅនៃសេចក្ដីធ្លាក់ចុះខាងវិញ្ញាណ ដែលយើងស្រាប់តែធ្លាក់ចុះតែម្ដង។ ហើយបន្ទាប់មកអ្នកជិតខាងរបស់ខ្ញុំលោកងាយអូសទាញក៏ខកចិត្ត ហើយមិនចង់បន្តដំណើរទៅមុខទៀតឡើយ។ ដូច្នេះ គាត់ក៏បានឡើងចេញទៅត្រើយម្ខាងទៀតដែលនៅក្បែរផ្ទះរបស់គាត់ គាត់បានប្រាប់ខ្ញុំថា ខ្ញុំគួរតែកាន់កាប់ប្រទេសដែលក្លាហានម្នាក់ឯងជំនួសគាត់ទៅ ហើយគាត់ក៏ទៅតាមផ្លូវរបស់គាត់ ហើយខ្ញុំបានមកតាមផ្លូវរបស់ខ្ញុំ។ គាត់ទៅតាមលោកមានៈ ហើយខ្ញុំមកកាន់ឃ្លោងទ្វារនេះ។

បំណងល្អ៖ បន្ទាប់មកលោកបំណងល្អបាននិយាយថា "ឱ នាយកំសត់អើយ! តើសិរីល្អពីស្ថានសួគ៌មានតម្លៃតិចណាស់ឬសម្រាប់គាត់ ដែលគាត់បានរាប់ថាមិនសមនឹងប្រថុយគ្រោះថ្នាក់បន្តិចបន្តួចដើម្បីបានវាមកនោះ?"

គ្រីស្ទាន៖ គ្រីស្ទាននិយាយថា "ពិតណាស់" "ខ្ញុំបាននិយាយការពិតពីលោកងាយអូសទាញ ហើយប្រសិនបើខ្ញុំត្រូវនិយាយសេចក្ដីពិតទាំងអស់អំពីខ្លួនខ្ញុំនោះ វានឹងមិនមានភាពល្អឹងជួរចត់អ្វីរវាងគាត់និងខ្ញុំទេ។ ជាការពិតដែលគាត់បានត្រឡប់ទៅផ្ទះខ្លួនវិញ តែខ្ញុំក៏បានបែរចេញទៅរកផ្លូវនៃសេចក្ដីស្លាប់

ផងដែរ ដោយត្រូវបានអូសទាញនៅទីនោះដោយការវែកញែកខាងសាច់ឈាមរបស់លោកអ្នកប្រាជ្ញខាងលោកិយ។”

បំណងល្អ៖ អូ តើគាត់បានបំភ្លឺដល់អ្នកមែនទេ? ថាម៉េច! គាត់នឹងឱ្យអ្នកស្វែងរកដើម្បីនឹងភាពសុខស្រួលពីជំនួយរបស់លោកស្របច្បាប់ ពួកគេទាំងពីរសុទ្ធតែជាអ្នកបោកប្រាស់ តែតើអ្នកបានស្តាប់តាមការព្រិក្សារបស់គាត់ទេ?

គ្រីស្ទាន៖ បាទបាន តាមដែលខ្ញុំប្រថុយធ្វើតាម។ ខ្ញុំបានទៅរកលោកស្របច្បាប់ រហូតដល់ខ្ញុំបានគិតថាភ្នំដែលឈរនៅក្បែរផ្ទះរបស់គាត់នឹងធ្លាក់មកលើក្បាលរបស់ខ្ញុំ ដូច្នេះខ្ញុំបង្ខំឱ្យត្រូវបញ្ឈប់នៅត្រឹមនោះ។

បំណងល្អ៖ ភ្នំនោះធ្លាប់ជាសេចក្តីស្លាប់របស់មនុស្សជាច្រើន ហើយក៏នឹងក្លាយជាសេចក្តីស្លាប់របស់មនុស្សច្រើនទៀត ល្អហើយដែលអ្នកគិតផុតមិនត្រូវវាកំទេចអ្នកជាចំណែកៗ។

គ្រីស្ទាន៖ ខ្ញុំពិតជាមិនដឹងថាខ្ញុំនឹងក្លាយទៅជាអ្វីឡើយនៅទីនោះ អ្នកផ្សាយដំណឹងល្អបានជួបខ្ញុំម្តងទៀត ពេលដែលខ្ញុំកំពុងគិតពិចារណាក្នុងក្បាលរបស់ខ្ញុំ តែវាជាសេចក្តីមេត្តារបស់ព្រះដែលគាត់បានមករកខ្ញុំម្តងទៀត មិនដូច្នោះទេខ្ញុំមិនបានមកដល់ទីនេះទេ។ តែពេលនេះខ្ញុំបានមកហើយ មនុស្សដូចខ្ញុំសមតែត្រូវស្លាប់ដោយសារភ្នំនោះ ជាជាងដែលឈរនិយាយជាមួយលោកម្ចាស់របស់ខ្ញុំ។ តែអូ នេះជាសេចក្តីមេត្តាខ្លាំងណាស់ដល់ខ្ញុំ ដែលខ្ញុំបានអនុញ្ញាតឱ្យបានចូលមកទីនេះ!

បំណងល្អ៖ យើងមិនមានអ្វីជំទាស់នឹងនរណាម្នាក់ឡើយ។ ទោះជាយ៉ាងណាគ្រប់យ៉ាងដែលគេបានធ្វើមុនពេលដែលពួកគេមកទីនេះ ពួកគេមិនត្រូវបានបណ្តេញចេញឡើយ។

**"អស់អ្នកណាដែលព្រះវរបិតាប្រទានមកខ្ញុំ នោះនឹងមកឯខ្ញុំ ហើយអ្នកណាដែលមកឯខ្ញុំ ខ្ញុំមិនដែលចោលទៅក្រៅឡើយ។" យ៉ូហាន 6:37**

ដូច្នេះគ្រីស្ទានល្អ ចូរខិតមកជិតខ្ញុំបន្តិចមក ខ្ញុំនឹងបង្រៀនអ្នកអំពីផ្លូវដែលអ្នកត្រូវទៅ។ ចូរមើលទៅខាងមុខអ្នក តើអ្នកបានឃើញផ្លូវចង្អៀតនេះទេ? នោះហើយជាផ្លូវដែលអ្នកត្រូវទៅ។ វាជាផ្លូវដែលត្រូវនាំមកពីពួកឰយុកោ ហោរា ព្រះគ្រីស្ទ និងពួកសាវក។ ហើយវាជាផ្លូវត្រង់ដូចគូសបន្ទាត់អីចឹង នេះជាផ្លូវដែលអ្នកត្រូវទៅ។

គ្រីស្ទាន៖ គ្រីស្ទាននិយាយថា "តែវាមិនមានផ្លូវបត់ឬផ្លូវបំបែក ដែលអ្នកប្លែកមុខអាចនឹងវង្វេងផ្លូវរបស់ពួកគេ។"

បំណងល្អ៖ ពិតណាស់ មានផ្លូវជាច្រើនដែលបែកខ្នែងចេញពីផ្លូវនេះ ហើយវាវៀចវេរព្រមទាំងទូលាយផង តែអ្នកនឹងអាចបែងចែករវាងត្រូវនិងខុសបាន ផ្លូវត្រូវជាផ្លូវដែលត្រង់ភ្លឹងហើយចង្អៀតផង។

**"តែឯទ្វារដែលនាំទៅជីវិត នោះតូច ហើយចង្អៀតវិញ ក៏មានមនុស្សតូចណាស់ដែលរកផ្លូវនោះឃើញ។" ម៉ាថាយ 7:14**

បន្ទាប់មកខ្ញុំបានឃើញនៅក្នុងសុបិន្តរបស់ខ្ញុំថា គ្រីស្ទានសួរបន្ថែមទៀតថា គាត់អាចជួយដកបន្ទុករបស់គាត់ដែលនៅលើខ្នងនោះបានដែរទេ ដោយសារគាត់មិនទាន់បានដកវាចេញនៅឡើយ ហើយគាត់ក៏មិនអាចដកវាចេញដោយមិនមានជំនួយផងដែរ។

គាត់បានប្រាប់ថា "សម្រាប់បន្ទុករបស់អ្នកនោះ ចូរចេះស្កប់ចិត្តនឹងស្ពាយវារហូតទាល់តែអ្នកមកដល់កន្លែងនៃសេចក្តីប្រោសលោះ ដោយសារទីនោះវានឹងធ្លាក់ចេញពីខ្នងរបស់អ្នកដោយខ្លួនវា។"

បន្ទាប់មកគ្រីស្ទានចាប់ផ្តើមមូរដៃអាវរបស់គាត់ឡើង ហើយរៀបចំខ្លួនដើម្បីនឹងចេញដំណើរទៅ។ ដូច្នេះម្នាក់ទៀតបានប្រាប់គាត់ថា នៅពេលដែលគាត់បានទៅឆ្ងាយបន្តិចពីឃ្លោងទ្វារ គាត់នឹងទៅដល់ផ្ទះរបស់អ្នកបកប្រែ ដែលគាត់ត្រូវគោះទ្វារផ្ទះនោះ រួចគាត់នឹងបង្ហាញរបស់ល្អៗឥតខ្ចោះដល់គាត់។ បន្ទាប់មកគ្រីស្ទានបានចាកចេញពីមិត្តភក្តិរបស់គាត់ទៅ ហើយគាត់ធ្វើដំណើរសំដៅទៅរកព្រះ។

## អ្នកបកស្រាយ

បន្ទាប់មកគាត់បានដើរទៅរហូតដល់ព្រះរបស់អ្នកបកប្រែ គាត់បានគោះទ្វារ ហើយគោះទៀត ហើយទីបំផុតមានមនុស្សម្នាក់បានដើរមកទ្វារ ហើយសួរថាអ្នកណាហ្នឹង?

គ្រីស្ទាន៖ ឱលោក នេះជាអ្នកធ្វើដំណើរម្នាក់ ដែលត្រូវបានស្គាល់ដោយអ្នកជិតជិតនៅក្នុងផ្ទះឱ្យមកទីនេះទទួលប្រយោជន៍។ ដូច្នេះខ្ញុំចង់និយាយជាមួយនឹងម្ចាស់ផ្ទះ។ ដូច្នេះគាត់បានហៅរកម្ចាស់ផ្ទះ ហើយបន្តិចក្រោយមកគាត់បានចេញមករកគ្រីស្ទាន ហើយបានសួរអ្វីដែលគាត់ចង់បាន?

គ្រីស្ទាន៖ គ្រីស្ទានបាននិយាយថា "លោកម្ចាស់អើយ ខ្ញុំជាមនុស្សម្នាក់ដែលបានចាកចេញពីទីក្រុងនៃសេចក្តីវិនាសអន្តរាយ ហើយខ្ញុំកំពុងធ្វើដំណើរទៅកាន់ភ្នំស៊ីយ៉ូន។ មានបុរសម្នាក់ដែលឈរនៅក្បែរឃ្លោងទ្វារនៅឯដើមផ្លូវនេះបានប្រាប់ខ្ញុំពីផ្លូវនេះ គាត់ថាប្រសិនបើខ្ញុំនឹងស្រែកហៅ នោះអ្នកនឹងបង្ហាញខ្ញុំពីការល្អឥតខ្ចោះជាច្រើន ដែលសុទ្ធតែជារបស់ដែលមានប្រយោជន៍សម្រាប់ខ្ញុំនៅក្នុងការធ្វើដំណើរនេះ។"

អ្នកបកប្រែ៖ បន្ទាប់មកអ្នកបកស្រាយបាននិយាយថា "ចូរមកខាងក្នុងមក ខ្ញុំនឹងបង្ហាញអ្នកពីអ្វីដែលមានប្រយោជន៍ដល់អ្នក។" គាត់ក៏ប្រាប់ដល់មនុស្សរបស់គាត់ឱ្យដុតទៀន ហើយប្រាប់គ្រីស្ទានឱ្យដើរតាមគាត់ គាត់ក៏នាំគេទៅកាន់បន្ទប់ឯកជនមួយ ហើយប្រាប់មនុស្សរបស់គាត់ឱ្យបើកទ្វារ ពេលបើករួចគ្រីស្ទានបានឃើញរូបភាពរបស់មនុស្សសំខាន់មនុស្សដែលព្យួរនៅ

ជញ្ចាំងនោះ ហើយនោះជាបែបបទរបស់វា វាមានភ្នែកមើលទៅលើមេឃ ហើយសៀវភៅដ៏ល្អបំផុតនៅក្នុងដៃរបស់គាត់ ក្រិត្យវិន័យនៃសេចក្តីពិត ដែលសរសេរនៅលើបបូរមាត់របស់គាត់ ហើយលោកិយនៅពីក្រោយគាត់ គាត់បានឈរដូចជាគាត់អង្វរមនុស្សអីចឹង ហើយមកុដមាសបានបំពាក់នៅលើក្បាលរបស់គាត់។

គ្រីស្ទាន៖ គ្រីស្ទានបាននិយាយថា "តើនេះមានន័យយ៉ាងណា?"

អ្នកបកស្រាយ៖ មនុស្សដែលនៅក្នុងរូបភាពនេះជា ម្នាក់នៅក្នុងចំណោមមនុស្ស១០០០នាក់ គាត់អាចបង្កើតកូនបាន។

**"ដ្បិតថ្វីបើអ្នករាប់គ្នាមានគ្រូរាប់ម៉ឺនក្នុងព្រះគ្រីស្ទ តែគ្មានឪពុកជាច្រើនទេ មានតែខ្ញុំមួយប៉ុណ្ណោះ ដែលបានបង្កើតអ្នករាល់គ្នាក្នុងព្រះគ្រីស្ទដោយសារដំណឹងល្អ។" កូរិនថូស ទី១ 4:15**

ដែលខំប្រឹងនៅក្នុងការផ្តល់កំណើតដល់កូនៗ

**"កូនចៅអើយ ខ្ញុំលំបាកក្នុងចិត្តជាពន់ពេក ដោយព្រោះអ្នករាល់គ្នាម្តងទៀត ទាល់តែព្រះគ្រីស្ទបានក មានរូបរាងក្នុងអ្នករាល់គ្នាឡើង។" កាឡាទី 4:19**

ហើយបំបៅពួកគេដោយផ្ទាល់នៅពេលដែលគេបានកើតមក។

**“ខ្ញុំបានឱ្យទឹកដោះមកអ្នករាល់គ្នាផឹក មិនបានឱ្យសាច់បរិភោគទេ ដ្បិតកាលនោះអ្នករាល់គ្នាពុំអាចនឹងបរិភោគបាន ហើយឥឡូវនេះ ក៏មិនទាន់បានដែរ។” កូរិនថូស ទី១ 3:2**

ហើយនៅពេលដែលអ្នកឃើញគាត់សម្លឹងភ្នែកឡើងទៅលើមេឃ សៀវភៅល្អបំផុតនៅក្នុងដៃរបស់គាត់ ហើយនិងក្រឹត្យវិន័យសរសេរនៅលើបបូរមាត់របស់គាត់ គឺបង្ហាញអ្នកថាកិច្ចការរបស់គាត់នោះគឺ ដើម្បីស្គាល់និងលាតត្រដាងកិច្ចការពីការខាងសេចក្តីងងឹតដល់មនុស្សមានបាប។ អ្នកទាំងឃើញថាគាត់បានឈរដូចជាគាត់កំពុងអង្វរដល់មនុស្សផង ហើយលោកិយត្រូវបោះចោលនៅខាងក្រោយគាត់ ហើយមកុដពាក់នៅលើក្បាលរបស់គាត់ គឺដើម្បីបង្ហាញដល់អ្នកថា ការបន្ថោកនិងមើលងាយដល់កិច្ចការខាងលោកិយនាពេលបច្ចុប្បន្ន ដើម្បីសេចក្តីស្រឡាញ់ដែលគាត់មានចំពោះកិច្ចការរបស់ម្ចាស់របស់គាត់ គាត់ដឹងប្រាកដពីពិភពលោកដែលនឹងត្រូវមកដែលមានសិរីល្អជារង្វាន់ដល់គាត់។ ពេលនេះអ្នកបកស្រាយបាននិយាយថា ខ្ញុំបានបង្ហាញរូបភាពនេះដល់អ្នកជាដំបូងបង្អស់ ដោយសារមនុស្សដែលនៅក្នុងរូបភាពនេះ ជាបុរសតែម្នាក់គត់ដែលព្រះអម្ចាស់នៃកន្លែងនោះបានផ្តល់នូវឫទ្ធិអំណាច ឱ្យបានធ្វើជាអ្នកដឹកនាំរបស់អ្នកនៅទីកន្លែងដែលពិបាកៗដែលអ្នកនឹងជួបនៅតាមផ្លូវ។ ដូច្នេះ ចូរស្តាប់ឱ្យបានល្អទៅកាន់អ្វីដែលខ្ញុំបានបង្ហាញដល់អ្នក ហើយរក្សាវាទុកនៅក្នុងគំនិតរបស់អ្នកនូវអ្វីដែលអ្នកបានឃើញ បើមិនដូច្នោះទេនៅក្នុងដំណើររបស់អ្នក អ្នកនឹងជួយមនុស្សមួយចំនួនដែលនឹងធ្វើពុតដូចជាអ្នកនាំទៅកាន់ផ្លូវត្រូវ តែផ្លូវរបស់គេទៅកាន់សេចក្តីវិញ។

បន្ទាប់មកក៏ចាប់ដៃរបស់គាត់ ហើយនាំគាត់ទៅកាន់ឃ្លាំងដ៏ធំមួយដែលពេញដោយធូលី ពីព្រោះមិនដែលបោសសោះ ហើយបន្ទាប់ពីគាត់បានសង្កេតមើលបន្តិចមក អ្នកបកស្រាយបានហៅមនុស្សមកបោសសំអាត។ ឥលូវនៅពេលដែលគាត់ចាប់ផ្តើមសំអាត ធូលីចាប់ផ្តើមហើរឡើងយ៉ាងបរិបូរ ដែលគ្រីស្ទានស្ទើតែឈ្លក់។ បន្ទាប់មកអ្នកបកស្រាយបាននិយាយទៅកាន់នារីក្មេងម្នាក់ដែលឈរនៅក្បែរថា "សូមយកទឹកមកនេះ ហើយបាយនៅក្នុងបន្ទប់នេះ" ហើយបន្ទាប់ពីនាងធ្វើរួច នោះវាក៏បានបោសស្អាតដោយអំណរ។

គ្រីស្ទាន៖ គ្រីស្ទានក៏និយាយថា "តើនេះមានន័យយ៉ាងណា?"

អ្នកបកស្រាយ៖ អ្នកបកស្រាយបានឆ្លើយថា "ឃ្លាំងនេះជាចិត្តរបស់មនុស្សដែលមិនដែលបានបន្សុតដោយព្រះគុណដ៏ផ្អែមនៃដំណឹងល្អ។ ធូលីជាអំពើបាបដើម និងសេចក្តីរលួយនៅខាងក្នុង ដែលបានធ្វើឱ្យមនុស្សទាំងមូលទៅជាអាក្រក់។ អ្នកដែលមកបោសពីដំបូង នោះជាក្រឹត្យវិន័យ តែនារីដែលបានយកទឹកមក  ហើយបាយទឹកនោះ ជាដំណឹងល្អ។ ឥលូវនេះ ដូចដែលអ្នកបានឃើញថា ភ្លាមៗដែលគេចាប់ផ្តើមបោសនោះ ធូលីក៏ហោះពាសពេញទាំងអស់ ហើយបន្ទប់ក៏មិនអាចនឹងស្អាតបានដោយសារគាត់ដែរ ហើយអ្នកស្ទើតែឈ្លក់នៅទីនោះ នេះបង្ហាញមកអ្នកថា ជំនួសឱ្យការសម្អាតចិត្តពីបាបនោះក្រឹត្យវិន័យធ្វើឱ្យបាបនោះរស់ឡើងវិញ បន្ថែមកម្លាំងដល់វា ហើយវាបានចម្រើននៅក្នុងព្រលឹង ទាំងបានរកឃើញនិងហាមវាផង ដោយសារវាមិនបានផ្តល់អំណាចដើម្បីបង្រាបឡើយ។"

**"តែក្រឹត្យវិន័យបានចូលមកថែមទៀត ដើម្បីឱ្យសេចក្ដីរំលងនោះបានរឹតតែធ្ងន់ឡើង ប៉ុន្តែកន្លែងណាដែលមានបាបចម្រើនជាបរិបូរឡើង នោះព្រះគុណក៏ចម្រើនជាបរិបូរលើសទៅទៀត។" រ៉ូម 5:20**

**"តែពីដើម ក្រៅពីក្រឹត្យវិន័យ នោះខ្ញុំបានរស់នៅ លុះសេចក្ដីបញ្ញត្តិបានកើតមក នោះបាបក៏រស់ឡើង ឯខ្ញុំក៏ត្រូវស្លាប់វិញ។" រ៉ូម 7:9**

**"រីឯទ្រនិចនៃសេចក្ដីស្លាប់ គឺជាអំពើបាប ហើយអំណាចរបស់បាប គឺជាក្រឹត្យវិន័យ។" កូរិនថូស ទី១ 15:56**

"ម្ដងទៀត នៅពេលដែលអ្នកឃើញនារីក្មេងប្រោះទឹកទៅក្នុងបន្ទប់ នោះបន្ទប់ក៏បានស្អាតដោយមានអរសប្បាយ (ងាយ) នេះបង្ហាញអ្នកថា នៅពេលដែលដំណឹងល្អមកដល់ វាមានឥទ្ធិពលយ៉ាងផ្អែមល្ហែមនិងមានតម្លៃបែបនោះ ដល់ចិត្ត។ បន្ទាប់មកខ្ញុំនិយាយថានៅពេលដែលអ្នកបានឃើញ នារីក្មេងបានប្រោះទឹកទៅកាន់ធូលីដែលនៅផ្ទៃខាងក្រោមនៃបន្ទប់ នោះអំពើបាបត្រូវរលាយហើយត្រូវបង្ក្រាបបាន ហើយព្រលឹងត្រូវបានសម្អាតតាមរយៈសេចក្ដីជំនឿ ហើយជាចុងក្រោយសាកសមនឹងស្ដេចនៃសិរីល្អមកគង់កាន់កាប់បាន។"

**"ឯអ្នករាល់គ្នាបានស្អាតហើយ ដោយពាក្យដែលខ្ញុំបានប្រាប់។" យ៉ូហាន 15:3**

**"ទ្រង់មិនបានរាប់ពួកយើង និងពួកគេ ខុសគ្នាទេ គឺបានសម្អាតចិត្តគេដោយសារសេចក្ដីជំនឿជឿដែរ។" កិច្ចការ 15:9**

**"រីឯព្រះដែលអាចនឹងតាំងអ្នករាល់គ្នា ឱ្យខ្ជាប់ខ្ជួនតាមដំណឹងល្អខ្ញុំ និងតាមខ្លឹម នៃលិទ្ធិរបស់ព្រះយេស៊ូវគ្រីស្ទ ដែលត្រូវនឹងសេចក្តីបើកសម្តែង អំពីការអាថ៌ កំបាំង ដែលបានលាក់ទុកនៅអស់ទាំងកល្បរៀងមក។ តែឥលូវនេះបានបើក សម្តែងមក ឱ្យទាំងសាសន៍ដឹង ដោយសារគម្ពីរហោរា តាមបង្គាប់នៃព្រះដ៏ មានព្រះជន្មរស់អស់កល្បជានិច្ច ដើម្បីឱ្យគេបានចុះចូលជឿ ដោយសារព្រះ យេស៊ូវគ្រីស្ទ។" រ៉ូម 16:25, 25**

**"ដើម្បីឱ្យទ្រង់បានញែកពួកជំនុំចេញជាបរិសុទ្ធ ដោយបានលាងសម្អាតនឹង ទឹក គឺជាព្រះបន្ទូល។" អេភេសូ 5:26**

ខ្ញុំបានឃើញនៅក្នុងសុបិន្តរបស់ខ្ញុំទៀតថា អ្នកបកស្រាយបានចាប់ដៃរបស់ គាត់ ហើយនាំចូលទៅក្នុងបន្ទប់តូចមួយ ដែលមានក្មេងតូចពីនាក់អង្គុយនៅ លើកៅអីម្នាក់មួយ។ ក្មេងបងមានឈ្មោះថាចំណង់ ហើយម្នាក់ទៀតឈ្មោះ អត់ធ្មត់។ ចំណង់ហាក់បីដូចជាមិនចេះស្កប់ស្កល់សោះ តែអត់ធ្មត់នៅស្ងៀម ស្ងាត់វិញ។ បន្ទាប់មកគ្រីស្ទានបានសួរថា "តើអ្វីទៅជាហេតុផលដែលចំណង់ មិនចេះស្កប់ចិត្ត?" អ្នកបកស្រាយបានឆ្លើយថា "អ្នកគ្រប់គ្រងរបស់គាត់ចង់ ឱ្យគាត់នៅទទួលរបស់ដ៏ល្អបំផុតរបស់គាត់រហូតដល់ដើមឆ្នាំក្រោយ តែគាត់ ចង់បានវានៅពេលនេះ តែអត់ធ្មត់ស្ម័គ្រចិត្តនឹងរងចាំវិញ។"

បន្ទាប់មកខ្ញុំបានឃើញម្នាក់បានមកកាន់ចំណង់ ហើយយកកំណព្វមួយ ស្រោងឱ្យគាត់ ហើយក៏ចាក់វាចេញនៅក្បែរជើងគាត់ គាត់ក៏យកវាមក ហើយសប្បាយជាមួយវា ហើយក៏សើចចំអកដល់អត់ធ្មត់។ ប៉ុន្តែខ្ញុំបានមើល មួយសន្ទុះមក នោះវាបានរលាយបាត់មួយរំពេច ហើយគ្មានអ្វីសល់សោះ។

គ្រីស្ទាន៖ បន្ទាប់មកគ្រីស្ទាននិយាយទៅកាន់អ្នកបកស្រាយថា "ចូរបកស្រាយពន្យល់ពីការនេះឱ្យពេញលេញដល់ថែមទៀតដល់ខ្ញុំផង"

អ្នកបកស្រាយ៖ ដូច្នេះគាត់បាននិយាយថា "ក្មេងទាំងពីនេះជារូបតំណាងចំណង់ ជាតំណាងនៃមនុស្សនៅក្នុងលោកិយនេះ ហើយអត់ធ្មត់ ជាតំណាងនៃមនុស្សនៃលោកិយដែលនឹងមកដល់។ ទីនេះអ្នកបានឃើញចំណង់នឹងទទួលបានរបស់ទាំងអស់នៅឆ្នាំនេះ នោះចង់និយាយថា នៅក្នុងលោកិយនេះ។ ហើយមនុស្សទាំងអស់លើលោកិយនេះសុទ្ធតែចង់បាន ពួកគេនឹងត្រូវបានរបស់ល្អៗនៅពេលនេះ ពួកគេមិនអាចចាំដល់ឆ្នាំក្រោយឡើយ ដែលជាផែនដីដែលនឹងមកសម្រាប់ចំណែកល្អរបស់ពួកគេ។ សុភាសិតដែលថា បក្សីមួយនៅក្នុងដៃមានតម្លៃជាងបក្សីពីដែលនៅក្នុងគុម្ពបន្លា។ ហើយវាមានអំណាចដល់គេជាជាងទីបន្ទាល់ទាំងប៉ុន្មានរបស់ព្រះ ដែលនិយាយពីការល្អនៃលោកិយដែលនឹងមកដល់ទៅទៀត។ តែដូចដែលអ្នកឃើញហើយថា វានឹងត្រូវហោចទៅយ៉ាងរហ័ស ហើយមិនមានអ្វីនៅសល់ជាមួយគាត់សោះមានតែកន្ទប ដូច្នេះវាជាអ្វីដែលមនុស្សបែបដូច្នោះនឹងទទួលបាននៅទីបញ្ចប់នៃលោកិយនេះ។"

គ្រីស្ទាន៖ បន្ទាប់មកគ្រីស្ទានបាននិយាយថា "ពេលនេះ ខ្ញុំដឹងថាអត់ធ្មត់មានប្រាជ្ញាប្រសើរជាង ដោយសារការជាច្រើន៖ 1. គាត់រងចាំការដ៏ល្អបំផុត។ 2. ហើយដោយសារគាត់នឹងមានសិរីល្អដែលជារបស់គាត់ផង នៅពេលដែលម្នាក់ទៀតមិនមានអ្វីសោះក្រៅពីកន្ទប។"

អ្នកបកស្រាយ៖ ទេ តែអ្នកអាចបន្ថែមការមួយទៀតទៅលើការនោះ នោះជាសិរីល្អនៃលោកិយដែលនឹងមកដល់ដែលមិនដែលខូចបង់ទៅឡើយ។ តែរបស់លោកិយនេះនឹងបាត់បង់ទៅមួយរំពេច។ ដូច្នេះចំណង់មិនមានហេតុផលច្រើនដើម្បីនឹងសើចចំអកដល់អត់ធ្មត់នោះទេ ពីព្រោះពេលនេះគាត់ទទួលបានរបស់ដែលល្អរួចហើយ សម្រាប់អត់ធ្មត់វិញនឹងត្រូវសើចដាក់ចំណង់វិញ ពីព្រោះគាត់ទទួលបានរបស់ល្អរបស់គាត់ជាចុងក្រោយដោយសារអ្នកមុននឹងត្រូវប្រគល់ដំណែងដល់អ្នកដែលមកក្រោយដោយសារអ្នកដែលមកក្រោយនឹងមានពេលដែលត្រូវមកដល់ ប៉ុន្តែអ្នកដែលមកក្រោយមិនត្រូវប្រគល់កន្លែងទៅណាទៀតនោះឡើយ ដោយសារមិនមានអ្នកណាដែលនឹងមកបន្តទៀតនោះទេ។ ដូច្នេះ អ្នកដែលទទួលបានចំណែកមុននឹងមានពេលដែលនឹងចាយវាយវាទៅអស់ តែអ្នកដែលទទួលបានចំណែកជាក្រោយ នោះនឹងនៅជាប់ជារៀងដរាបទៅ។ ដូច្នេះមាននិយាយពីអ្នកមានថា "នៅក្នុងពេញមួយជីវិតអ្នក អ្នកបានទទួលសុទ្ធតែរបស់ល្អៗ តែឡាសាបានទទួលការអាក្រក់វិញ ប៉ុន្តែពេលនេះគាត់បានទទួលការកំសាន្តវិញ ហើយអ្នកទទួលបានការទួញសោកវិញ។"

**"តែលោក អ័ប្រាហាំ ឆ្លើយថា កូនអើយ ចូរនឹងចាំថាកាលឯងនៅរស់នៅឡើយ ឯងបានទទួលសុទ្ធតែសេចក្តីល្អ ឯឡាសារគាត់បានតែសេចក្តីអាក្រក់ទេ ឥឡូវនេះគាត់បានសេចក្តីកំសាន្តចិត្តវិញ ហើយឯងត្រូវវេទនា។" លូកា 16:25**

គ្រីស្ទាន៖ អឺចឹង ខ្ញុំយល់ឃើញថា វាមិនសូវល្អទេដែលលោកនូវរបស់នាបច្ចុប្បន្ននេះ តែគួររងចាំការដែលនឹងមកដល់វិញ។

អ្នកបកស្រាយ៖ អ្នកនិយាយត្រូវហើយ "ដោយសារការដែលមើលឃើញនោះនៅតែមួយរយៈទេ តែការដែលមើលមិនឃើញនៅអស់កល្បជានិច្ច។"

**"ដោយយើងមិនរាប់អានរបស់ដែលមើលឃើញឡើយ គឺរាប់អានតែរបស់ដែលមើលមិនឃើញវិញ ដ្បិតរបស់ដែលមើលឃើញ នោះស្ថិតស្ថេរមិនយូរប៉ុន្មានទេ តែឯរបស់ដែលមើលមិនឃើញ នោះនៅស្ថិតស្ថេរអស់កល្បជានិច្ចវិញ។" កូរិនថូស ទី២ 4:18**

ប៉ុន្តែបើទោះជាវាបែបនេះក៏ដោយ ក្នុងកាលដែលការបច្ចុប្បន្ននេះនិងសម្រេកខាងសាច់ឈាមរបស់យើង ប្រៀបដូចនឹងអ្នកជិតខាងគ្នាទៅវិញទៅមក ហើយដោយសារការដែលនឹងមកនិងញាណខាងសាច់ឈាមជាអ្នកមិនដែលស្គាល់គ្នា ដូច្នេះវាអ្នកដែលមកមុននឹងធ្លាក់ទៅក្នុងភាពជាសត្រូវ ហើយគំលាតនោះនៅតែបន្តរហូតជាមួយនឹងការដែលមកទីពីរ។

រួចខ្ញុំបានឃើញនៅក្នុងសុបិន្តរបស់ខ្ញុំថា អ្នកបកស្រាយបានចាប់ដៃរបស់គ្រីស្ទាន ហើយបាននាំគាត់ទៅកន្លែងមួយ ដែលមានភ្លើងឆេះក្បែរជញ្ជាំង ហើយម្នាក់ដែលឈរនៅក្បែរនោះតែតែជះទឹកដើម្បីនឹងពន្លត់វា តែភ្លើងកាន់តែឆេះខ្លាំងទៅៗ។

គ្រីស្ទាន៖ បន្ទាប់មកគ្រីស្ទានបាននិយាយថា "តើនេះមានន័យយ៉ាងណា?"

អ្នកបកស្រាយ៖ អ្នកបកស្រាយបានឆ្លើយថា "ភ្លើងនេះជាកិច្ចការនៃព្រះគុណដែលមាននៅក្នុងចិត្ត អ្នកដែលជះទឹកញែកវានិងពន្លត់វានោះ ជាអារក្ស តែអ្នកឃើញថាភ្លើងមិនបានរលត់ទេ តែឆេះកាន់តែក្តៅខ្លាំងឡើងៗ អ្នកក៏នឹង

ដឹងពីហេតុផលនោះដែរ។ រួចគាត់បាននាំគាត់ទៅក្បែរជញ្ជាំងដែលនៅខាងក្រោយជញ្ជាំង ដែលគាត់បានឃើញបុរសម្នាក់មានភាជនៈដាក់ប្រេងនៅក្នុងដៃរបស់គាត់ ដែលគាត់តែងតែចាក់បន្តបន្ទាប់ តែចាក់ដោយសម្ងាត់ទៅក្នុងភ្លើង។"

គ្រីស្ទានៈ រួចគ្រីស្ទាននិយាយថា "តើនេះមានន័យយ៉ាងណា?"

អ្នកបកស្រាយៈ អ្នកបកស្រាយបានឆ្លើយថា "នេះជាព្រះគ្រីស្ទ ជាអ្នកដែលបន្តចាក់ប្រេងនាំព្រះគុណដើម្បីនឹងពង្រឹងដល់កិច្ចការដែលបានចាប់ផ្ដើមរួចនៅក្នុងចិត្ត ដោយមិនត្រូវបំផ្លាញដោយការដែលអារក្សអាចធ្វើបាននោះឡើយ ហើយព្រលឹងរបស់រាស្ត្រទ្រង់នឹងមានពេញដោយព្រះគុណដដែល។"

**"តែទ្រង់មានបន្ទូលមកខ្ញុំថា គុណរបស់អញល្មមដល់ឯងហើយ ដ្បិតកំលាំងអញបានពេញខ្នាត ដោយសេចក្ដីកំសោយ ដូច្នេះខ្ញុំនឹងស៊ូអួតពីសេចក្ដីកំសោយរបស់ខ្ញុំ ដោយអំណរជាខ្លាំង ដើម្បីឱ្យចេស្តានៃព្រះគ្រីស្ទ បានសណ្ឋិតនៅនឹងខ្ញុំ។" កូរិនថូស ទី២ 12:9**

ហើយកាលដែលអ្នកបានឃើញបុរសម្នាក់នៅខាងក្រោយជញ្ជាំងដែលនៅរក្សាភ្លើង នេះចង់បង្រៀនអ្នកថា វាពិបាកណាស់សម្រាប់នឹងឱ្យអ្នកដែលត្រូវល្បួងដឹងពីរបៀបដែលកិច្ចការនៃព្រះគុណធ្វើការរក្សាព្រលឹងនោះ។"

ខ្ញុំបានឃើញផងដែរថាអ្នកបកស្រាយ បានចាប់ដៃគាត់ម្តងទៀត ហើយបាននាំគាត់ទៅកាន់កន្លែងដែលល្អ ដែលមានរាជវាំងដែលត្រូវបានសង់នៅទីនោះយ៉ាងមាំ ដែលស្រស់ស្អាតគួរឱ្យគួយគន់ ដោយទស្សនិយភាពនោះបានធ្វើឱ្យគ្រីស្ទានមានអំណរយ៉ាងខ្លាំង។ គាត់ក៏ឃើញនៅលើកំពូលមានមនុស្សម្នាក់កំពុងដើរ ដែលមានស្លៀកពាក់មាស។

គ្រីស្ទានៈ បន្ទាប់មកគ្រីស្ទានបាននិយាយថា "តើយើងអាចទៅទីនោះទេ?"

បន្ទាប់មកអ្នកបកស្រាយបានយកគាត់ ហើយនាំទៅកាន់ទ្វារនៃបរមរាជវាំង ហើយមើល មានមនុស្សមួយក្រុមធំឈរនៅមាត់ទ្វារ ដែលពួកគេប្រថ្នាចង់ចូលទៅខាងក្នុង តែចូលមិនបាន។ មានបុរសម្នាក់អង្គុយនៅឆ្ងាយបន្តិចពីទ្វារ នៅក្បែរតុ មានសៀវភៅមួយនិងជក់នៅខាងមុខគាត់ ដើម្បីនឹងសរសេរឈ្មោះអ្នកដែលនឹងចូលក្នុងបាន។ គាត់ក៏បានឃើញនៅចន្លោះផ្លូវចូលទ្វារមានមនុស្សជាច្រើនមានអាវុធ នៅរក្សាទ្វារ ដើម្បីដោះស្រាយជាមួយនឹងអ្នកដែលចូលធ្វើឱ្យមានការឈឺចាប់និងការបោកបន្លំ គ្រីស្ទានមានអារម្មណ៍កោតសរសើរ។ ចុងក្រោយមនុស្សម្នាក់ៗចាប់ផ្តើមថយទៅវិញ ដោយសារខ្លាចអ្នកយាម គ្រីស្ទានបានឃើញមនុស្សម្នាក់ដែលមានទឹកមុខក្លាហានចេញមកកាន់បុរសម្នាក់ដែលអង្គុយសរសេរនោះ ដោយនិយាយថា "សូមបញ្ចូលឈ្មោះខ្ញុំផង លោក" បន្ទាប់ពីចប់នោះ គាត់ឃើញមនុស្សម្នាក់បានហូតដាវរបស់គាត់ចេញមក ហើយពាក់ពួកការពារនៅលើក្បាលរបស់គាត់ ហើយប្រញាប់រត់ទៅកាន់ទ្វារទៅកាន់អ្នកការពារ នោះគេបានប្រើកម្លាំងខ្លាំងដល់ពួកគេ ប៉ុន្តែបុរសនោះមិនបាក់ទឹកចិត្តឡើយ បានដួលដោយសារត្រូវបានកាត់និងភ្លាសសាច់យ៉ាងខ្លាំង។ ដូច្នេះ បន្ទាប់ពីគាត់បានទទួលបាន

របួសយ៉ាងច្រើនពីអ្នកដែលព្យាយាមឃាត់មិនឱ្យចូលទៅក្នុង គាត់បានច្រាន ពួកគេផុតទៅ ហើយបានសម្រុកទៅកាន់វាំង។

**"ព្រមទាំងចម្រើនកម្លាំងដល់ពួកសិស្ស ឱ្យមានចិត្តរឹងប៉ឹងឡើង ហើយទូន្មាន ឱ្យនៅស្ថិតស្ថេរក្នុងសេចក្តីជំនឿ ដោយពាក្យថា ត្រូវតែទ្រាំរងវេទនាជាច្រើន ទើបនឹងចូលទៅក្នុងនគរព្រះបាន។" កិច្ចការ 14:22**

ទីនោះមានសម្លេងយ៉ាងពីរោះឮចេញពីអ្នកដែលនៅខាងក្នុង ទាំងអ្នកដែល ដើរលើកំពូលនៃវាំង និយាយថា "ចូលមក! ចូរមក!" "អ្នកនឹងឈ្នះសិរីល្អនៅ អស់កល្ប"

ដូច្នេះគាត់បានចូលទៅខាងក្នុង ហើយត្រូវបានស្លៀកពាក់សំលៀកបំពាក់ ដូចពួកគេដែរ។ បន្ទាប់មកគ្រីស្ទានបានញញឹម ហើយនិយាយថា "ពិត ណាស់ខ្ញុំគិតថា ខ្ញុំយល់អត្ថន័យនៃការនេះ។"

គ្រីស្ទាននិយាយថា "ឥលូវ" "សូមឱ្យខ្ញុំទៅទីនោះ"

អ្នកបកស្រាយបាននិយាយថា "ទេ ចូរស្នាក់នៅចុះ" "រហូតដល់ខ្ញុំបានបង្ហាញ អ្នកបន្តិចទៀត ហើយបន្ទាប់មកអាចនឹងទៅតាមផ្លូវរបស់អ្នកបាន។" រួចក៏ ចាប់ដៃរបស់គាត់ម្តងទៀត ហើយនាំគាត់ទៅបន្ទប់ងងឹតមួយ ដែលមាន បុរសម្នាក់អង្គុយនៅក្នុងទ្រុងដែកមួយ។

ឥលូវពេលមើលទៅ បុរសនោះហាក់បីដូចជាក្រៀមក្រំខ្លាំងណាស់។ គាត់ អង្គុយដោយភ្នែកសម្លឹងមើលចុះទៅដី ហើយគាត់ដាក់ដៃរបស់គាត់ជាមួយ

គ្នា ហើយគាត់ដកដង្ហើមធំហាក់ដូចជាបំបែកចិត្តរបស់គាត់អីចឹង។ បន្ទាប់មកគ្រីស្ទានបាននិយាយថា "តើនេះមានន័យយ៉ាងណា?" នោះអ្នកបកស្រាយក៏ប្រាប់គាត់ឱ្យទៅនិយាយជាមួយបុរសនោះតែម្តង។

គ្រីស្ទាន៖ បន្ទាប់មកគ្រីស្ទានបាននិយាយទៅកាន់បុរសនោះថា "តើអ្នកជាអ្វី?"

អ្នកបែរថយក្រោយ៖ បុរសនោះក៏ឆ្លើយថា "ខ្ញុំជាអ្វី ដែលពីមុនខ្ញុំមិនមែននោះឡើយ។"

គ្រីស្ទាន៖ តើម្តងនោះអ្នកជាអ្វី?

អ្នកបែរថយក្រោយ៖បុរសនោះនិយាយថា "ម្តងនោះខ្ញុំជាសាស្ត្រាចារ្យយ៉ាងត្រឹមត្រូវហើយសមប្រកបម្នាក់ ទាំងនៅក្នុងភ្នែករបស់ខ្ញុំនិងអ្នកដទៃ។ ពីមុនខ្ញុំបើតាមខ្ញុំគិតថាខ្ញុំសាកសមនឹងទីក្រុងស្ថានសួគ៌ ហើយខ្ញុំថែមទាំងមានអំណរដោយគ្រាន់តែគិតថាខ្ញុំនឹងទៅដល់ទីនោះ។"

**"ឯពួកអ្នកដែលទទួលនៅលើថ្ម គឺអស់អ្នកដែលកាលណាឮព្រះបន្ទូលហើយនោះក៏ទទួលដោយអំណរ តែគ្មានចាក់ឫសសោះ គេជឿនៅតែមួយស្របក់ប៉ុណ្ណោះ លុះកើតមានសេចក្តីល្បួង នោះគេរសាយចិត្តទៅវិញ។" លូកា 8:13**

គ្រីស្ទាន៖ អីចឹង តើឥលូវអ្នកជាអ្វីដែរ?

អ្នកបែរថយក្រោយ៖ ពេលនេះខ្ញុំជាមនុស្សម្នាក់ដែលវេទនាម្នាក់ ខ្ញុំត្រូវបានឃុំឃាំងនៅក្នុងវា ប្រៀបដូចជាទ្រុងដែកនេះ។ ខ្ញុំមិនអាចចេញក្រៅបានទេ។ ពេលនេះ ខ្ញុំមិនអាចចេញរួចឡើយ!"

គ្រីស្ទាន៖ តែតើអ្នកស្ថិតនៅក្នុងស្ថានភាពបែបនេះបានយ៉ាងដូចម្ដេច?

អ្នកបែរថយក្រោយ៖ ខ្ញុំបានចាកចេញទៅដើម្បីនឹងមើលហើយបានសម្រាក។ ខ្ញុំបានដាក់ការសោយរាជ្យនៅលើកនៃសេចក្ដីតណ្ហារបស់ខ្ញុំ។ ខ្ញុំបានធ្វើបាបទាស់នឹងពន្លឺនៃលោកិយ និងសេចក្ដីសប្បុរសរបស់ព្រះ។ ខ្ញុំបានធ្វើឱ្យព្រះវិញ្ញាណព្រួយ ហើយទ្រង់ក៏បានចាកចេញទៅ។ ខ្ញុំបានល្បួងដល់អារក្ស ហើយវាបានមកឯខ្ញុំ។ ខ្ញុំបានធ្វើឱ្យព្រះខ្ញាល់ ហើយទ្រង់បានចាកចោលខ្ញុំ។ ខ្ញុំបានធ្វើចិត្តរឹងយ៉ាងខ្លាំង រហូតដល់ខ្ញុំមិនអាចនឹងប្រែចិត្តបាន។

បន្ទាប់មកគ្រីស្ទានបាននិយាយទៅកាន់អ្នកបកស្រាយថា "ប៉ុន្តែតើមិនមានសេចក្ដីសង្ឃឹមសម្រាប់មនុស្សដូចនេះទេឬយ៉ាងណា?" អ្នកបកស្រាយនិយាយថា "ចូរសួរគាត់ទៅ"

អ្នកបែរថយក្រោយ៖ ទេ គ្មានសោះឡើយ។

គ្រីស្ទាន៖ ហេតុអ្វីទៅ? បុត្ររបស់អ្នកមានពរគួរឱ្យអាណិតណាស់។

អ្នកបែរថយក្រោយ៖ ខ្ញុំបានឆ្កាងទ្រង់ទៅកាន់ខ្លួនខ្ញុំជាថ្មីម្ដងទៀត។

"រួចធ្លាក់ទៅវិញ នោះគ្មានផ្លូវណានឹងនាំឱ្យគេប្រែចិត្តម្តងទៀតទេ ដោយព្រោះគេបានឆ្កាងព្រះរាជ្យបុត្រានៃព្រះ ខាងឯខ្លួនគេរួចទៅហើយ ព្រមទាំងធ្វើឱ្យទ្រង់ហាលមុខនៅកណ្តាលជំនុំផង។" ហេព្រើរ 6:6

ខ្ញុំបានមើលថោកដល់រូបអង្គទ្រង់

"ប៉ុន្តែពួកអ្នកស្រុករបស់លោក គេស្អប់លោកណាស់ ក៏ចាត់សារឱ្យទៅតាមក្រោយលោក ទូលថា យើងរាល់គ្នាមិនចង់ឱ្យមនុស្សនេះសោយរាជ្យលើយើងទេ។" លូកា 19:14

ខ្ញុំបានមើលថោកដល់សេចក្តីសុចរិតរបស់ទ្រង់។ ខ្ញុំបានរាប់ព្រះលោហិតទ្រង់ជារបស់ដែលមិនបរិសុទ្ធ។ ខ្ញុំបានធ្វើការជំនួសឱ្យព្រះគុណរបស់ព្រះវិញ្ញាណ។

"ដ្បិតក្រោយដែលយើងបានទទួលស្គាល់សេចក្តីពិតហើយ បើយើងធ្វើបាបស្ម័គ្រពីចិត្តទៀត នោះគ្មានយញ្ញបូជាណាសម្រាប់នឹងលោះបាបទៀតទេ។ មានតែរង់ចាំ ដោយស្ញែងខ្លាចចំពោះសេចក្តីជំនុំជម្រះ និងសេចក្តីសហ័សនៃភ្លើង ដែលរៀបនឹងឆេះដល់អស់ទាំងពួកទាស់ទទឹងផងប៉ុណ្ណោះ។ ឯអ្នកណាដែលក្បត់ក្រឹត្យវិន័យលោកម៉ូសេ នោះបានត្រូវស្លាប់ឥតប្រណី ដោយសេចក្តីបន្ទាល់របស់មនុស្ស២ឬ៣នាក់ ចុះតើអ្នករាល់គ្នាស្មានថាគេគួរមានទោសជាធ្ងន់ជាងយ៉ាងណាទៅ ដែលគេជាន់ឈ្លីព្រះរាជបុត្រានៃព្រះ ទាំងរាប់ព្រះលោហិតនៃសេចក្តីសញ្ញា ដែលបានញែកគេចេញជាបរិសុទ្ធ

**ទុកដូចជារបស់ប្រើធម្មតា ហើយត្មះតិះដៀលដល់ព្រះវិញ្ញាណដ៏មានព្រះគុណផងនោះ” ហេព្រើរ 10:26-29**

ដូច្នេះខ្ញុំបានបាំងខ្លួនខ្ញុំចេញពីគ្រប់ទាំងសេចក្ដីសន្យាទាំងអស់ ហើយឥឡូវមិនមានអ្វីដែលសល់សម្រាប់ខ្ញុំឡើយក្រៅពីសេចក្ដីគម្រាមកំហែង ដែលគួរភ័យខ្លាច ការព្រមានដែលគួរឱ្យខ្លាចពីសេចក្ដីជំនុំជំរះនិងសេចក្ដីក្រោធយ៉ាងខ្លាំង ដែលនឹងត្របាក់លេបខ្ញុំដូចជាសត្រូវ។

គ្រីស្ទាន៖ តើអ្នកយកខ្លួនមកដល់សភាពបែបនេះសម្រាប់អ្វីទៅ?

អ្នកបែរថយក្រោយ៖ សម្រាប់តណ្ហា ការសប្បាយ និងផលប្រយោជន៍នៅក្នុងលោកិយនេះ នៅក្នុងការសប្បាយនឹងអ្វីដែលធ្វើឱ្យខ្ញុំមានអំណរយ៉ាងខ្លាំង តែពេលនេះការនីមួយៗទាំងនោះបានខាំខ្ញុំ ទាំងគ្របហឹមដាក់ខ្ញុំដូចជាដង្កូវដែលឆេះអីចឹង។

គ្រីស្ទាន៖ តើពេលនេះអ្នកមិនអាចប្រែចិត្តហើយវិលត្រឡប់វិញទេឬយ៉ាងណា?

អ្នកបែរថយក្រោយ៖ ព្រះបានបដិសេធការប្រែចិត្តរបស់ខ្ញុំហើយ។ ព្រះបន្ទូលរបស់ទ្រង់មិនបានលើកទឹកចិត្តឱ្យបានជឿឡើយ។ ពិតណាស់ ទ្រង់បានឃុំខ្ញុំនៅក្នុងទ្រុងដែកនេះ ក៏គ្មានមនុស្សនៅក្នុងលោកិយណាដែលអាចឱ្យខ្ញុំចេញបានឡើយ។ អូ ភាពអស់កល្បជានិច្ចអើយ! ភាពអស់កល្បអើយ! តើខ្ញុំដោះស្រាយយ៉ាងណាជាមួយនឹងសេចក្ដីលំបាកវេទនា ដែលខ្ញុំនឹងត្រូវជួបនៅអស់កល្បជានិច្ចនោះ?

អ្នកបកស្រាយ៖ បន្ទាប់មកអ្នកបកស្រាយបាននិយាយទៅកាន់គ្រីស្ទានថា "សូមអ្នកចាំពីសេចក្តីវេទនារបស់បុរសនេះ ហើយតែងតែប្រយ័ត្នជារហូតទៅ។"

គ្រីស្ទាន៖ គ្រីស្ទាននិយាយថា "ពិតណាស់" "វាគួរឱ្យខ្លាចណាស់! ព្រះបានឱ្យខ្ញុំឃើញហើយបានធូរស្បើយ ហើយអធិស្ឋានថាខ្ញុំនឹងមិនជួបនឹងសេចក្តីវេទនាដូចជាបុរសនេះឡើយ។ លោកម្ចាស់អើយ តើមិនទាន់ដល់ពេលដែលខ្ញុំត្រូវទៅតាមផ្លូវទេឬពេលនេះ?"

អ្នកបកស្រាយ៖ ចាំរហូតដល់ខ្ញុំនឹងបង្ហាញការមួយទៀតដល់អ្នក ហើយបន្ទាប់មកអ្នកនឹងទៅតាមផ្លូវរបស់អ្នកបាន។

ដូច្នេះចាប់ដៃរបស់គ្រីស្ទានម្តងទៀត ហើយនាំគាត់ទៅក្នុងបន្ទប់ ដែលមានមនុស្សម្នាក់កំពុងងើបពីលើគ្រែ ហើយនៅពេលដែលគាត់ពាក់សំលៀកបំពាក់របស់គាត់ គាត់ញ័រញ័រ។ បន្ទាប់មកគ្រីស្ទាននិយាយថា "ហេតុអ្វីបានជាបុរសនោះញ័រញ័របែបនេះ?" អ្នកបកប្រែបានប្រាប់បុរសនោះឱ្យប្រាប់ដល់គ្រីស្ទានពីហេតុផលដែលគាត់ធ្វើបែបនោះ។ ដូច្នេះគាត់ក៏ចាប់ផ្តើមប្រាប់ "យប់នេះ កាលដែលខ្ញុំកំពុងដេក ខ្ញុំសុបិន្តឃើញ មេឃក្លាយទៅជាខ្មៅយ៉ាងខ្លាំង ហើយមានរន្ទះ និងផ្លេកបន្ទោរដែលគួរឱ្យភ័យខ្លាច ដែលវាបានធ្វើឱ្យខ្ញុំមានសេចក្តីវេទនាយ៉ាងខ្លាំង។ ដូច្នេះខ្ញុំបានមើលនៅក្នុងសុបិន្តរបស់ខ្ញុំ ឃើញសសរពពកនៅក្នុងកម្រិតមួយដែលមិនធម្មតា នៅខាងវាមានសម្លេងត្រែយ៉ាងអស្ចារ្យមួយ ហើយបានឃើញបុរសដែលអង្គុយនៅលើពពក មានអ្នកហែរហមរាប់ពាន់ពីស្ថានសួគ៌។ ពួកគេទាំងអស់នៅក្នុងភ្លើងដែលកំពុងឆេះ

ហើយស្ថានសួគ៌កំពុងនៅលើភ្លើងឆេះដែរ។ ហើយខ្ញុំឮសម្លេងមួយនិយាយថា "ចូរក្រោកឡើង ឱមនុស្សស្លាប់អើយ ហើយមកកាន់សេចក្តីជំនុំជំរះ" ហើយថ្មក៏រមៀលចេញ ហើយផ្នូរក៏បើកឡើង ហើយមនុស្សស្លាប់បានចេញមក។"

"កុំឲ្យឆ្ងល់ពីសេចក្តីនេះឡើយ ដ្បិតមានពេលវេលាមក ដែលអស់ទាំងខ្មោចនៅក្នុងផ្នូរនឹងឮសំឡេងទ្រង់ ហើយនិងចេញមក" យ៉ូហាន 5:28

"បើសិនជាបានផ្សាយដំណឹងល្អពីព្រះគ្រីស្ទថា ទ្រង់មានព្រះជន្មរស់ពីស្លាប់ឡើងវិញហើយ នោះធ្វើដូចម្តេចឲ្យពួកអ្នករាល់គ្នាខ្លះ និយាយបាន ថាពួកស្លាប់មិនរស់ឡើងវិញទេ។ បើសិនជាពួកស្លាប់មិនរស់ឡើងវិញមែន នោះព្រះគ្រីស្ទក៏មិនបានរស់ឡើងវិញដែរ។ ហើយបើព្រះគ្រីស្ទមិនបានរស់ឡើងវិញ នោះដំណឹងដែលយើងខ្ញុំផ្សាយនេះ ជាការឥតប្រយោជន៍ទទេ ហើយសេចក្តីជំនឿរបស់អ្នករាល់គ្នា ក៏ឥតអំពើដែរ។ ឈ្មោះថាយើងខ្ញុំជាស្មរបន្ទាល់ក្លែងក្លាយពីព្រះវិញ ដ្បិតយើងខ្ញុំបានធ្វើបន្ទាល់ពីព្រះថា ទ្រង់បានប្រោសឲ្យព្រះគ្រីស្ទរស់ឡើងវិញហើយ តែបើពួកស្លាប់មិនរស់ឡើងវិញមែន នោះប្រាកដជាទ្រង់មិនបានប្រោសឲ្យព្រះគ្រីស្ទរស់ឡើងវិញពិត។ ដ្បិតបើសិនជាពួកស្លាប់មិនរស់ឡើងទេ នោះព្រះគ្រីស្ទក៏មិនបានរស់ឡើងដែរ។ ហើយបើព្រះគ្រីស្ទមិនបានរស់ឡើងវិញមែន នោះសេចក្តីជំនឿរបស់អ្នករាល់គ្នាក៏ជាការឥតអំពើ អ្នករាល់គ្នានៅក្នុងអំពើបាបនៅឡើយ។ ហើយអស់អ្នកដែលបានដេកលក់ទៅក្នុងព្រះគ្រីស្ទ គេបានត្រូវវិនាសហើយ។ បើសិនជាយើងមានទីសង្ឃឹមក្នុងព្រះគ្រីស្ទ នៅតែក្នុងជីវិតនេះប៉ុណ្ណោះ នោះយើងវេទនា លើសជាងមនុស្សទាំងអស់ទៅទៀត។" កូរិនថូស ទី១ 15:12-19

“ដ្បិតព្រះបន្ទូលនៃព្រះអម្ចាស់បានផ្សាយចេញពីអ្នករាល់គ្នា មិនមែនតែក្នុងស្រុកម៉ាសេដូន និងស្រុកអាខៃប៉ុណ្ណោះទេ គឺរហូតដល់គ្រប់ទាំងកន្លែង ដែលឮនិយាយពីសេចក្ដីជំនឿរបស់អ្នករាល់គ្នាចំពោះព្រះថែមទៀតផង បានជាមិនចាំបាច់ឲ្យយើងខ្ញុំនិយាយអ្វីទៀតទេ” **ថែស្សាឡូនិច ទី១ 1:8**

“ដើម្បីនឹងកាត់ទោសដល់គ្រប់មនុស្សទាំងឡាយ ហើយនិងរំឭកពួកទមិឡល្មើសទាំងអម្បាលម៉ាន ឲ្យដឹងខ្លួនពីគ្រប់ទាំងការទមិឡល្មើស ដែលគេបានប្រព្រឹត្តធ្វើ ដោយចិត្តល្មើស ហើយពីអស់ទាំងសេចក្ដីរឹងទទឹងទាំងប៉ុន្មាន ដែលអស់ពួកទមិឡល្មើសដ៏មានបាបទាំងនោះ បានពោលទាស់នឹងទ្រង់” **យូដាស 15**

“ខ្ញុំក៏ឃើញបល្ល័ង្កស១យ៉ាងធំ និងព្រះអង្គដែលគង់លើ ឯផែនដី និងផ្ទៃមេឃក៏រត់ពីចំពោះទ្រង់ចេញ ឥតឃើញមានកន្លែងណាឲ្យនៅទៀតឡើយ។ នោះខ្ញុំឃើញមនុស្សស្លាប់ ទាំងអ្នកធំ ទាំងអ្នកតូច គេឈរនៅចំពោះព្រះ បញ្ជីក៏បានបើកឡើង ហើយបញ្ជី១ទៀត គឺជាបញ្ជីជីវិតបានបើកឡើងដែរ រួចមនុស្សស្លាប់ទាំងអស់ត្រូវជំនុំជម្រះ ពីសេចក្ដីដែលកត់ទុកក្នុងបញ្ជីទាំងនោះ តាមអំពើដែលគេបានប្រព្រឹត្តរៀងខ្លួន។ ឯសមុទ្រ នោះបានប្រគល់ពួកមនុស្សស្លាប់ ដែលនៅក្នុងទឹកមកវិញ ហើយសេចក្ដីស្លាប់ និងស្ថានឃុំព្រលឹងមនុស្សស្លាប់ ក៏ប្រគល់ពួកមនុស្សស្លាប់ ដែលនៅឯណោះមកវិញដែរ រួចគេត្រូវជំនុំជម្រះ តាមអំពើដែលគេបានប្រព្រឹត្តរៀងខ្លួន។ ចំណែកសេចក្ដីស្លាប់ និងស្ថានឃុំព្រលឹងមនុស្សស្លាប់ នោះត្រូវបោះទៅក្នុងបឹងភ្លើងដែរ នេះជាសេចក្ដីស្លាប់ទី២” **វិវរណៈ 20:11-14**

មួយចំនួននៅក្នុងពួកគេមានសេចក្តីអំណរខ្លាំងណាស់ ហើយបានមើលទៅលើ។ ហើយអ្នកខ្លះទៀតបានពួននៅខាងក្រោមភ្នំ។ បន្ទាប់មកខ្ញុំបានឃើញបុរសដែលបានអង្គុយនៅលើពពកបើកសៀវភៅ ហើយប្រាប់លោកិយឱ្យខិតមកជិត។

"ព្រះ គឺជាព្រះដ៏មានឥទ្ធិឫទ្ធិ ព្រះនាមជាព្រះយេហូវ៉ា ទ្រង់បានមានព្រះបន្ទូលហើយ ទ្រង់បានកោះហៅទាំងអស់ដែលនៅលើផែនដី ចាប់តាំងពីទិសខាងថ្ងៃរះទៅដល់ទិសថ្ងៃលិច។ ព្រះទ្រង់បានភ្លឺមកពីក្រុងស៊ីយ៉ូន ដែលជាទីក្រុងមានលំអដ៏គ្រប់លក្ខណ៍។ ព្រះនៃយើងខ្ញុំទ្រង់យាងមក ហើយមិននៅស្ងៀមទេ មានភ្លើងឆេះនៅចំពោះទ្រង់ ហើយនៅព័ទ្ធជុំវិញទ្រង់មានព្យុះសង្ឃរា" ទំនុកដំកើង 50:1-3

"ដ្បិតមើល ព្រះយេហូវ៉ាទ្រង់យាងចេញពីស្ថានរបស់ទ្រង់មក ដើម្បីនឹងសម្រេចទោសដល់មនុស្សនៅផែនដី ដោយព្រោះអំពើទុច្ចរិតរបស់គេ ឯដីនឹងបើកបង្ហាញឈាមគេឲ្យឃើញ ឥតគ្របបាំងមនុស្សដែលត្រូវគេសម្លាប់ទៀតឡើយ។" អេសាយ 26:21

"អស់ទាំងសាសន៍នឹងឃើញ ហើយនិងឡើងមុខស្លាំង ដោយព្រោះឥទ្ធិឫទ្ធិរបស់គេ ពួកទាំងនោះនឹងដាក់ដៃខ្ទប់មាត់ ហើយត្រចៀកគេនឹងត្រូវថ្លង់ទៅដែរ។ គេនឹងលិទ្ធធូលីដីដូចជាពស់ គេនឹងញាប់ញ័រចេញពីទីមាំមួនរបស់គេ គឺដូចជាសត្វលូនវារនៅផែនដីចេញពីរន្ធ គេនឹងមកឯព្រះយេហូវ៉ាជាព្រះនៃយើង ដោយកោតខ្លាច ហើយនិងភិតភ័យដោយព្រោះឯង។" មីកា 7:16, 17

ដោយមានអណ្តាតភ្លើងខ្លាំងដែលចេញមកនៅចំពោះទ្រង់ ដែលនៅចន្លោះល្អងរវាងទ្រង់នឹងពួកគេ ដូចជាចន្លោះរវាងចៅក្រមនិងអ្នកទោសនៅក្នុងគុក។

"ខ្ញុំក៏គន់មើល ទាល់តែមានគេយកបល្ល័ង្កមកតាំង ហើយព្រះដ៏មានព្រះជន្មពីចាស់បុរាណ ទ្រង់ក៏គង់លើ ព្រះពស្ត្រទ្រង់សស្គុសដូចហិមៈ ហើយព្រះកេសនៅព្រះសិរទ្រង់ ក៏សដូចរោមចៀមយ៉ាងស្អាត ឯបល្ល័ង្កទ្រង់ នោះសុទ្ធតែជាអណ្តាតភ្លើង ហើយកង់នៃបល្ល័ង្កនោះ ក៏ជាភ្លើងឆេះដែរ។ មានដូចជាភ្លើងហូរចេញពីចំពោះទ្រង់មក មានទាំងពាន់ទាំងពាន់ដែលគោរពដល់ទ្រង់ ហើយទាំង ម៉ឺនទាំងសែនក៏ឈរនៅចំពោះទ្រង់ នោះការវិនិច្ឆ័យបានរៀបចំជាស្រេច ឯបញ្ជីទាំងប៉ុន្មានបានបើកឡើងហើយ" ដានីយ៉ែល 7:9-10

"តែមានអ្នកឯណាធន់នៅបាន ក្នុងកាលដែលទ្រង់យាងមកនោះ តើអ្នកណានឹងឈរនៅ ក្នុងកាលដែលទ្រង់លេចមក ដ្បិតទ្រង់ប្រៀបដូចជាភ្លើងរបស់ជាងសំរង ហើយដូចជាក្បុងរបស់ជាងប្រមោក។ ទ្រង់នឹងគង់ចុះ ដូចជាជាងសំរង ហើយនិងដេញអាចម៍ប្រាក់ ទ្រង់នឹងសម្អាតពួកកូនចៅលេវី ហើយសំរងគេដូចជាមាស ហើយនិងប្រាក់ នោះគេនឹងថ្វាយតង្វាយដល់ព្រះយេហូវ៉ា ដោយសេចក្តីសុចរិត" ម៉ាឡាគី 3:2, 3

ខ្ញុំបានព្រប្រកាសទៅកាន់ពួកគេដែលមកកាន់បុរសដែលអង្គុយនៅលើពពកថា "ចូរប្រមូលអង្កាម និងចំបើងមក ហើយទម្លាក់ពួកគេទោក្នុងបឹងភ្លើងទៅ។"

“ទ្រង់កាន់ចង្អេរនៅព្រះហស្ត ទ្រង់នឹងបោសរំលីងទីលានទ្រង់ ហើយនិងប្រមូលស្រូវទ្រង់ មកដាក់ក្នុងជង្រុក តែអង្កាម ទ្រង់នឹងដុតក្នុងភ្លើងដែលពន្លត់មិនបានវិញ។” **ម៉ាថាយ 3:12**

“ទុកឲ្យវាដុះជាមួយគ្នា ដរាបដល់ពេលច្រូតចុះ ចាំដល់រដូវចម្រូត នោះអញនឹងប្រាប់ពួកចម្រូតថា ចូរច្រូតស្រងែសិន ហើយចងជាកណ្តាប់ ទុកសម្រាប់ដុត ឯស្រូវសាលី ឲ្យប្រមូលដាក់ក្នុងជង្រុកអញវិញ។” **ម៉ាថាយ 13:30**

“ដ្បិតមើល ថ្ងៃនោះកំពុងតែមកដល់ ថ្ងៃនោះឆេះឆ្អៅ ដូចជាគុកភ្លើង នោះអស់ពួកអ្នកឆ្មើងឆ្មៃ ហើយនិងអស់ពួកអ្នកដែលប្រព្រឹត្តអំពើអាក្រក់ គេនឹងដូចជាជញ្ជ្រាំង ហើយថ្ងៃដែលត្រូវមកដល់នោះ នឹងឆេះបន្សុសគេទាំងអស់ទៅ ឥតទុកឲ្យគេមានឫស ឬមែកនៅសល់ឡើយ នេះហើយ ជាព្រះបន្ទូលរបស់ព្រះយេហូវ៉ានៃពួកពលបរិវារ” **ម៉ាឡាគី 4:1**

ហើយជង្ហុកដែលគ្មានបាតនោះក៏បានបើកឡើងក្បែរកន្លែងដែលខ្ញុំឈរ នៅមាត់ជង្ហុកនោះមានចេញមក ដូចជា ផ្សែង ធ្យូងថ្មជាភ្លើង ជាមួយនឹងសម្លេងដ៏គួរឱ្យខ្លាច។ ក៏បាននិយាយទៅកាន់មនុស្សដដែលនោះថា “ចូរប្រមូលស្រូវសាឡីរបស់អញដាក់ទៅក្នុងជង្រុកនោះទៅ។”

“ទ្រង់កាន់ចង្អេរនៅព្រះហស្ត ទ្រង់នឹងបោសរំលីងទីលានទ្រង់ ហើយនិងប្រមូលស្រូវមកដាក់ក្នុងជង្រុកទ្រង់ តែអង្កាម ទ្រង់នឹងដុតក្នុងភ្លើងដែលពន្លត់មិនបាន” **លូកា 3:17**

ដោយព្យុះផ្គរ នោះខ្ញុំបានឃើញមនុស្សជាច្រើនត្រូវបានលើកឡើងទៅក្នុងពពក។

"ព្រោះព្រះអម្ចាស់ទ្រង់នឹងយាងចុះពីស្ថានសួគ៌មក ដោយស្រែកបង្គាប់១ព្រះឱស្ឋ ទាំងមានឮសំឡេងមហាទេវតា និងត្រែរបស់ព្រះផង នោះពួកស្លាប់ក្នុងព្រះគ្រីស្ទនឹងរស់ឡើងវិញជាមុនបង្អស់។ រួចយើងរាល់គ្នាដែលកំពុងតែរស់នៅ ក៏នឹងបានលើកឡើង ទៅក្នុងពពកជាមួយគ្នាទាំងអស់ ដើម្បីឲ្យបានជួបជុំនឹងព្រះអម្ចាស់នៅនាអាកាស យ៉ាងនោះ យើងនឹងនៅជាមួយនឹងព្រះអម្ចាស់ជាដរាបទៅ" **ថែស្សាឡូនិច ទី១ 4:16, 17**

តែខ្ញុំត្រូវទុកឱ្យនៅវិញ។ ខ្ញុំក៏បានរកនឹងលាក់ខ្លួន តែខ្ញុំមិនអាចពួនបានឡើយ ដោយបុរសដែលអង្គុយនៅលើពពកនៅតែដាក់ភ្នែករបស់ទ្រង់សម្លឹងមកខ្ញុំ។ អំពើបាបរបស់ខ្ញុំបានចូលមកក្នុងគំនិតរបស់ខ្ញុំ ហើយសតិបញ្ញារបស់ខ្ញុំបានចោទប្រកាន់ខ្ញុំគ្រប់ជ្រុង។

"ពីព្រោះកាលណាពួកសាសន៍ដទៃ ដែលគ្មានក្រឹត្យវិន័យ គេបានប្រព្រឹត្តតាមក្រឹត្យវិន័យពីបវេណី នោះពួកដែលគ្មានក្រឹត្យវិន័យនោះឯង គេជាក្រឹត្យវិន័យដល់ខ្លួនគេវិញ។ ដោយសម្តែងថា របៀបក្រឹត្យវិន័យបានកត់ទុកក្នុងចិត្តគេហើយ បញ្ញាចិត្តគេក៏ធ្វើបន្ទាល់ឲ្យ ហើយគំនិតគេជួនកាលប្រកាន់ទោស ជួនកាលដោះសាគ្នាទៅវិញទៅមក)" **រ៉ូម 2:14, 15**

ដោយហេតុនោះខ្ញុំក៏បានភ្ញាក់ពីដេកទៅ។"

គ្រីស្ទានៈ ប៉ុន្តែតើអ្វីទៅដែលធ្វើឱ្យអ្នកភ័យខ្លាចនឹងរូបភាពនោះខ្លាំងម្ល៉េះ?

មិនទាន់រួចរាល់៖ ហេតុនោះគឺ ខ្ញុំបានគិតថាថ្ងៃនៃការជំនុំជំរះត្រូវបានមកដល់ ហើយថាខ្ញុំមិនទាន់រួចរាល់នូវឡើយ។ ប៉ុន្តែវាបានបន្លាចខ្ញុំយ៉ាងខ្លាំងដែលពួកទេវតាបានប្រមូលគ្នាមួយចំនួន ហើយបានចាកចោលខ្ញុំទៅ ហើយជង្ហុកនៃស្ថាននរកបានបើកមាត់របស់វានៅត្រង់កន្លែងដែលខ្ញុំឈរ។ សតិរបស់ខ្ញុំផង បានធ្វើទុកដល់ខ្ញុំ ហើយកាលដែលខ្ញុំគិត ចៅក្រមតែងតែចោលភ្នែកមកលើខ្ញុំ ដែលបង្ហាញពីទឹកមុខពេញដោយកំហឹងរបស់ទ្រង់។

បន្ទាប់មកអ្នកបកប្រែបាននិយាយទៅកាន់គ្រីស្ទានថា "តើអ្នកដែលគិតពិចារណាពីការទាំងនេះដែរទេ?"

គ្រីស្ទាន៖ បាទបាន ការនេះធ្វើឱ្យខ្ញុំមានសង្ឃឹមនិងសេចក្តីភ័យខ្លាចផង។

អ្នកបកស្រាយ៖ អីចឹង ចូររក្សាការទាំងនេះនៅក្នុងគំនិតរបស់អ្នកទៅ នោះនឹងបានធ្វើជាកន្លួសនៅក្បែរអ្នក ដើម្បីនឹងទាញអ្នកទៅមុខត្រង់តាមផ្លូវដែលអ្នកត្រូវទៅ។ បន្ទាប់មកគ្រីស្ទានចាប់ផ្តើមមូរដៃអាវរបស់គាត់ ដើម្បីរៀបចំខ្លួនធ្វើដំណើរទៅ។ អ្នកបកស្រាយបាននិយាយថា "អ្នកកំសាន្តចិត្តនឹងនៅជាមួយអ្នកជានិច្ច អ្នកគ្រីស្ទានល្អអើយ គេនឹងដឹកនាំអ្នកតាមផ្លូវទៅកាន់ទីក្រុងនោះ។"

ដូច្នេះគ្រីស្ទានបានទៅតាមរបស់គាត់ និយាយថា

"នៅទីនេះ ខ្ញុំបានឃើញការដែលកម្រនិងមានប្រយោជន៍ ការដែលអរសប្បាយ ការដែលគួរឱ្យភ័យខ្លាច ដែលធ្វើឱ្យខ្ញុំនៅនឹងនរក្នុងការអ្វីដែលខ្ញុំបានចាប់ផ្តើមចាប់មកក្នុងដៃ។ អីចឹងចូរឱ្យខ្ញុំគិតពីការទាំងនោះ ហើយយល់

ពីអ្វីដែលគេបានបង្ហាញដល់ខ្ញុំផង។ ហើយសូមឱ្យខ្ញុំចេះដឹងគុណផង ឱអ្នកបកស្រាយល្អអើយ!”

## ឈើឆ្កាង

ឥឡូវខ្ញុំបានឃើញនៅក្នុងសុបិន្តរបស់ខ្ញុំថា ផ្លូវធំដែលគ្រីស្ទានកំពុងដើរទៅត្រូវបានដាក់របងដោយជញ្ជាំងទាំងសងខាង ហើយរបងនោះត្រូវបានហៅថា "សេចក្តីសង្គ្រោះ។"

"នៅគ្រានោះគេនឹងច្រៀងបទនេះ នៅក្នុងស្រុកយូដា យើងមានទីក្រុងមួយដ៏មាំមួន ទ្រង់នឹងតម្រូវឱ្យមានសេចក្តីសង្គ្រោះ ទុកជាកំផែង ហើយជាទីការពារយើង។" អេសាយ 26:1

ដូច្នេះគ្រីស្ទានបានរត់តាមផ្លូវនោះដោយមានបន្ទុក ហើយការលំបាកយ៉ាងខ្លាំងដោយសារបន្ទុកនៅលើខ្នងរបស់គាត់។

គាត់បានរត់រហូតដល់គាត់បានមកដល់កន្លែងមួយដែលឡើងទៅលើ ហើយនៅលើនោះមានឈើឆ្កាងបញ្ឈរនៅទីនោះ ហើយនៅទាបបន្តិច នៅបាតមានផ្នូរមួយ។ ដូច្នេះខ្ញុំបានឃើញនៅក្នុងសុបិន្តរបស់ខ្ញុំថា គ្រាន់តែគ្រីស្ទានបានទៅដល់ឈើឆ្កាង បន្ទុករបស់គាត់បានរលាចេញពីស្មារបស់គាត់ ហើយធ្លាក់ចេញពីខ្នងរបស់គាត់ ហើយចាប់ផ្តើមដួលចុះ។ ហើយនៅតែធ្វើដូច្នេះរហូតទៅដល់មាត់ផ្នូរ នោះវាក៏បានធ្លាក់ចូលទៅខាងក្នុង ហើយខ្ញុំក៏លែងឃើញវាទៀតទៅ។

បន្ទាប់មកគ្រីស្ទានបានរីករាយ ហើយបានធូរស្រាល ក៏និយាយដោយចិត្តសប្បាយថា

"ទ្រង់បានប្រទានសេចក្តីសម្រាកដល់ខ្ញុំដោយសារសេចក្តីទុក្ខសោករបស់ទ្រង់ ហើយផ្តល់ជីវិតមកដោយសារការសុគតរបស់ទ្រង់។

បន្ទាប់មកគាត់បានឈរស្ងៀមមួយរយៈដើម្បីនឹងមើលនិងគិត ដោយសារវាគួរឱ្យភ្ញាក់ផ្អើលណាស់ដល់គាត់ ដែលរូបភាពនៃឈើឆ្កាងបានសម្រាលដល់បន្ទុករបស់គាត់។ ដូច្នេះគាត់បានសម្លឹងមើល ហើយមើលទៀត រហូតទាល់តែមានប្រភពទឹកដែលចេញពីក្បាលរបស់គាត់ហូរចុះរហូតដល់ថ្ពាល់របស់គាត់។

**"អញនឹងចាក់និស្ស័យមកលើពួកវង្សដាវីឌ និងពួកអ្នកនៅក្រុងយេរូសាឡិម ឱ្យគេមានចិត្តប្រកបដោយគុណ និងសេចក្តីទូលអង្វរ នោះគេនឹងគន់មើលអ្នកដែលគេបានចាក់ ហើយគេនឹងយំសោកនឹងអ្នកនោះ ដូចជាយំសោកនឹងកូនខ្លួនតែមួយ គេនឹងយំខ្សឹកខ្សួលនឹងអ្នកនោះ ដូចជាយំនឹងកូនច្បងរបស់ខ្លួន។" សាការី 12:10**

ពេលនេះ ពេលគាត់ឈរមើលហើយយំ មើលមនុស្សចែងចាំងបីនាក់បានមកកាន់គាត់ ហើយរាក់ទាក់គាត់ថា "សូមឱ្យសេចក្តីសុខសាន្តនៅជាមួយអ្នក!" អ្នកទីមួយក៏និយាយទៅគាត់ថា "អំពើបាបរបស់អ្នកត្រូវបានអត់ទោសឱ្យអ្នកហើយ។"

**"ព្រះយេស៊ូវក៏ឃើញសេចក្តីជំនឿរបស់អ្នកទាំងនោះ ហើយទ្រង់ក៏មានបន្ទូលទៅអ្នកស្លាប់ដៃស្លាប់ជើងថា កូនអើយ បាបរបស់ឯងបានអត់ទោសឱ្យឯងហើយ។" ម៉ាកុស 2:5**

អ្នកទីពីរបានសម្រាតកន្ទបរបស់គាត់ចេញ ហើយបំពាក់គាត់ដោយសំលៀក បំពាក់ផ្សេង

**"ទ្រង់ក៏បង្គាប់ដល់ពួកដែលឈរនៅចំពោះទ្រង់ថា ចូរដោះសំលៀកបំពាក់ កខ្វក់ពីលោកចេញ រួចទ្រង់មានបន្ទូលដល់លោកថា មើលអញបានលើក ចោលអំពើទុច្ចរិតពីឯងចេញហើយ អញនឹងប្រដាប់ខ្លួនឯងដោយសំលៀក បំពាក់ដ៏រុងរឿងវិញ។" សាការី 3:4**

អ្នកទីបីក៏បានដាក់សញ្ញានៅលើថ្ងាស់របស់គាត់ ហើយបានឱ្យផ្ទាំងមូរមួយ ដែលមានត្រានៅលើវា

**"ឯអ្នករាល់គ្នាក៏បានឮព្រះបន្ទូលនៃសេចក្ដីពិត គឺជាដំណឹងល្អពីសេចក្ដីស ង្គ្រោះរបស់អ្នករាល់គ្នាដោយសារទ្រង់ដែរ នោះទ្រង់ក៏ដៅចំណាំដោយព្រះ វិញ្ញាណបរិសុទ្ធដែលបានសន្យា។" អេភេសូ 1:3**

ដែលគាត់បានប្រាប់គាត់ឱ្យមើលទៅមុខពេលដែលគាត់រត់ទៅ ហើយថា គាត់គួរតែលះបង់ខ្លួននៅឃ្លោងទ្វារស្ថានសួគ៌។ ដូច្នេះពួកគេបានទៅតាមផ្លូវ របស់ពួកគេ។ រួចមកគ្រីស្ទានបានលោតដោយអំណរបីដង ហើយដើរទៅ ទាំងច្រៀងបណ្ដើរផង។

"តាំងពីខ្ញុំចេញមក ខ្ញុំបានមកជាមួយនឹងអំពើបាបរបស់ខ្ញុំ ហើយក៏មិនអាច នឹងសម្រាលដល់សេចក្ដីព្រួយដែលខ្ញុំមានដែរ រហូតទាល់តែខ្ញុំបានមកដល់ ទីនេះ។ តើនេះជាកន្លែងដ៏អស្ចារ្យយ៉ាងហ្ន៎! នេះគួរតែជាការចាប់ផ្ដើមនៃសេច ក្ដីអំណររបស់ខ្ញុំ! ទីនេះជាទីដែលបន្ទុកត្រូវធ្លាក់ចេញពីខ្នងរបស់ខ្ញុំ! ទីនេះជា

ខ្សែរដែលចងការបាក់បែករបស់ខ្ញុំ! សូមថ្វាយព្រះពរដល់ឈើឆ្កាង! សូមសរសើរដល់ផ្នូរ! សូមថ្វាយពរដល់មនុស្សម្នាក់ដែលនៅទីនោះ ដែលត្រូវអាម៉ាស់ជំនួសខ្ញុំ!"

## មនុស្សល្ងង់ មនុស្សខ្ជិល និងមនុស្សសន្មត់

ខ្ញុំបានឃើញនៅក្នុងសុបិន្តរបស់ខ្ញុំ ថាគាត់បានដើរទៅរហូតដល់បាត ជាកន្លែងដែលគាត់បានឃើញ ដូចជារាងចេញពីផ្លូវបន្តិច មានមនុស្សបីនាក់បានឆាប់ដេកលក់ មានច្រវ៉ាក់នៅជាប់កែងជើងរបស់ពួកគេ។ ម្នាក់ឈ្មោះលោកល្ងង់ ម្នាក់ទៀតឈ្មោះកំជិល និងម្នាក់ទៀត លោកសម្មត់។

កាលដែលគ្រីស្ទានឃើញពួកគេដេកបែបនេះ ក៏ទៅរកពួកគេ ប្រហែលជាគាត់អាចនឹងដាស់ពួកគេឱ្យភ្ញាក់ ហើយក៏ស្រែកថា "អ្នកដូចជាពួកគេដែលដេកនៅលើសសរមួយអីចឹង ដោយសារសមុទ្រក្រហមនៅខាងក្រោមអ្នកជាជង្ហុកដែលគ្មានបាត។"

**"អើ ឯងនឹងបានដូចជាមនុស្សដែលដេកនៅកណ្តាលសមុទ្រ ឬដូចជាមនុស្សដែលដេកនៅលើចុងដងក្តោង។" សុភាសិត 23:34**

ចូរភ្ញាក់ឡើងហើយចេញមក ហើយឱ្យបានស្ម័គ្រចិត្តផង នោះខ្ញុំនឹងជួយអ្នកឱ្យរួចពីដែករបស់អ្នក។ គាត់ក៏បានប្រាប់ដល់ពួកគេថា "ប្រសិនបើម្នាក់ដែលដើរក្រវែលទាំងគ្រហឹមដូចសត្វសិង្ហមកក្បែរ នោះអ្នកនឹងក្លាយទៅជាចំណីដល់ធ្មេញរបស់វាមិនខាន។"

**"ចូរឱ្យដឹងខ្លួន ហើយចាំយាមចុះ ព្រោះអារក្ស ដែលជាខ្មាំងសត្រូវរបស់អ្នករាល់គ្នា វាតែងដើរក្រវែល ទាំងគ្រហឹមដូចជាសិង្ហ ដើម្បីនឹងរកអ្នកណាដែលវានឹងត្របាក់លេបបាន។" ពេត្រុស ទី១ 5:8**

នោះពួកគេបានសម្លឹងមកមើលគាត់ ហើយបានឆ្លើយបែបនេះ

មនុស្សល្ងង់បាននិយាយថា "ខ្ញុំមើលមិនឃើញគ្រោះថ្នាក់សោះ។"

មនុស្សកំជិលនិយាយថា "មិនទាន់នៅឡើយ ដេកបន្តិចទៀតសិន។"

និង មនុស្សដែលសន្មត់បាននិយាយថា "ធុងទឹកនីមួយៗត្រូវតែឈរនៅលើបាតរបស់វា។"

ហើយពួកគេក៏ផ្ដេកខ្លួនដេកម្ដងទៀតទៅ ហើយគ្រីស្ទានក៏ទៅតាមផ្លូវរបស់គាត់ទៅ។

## អ្នកផ្លូវការ និង សេចក្ដីកំពុត

តែគាត់មានការលំបាកដែលគិតថា មនុស្សដែលមានគ្រោះថ្នាក់គួរតែឱ្យតម្លៃដល់អ្នកដែលផ្ដល់ជំនួយដល់គាត់ដោយឥតគិតថ្លៃ ទាំងដាល់ពួកគេឱ្យភ្ញាក់ និងផ្ដល់ការព្រឹក្សាដល់ពួកគេ ហើយបានជួយយកដែករបស់គេចេញថែមទៀត។ ហើយនៅពេលដែលគាត់កំពុងតែពិបាកដោយការនោះ គាត់បានឃើញបុរសពីរនាក់ដែលបានមក បានដួលទៅលើជញ្ជាំង នៅខាងស្ដាំដៃនៃផ្លូវចង្អៀតនោះ ហើយពួកគេបានផ្សះផ្សាជាមួយគាត់យ៉ាងរហ័ស។ មានម្នាក់ឈ្មោះអ្នកផ្លូវការ ហើយម្នាក់ទៀតឈ្មោះថា សេចក្ដីកំពុត។ ដូច្នេះ ក្នុងកាលដែលខ្ញុំបាននិយាយនោះ ពួកគេបានខិតមកជិតគាត់ ជាអ្នកដែលបានចូលជជែកជាមួយនឹងពួកគេ។

គ្រីស្ទាន៖ សុភាពបុរសទាំងពីរអើយ តើអ្នកមកពីពេលណា ហើយតើអ្នកទៅណា?

អ្នកផ្លូវការ និង សេចក្ដីកំពុត៖ យើងបានកើតនៅក្នុងទឹកដែលនៃ សិរិល្អដែលឥតប្រយោជន៍ ហើយកំពុងទៅរកសេចក្ដីកោតសរសើរនៅភ្នំស៊ីយ៉ូន។

គ្រីស្ទាន៖ ហេតុអ្វីបានជាអ្នកមិនមកតាមឃ្លោងទ្វារដែលឈរនៅដើមផ្លូវ? តើអ្នកមិនបានដឹងការដែលបានសរសេរមកថា "អ្នកដែលមិនចូលតាមទ្វារទេ តែឡើងតាមផ្លូវណាផ្សេងទៀត នោះប្រៀបដូចជាចោរលួចចោរប្លន់ដែរ"?

**"ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នកណាដែលចូលទៅក្នុងក្រោលចៀម មិនមែនតាមទ្វារ គឺឡើងចូលតាមកន្លែងណាឯទៀតវិញ អ្នកនោះឈ្មោះថាជាចោរលួច ចោរប្លន់ហើយ" យ៉ូហាន 10:1**

អ្នកផ្លូវការ និង សេចក្តីកំពុត៖ ពួកគេនិយាយថា ការដែលទៅកាន់ឃ្លោងទ្វារនៃច្រកចូលនោះ មនុស្សនានាតែងតែគិតថាវាឆ្ងាយពេក ហើយដូច្នេះផ្លូវទូទៅដែលវាខ្លីជាងនោះ គឺជាការឡើងតាមជញ្ជាំងដូចដែលពួកគេបានធ្វើនោះឯង។

គ្រីស្ទាន៖ ប៉ុន្តែតើនេះមិនបានរាប់ថាជាការរំលងទាស់នឹងព្រះអម្ចាស់នៃទីក្រុងទេឬ ដែលយើងធ្វើខុសនឹងបំណងព្រះហឫទ័យរបស់ទ្រង់ដែលបង្ហាញមកនោះ?

អ្នកផ្លូវការ និង សេចក្តីកំពុត៖ ពួកគេបានប្រាប់គាត់ថាសម្រាប់ការនោះវិញទ្រង់មិនចាំបាច់នឹងរំខាងនឹងគិតពីការនោះទេ ដោយសារការដែលពួកគេបានធ្វើនោះជាទំលាប់ទៅហើយ ហើយអាចបង្កើត ប្រសិនបើត្រូវការទីបន្ទាល់ដែលអាចនឹងធ្វើបន្ទាល់ពីវា នោះមានច្រើនជាងមួយពាន់ឆ្នាំទៅទៀត។

គ្រីស្ទាន៖ "ប៉ុន្តែ" គ្រីស្ទានបាននិយាយថា "តើការអនុវត្តរបស់អ្នកនឹងអាចឈរបាននៅចំពោះច្បាប់បានទេ?"

អ្នកផ្លូវការ និង សេចក្តីកំពុត៖ ពួកគេបានប្រាប់គាត់ថា វាបានឈរដូចនេះលើសពីមួយពាន់ឆ្នាំទៅទៀត ទម្រាំមកដល់ពេលនេះនោះវានឹងត្រូវបានទទួលស្គាល់តាមច្បាប់ដោយចៅក្រមដែលមិនចេះលំអៀងរួចទៅហើយ។ ហើយក្រៅពីនោះ ពួកគេបាននិយាយថា ដូច្នេះយើងបានដើរតាមផ្លូវនេះ តើវាជាបញ្ហាអ្វីដែរ ដែលយើងចូលមកតាមផ្លូវមួយណានោះ? ប្រសិនបើយើងបានចូលខាងក្នុង នោះគឺនៅខាងក្នុងហើយ អ្នកកំពុងតែនៅលើផ្លូវហើយដែលយើងគិតថាអ្នកជាអ្នកដែលចូលតាមឃ្លោងទ្វារ ចំណែកពួកយើងក៏កំពុងតែនៅលើផ្លូវដែរ ដែលមកដោយធ្លាក់ពីលើជញ្ជាំងមក។ តើស្ថានភាពត្រង់ណារបស់អ្នកដែលប្រសើរជាងពួកយើងនោះ?

គ្រីស្ទាន៖ ខ្ញុំបានដើរតាមក្រិត្យក្រមរបស់ម្ចាស់របស់ខ្ញុំ ឯអ្នកដើរតាមកិច្ចការដែលឈ្លើយនៃការគិតរបស់អ្នក។ អ្នកត្រូវបានព្រះអម្ចាស់នៃផ្លូវនេះរាប់ថាជាចោររួចទៅហើយ ដូច្នេះខ្ញុំគិតជាសង្ស័យណាស់ថាអ្នកនឹងមិនត្រូវបានរកឃើញថាជាមនុស្សពិតនៅពេលដល់ទីបំផុតនៃផ្លូវនេះ។ អ្នកចូលមកដោយខ្លួនអ្នកដោយមិនមានការប្រាប់ផ្លូវពីទ្រង់ ហើយអ្នកនឹងទៅដោយខ្លួនអ្នកដោយមិនមានសេចក្តីមេត្តារបស់ទ្រង់ដែរ។

ដោយការនេះពួកគេមិនបានឆ្លើយអ្វីច្រើនទេ តែពួកគេបានប្រាប់គាត់ឱ្យមើលខ្លួនឯងទៅ។ បន្ទាប់មកខ្ញុំឃើញថាម្នាក់ៗក៏ទៅតាមផ្លូវរបស់ខ្លួនទៅដោយមិនបាននិយាយជាមួយគ្នាទៅវិញទៅមកឡើយ ចូររក្សានូវការដែលអ្នកទាំងពីរបានប្រាប់ដល់គ្រីស្ទាន ដែលសម្រាប់ក្រឹត្យវិន័យនិងពិធីផ្សេងៗ ពួកគេមិនបានសង្ស័យអ្វីឡើយ ក្នុងកាលដែលពួកគេធ្វើការនោះដោយដឹងខ្លួនដូចជាគាត់ដែរ។ "ដូច្នេះ" ពួកគេបាននិយាយថា "យើងមិនបានឃើញថា

អ្នកបានលាក់សេចក្ដីអាម៉ាស់និងសេចក្ដីអាក្រាតរបស់អ្នកជាមួយនឹងអ្នកជិតខាងរបស់អ្នកឡើយ។"

គ្រីស្ទាន៖ ដោយក្រឹត្យវិន័យ និងពិធីផ្សេងៗ អ្នកនឹងមិនត្រូវបានសង្គ្រោះឡើយ ក្នុងកាលដែលអ្នកមិនបានចូលមកតាមទ្វារទេ។

**"យើងដឹងថា មនុស្សមិនបានរាប់ជាសុចរិត ដោយប្រព្រឹត្តតាមក្រឹត្យវិន័យនោះឡើយ គឺដោយសេចក្ដីជំនឿ ជឿដល់ព្រះយេស៊ូវគ្រីស្ទវិញ ហេតុនោះបានជាយើងជឿដល់ព្រះគ្រីស្ទយេស៊ូវ ដើម្បីឲ្យបានរាប់ជាសុចរិត ដោយសារសេចក្ដីជំនឿ ជឿដល់ព្រះគ្រីស្ទ នោះ មិនមែនដោយប្រព្រឹត្តតាមក្រឹត្យវិន័យទេ ពីព្រោះគ្មានមនុស្សណាបានរាប់ជាសុចរិតដោយប្រព្រឹត្តតាមក្រឹត្យវិន័យឡើយ"**
**កាឡាទី 2:16**

ហើយសម្រាប់អាវធំដែលនៅលើខ្នងរបស់ខ្ញុំនេះ ព្រះអម្ចាស់នៃកន្លែងដែលខ្ញុំទៅបានប្រទានមកខ្ញុំ ហើយគឺប្រើសម្រាប់នឹងគ្របបាំងសេចក្ដីអាក្រាតរបស់ខ្ញុំ ដែលអ្នកបាននិយាយនោះ។ ហើយខ្ញុំបានរាប់វាថាជាចំណែកមួយនៃសេចក្ដីសប្បុរសរបស់ទ្រង់មកកាន់ខ្ញុំ ដោយសារខ្ញុំមិនមានអ្វីសោះ មានតែកន្ទបកាលពីមុននោះ។ ហើយក្រៅពីនោះ ខ្ញុំបានកំសាន្តចិត្តរបស់ខ្ញុំកាលដែលខ្ញុំទៅនោះ។ ពិតណាស់ កាលមកដល់ឃ្លោងទ្វារនៃទីក្រុងខ្ញុំបានគិតថា ព្រះអម្ចាស់នឹងស្គាល់ខ្ញុំរាប់ជាការល្អ ក្នុងកាលដែលខ្ញុំមានអាវធំរបស់ទ្រង់នៅលើខ្នងរបស់ខ្ញុំ អាវធំដែលទ្រង់បានឱ្យដល់ខ្ញុំដោយឥតគិតថ្លៃនៅថ្ងៃដែលទ្រង់ដោះកន្ទបចេញពីខ្ញុំ។ ក្រៅពីនោះ ខ្ញុំមានសញ្ញានៅលើថ្ងាស់របស់ខ្ញុំដែលប្រហែលអ្នកមិនបានកត់សម្គាល់ទេ វាជាទំនាក់ទំនងមួយយ៉ាងជិត

ស្និតមួយរបស់ព្រះអម្ចាស់របស់ខ្ញុំ ដែលបានសម្រេចនៅថ្ងៃដែលបន្ទុករបស់ខ្ញុំបានធ្លាក់ចុះពីស្មាររបស់ខ្ញុំ។ បន្ថែមលើនោះ ខ្ញុំនឹងប្រាប់អ្នកទៀតថា មានគេប្រាប់ខ្ញុំថាខ្ញុំនឹងត្រូវបង្ហាញវានៅឃ្លោងទ្វារនៃទីក្រុងស្ថានសួគ៌ ជាទីសម្គាល់នៃការចូលខាងក្នុងពិតប្រាកដ ខ្ញុំឆ្ងល់ថាតើរបស់មួយណាដែលអ្នកចង់បាន ដោយសារអ្នកមិនបានចូលមកតាមឃ្លោងទ្វារទេ។

ដោយបែបនោះ ពួកគេមិនបានឆ្លើយតបទៅគាត់ទេ ពួកគេមើលមុខគ្នាទៅវិញទៅមកហើយសើច។ បន្ទាប់មកខ្ញុំឃើញថាពួកគេបន្តទៅមុខទៀត ហើយគ្រីស្ទានបានធ្វើដូចមុនដែរ គាត់មិននិយាយទៀតឡើយ តែនិយាយជាមួយខ្លួនឯង ហើយជូនកាលក៏ដល់ដង្ហើមធំ ហើយជាញឹកញាប់គាត់អានសារដែលបុរសភ្លឺថ្លៃចែងចាំងម្នាក់បានអោយគាត់ នោះគាត់ក៏បានស្រស់ស្រាយឡើយវិញ។

ខ្ញុំមើលទៅ ឃើញថាពួកគេបានមកដល់ជើងភ្នំ "សេចក្ដីលំបាក" នៅបានវាមានប្រភពទឹកមួយ។ ហើយនៅកន្លែងនោះមានផ្លូវពីរទៀតនៅក្បែរផ្លូវដែលត្រង់ចេញពីឃ្លោងទ្វារ ផ្លូវមួយបត់ទៅឆ្វេងដៃ ហើយផ្លូវមួយទៀតបត់ទៅស្តាំដៃនៅបាតភ្នំនោះ តែផ្លូវចង្អៀតលាតទៅត្រង់ឡើងភ្នំ (ឈ្មោះនៃការឡើងទៅលើភ្នំត្រូវបានហៅថា សេចក្ដីលំបាក)។ ពេលនេះគ្រីស្ទានបានទៅកាន់ប្រភពទឹក រួចផឹកដើម្បីនឹងជួយឱ្យបានស្រស់ស្រាយ។

**"គេនឹងមិនដែលស្រេកឃ្លានទៀត ឯចំហាយក្តៅ ឬព្រះអាទិត្យ នឹងមិនធ្វើទុក្ខគេ ដ្បិតព្រះដែលផ្តល់សេចក្តីមេត្តាដល់គេ ទ្រង់នឹងនាំគេទៅ អើ ទ្រង់នឹងដឹកដៃគេនាំទៅតាមទីមានក្បាលទឹក" អេសាយ 49:10**

ហើយក៏ចាប់ឡើងទៅលើកំពូលភ្នំដោយនិយាយថា

"ភ្នំនេះទោះជាខ្ពស់ក៏ដោយ ក៏ខ្ញុំនៅតែចង់ឡើងដែរ។ ខ្ញុំនឹងមិនរាថយដោយសារសេចក្ដីលំបាកឡើយ ដោយសារខ្ញុំយល់ថា ផ្លូវនៃជីវិតស្ថិតនៅទីនេះ។ ចូរមក ចូរតាំងចិត្តឡើង ចូរកុំដួលចុះ ឬភ័យខ្លាចឡើយ! ជាការដែលល្អប្រសើរដែលទៅតាមផ្លូវត្រូវ បើទោះជាលំបាកក៏ដោយ ជាជាងទៅតាមផ្លូវស្រួល តែទីបញ្ចប់ជាសេចក្ដីបណ្ដាសា។"

ពីរនាក់ទៀតក៏បានមកដល់ជើងភ្នំដែរ តែនៅពេលពួកគេបានឃើញថា ភ្នំនោះចោត ហើយខ្ពស់ទៀត ហើយកាលដែលមានផ្លូវពីរផ្សេងទៀតដើម្បីនឹងដើរទៅនោះ ហើយនិយាយថាផ្លូវពីរនេះនឹងទៅជួបទាន់ជាមួយនឹងផ្លូវដែលគ្រីស្ទានដើរដែរ ដែលនៅម្ខាងទៀតនៃភ្នំ ដូច្នេះសម្រេចថានឹងទៅតាមផ្លូវទាំងនោះ (ឥឡូវឈ្មោះរបស់ផ្លូវទាំងនោះគឺ "គ្រោះថ្នាក់" និងមួយទៀត "សេចក្ដីវិនាសអន្តរាយ")។ ដូចនេះម្នាក់បានជ្រើសយកផ្លូវដែលមានឈ្មោះថា "គ្រោះថ្នាក់" ដែលបានទៅកាន់ព្រៃមួយយ៉ាងធំ ហើយម្នាក់ទៀតបានដើរតាមផ្លូវនៃសេចក្ដីវិនាសអន្តរាយ ដែលនាំទៅកានទីវាលមួយយ៉ាងធំពេញដោយភ្នំងងឹតៗ ដែលគាត់បានជំពប់ដួលហើយងើបមិនរួចសោះ។

## ភ័យខ្លាច និង មិនទុកចិត្ត

ខ្ញុំបានមើលទៅកាន់គ្រីស្ទានដើរឡើងលើភ្នំ នៅពេលដែលខ្ញុំឃើញថាគាត់កំពុងតែធ្លាក់ពីការរត់ឡើង ហើយពីការដែលគាត់ស្រវាឡើងដោយដៃនិងជង្គង់របស់គាត់ ដោយសារតែកន្លែងនោះវាចោតពេក។ ឥឡូវប្រហែលមកដល់ពាក់កណ្ដាលផ្លូវទៅដល់កំពូលភ្នំមានកន្លែងសម្រាកមួយយ៉ាងល្អ ដែលព្រះអម្ចាស់នៃភ្នំនោះបានបង្កើតឡើង សម្រាប់ជាទ្រទ្រង់ដល់អ្នកធ្វើដំណើរដែលនឿយហត់។ ដូច្នេះគ្រីស្ទានបានទៅអង្គុយសម្រាកនៅទីនោះ។ បន្ទាប់មកគាត់បានទាញសារពីដើមទ្រូងរបស់គាត់មកអាននៅទីនោះដើម្បីជាការកំសាន្តចិត្តដល់គាត់។ ពេលនេះគាត់ក៏បានសង្កេតមើលអាវក្រៅរបស់គាត់ជាថ្មីម្ដងទៀត ជាអាវដែលមួយអង្គបានឱ្យមកគាត់ពេលគាត់បានឈរក្បែរឈើឆ្កាង។ ដូច្នេះក៏បានគាប់ចិត្តដល់ខ្លួនមួយរយៈ ហើយចុងក្រោយគាត់បានងោកងុយ ហើយក៏ដេកលក់ភ្លាមរហូតដល់ជិតយប់ ហើយកាលគាត់នៅដេកនៅឡើយសារនោះបានធ្លាក់ចេញពីដៃរបស់គាត់។ ឥឡូវកាលដែលកំពុងដេក មានម្នាក់បានមកហើយដាស់គាត់ដោយនិយាយថា "ចូរទៅកាន់សត្វស្រមោច ឱមនុស្សកំជិលអើយ ចូរពិចារណាហើយចូរមានប្រាជ្ញាចុះ។"

**"ឱមនុស្សខ្ជិលច្រអូសអើយ ចូរទៅមើលស្រមោចចុះ ចូរពិចារណាផ្លូវទាំងប៉ុន្មានរបស់វា ហើយមាន ប្រាជ្ញាឡើង" សុភាសិត 6:6**

ហើយដោយដូច្នោះ គ្រីស្ទានក៏បានក្រោកភ្លាម ហើយបានទៅតាមផ្លូវរបស់គាត់យ៉ាងលឿន ហើយទៅរហូតទាល់តែគាត់បានមកដល់កំពូលភ្នំ។

ពេលនេះគាត់បានមកដល់កំពូលភ្នំ ហើយមានបុរសពីរនាក់បានរត់មកប
ញ្រ្ចាស់ជាមួយគាត់ដោយកំហឹង។ ម្នាក់មានឈ្មោះថាភ័យខ្លាច និងម្នាក់
ទៀតឈ្មោះថា មិនទុកចិត្ត។ គ្រីស្ទានបាននិយាយទៅពួកគេថា "លោក
ម្ចាស់អើយ មានរឿងអ្វីដែរ? អ្នករត់ទៅខុសផ្លូវហើយ!"

ភ័យខ្លាចបានឆ្លើយថា ពួកគេកំពុងតែទៅកាន់ក្រុងសីយ៉ូន ហើយបានមក
ដល់កន្លែងលំបាក "តែ" គាត់និយាយថា "យើងទៅកាន់តែឆ្ងាយ យើងជួប
ការលំបាកកាន់តែច្រើន ដូច្នេះយើងបានត្រលប់មកវិញ ហើយកំពុងដើរទៅ
ក្រោយវិញ។"

មិនទុកចិត្ត បាននិយាយថា "បាទ" "ទៅមុខយើងបន្តិចមានសត្វតោដេកមួយ
ចំនួននៅតាមផ្លូវ មិនដឹងថាពួកវាដេកឬអត់នោះទេ ហើយយើងគិតមិនចេញ
ឡើយ ថាប្រសិនបើយើងមកជិតដល់ នោះពួកវានឹងហែកយើងទៅជាចំណែ
កៗភ្លាមៗនោះ។"

គ្រីស្ទានៈ បន្ទាប់មកគ្រីស្ទានបាននិយាយថា "អ្នកធ្វើឱ្យខ្ញុំខ្លាចហើយ តែ តើខ្ញុំ
គួរតែហោះទៅទីណាទើបមានសុវត្ថិភាពនោះ? ប្រសិនបើខ្ញុំត្រឡប់ទៅ
ប្រទេសរបស់ខ្ញុំវិញ នោះជាទីដែលទុកសម្រាប់នឹងភ្លើងឆេះនិងស្ពាន់ធ័រ
ហើយខ្ញុំនឹងត្រូវវិនាសយ៉ាងពិតប្រាកដនៅទីនោះ! ប្រសិនបើខ្ញុំអាចទៅដល់
ទីក្រុងស្ថានសួគ៌វិញ ខ្ញុំប្រាកដថានឹងមានសុវត្ថិភាពនៅទីនោះ។ ខ្ញុំត្រូវតែ
ប្រថុយទៅ។ បើត្រឡប់ទៅវិញ គឺមិនមានអ្វីក្រៅពីសេចក្ដីស្លាប់ឡើយ។ ទៅ
មុខជាសេចក្ដីភ័យខ្លាចនៃការស្លាប់និងជីវិតអស់កល្បជានិច្ចដែលលើសលប់

! ខ្ញុំនឹងដើរទៅមុខដដែល!"

## ដេកនៅពេលថ្ងៃ

ដូច្នេះមិនទុកចិត្ត និង ភ័យខ្លាចបានរត់ចុះពីភ្នំ ហើយគ្រីស្ទានបានទៅតាមផ្លូវរបស់គាត់ទៅ។ តែបានគិតពីអ្វីដែលគាត់បានឮពីបុរសទាំងពីរ គាត់ក៏ស្ទាបដើមទ្រូងរបស់គាត់រកមើលគម្ពីររបស់គាត់ ដើម្បីយកមកអាននិងទទួលបានការកំសាន្តចិត្ត តែគាត់មិនស្ទាបមិនប៉ះទេ។ បន្ទាប់មកគ្រីស្ទានមានទុកលំបាកយ៉ាងខ្លាំង ហើយមិនដឹងថាត្រូវធ្វើអ្វីទេ ដោយសារគាត់ចង់បានរបស់ដែលជួយឱ្យគាត់បានរសាយចិត្ត ដែលជាអ្វីដែលជួយឱ្យគាត់បានឆ្លងគាត់រហូតដល់ទីក្រុងស្ថានសួគ៌។ ដូច្នេះទីនេះ គាត់ចាប់ផ្តើមច្របូកច្របល់ ហើយមិនថាត្រូវធ្វើអ្វីទេ។ ជាចុងក្រោយគាត់បានគិតថាគាត់នឹងដេកនៅក្នុងទីសំណាក់ដែលនៅក្បែរភ្នំសិន ហើយគាត់បានលត់ជង្គង់ចុះ ហើយសុំការអត់ទោសមកពីព្រះសម្រាប់អំពើល្ងង់ខ្លៅរបស់គាត់ ហើយបន្ទាប់មកបានត្រឡប់ទៅរកសាររបស់គាត់វិញ។ តែតាមផ្លូវដែលគាត់ត្រឡប់ទៅវិញនោះ តើមានមនុស្សណាដែលអាចនឹងរៀបរាប់ឱ្យត្រឹមត្រូវពីសេចក្តីសោកសង្រេងនៅក្នុងចិត្តរបស់គ្រីស្ទានបានដែរទេ? ពេលខ្លះគាត់ក៏ដកដង្ហើមធំ ជួនកាលគាត់ទួញយំ ហើយជាញឹកញាប់គាត់បន្ទោសខ្លួនឯងដែលល្ងង់ទៅដេកលក់នៅកន្លែងដូចនោះ ជាកន្លែងដែលបានសង់ឡើងសម្រាប់ឱ្យបានធូរស្បើយតែបន្តិចពីការនឿយហត់ប៉ុណ្ណោះ។

ដូច្នេះគាត់ក៏បានត្រឡប់ទៅវិញ ហើយសម្លឹងរកកៀននេះកៀននោះដោយប្រយត្នតាមផ្លូវដែលគាត់ត្រឡប់ទៅវិញដោយថាប្រហែលគាត់អាចនឹងរកឃើញសាររបស់គាត់ ដែលធ្លាប់តែជាសេចក្តីកំសាន្តដល់គាត់ជាច្រើនដងនៅក្នុងការធ្វើដំណើររបស់គាត់។ គាត់ត្រឡប់ទៅវិញរហូតដល់គាត់ទៅដល់ទីកំណាក់ម្តងទៀតជាកន្លែងដែលគាត់បានអង្គុយហើយដេកលក់។ តែទីនោះបានធ្វើឱ្យគាត់មានក្តីទុក្ខថែមទៀត ដោយបានទាញយកអំពើអាក្រក់របស់គាត់ជាថ្មីមក ដែលបានដេកលក់នៅក្នុងគំនិតរបស់គាត់។ ដូច្នេះគាត់បានបន្តទៅមុនដោយស្តាយពីបាបដែលដេកលក់របស់គាត់ ដោយនិយាយថា "ឱ តើខ្ញុំជាមនុស្សអាក្រក់យ៉ាងណាហ្ន៎ ដែលខ្ញុំដេកនៅពេលថ្ងៃទៅវិញ! ដែលខ្ញុំបានដេកនៅក្នុងពេលដែលមានទុក្ខលំបាកទៅវិញ!"

**“ដ្បិតអ្នកដេកលក់នោះគេតែងដេកលក់នៅពេលយប់ ហើយពួកអ្នកដែលស្រវឹងស្រា ក៏តែងស្រវឹងនៅពេលយប់ដែរ។ តែយើងដែលជាពួកនៃថ្ងៃ យើងត្រូវដឹងខ្លួន ទាំងប្រដាប់កាយដោយសេចក្តីជំនឿ និងសេចក្តីស្រឡាញ់ ទុកជាប្រដាប់បាំងដើមទ្រូង ហើយសេចក្តីសង្ឃឹមរបស់ផងសេចក្តីសង្គ្រោះ ទុកជាមួកសឹក។” ថែស្សាឡូនិច ទី១5:7, 8**

**“តែអញប្រកាន់សេចក្តីនេះនឹងឯង គឺថាឯងបានបោះបង់ចោលសេចក្តីស្រឡាញ់ដើមចេញ។ ដូច្នេះចូរនឹកចាំ ដែលឯងបានធ្លាក់ចេញពីសណ្ឋានណានោះ ហើយប្រែចិត្តចុះ រួចប្រព្រឹត្តតាមការដើមដំបូងនោះវិញ ពុំនោះសោតអញនឹងមកឯឯង ហើយនឹងហូតយកជើងចង្កៀងឯងពីកន្លែងចេញ លើកតែឯងប្រែចិត្តឡើងវិញ។” វិវរណៈ 2:4, 5**

ដែលខ្ញុំបានផ្គាប់ដល់សាច់ឈាម ដែលប្រើដើម្បីសំរាកដល់សាច់ឈាមរបស់ខ្ញុំ ដែលព្រះអម្ចាស់នៃភ្នំបានសង់សំរាប់ជួយសំរាលទុក្ខវិញ្ញាណរបស់អ្នកដែលធ្វើដំណើរ។ តើខ្ញុំបានបោះជំហានដោយឥតប្រយោជន៍ប៉ុន្មានជំហានហើយហ្ន៎! (ការនេះក៏បានកើតឡើងដល់ពួកអ៊ីស្រាអែល ដោយសារបាបរបស់ពួកគេ ពួកគេបានវិលត្រឡប់ទៅតាមផ្លូវសមុទ្រក្រហមម្តងទៀត។ ហើយខ្ញុំបានដើរជាន់ជំហានទាំងនោះដោយទុក្ខព្រួយ ដែលខ្ញុំគួរតែដើរដោយរីករាយវិញ ប្រសិនបើមិនបានដេកលក់ជាបាបនោះទេ។ តើពេលនេះខ្ញុំអាចធ្វើដំណើរបានឆ្ងាយប៉ុណ្ណាទៅហ្ន៎! ខ្ញុំត្រូវបានដើរតាមដានជើងនោះបីដង ដែលខ្ញុំមិនចាំបាច់ដើរតាមសូមបីតែម្តងទេ។ ឥឡូវនេះខ្ញុំក៏ដូចជាល្ងង់អឹចឹង ដោយព្រោះយប់ជិតមកដល់ហើយ។ អូថាបើខ្ញុំមិនបានដេកទេ!˝

ឥឡូវនេះលោកបានទៅដល់កន្លែងសំណាក់ម្តងទៀត ដែលគាត់អង្គុយចុះរួចយំមួយរយៈ។ ប៉ុន្តែនៅពេលចុងក្រោយ (ដូចជាគ្រីស្តគ្រីស្ទៀនចង់បាន) ក្រលេកមើលដោយក្រៀមក្រំនៅលើទីជំរក គាត់បានមើលឃើញគម្ពីររបស់គាត់ ដែលធ្វើឱ្យគាត់រញ្ជួយញាប់ញ័រហើយស្ទុះទៅយក រួចដាក់លើទ្រូងរបស់គាត់។ ប៉ុន្តែតើនរណាអាចប្រាប់បានថាបុរសនេះសប្បាយចិត្តយ៉ាងណាពេលដែលគាត់បានគម្ពីររបស់គាត់ម្តងទៀត! សម្រាប់គម្ពីរនេះគឺជាការធានាអះអាងនៃជីវិតនិងការទទួលយករបស់គាត់នៅឯកន្លែងដែលជាស្ថានសួគ៌។ ដូច្នេះគាត់ដាក់វានៅក្នុងទ្រូងរបស់គាត់។ អរព្រះគុណព្រះដែលបាននាំភ្នែកទៅកន្លែងដែលដាក់គម្ពីរនោះ។ ហើយដោយទឹកមុខសប្បាយរីករាយនិងទឹកភ្នែក គាត់បានធ្វើដំណើររបស់គាត់តទៅទៀត។ អូប៉ុន្តែ! តើគាត់បានឡើងទៅលើភ្នំដែលនៅសល់យ៉ាងដូចម្តេចទៅ! តែមុនពេលគាត់ក្រោកពី

ដំណេក ព្រះអាទិត្យបានលិចទៅរំលងលើគ្រីស្ទានទៅហើយ។ ហើយនេះបានធ្វើឱ្យគាត់រំនឹកចាំពីភាពឥតប្រយោជន៍នៃការគេងរបស់គាត់ជាថ្មីម្តងទៀត ហើយដូច្នេះគាត់បានចាប់ផ្តើមសោកសៅជាមួយខ្លួនគាត់ម្តងទៀតដោយនិយាយថា "អូអ្នកដេកលក់ដែលមានបាបអើយ! ដោយសារតែអ្នកនោះការធ្វើដំណើររបស់ខ្ញុំត្រូវបានពន្យាពេល ខ្ញុំត្រូវដើរដោយគ្មានពន្លឺព្រះអាទិត្យ ភាពងងឹតត្រូវគ្របដណ្តប់លើផ្លូវនៃជើងខ្ញុំហើយ ខ្ញុំត្រូវស្លាប់ឮសំលេងរបស់សត្វយំ - ព្រោះតែបាបនៃការដេកលក់របស់ខ្ញុំ! ឥឡូវនេះគាត់ក៏បានចងចាំរឿងរ៉ាវដែលមិនទុកចិត្ត និងភ័យខ្លាចបានប្រាប់គាត់ ពីរបៀបដែលពួកគេភ័យខ្លាចជាមួយនឹងការជួបសត្វតោ។ បន្ទាប់មកគ្រីស្ទសាសនាបាននិយាយទៅកាន់ខ្លួនគាត់ជាថ្មីម្តងទៀតថា "សត្វទាំងនេះមាននៅពេលយប់ដើររកចំណីរបស់វា ប្រសិនបើពួកវាមកជួបខ្ញុំនៅក្នុងទីងងឹត តើខ្ញុំគួរផ្លាស់ប្តូរពួកគេយ៉ាងដូចម្តេច? តើខ្ញុំនឹងគេចឱ្យរួចកុំឱ្យត្រូវវាហែកជាចំណែកបានយ៉ាងដូចម្តេច? គាត់ក៏ចេញទៅ។ ប៉ុន្តែនៅពេលដែលគាត់កំពុងតែទួញសោកដោយសារការបរាជ័យរបស់គាត់ នោះគាត់បានងើបភ្នែកឡើងហើយឃើញមានវិមានមួយនៅពីមុខគាត់ ដែលមានឈ្មោះថាស្រស់ស្អាត ហើយវាឈរនៅក្បែរមហាវិថី។

## ការចូលទៅកាន់វិមាន "ស្រស់ស្អាត"

ដូច្នេះខ្ញុំបានឃើញក្នុងសុបិនខ្ញុំថា គាត់ប្រញាប់ហើយទៅមុខ បើអាចទៅរួច នោះគាត់អាចនឹងស្នាក់នៅទីនោះ។ មុនពេលដែលគាត់ធ្វើដំណើរទៅឆ្ងាយ គាត់បានទៅដល់ផ្លូវតូចមួយចម្ងាយប្រហែលមួយគីឡូម៉ែត្រពីផ្ទះសំណាក់របស់អ្នកយាម។ គាត់សំឡឹងមើលទៅមុខគាត់កាលដែលដើរទៅនោះ ឃើញមានសឹង្ហពីរនៅចំពោះមុខ។ ឥឡូវគាត់គិតថាខ្ញុំមើលឃើញថាគ្រោះថ្នាក់ដែលមិនទុកចិត្តនិងភ័យខ្លាចបានរត់គេចចេញនោះហើយ។ (សត្វតោត្រូវបានគេដាក់ច្រវាក់ ប៉ុន្តែគាត់មិនបានឃើញច្រវាក់ទេ)។ ពេលនោះគាត់ខ្លាច ហើយគាត់គិតថាខ្លួនត្រូវរត់តាមពួកគេហើយ។ ព្រោះគាត់មិនបានគិតអ្វីក្រៅពីសេចក្តីស្លាប់នៅមុខគាត់ទេ។ ប៉ុន្តែអ្នកយាមនៅឯផ្ទះសំណាក់ដែលមានឈ្មោះថាឃ្លាំមើល ដឹងថាគ្រីស្ទានឈប់ ហាក់ដូចជាចង់ត្រលប់ទៅវិញ ក៏បានស្រែករកគាត់ថា "តើកម្លាំងរបស់អ្នកតូចឬអី?"

**"រួចទ្រង់មានបន្ទូលថា ហេតុអ្វីបានជាអ្នករាល់គ្នាភ័យដល់ម៉្លេះ ម្តេចក៏គ្មានសេចក្តីជំនឿ?" ម៉ាកុស 4:40**

ចូរកុំខ្លាចសត្វតោធ្វើអ្វី ដោយសារពួកវានៅជាប់ច្រវាក់ទេ ហើយពួកវាត្រូវបានដាក់នៅទីនោះសម្រាប់ជាការសាកល្បងដល់ជំនឿនៅទីនោះ ហើយសម្រាប់នឹងស្វែងរកអ្នកដែលមិនមានសេចក្តីជំនឿសោះ ចូរនៅកណ្តាលផ្លូវរបស់អ្នក ហើយនឹងមិនមានការឈឺចាប់ណាមកកាន់អ្នកឡើយ!"

បន្ទាប់មកខ្ញុំបានឃើញគាត់បន្តទៅមុខទៀត ដោយញាប់ញ័រទាំងខ្លាចសត្តោ តែបានស្តាប់ទៅការណែនាំយ៉ាងល្អរបស់អ្នកយាមទ្វារ។ គាត់បានពួកវាគ្រហឹម តែពួកវាមិនបានធ្វើឱ្យគាត់មានរបួសអ្វីទាំងអស់។ បន្ទាប់មកគាត់បានទះដៃ រួចបន្តទៅមុខទៀត រហូតដល់គាត់មកដល់ឃ្លោងទ្វាររួចឈរនៅមុខអ្នកយាមទ្វារនៅទីនោះ។ បន្ទាប់មកគ្រីស្ទានបាននិយាយទៅកាន់អ្នកយាមទ្វារថា "ឱលោក តើផ្ទះនេះជាអ្វីទៅ? ហើយតើខ្ញុំអាចស្នាក់នៅទីនេះយប់នេះបានទេ?" អ្នកយាមបានឆ្លើយថា "ផ្ទះនេះត្រូវបានសង់ឡើងដោយព្រះអម្ចាស់នៃភ្នំនេះ ហើយទ្រង់បានសង់វាសម្រាប់ជាការបន្ធូរស្រាលនិងសុវត្ថិភាពរបស់អ្នកធ្វើដំណើរ។" អ្នកយាមសួរថាគាត់បានមកពីពេលណាហើយកំពុងទៅណា?

គ្រីស្ទាន៖ ខ្ញុំមកពីទីក្រុងនៃសេចក្តីវិនាសអន្តរាយ ហើយកំពុងទៅកាន់ភ្នំស៊ីយ៉ូន តែដោយសារព្រះអាទិត្យបានលិចទៅហើយ ខ្ញុំចង់សម្រាកនៅទីនេះយប់នេះ ប្រសិនបើអាច។

អ្នកចាំយាមល្អ៖ តើអ្នកឈ្មោះអ្វីដែរ?

គ្រីស្ទាន៖ ខ្ញុំឈ្មោះគ្រីស្ទាន តែឈ្មោះរបស់ខ្ញុំដំបូងនោះគឺ គ្មានព្រះគុណ។ ខ្ញុំកើតមកពីពូជយ៉ាផែត ជាអ្នកដែលព្រះនឹងនាំឱ្យសម្រាកនៅក្នុងជំរុំរបស់សិម។

**"សូមព្រះទ្រង់វាតទីឱ្យយ៉ាផែត សូមឱ្យវាបានស្រោយនៅក្នុងទីលំនៅរបស់សិម ហើយឱ្យកាណានបានធ្វើជាបាវបំរើរបស់វាដែរ។" លោកុប្បត្តិ 9:27**

អ្នកយាមទ្វារ៖ តែតើមានអ្វីកើតឡើងបានជាអ្នកមកយឺតម្ល៉េះ? ព្រះអាទិត្យបានលិចទៅហើយ!

គ្រីស្ទាន៖ ខ្ញុំបានមកនេះដល់ឆាប់ដែរ តែដោយសារខ្ញុំជាមនុស្សអាក្រក់ ខ្ញុំបានដេកនៅទីសំណាក់ដែលនៅក្បែរភ្នំនោះ។ បើមិនដោយសារការនោះទេ នោះខ្ញុំនឹងមកដល់ឆាប់ជាងនេះ តែនៅក្នុងពេលដេកលក់ខ្ញុំបាត់ភស្តុតាងរបស់ខ្ញុំ ហើយមកដោយមិនយកវាមករហូតដល់កំពូលភ្នំ ហើយបន្ទាប់មកក៏បានស្ទាបរកវាដែរ ហើយរកមិនឃើញសោះ ក៏មិនចិត្តសោកសង្រេងដែលត្រូវត្រឡប់ទៅកន្លែងដែលខ្ញុំបានដេកលក់វិញ នោះខ្ញុំក៏រកវាឃើញ ហើយឥឡូវនេះខ្ញុំបានមកដល់ហើយ។

អ្នកយាមទ្វារ៖ ល្អណាស់ ខ្ញុំនឹងហៅស្រីក្រមុំនៅទីនេះម្នាក់មក នាងនឹងនិយាយជាមួយអ្នកហើយនាំអ្នកទៅកាន់អ្នកផ្សេងទៀតនៅក្នុងគ្រួសារ ធ្វើទៅតាមច្បាប់របស់គ្រួសារ។ ដូច្នេះអ្នកយាមទ្វារបានគោះកណ្ដឹង ស្រីក្រមុំម្នាក់បានចេញពីទ្វារមកកាលដែលបានឮសម្លេងកណ្ដឹង នាងមានឈ្មោះថាការសម្រេចចិត្ត ហើយបានសួរហេតុអ្វីបានជាហៅនាងមក។

អ្នកយាមទ្វារ បានឆ្លើយថា "បុរសម្នាក់នេះធ្វើដំណើរពីទីក្រុងនៃសេចក្ដីវិនាសអន្តរាយទៅកាន់ភ្នំស៊ីយ៉ូន។ តែដោយសារតែងងឿយហត់ ហើយមិនដឹងធ្វើយ៉ាងណា គាត់បានសុំស្នាក់នៅទីនេះនៅយប់នេះ។ ដូច្នេះខ្ញុំបានប្រាប់គាត់ថាខ្ញុំនឹងហៅរកនាងមក ដែលនាងជាអ្នកដែលនឹងពិភាក្សាជាមួយគាត់ ដែលនឹងធ្វើតាមដែលល្អសម្រាប់អ្នក ទាំងធ្វើតាមច្បាប់នៃគ្រួសារផង។"

ការសម្រេចចិត្តៈ បន្ទាប់មកនាងបានសួរគាត់ថា តើគាត់នៅឯណា ហើយគាត់កំពុងទៅទីណា។ ហើយគាត់ក៏បានប្រាប់នាង។ នាងក៏បានសួរថាគាត់បានមកតាមផ្លូវនេះដោយរបៀបណា ហើយគាត់ក៏ប្រាប់នាង។ បន្ទាប់មកនាងបានសួរថាតើគាត់បានឃើញនិងជួបអ្វីខ្លះនៅតាមផ្លូវ ហើយគាត់ក៏បានប្រាប់នាង។ ហើយចុងក្រោយ នាងបានសួរឈ្មោះរបស់គាត់ ដូច្នេះគាត់បាននិយាយថា "គឺជាគ្រីស្ទាន ហើយខ្ញុំមានបំណងចង់ស្នាក់នៅទីនេះណាស់នៅយប់នេះ ដោយសារតាមដែលខ្ញុំយល់ ទីនេះត្រូវបានសង់ឡើងដោយព្រះអម្ចាស់នៃភ្នំនេះ សម្រាប់ជាការសម្រាលនិងសុវត្ថិភាពដល់អ្នកធ្វើដំណើរ។" ដូច្នេះនាងបានញញឹម តែទឹកបានឈរនៅក្នុងភ្នែករបស់នាង ហើយបន្ទាប់ពីឈប់បន្តិចមក នាងបាននិយាយថា "ខ្ញុំនឹងហៅពីបីនាក់នៅក្នុងគ្រួសារមក" ដូច្នេះនាងបានរត់ទៅកាន់ទ្វារ ហើយបានហៅរក ប្រយត្នប្រយែង មុតមាំ និង សប្បុរស ពួកគេជាអ្នកដែលនឹងនាំគាត់ចូលទៅក្នុងគ្រួសារបន្ទាប់ពីបាននិយាយជាមួយគាត់បន្តិចមក ហើយមានមនុស្សជាច្រើនបានជួបគាត់នៅទីលានខាងមុខផ្ទះ បាននិយាយថា "ចូលមក ឱអ្នកដ៏មានពររបស់ព្រះអម្ចាស់អើយ! ផ្ទះនេះត្រូវបានសង់ឡើងដោយព្រះអម្ចាស់នៃភ្នំនេះ ដោយមានគោលបំណងនឹងកំសាន្តចិត្តដល់អ្នកដែលធ្វើដំណើរដូចនេះ។" បន្ទាប់មកគាត់បានឱនក្បាលរបស់គាត់ ហើយដើរតាមពួកគេចូលទៅក្នុងផ្ទះ។ ដូច្នេះនៅពេលដែលគាត់បានចូលក្នុង រួចបានអង្គុយចុះ ពួកគេបានឱ្យអ្វីមួយដល់គាត់ផឹក ហើយបានយល់ស្របគ្នាថា ទាល់តែអាហារពេលយប់រួចរាល់ អ្នកខ្លះនៃពួកគេនឹងត្រូវជជែកជាមួយគ្រីស្ទានខ្លះៗ ដើម្បីប្រើពេលវេលាឲ្យមានប្រយោជន៍ នោះគេបានចាត់តាំង មុតមាំ ប្រយត្នប្រយែង និង សប្បុរសមកជជែកជាមួយគាត់។ ដូច្នេះពួកគេក៏ចាប់ផ្តើមធ្វើតាម។

មុតមាំ៖ ចូរចូលមកគ្រីស្ទានល្អអើយ កាលដែលយើងស្រឡាញ់ដល់អ្នកខ្លាំងណាស់ ដែលបានទទួលអ្នកមកក្នុងផ្ទះរបស់ពួកយើងយប់នេះ។ ប្រសិនជាយើង ដែលកាន់តែប្រសើរនោះ យើងនឹងជជែកជាមួយអ្នកនូវគ្រប់រឿងដែលបានកើតឡើងមកកាន់អ្នកនៅក្នុងការធ្វើដំណើររបស់អ្នក។

គ្រីស្ទាន៖ ដោយបំណងល្អ ហើយខ្ញុំក៏រីករាយដែលអ្នកមានបំណងដ៏ល្អបែបនេះ។

មុតមាំ៖ តើអ្វីដែលបានធ្វើឱ្យអ្នកមកកាន់ជីវិតជាអ្នកធ្វើដំណើរនេះពីដំបូងមកនោះ?

គ្រីស្ទាន៖ ខ្ញុំត្រូវបានបណ្តេញចេញពីប្រទេសកំណើតរបស់ខ្ញុំ ដោយសម្លេងដែលគួរឱ្យភ័យខ្លាចនៅក្នុងត្រចៀករបស់ខ្ញុំ ឱ្យគេចចេញ ដែលសេចក្តីវិនាសដែលគេចមិនផុតនឹងមកកាន់ខ្ញុំ ប្រសិនបើខ្ញុំនឹងនៅកន្លែងដែលខ្ញុំនៅនោះ។

មុតមាំ៖ តែតើវាកើតឡើងយ៉ាងដូចម្តេចទៅ ដែលអ្នកបានចេញមកពីប្រទេសរបស់អ្នករបៀបនេះ?

គ្រីស្ទាន៖ គឺវាដូចជាអ្វីដែលព្រះបានរៀបមកនោះ។ ដោយសារ នៅពេលដែលខ្ញុំនៅក្រោមការភ័យខ្លាចពីសេចក្តីអន្តរាយ ខ្ញុំមិនដឹងថានឹងទៅទីណានោះទេ។ តែចៃដន្យមានបុរសម្នាក់បានមកកាន់ខ្ញុំ (ក្នុងកាលដែលខ្ញុំកំពុងភ័យញ័រហើយទួញយំផង) គាត់ឈ្មោះ អ្នកផ្សាយដំណឹងល្អ ហើយគាត់បានណែនាំដល់ខ្ញុំឱ្យទៅកាន់ឃ្លោងទ្វារទុច្ចរិត មិនដូច្នោះទេខ្ញុំនឹងមិនអាចរក

ឃើញឡើយ។ ដូច្នេះក៏បាននាំខ្ញុំទៅកាន់ផ្លូវនោះដែលនាំខ្ញុំតម្រង់ទៅផ្ទះនេះ។

មុតមាំ៖ តែតើអ្នកមិនបានមកដោយឆ្លងកាត់ផ្ទះរបស់អ្នកបកស្រាយទេឬអី?

គ្រីស្ទាន៖ បាទបាន។ ហើយបានឃើញរបស់ដែលនៅទីនោះ ជាការចង់ចាំដែលនឹងនៅជាប់នឹងខ្ញុំពេញមួយជីវិតដែលខ្ញុំរស់នៅ។ ជាពិសេសគឺការបីយ៉ាង របៀបដែលគ្រីស្ទានរក្សាកិច្ចការនៃព្រះនៅក្នុងចិត្តជំនួសឱ្យកិច្ចការរបស់សាតាំង របៀបដែលមនុស្សបានធ្វើបាបផ្ទាល់ប្រៀបបីដូចជាមិនមានសង្ឃឹមថានឹងបានទទួលសេចក្តីមេត្តាមកពីព្រះ ហើយពីសុបិន្តដែលបានគិតនៅក្នុងពេលដេកលក់ពីថ្ងៃជំនុំជំរះដែលនឹងត្រូវមក។

មុតមាំ៖ ហេតុអ្វីបានជាអ្នកស្តាប់គាត់ប្រាប់ពីសុបិន្តនេះ?

គ្រីស្ទាន៖ បាទ ហើយខ្ញុំបានគិតថាវាគួរឱ្យភ័យខ្លាចណាស់។ វាបានធ្វើឱ្យចិត្តរបស់ខ្ញុំឈឺកាលដែលគាត់កំពុងប្រាប់ តែខ្ញុំរីករាយដែលបានស្តាប់។

មុតមាំ៖ តើទាំងនោះជាគ្រប់យ៉ាងដែលអ្នកបានឃើញនៅផ្ទះរបស់អ្នកបកប្រែមែនទេ?

គ្រីស្ទាន៖ ទេ។ គាត់បាននាំខ្ញុំទៅ ហើយបង្ហាញខ្ញុំនូវវិមានដ៏មាំមួនមួយ។ ហើយពីរបៀបដែលមនុស្សនៅទីនោះបំពាក់ដោយមាស ហើយពីរបៀបដែលមានបុរសបណ្តាក់ទុនម្នាក់មក ហើយបានជំនះបំរះរួចពីពួកអ្នកយាមដែលបានឈរនៅទ្វារដើម្បីកុំឱ្យគាត់ចូល ហើយពីរបៀបដែលគាត់ជំនះចូល

ក្នុងដើម្បីទទួលបានសិរីល្អដ៏អស់កល្ប។ ខ្ញុំគិតថាការទាំងនោះបានធ្វើឱ្យចិត្តរបស់ខ្ញុំមិនការស្ងប់ស្ងែង។ ខ្ញុំគួរតែសម្រាកនៅផ្ទះរបស់បុរសល្អមួយឆ្នាំ តែខ្ញុំដឹងថាខ្ញុំត្រូវដើរទៅមុខឆ្ងាយទៀត។

មុតមាំ៖ តើអ្នកបានឃើញអ្វីទៀតទេនៅតាមផ្លូវ?

គ្រីស្ទាន៖ បានឃើញ! ខ្ញុំបានទៅមុខបន្តិចទៀត ហើយបានឃើញម្នាក់ ដែលខ្ញុំបានគិតនៅក្នុងគំនិតរបស់ខ្ញុំ ថាគាត់ត្រូវបានព្យួរនៅលើដើមឈើ ហើយដោយឃើញរូបភាពរបស់គាត់ដូច្នោះ នោះបន្ទុកបានធ្លាក់ចុះពីខ្នងរបស់ខ្ញុំ (ដោយសារខ្ញុំថ្ងូរនៅក្រោមបន្ទុកដ៏លំបាក) តែបន្ទាប់មកវាបានធ្លាក់ចេញពីខ្ញុំ។ វាជាការចម្លែកមួយដល់ខ្ញុំ ដោយសារខ្ញុំមិនដែលឃើញការនោះពីមុនមកទេ។ ហើយកាលដែលខ្ញុំឈរមើលទៅលើ (ដោយបន្ទាប់មកខ្ញុំមិនអាចនឹងទ្រាំមើលបានទៀត) មនុស្សចែងចាំងបីនាក់បានមករកខ្ញុំ។ មានម្នាក់បានធ្វើបន្ទាល់ថាអំពើបាបរបស់ខ្ញុំត្រូវបានអត់ទោសឱ្យហើយ ម្នាក់ទៀតបានដោះកន្ទបចេញពីខ្ញុំ ហើយបានឱ្យអាវប៉ាក់ក្រៅដែលអ្នកឃើញនេះមកខ្ញុំ ហើយអ្នកទីបីបានដាក់សញ្ញាដែលអ្នកឃើញនេះនៅលើថ្ងាស់របស់ខ្ញុំ ហើយបានផ្តល់គម្ពីរបោះត្រានេះមកខ្ញុំ (ហើយដោយគាត់បានយកវាចេញពីដើមទ្រូងរបស់គាត់)។

មុតមាំ៖ តែអ្នកបានឃើញច្រើនជាងនេះ តើមែនទេ?

គ្រីស្ទាន៖ ការទាំងប៉ុន្មានដែលខ្ញុំបានប្រាប់អ្នកជាការដែលល្អបំផុត។ តែខ្ញុំបានឃើញតូចៗជាច្រើនទៀត និយាយទៅខ្ញុំបានឃើញមនុស្សបីនាក់

មនុស្សល្ងង់ កំជិល និងសម្ងត់ ដែលដេកចេញពីផ្លូវដែលខ្ញុំមកបន្តិច ដែលមានច្រវាក់ដែកនៅកែងជើងរបស់ពួកគេ។ តែតើអ្នកគិតថាខ្ញុំអាចដាស់ពួកគេឱ្យភ្ញាក់បានទេ! ខ្ញុំក៏បានឃើញ អ្នកស្របច្បាប់ និងមនុស្សកំពុតមកដោយភ័យញ័រពីលើជញ្ជាំង ដើរទៅដោយធ្វើពុតទៅកាន់ភ្នំស៊ីយ៉ូន តែពួកគេត្រូវវង្វេងមួយរំពេច។ ទោះតែខ្ញុំបានប្រាប់ពួកគេ ពួកគេនៅតែមិនជឿ តែលើសពីនោះទៀត ខ្ញុំបានរកឃើញថាវាពិតជាលំបាកណាស់ដែលត្រូវឡើងមកលើភ្នំនេះ ហើយកាន់តែលំបាកដែលត្រូវមកក្បែរមាត់សត្វតោ។ ហើយពិតណាស់ ប្រសិនបើមិនមានមនុស្សល្អទេ គឺអ្នកយាមដែលឈរនៅឃ្លោងទ្វារនោះខ្ញុំមិនដឹងថាខ្ញុំនឹងត្រូវត្រឡប់ក្រោយឬយ៉ាងណាទេ។ ប៉ុន្តែពេលនេះខ្ញុំអរព្រះគុណដល់ព្រះដែលខ្ញុំនៅទីនេះ ហើយខ្ញុំក៏អរគុណអ្នកដែលបានទទួលខ្ញុំ។

## ភាពកម្រនៃ "ស្រស់ស្អាត"

ដូច្នេះនៅពេលព្រឹកឡើង ពួកគេក៏ក្រោកឡើង ហើយបន្ទាប់ពីពិភាក្សាគ្នាបន្តិចទៀត ពួកគេបានប្រាប់គាត់ថា គាត់នឹងចាកចេញបានរហូតទាល់តែពួកគេបានបង្ហាញគាត់នូវសេចក្តីពិតនៃកន្លែងនោះ។ ហើយដំបូងគេឱ្យគាត់ចូលទៅក្នុងការសិក្សា ជាកន្លែងដែលពួកគេបានបង្ហាញគាត់ពីកំណត់ត្រានៃរឿងពីដើមដ៏អស្ចារ្យៗបំផុត។ ហើយដែលនៅក្នុងនោះ តាមដែលខ្ញុំចាំសុបិន្តរបស់ខ្ញុំ ពួកគេបានបង្ហាញពូជពង្សាដំបូងបង្អោះរបស់ព្រះអម្ចាស់នៃភ្នំនោះដែលថាទ្រង់ជាបុត្ររបស់សម័យបុរាណ ហើយមកពីជំនាន់ដែលនៅអស់កល្បជានិច្ច។ នៅទីនេះក៏មានការកត់ត្រាយ៉ាងពេញលេញពីសកម្មភាពដែលទ្រង់បានធ្វើ ហើយនឹងឈ្មោះរបស់មនុស្សរាប់រយនាក់ដែលទ្រង់បានយកមកបម្រើដល់ទ្រង់ ហើយពីរបៀបដែលទ្រង់បានដាក់ពួកគេនៅក្នុងកេរ្តិ៍មរតកដែលមិនរលួយតាមរយៈពេល ឬដោយធម្មជាតិ ឬត្រូវបាត់បង់នោះឡើយ។

បន្ទាប់មកពួកគេក៏បានអានពីទង្វើដ៏មានតម្លៃរបស់អ្នកបម្រើរបស់ទ្រង់ដែលបានធ្វើ។ ដូចជារបៀបដែលពួកគេ "ចុះចូលក្នុងអាណាចក្រ នាំមកនូវសេចក្តីសុចរិត សម្រេចតាមសេចក្តីសន្យា បញ្ឈប់មាត់របស់សត្វតោ បង្ក្រាបភ្លើងឆេះសន្ធោរសន្ធៅ គេចផុតពីមុខដាវ ចេញពីសេចក្តីកំសោយក៏បានធ្វើឱ្យរឹងមាំឡើង កាន់តែក្លាហាននៅក្នុងការប្រយុទ្ធ ហើយបង្វែរទៅប្រយុទ្ធជាមួយនឹងទ័ពរបស់សាសន៍ដទៃ។"

**"ដែលដោយសារសេចក្តីជំនឿ នោះគេបានឈ្នះនគរដទៃ បានសម្រេចការសុចរិត បានទទួលសេចក្តីសន្យា បានបិទមាត់សិង្ហ បានពន្លត់អំណាចភ្លើង បានរួចពីមុខដាវ បានមានកម្លាំងក្នុងកាលដែលកំពុងតែខ្សោយ ក៏ត្រឡប់ជាពូកែក្នុងចំបាំង ទាំងកំចាត់ពលទ័ពសាសន៍ដទៃផង។" ហេព្រើរ 11"33, 34**

បន្ទាប់មកពួកគេបានអានផ្នែកផ្សេងទៀតនៃកំណត់ត្រានៅផ្ទះនោះ ត្រង់កន្លែងដែលបានបង្ហាញ ថាព្រះអម្ចាស់របស់ពួកគេមានបំណងទទួលមកក្នុងសេចក្តីសប្បុរសរបស់ទ្រង់ នូវអស់អ្នកដែលទោះពីដើមបានផ្តល់ការចំអកឡកលើយយ៉ាងខ្លាំងមកដល់អង្គទ្រង់និងកិច្ចការរបស់ទ្រង់ក្តី។ នៅទីនេះក៏មានប្រវត្តិខ្លះៗទៀតនៃរឿងដែលល្បីៗជាច្រើន ដែលគ្រប់ទាំងរឿងនោះគ្រីស្ទានអាចយល់បាន។ សម្រាប់រឿងទាំងពីបុរាណនិងសម័យ ជាមួយនឹងការទស្សទាយន៍និងការប៉ាន់ស្មានដែលបានសម្រេចពិតប្រាកដ ទាំងការដែលគួរឱ្យភ័យខ្លាចនិងការដែលគួរកោតសរសើររបស់សត្រូវ និងការកំសាន្តចិត្តនិងការសម្រាលដល់អ្នកធ្វើដំណើរ។

ថ្ងៃបន្ទាប់មកពួកគេបានយកគាត់ទៅក្នុងបន្ទប់សព្វាវុធ ជាកន្លែងដែលពួកគេបង្ហាញគាត់នូវគ្រប់ប្រភេទគ្រឿងសង្ហារឹម ដែលព្រះអម្ចាស់របស់ពួកគេបានប្រគល់ឱ្យដល់អ្នកធ្វើដំណើរ មានដាវ ខែល មួកការពារ របាំងទ្រូង គ្រប់ការអធិស្ឋាន និងស្បែកជើងដែលនឹងមិនត្រូវចាស់ខូច។ ហើយមាននៅទីនេះគ្រប់គ្រាន់នឹងបំពាក់ដល់មនុស្សជាច្រើនសម្រាប់នឹងបម្រើដល់ព្រះអម្ចាស់របស់ពួកគេ ដែលច្រើនដូចជាហ្វូងផ្កាយនៅលើមេឃ។

ពួកគេក៏បង្ហាញដល់គាត់នូវសម្ភារៈមួយចំនួន ដែលអ្នកបម្រើរបស់ទ្រង់មួយចំនួនបានធ្វើការដ៏អស្ចារ្យជាមួយនឹងរបស់ទាំងនោះ។ ពួកគេបានបង្ហាញគាត់នូវ ដំបងរបស់ម៉ូសេ ញញួរ និងដេកគោលដែលនាងយ៉ាអែលបានសម្លាប់ស៊ីសេរ៉ា ក្រឡទឹក ត្រែ និងកង្កៀងផង ដែលហ្គីឌានបានប្រើរបស់ទាំងនោះបណ្ដេញនូវទ័ពរបស់ពួកមីឌានចេញអស់។ បន្ទាប់មកពួកគេបានបង្ហាញគាត់នូវ ឆ្អឹងសត្វគោឈ្មោលដែលសាំកាបានប្រើសម្រាប់សម្លាប់មនុស្ស៦០០នាក់។ ពួកគេបានបង្ហាញគាត់នុវឆ្អឹងថ្គាមដែលសាំសុនប្រើដើម្បីធ្វើកិច្ចការដ៏អស្ចារ្យ។ ពួកគេបានបង្ហាញគាត់ថែមទៀតនូវ ខ្សែរគ្រវីនិងដុះថ្មដែលដាវីឌប្រើដើម្បីសម្លាប់ហ្គូលីយ៉ាតរបស់សាសន៍ហ្គាត។ និងដាវផងដែលព្រះអម្ចាស់របស់ពួកគេប្រើសម្រាប់សម្លាប់មនុស្សមានបាប នៅក្នុងថ្ងៃដែលគេនឹងក្រោកឡើងមករកចំណី។ ក្រៅពីនោះពួកគេបានបង្ហាញដល់គាត់នូវការយ៉ាងអស្ចារ្យជាច្រើនទៀត ដែលគ្រីស្ទានបានពេញចិត្តយ៉ាងខ្លាំងជាមួយការនោះ។ រួចមកពួកគេក៏បានចូលសំរាកម្ដងទៀត។

បន្ទាប់មកខ្ញុំបានឃើញនៅក្នុងសុបិន្តរបស់ខ្ញុំថា នៅពេលព្រលឹមឡើងគាត់បានក្រោកឡើងដើម្បីនឹងទៅមុខ តែពួកគេចង់ឱ្យគាត់ស្នាក់នៅរហូតដល់ថ្ងៃបន្ទាប់ទៀតផង ហើយរួចមក ពួកគេបាននិយាយថា ប្រសិនបើថ្ងៃភ្លឺច្បាស់ឡើង នឹងបង្ហាញដល់អ្នកនូវភ្នំដែលគួរឱ្យចង់ញាំ ដែលពួកគេនិយាយថានឹងបានបន្ថែមលើសេចក្ដីកំសាន្តដល់គាត់ថែមទៀត ពីព្រោះពួកគេនៅជិតកន្លែងដែលប្រាថ្នា ជាជាងកន្លែងដែលទ្រង់គង់នៅ។ ដូច្នេះគាត់ក៏យល់ព្រមហើយក៏បានសំរាកទៅ។ នៅពេលព្រឹកព្រលឹមមកដល់ ពួកគេនាំគាត់ទៅ

លើដំបូលរបស់ព្រះ ហើយប្រាប់គាត់ឱ្យមើលទៅខាងត្បូង គាត់ក៏ធ្វើតាម ហើយឃើញចម្ងាយដ៏ឆ្ងាយ។

**"អ្នកនោះនឹងបាននៅក្នុងទីខ្ពស់ ទីពំនាក់របស់អ្នកនោះនឹងនៅលើថ្មដាដ៏មាំមួន ឯអាហារនឹងប្រទានមកអ្នកនោះ ហើយទឹករបស់អ្នកនោះនឹងចេះតែមាននៅ។ ភ្នែកឯងនឹងបានឃើញមហាក្សត្រ មានទាំងសេចក្ដីលំអរុងរឿងរបស់ទ្រង់ គេនឹងមើលទៅឃើញស្រុកដល់ទីឆ្ងាយបំផុត។" អេសាយ 33:16, 17**

គាត់បានឃើញប្រទេសដែលពេញដោយភ្នំដ៏គួរឱ្យគាប់ចិត្ត ស្រស់ស្អាតមានឈើ ចម្ការទំពាំងបាយជូរ ផ្លែឈើគ្រប់ប្រភេទ ទាំងផ្កាផង ដោយមានទឹកជ្រោះនិងប្រភពទឹក ដែលគួរឱ្យចង់ឃើញ។ បន្ទាប់មកគាត់បានសួរឈ្មោះនៃប្រទេសនោះ។ ពួកគេបាននិយាយថា វាជាទឹកដីរបស់អេម៉ាញូអែល ជាទីដែលពេញនិយមដូចជាភ្នំនេះដែរ គឺសម្រាប់អ្នកធ្វើដំណើរទាំងអស់។ ហើយនៅពេលដែលអ្នកដល់ទីនោះ ពួកគេនិយាយថា ពីទីនេះអ្នកនឹងមើលឃើញឃ្លោងទ្វារនៃទីក្រុងបរិសុទ្ធ ដូចជាអ្នកគង្វាលដែលរស់នៅទីនោះនឹងបង្ហាញមកដែរ។

ចាកចេញពីភ្នំ

ពេលនេះគាត់បានគិតមកកាន់ខ្លួនពីការធ្វើដំណើរទៅមុខទៀត ហើយពួកគេមានបំណងនឹងឱ្យគាត់ទៅ តែដំបូងពួកគេនិយាយថា សុំឱ្យពួកយើងបានចូលទៅក្នុងបន្ទប់ដាក់អាវុធម្ដងទៀត ពួកគេបានចូលទៅ។ ហើយនៅពេលដែលពួកគេមកដល់ទីនោះ ពួកគេបានបំពាក់គាត់ពីក្បាលដល់ចុងជើងនូវអ្វី

ដែលជាភស្តុតាង ក្រែងគាត់អាចនឹងជួបជាមួយការវាយប្រហារនៅតាមផ្លូវ។ ដោយគាត់ត្រូវបានបំពាក់គ្រឿងរួចមក គាត់បានដើរចេញក្រៅជាមួយនឹងមិត្តរបស់គាត់ទៅកាន់ឃ្លោងទ្វារ ហើយនៅទីនោះ គាត់បានសួរអ្នកយាមទ្វារថា គាត់បានឃើញអ្នកដំណើរណាដែលឆ្លងកាត់ដែរទេ។ បន្ទាប់មកអ្នកយាមទ្វារបានឆ្លើយថា មាន។

គ្រីស្ទាន៖ គាត់និយាយថា តើអ្នកស្គាល់គេទេ?

អ្នកយាមទ្វារ៖ ខ្ញុំបានសួរឈ្មោះរបស់គាត់ ហើយគាត់បានប្រាប់ខ្ញុំថាឈ្មោះស្មោះត្រង់។

គ្រីស្ទាន៖ គ្រីស្ទានបាននិយាយថា "អូ" "ខ្ញុំស្គាល់គាត់។ គាត់ជាអ្នកស្រុករបស់ខ្ញុំ អ្នកជិតខាងរបស់ខ្ញុំ។ គាត់មកពីកន្លែងដែលខ្ញុំកើត។ តើអ្នកគិតថាគាត់ទៅមុខចម្ងាយប៉ុន្មានដែរ?"

អ្នកយាមទ្វារ៖ ពេលនេះគាត់ប្រហែលទៅដល់ជើងភ្នំហើយ។

គ្រីស្ទាន៖ គ្រីស្ទាននិយាយថា "ល្អណាស់ អ្នកយាមទ្វារល្អអើយ សូមព្រះអម្ចាស់គង់នៅជាមួយអ្នក ហើយបន្ថែមព្រះពរដល់អ្នកថែមទៀតដោយសារសេចក្ដីសប្បុរសដែលអ្នកបង្ហាញមកដល់ខ្ញុំ!"

បន្ទាប់មកគាត់បានចាប់ផ្ដើមដើរទៅមុខ តែបំណាង មុតមាំ សប្បុរស និងប្រុងប្រយ័ត្នបានជូនដំណើរគាត់ចុះទៅដល់ជើងភ្នំ។ ដូច្នេះពួកគេបានទៅជាមួយគ្នា ដោយបន្តប្រាប់រឿងពីដើមៗរបស់ពួកគេ រហូតដល់ពួកគេមកដល់ជើងភ្នំ

។ បន្ទាប់មកគ្រីស្ទានបាននិយាយថា "កាលដែលពិបាកឡើងយ៉ាងណា ដូច្នេះវាក៏គ្រោះថ្នាក់ដែលចុះមកក្រោមផងដែរ (តាមដែលខ្ញុំអាចមើលឃើញ)។"

ប្រុងប្រយ័ត្នបាននិយាយថា "បាទ វាអីចឹងមែន ដោយសារវាពិបាកណាស់សម្រាប់ឱ្យមនុស្សម្នាក់ចុះទៅកាន់ជ្រលងនៃសេចក្តីអាម៉ាស ដូចជាអ្នកពេលនេះដែរ ហើយដើម្បីកុំឱ្យជំពប់ដួលនៅតាមផ្លូវ។" ដូច្នេះពួកគេបាននិយាយថា "ពួកយើងចេញមកដើម្បីនឹងជូនដំណើរអ្នកចុះភ្នំ" ដូច្នេះកាត់ក៏ចាប់ដើរចុះទៅក្រោម តែដោយមានក្តីព្រួយបារម្ភ តែគាត់ក៏បានជំពប់ដួលម្តងពីរដែរ។

បន្ទាប់មកខ្ញុំបានឃើញនៅក្នុងសុបិន្តរបស់ខ្ញុំថា មិនសំឡាញ់ទាំងនេះបានឱ្យនំប៉័ងមួយដុំ ទឹកមួយដង និងទំពាំងបាយជូរក្រៀមមួយចង្កោមដល់គាត់ នៅពេលគ្រីស្ទានបានទៅដល់បាតភ្នំ ហើយរួចមកគាត់ក៏ចេញទៅតាមផ្លូវរបស់គាត់ទៅ។

## អាប៉ូឡេអុង

តែពេលនេះ នៅក្នុងជ្រោះនៃសេចក្តីអាម៉ាស គ្រីស្ទានកំសត់ពិបាកនឹងដាក់វាណាស់ ដោយសារតែគាត់បានទៅមិនឆ្ងាយប៉ុន្មាន នៅខាងមុខនោះគាត់បានសម្លឹងមើលទៅឃើញបីសាយមួយដ៏អាក្រក់មកទីវាលដើម្បីនឹងជួបជាមួយគាត់ គេមានឈ្មោះថា អាប៉ូឡេអុង។ បន្ទាប់មកគ្រីស្ទានចាប់ផ្តើមភ័យខ្លាច ហើយដែលគិតនៅក្នុងចិត្តរបស់គាត់ថានឹងត្រូវត្រឡប់ក្រោយ ឬឈរនៅទីនោះទេ។ តែគាត់បានគិតពិចារណាម្តងទៀត គាត់មិនមានអាវុធសម្រាប់នឹងត្រឡប់ទៅវិញទេ ហើយដូច្នេះបានគិតថាការត្រឡប់ទៅវិញសម្រាប់គាត់ នឹងធ្វើឱ្យគេទទួលបានប្រយោជន៍យ៉ាងច្រើនដោយងាយ នៅក្នុងការដែលបាញ់ទំលុះគាត់ជាមួយនឹងព្រួយ។ ដូច្នេះគាត់សម្រេចចិត្តថានឹងប្រថុយគ្រោះថ្នាក់ ហើយនៅឈរនៅទីនោះ។ ដោយគាត់គិតថា ខ្ញុំមានភ្នែកសម្រាប់តែនឹងសង្គ្រោះជីវិតរបស់ខ្ញុំតែប៉ុណ្ណោះ នេះជាការល្អបំផុតហើយដែលត្រូវឈរនៅទីនេះ។

ដូច្នេះគាត់បានទៅមុខទៀត ហើយអាប៉ូឡេអុងបានជួបជាមួយគាត់។ ពេលនេះបិសាយអាក្រក់មើលណាស់។ វាមានគ្របដណ្តប់ដោយស្រកាដូចជាសត្វត្រី (ហើយទាំងនោះជាសេចក្តីអំណួតរបស់គេ) គេមានស្លាបដូចជាសត្វនាគ ប្រអប់ជើងដូចជាសត្វខ្លាឃ្មុំ ហើយចេញពីពោះរបស់គេមានភ្លើងនិងផ្សែង ហើយមាត់របស់គាត់ដូចជាមាត់តោ។ នៅពេលដែលគេមកក្បែរគ្រីស្ទាន គេបានមើលមកគាត់ដោយទឹកមុខឡកលើយ ហើយគេក៏ចាប់ផ្តើមសួរគាត់

អាប៉ូឡេអុង៖ តើអ្នកមកពីណា ហើយសំដៅទៅទីណាដែរ?

គ្រីស្ទាន៖ ខ្ញុំបានមកពីក្រុងនៃសេចក្ដីវិនាសអន្តរាយ ដែលជាទីកន្លែងនៃគ្រប់សេចក្ដីទុច្ចរិត ហើយខ្ញុំកំពុងទៅកាន់ក្រុងស៊ីយ៉ូន។

អាប៉ូឡេអុង៖ អីចឹងខ្ញុំយល់ថាអ្នកជាបញ្ជាមួយរបស់ខ្ញុំ ដោយសារតែប្រទេសនោះទាំងមូលជារបស់ខ្ញុំ ហើយខ្ញុំធ្វើជាស្ដេចនិងជាព្រះនៅទីនោះ។ តើហេតុអ្វីបានជាអ្នកបានរត់ចេញពីស្ដេចរបស់អ្នកដូច្នេះ? តើខ្ញុំមិនបានប្រាប់ផ្ដាថាអ្នកនឹងបម្រើខ្ញុំទេឬយ៉ាងណា? ខ្ញុំនឹងកាប់ឯងឱ្យដួលនៅនឹងដីតែម្ដង។

គ្រីស្ទាន៖ ខ្ញុំបានកើតនៅក្នុងការគ្រប់គ្រងរបស់អ្នកពិតមែន តែកិច្ចការរបស់អ្នកពិបាកខ្លាំងណាស់ ហើយថ្លៃឈ្នួលរបស់អ្នកគឺមិនអាចឱ្យមនុស្សរស់បានទេ ដោយសារឈ្នួលនៃអំពើបាបជាសេចក្ដីស្លាប់។

"ដ្បិតគ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ" រ៉ូម 3:23

ដូច្នេះ នៅពេលដែលខ្ញុំរស់នៅជាច្រើនឆ្នាំ នោះខ្ញុំបានធ្វើដូចជាមនុស្សវ័យឆ្លាតផ្សេងទៀត ដោយសម្លឹងមើល ប្រហែលជាខ្ញុំអាចនឹងបំបែរខ្លួនរបស់ខ្ញុំបាន។

អាប៉ូឡេអុង៖ មិនមានស្ដេចណាដែលនឹងត្រូវបាត់បង់កូនចៅរបស់ខ្លួនដោយងាយនោះទេ ហើយខ្ញុំក៏នឹងមិនត្រូវបាតបង់អ្នកដែរ។ តែដោយអ្នកបានរអ៊ូរទាំនឹងការងាររបស់អ្នកនិងថ្លៃឈ្នួលផងនោះ ចូរអ្នកត្រឡប់ទៅវិញទៅ ខ្ញុំ

នឹងសន្យានឹងអ្នកនៅទីនេះថា នឹងឱ្យដល់អ្នកនូវអ្វីដែលប្រទេសរបស់យើង អាចឱ្យបាន។

គ្រីស្ទាន៖ តែខ្ញុំបានអនុញ្ញាតខ្លួនទៅដល់ស្ដេចមួយអង្គផ្សេងទៀតហើយ ដែលទ្រង់ជាស្ដេចលើអស់ទាំងស្ដេច ហើយតើខ្ញុំនឹងត្រឡប់ទៅវិញជាមួយ អ្នកដោយសេចក្ដីត្រឹមត្រូវបានយ៉ាងម៉េច?

អាប៉ូឡេអុង៖ អ្នកបានធ្វើដូចនឹងសុភាសិតមួយនិយាយថា "បានប្ដូរពីការ អាក្រក់ជាមួយនឹងការដ៏អាក្រក់បំផុត" តែវាជាការធម្មតាសម្រាប់ពួកអ្នក ដែលសារភាពថាជាអ្នកបម្រើរបស់ទ្រង់ មួយរយៈក្រោយនឹងជំពប់ដួល ហើយត្រឡប់មករកខ្ញុំម្ដងទៀត។ អ្នកក៏អាចធ្វើបែបនោះបាន ហើយវាមិន មានរឿងអ្វីឡើយ។

គ្រីស្ទាន៖ ខ្ញុំបានផ្ដល់ដល់ទ្រង់នូវសេចក្ដីជំនឿរបស់ខ្ញុំ និងស្បថនូវសេចក្ដី ស្មោះត្រង់របស់ខ្ញុំដល់ទ្រង់ តើខ្ញុំអាចនឹងត្រឡប់ចេញពីការនេះ ហើយមិន ត្រូវរាប់ជាមនុស្សក្បត់បានយ៉ាងដូចម្ដេច?

អាប៉ូឡេអុង៖ អ្នកបានធ្វើដូច្នោះមកកាន់ខ្ញុំដូចគ្នា តែខ្ញុំនឹងមិនរាប់វាឡើយ ប្រសិនបើអ្នកនឹងប្រឡប់ក្រោយម្ដងទៀតនៅពេលនេះ។

គ្រីស្ទាន៖ អ្វីដែលខ្ញុំបានសន្យានឹងអ្នកនោះ គឺមុនពេលដែលខ្ញុំធំនៅឡើយ ហើយក្រៅពីនោះ ខ្ញុំបានរាប់ថាស្ដេចដែលខ្ញុំនៅក្រោមពេលនេះអាចនឹងជួយ ខ្ញុំបាន។ ហើយពិតណាស់ទ្រង់បានអត់ទោសឱ្យនូវអ្វីដែលខ្ញុំបានធ្វើដោយ ការឃុបឃិតរបស់ខ្ញុំជាមួយអ្នក។ ហើយក្រៅពីនោះ ឱអាប៉ូឡេអុងបំផ្លាញ

អើយ បើនិយាយការពិតទៅ ខ្ញុំចូលចិត្តកិច្ចរបស់ទ្រង់ណាស់ ទាំងថ្លៃឈ្នួលសំលៀកបំពាក់របស់ទ្រង់ បរិវាររបស់ទ្រង់ និងប្រទេសរបស់ទ្រង់ជាងប្រទេសរបស់អ្នក។ ដូច្នេះសូមឈប់បបួលខ្ញុំបន្តធ្វើអ្វី។ ខ្ញុំជាអ្នកបម្រើរបស់ទ្រង់ ហើយខ្ញុំនឹងដើរតាមទ្រង់។

អាប៉ូឡេអុង៖ ចូរពិចារណាម្តងទៀត នៅពេលដែលអ្នកនៅឈាមត្រជាក់នៅឡើយ នូវអ្វីដែលអ្នកនឹងជួបនៅតាមផ្លូវដែលអ្នកទៅ។ អ្នកបានដឹងថា ភាគច្រើនអ្នកបម្រើរបស់ទ្រង់មកដល់ទីបញ្ចប់ដ៏អាក្រក់ ដោយសារពួកគេប្រឆាំងទាស់នឹងខ្ញុំនិងផ្លូវរបស់ខ្ញុំ។ តើពួកគេប៉ុន្មានអ្នកដែលត្រូវបានស្លាប់ដោយសេចក្តីអាម៉ាស! ហើយក្រៅពីនោះអ្នកបានរាប់ថាកិច្ចការរបស់ទ្រង់ប្រសើរជាងខ្ញុំ ជាកន្លែងដែលទ្រង់មិនដែលចេញមកផង ដើម្បីនឹងរំដោះពួកអ្នកដែលបម្រើទ្រង់ពីដៃរបស់យើង។ ប៉ុន្តែសម្រាប់ខ្ញុំវិញ តើមានប៉ុន្មានដងដែរដូចដែលមនុស្សមួយពិភពលោកបានដឹងយ៉ាងច្បាស់ថា ខ្ញុំបានរំដោះ មិនថាដោយអំណាច ឬការបោកបញ្ឆោតនោះទេ អស់អ្នកដែលបានបម្រើខ្ញុំដោយស្មោះត្រង់ ចេញពីទ្រង់និងរបស់ផងទ្រង់ បើទោះជាត្រូវបានពួកគេយកមកហើយដូច្នោះខ្ញុំក៏នឹងរំដោះពួកគេ!

គ្រីស្ទាន៖ការអត់ធ្មត់របស់គាត់នៅពេលបច្ចុប្បន្ននេះគឺដើម្បីរំដោះពួកគេ ជាគោលបំណងដើម្បីសាកល្បងសេចក្តីស្រឡាញ់របស់ពួកគេ ថាពួកគេនឹងនៅជាប់ជាមួយនឹងទ្រង់ដល់ទីបញ្ចប់ដែរទេ។ ហើយមកដល់ទីបញ្ចប់ដែលអាក្រក់ដែលពួកគេមកដល់វិញ នោះជាការដែលពេញដោយសិរីរុងរឿងបំផុតរបស់ពួកគេ។ ដោយសារសេចក្តីប្រោសលោះនាពេលបច្ចុប្បន្ន ពួកគេមិនបានសង្ឃឹមអ្វីច្រើនទេ ដោយសារពួកគេរំពឹងចង់បានសិរីរុងរឿងរបស់

ពួកគេ ហើយបន្ទាប់មកនោះគេនឹងទទួលបាន នៅពេលដែលព្រះអង្គម្ចាស់របស់ពួកគេយាងមក ជាមួយនឹងសិរីល្អរបស់ពួកទេវតាផង។

អាប៉ូឡូអុង៖ អ្នកបានស្មោះត្រង់នៅក្នុងការបម្រើទៅដល់ទ្រង់រួចហើយ ហើយហេតុអ្វីបានជាអ្នកគិតថានឹងទទួលឈ្នួលរបស់ទ្រង់ដូច្នេះ?

គ្រីស្ទាន៖ ឱអាប៉ូឡូអុងអើយ តើខ្ញុំមិនបានស្មោះត្រង់នឹងទ្រង់នៅត្រង់ណា?

អាប៉ូឡូអុង៖ អ្នកបានដួលកាលពីចេញមកដំបូង នៅពេលដែលអ្នកស្ទើរតែដាច់ខ្យល់នៅឯរណ្តៅនៃការចុះខ្សោយខាងវិញ្ញាណ។ អ្នកមានបំណងទៅតាមផ្លូវខុស ដើម្បីដោះបន្ទុករបស់អ្នកចេញ ជាកន្លែងដែលអ្នកមិនគួរស្នាក់នៅឡើយ ទាល់តែព្រះអម្ចាស់របស់អ្នកយកបន្ទុកនោះចេញ។ អ្នកបានដេកដោយធ្វើបាប ហើយបាត់បង់របស់ល្អៗរបស់អ្នក។ ហើយអ្នកស្ទើរតែត្រូវទាក់ទាញឱ្យត្រឡប់ក្រោយវិញដោយសារឃើញសត្វតោ។ ហើយនៅពេលដែលអ្នកនិយាយពីការធ្វើដំណើររបស់ព្រះ និងការដែលអ្នកបានឮនិងបានឃើញ អ្នកប៉ងប្រាថ្នាចង់បានសិរីល្អដែលឥតប្រយោជន៍នៅក្នុងការដែលអ្នកនិយាយនិងធ្វើផងនៅក្នុងចិត្ត។

គ្រីស្ទាន៖ ការទាំងនេះសុទ្ធតែត្រូវ ហើយមានការជាច្រើនទៀតដែលអ្នករំលង តែព្រះអម្ចាស់ដែលខ្ញុំបម្រើ និងគោរព ទ្រង់មានមេត្តាករុណា និងរួចរាល់ដើម្បីអត់ទោសឱ្យ។ តែក្រៅពីនោះ ជំងឺទាំងនេះបានមកលើខ្ញុំនៅក្នុងប្រទេសរបស់អ្នក។ ដោយសារនៅទីនោះខ្ញុំបានជញ្ជក់វាចូល ហើយខ្ញុំបាន

ទូញសោកដោយសារការទាំងនោះ ហើយសោកស្ដាយនឹងការនោះ ហើយក៏បានទទួលការអត់ទោសពីព្រះអម្ចាស់របស់ខ្ញុំ។

អាប៉ូឡូអុង៖ បន្ទាប់មកអាប៉ូឡូអុងបានយំស្រែកយ៉ាងក្រៃលែង ដោយនិយាយថា "ខ្ញុំជាសត្រូវនឹងព្រះអម្ចាស់នេះ។ ខ្ញុំស្អប់អង្គទ្រង់ ក្រិត្យវិន័យទ្រង់ និងរាស្ត្ររបស់ទ្រង់។ ខ្ញុំបានចេញមកដោយមានបំណងដើម្បីយកឈ្នះលើអ្នក។"

គ្រីស្ទាន៖ អាប៉ូឡូអុងអើយ ចូរប្រយ័ត្ននឹងអ្វីដែលអ្នកធ្វើ ដោយសារខ្ញុំកំពុងនៅលើផ្លូវធំរបស់ស្តេច ជាផ្លូវនៃសេចក្ដីបរិសុទ្ធ ដូច្នេះចូរប្រយ័ត្នខ្លួនអ្នកផង!

អាប៉ូឡូអុង៖ បន្ទាប់មកអាប៉ូឡូអុងបានដើរកាត់ទទឹងផ្លូវទាំងមូលហើយនិយាយថា "ខ្ញុំគ្មានការភ័យខ្លាចក្នុងរឿងនេះទេ សូមត្រៀមខ្លួនស្លាប់ទៅ! ដ្បិតខ្ញុំបានស្បថដោយរូងដ៏រំខាងរបស់ខ្ញុំថា អ្នកនឹងមិនទៅណាឆ្ងាយទេ! ។" នៅទីនេះ អញនឹងបង្ហូរព្រលឹងរបស់ឯង ហើយក៏បានបាញ់ព្រួញភ្លើងទៅទ្រូងរបស់គាត់។ ប៉ុន្តែគ្រីស្ទានមានខែលមួយនៅក្នុងដៃរបស់គាត់ដែលគាត់បានចាប់យក ហើយបានការពារពីគ្រោះថ្នាក់នោះ។ គ្រីស្ទានបានគួរដោយសារគាត់បានមើលឃើញថា វាជាពេលវេលាដែលគាត់ត្រូវចាប់ផ្ដើមធ្វើការហើយ។ នោះអាប៉ូឡូអុងចាប់ផ្ដើមបាញ់ព្រួញទៅគាត់យ៉ាងលឿនដែលក្រាស់ដូចព្រិល។ ដោយអ្វីដែលគ្រីស្ទសាសនាអាចធ្វើបាន មិនអាចគេចរួចពីអាប៉ូឡូអុង។ នោះអាប៉ូឡូអុងបានធ្វើឱ្យគាត់បានរងរបួសត្រង់ក្បាលដៃនិងជើង។ នេះបានធ្វើឱ្យគ្រីស្ទានផ្ដល់ឱ្យត្រឡប់មកវិញតិចតួចដែរ។ ដូច្នេះអាប៉ូឡូអុងបានដើរតាមការងាររបស់គាត់យ៉ាងខ្លាំង ហើយគ្រីស្ទា

នក៏មានភាពក្លាហានម្តងទៀត ហើយបានតស៊ូយ៉ាងអង់អាចតាមដែលអាចធ្វើទៅបាន។ ការប្រយុទ្ធដ៏ស្វិតស្វាញនេះបានអូសបន្លាយអស់រយៈពេលជាងកន្លះថ្ងៃ ហើយរហូតដល់គ្រីស្ទានស្ទើរតែត្រូវចំណាយកម្លាំងច្រើន។ ដោយសារអ្នកដឹងថាគ្រីស្ទាន ដោយសាររបួសរបស់គាត់ ក៏ត្រូវបានចុះខ្សោយទៅៗផង។

បន្ទាប់មកអាប៉ូឡែអុងដែលឆ្លៀតឱកាសរបស់គាត់ បានចាប់ផ្តើមប្រមូលមកជិតនឹងគ្រីស្ទាន ហើយការប្រយុទ្ធជាមួយគាត់បានធ្វើឱ្យគាត់ដួលរលំគួរឱ្យខ្លាច។ ហើយជាមួយនោះ ដាវរបស់គ្រីស្ទានបានហោះចេញពីដៃរបស់គាត់។ បន្ទាប់មក អាប៉ូឡែអុងបាននិយាយថា"ខ្ញុំដឹងច្បាស់ពីអ្នកហើយឥឡូវនេះ" ដូចនោះគាតគាត់បានសង្កត់គាត់ស្ទើរតែដល់ស្លាប់ ដូច្នេះគ្រីស្ទានចាប់ផ្តើមអស់សង្ឃឹមនៃជីវិត។ ប៉ុន្តែដូចជាព្រះទ្រង់ចង់បានដែរខណៈពេលដែលអាប៉ូឡែអុងបានវាយជាចុងក្រោយ ដើម្បីធ្វើឱ្យបញ្ចប់ជីវិតគ្រីស្ទានដ៏ល្អម្នាក់នេះ គ្រីស្ទានបានលូកដៃទៅដាវរបស់គាត់ហើយចាប់វាមក ដោយនិយាយថា" ឱ! កុំរីករាយនឹងខ្ញុំឡើយ! ខ្មាំងសត្រូវពេលខ្ញុំដួល ខ្ញុំនឹងក្រោកឡើង។"

"ឱខ្មាំងសត្រូវអើយ កុំឱ្យសប្បាយចិត្តពីដំណើរខ្ញុំឡើយ កាលណាខ្ញុំដួល នោះខ្ញុំនឹងក្រោកឡើងវិញ កាលណាខ្ញុំអង្គុយក្នុងទីងងឹត នោះព្រះយេហូវ៉ានឹងជាពន្លឺដល់ខ្ញុំ។" មីកា 7:8

ហើយដូចនោះក៏បានផ្តល់ការវាយប្រហារគាត់ស្ទើរស្លាប់ ដែលធ្វើឱ្យគាត់ចុះចាញ់ ដូចជាម្នាក់ដែលបានទទួលរបួសខាងលោកិយ។ គ្រីស្ទានយល់ថា វា

បានធ្វើឱ្យគាត់និយាយម្តងទៀតថា "នៅក្នុងគ្រប់ការទាំងនេះ យើងប្រសើរជាងអ្នកមានជ័យជម្នះផង តាមរយៈទ្រង់ដែលបានស្រឡាញ់ដល់យើង។"

‟ទេ គឺនៅក្នុងសេចក្តីទាំងនោះ យើងខ្ញុំវិសេសលើសជាងអ្នកដែលមានជ័យជម្នះទៅទៀត ដោយសារព្រះអង្គដែលទ្រង់ស្រឡាញ់យើង។˝ រ៉ូម 8:37

ដូចនោះ អាប៉ូឡូអ៊ុងក៏បានពន្លាស្លាបនាគរបស់គេចេញមក ហើយបានហោះចេញបាត់ទៅ

‟ដូច្នេះ ត្រូវចុះចូលចំពោះព្រះ ហើយតស៊ូនឹងអារក្សវិញចុះ នោះវានឹងរត់ចេញពីអ្នកពាលគ្នាទៅ។˝ យ៉ាកុប 4:7
នោះគ្រីស្ទានក៏លែងបានឃើញគាត់ទៀតទៅ។

នៅក្នុងការប្រយុទ្ធនេះ គ្មាននរណាម្នាក់អាចស្រមៃគិតដល់បានទេ លើកលែងតែគាត់បានឃើញនិងធ្វើដូចដែលខ្ញុំបានជួប។ អ្វីដែលជាសម្រែកនិងគ្រហឹមរបស់អាប៉ូឡូអ៊ុង បានធ្វើគ្រប់ពេលនៃការប្រយុទ្ធគឺ - គាត់និយាយដូចជានាគ ហើយភាគីម្ខាងទៀត អ្វីដែលស្រែកថ្ងូរនិងថ្ងូរចេញពីដួងចិត្តរបស់គ្រីស្ទាន។ ខ្ញុំមិនដែលឃើញគាត់គ្រប់ពេលវេលាមើលទៅគួរឱ្យរីករាយដូចនេះ រហូតដល់គាត់ដឹងថាគាត់បានបង្ករបួសដល់អាប៉ូឡូអ៊ុងដោយដាវមុខពីររបស់គាត់ បន្ទាប់មក គាត់បានញញឹមហើយមើលទៅខាងលើ។ ប៉ុន្តែការមើលឃើញរូបភាពដ៏គួរឱ្យខ្លាចបំផុតដែលខ្ញុំធ្លាប់បានឃើញ!

ដូច្នេះនៅពេលដែលការប្រយុទ្ធបានបញ្ចប់ គ្រីស្ទានបាននិយាយថា"ខ្ញុំនឹងអរព្រះគុណដល់ព្រះអង្គដែលបានរំដោះខ្ញុំចេញពីមាត់តោ ដល់ទ្រង់ដែលបានជួយខ្ញុំវាយប្រឆាំងនឹងអាប៉ូឡេអុង។ ដូច្នេះគាត់និយាយថា

"បីលសេប៊ុលដ៏អស្ចារ្យ ជាមេលើកូនចៅមួយនេះ បានរៀបចំសេចក្តីវិនាសរបស់ខ្ញុំ។ ដូច្នេះមកដល់ទីបញ្ចប់នេះ គាត់បានបំពាក់គេឱ្យចេញមក ហើយដោយកំហឹងយ៉ាងអាក្រក់នោះ បានមករកខ្ញុំយ៉ាងខ្លាំង។ តែមានពរហើយមីកែលដែលបានជួយដល់ខ្ញុំ ហើយដោយមុខដាវបានធ្វើឱ្យគាត់ហោះទៅយ៉ាងលឿន។ ដូច្នេះសូមឱ្យខ្ញុំបានថ្វាយការសរសើរដល់ទ្រង់អស់កល្បជានិច្ច និងការអរគុណ ហើយនឹងសរសើរនាមបរិសុទ្ធរបស់ទ្រង់ជានិច្ច!"

បន្ទាប់មកមានដៃមួយមកកាន់គាត់ ដែលមានស្លឹកឈើនៃដើមជីវិត ដែលគ្រីស្ទានយកមក ហើយបានលាបវាទៅរបួសដែលគាត់បានទទួលនៅក្នុងសមរភូមិ ហើយត្រូវបានជាសះស្បើយភ្លាមៗ។ គាត់ក៏បានអង្គុយនៅកន្លែងនោះរួចញ៉ាំនំប៉័ងនិងផឹកពីដបដែលត្រូវបានផ្តល់ឱ្យគាត់ពីមុន។ ដូច្នេះលោកបានធូរស្បើយឡើងវិញ ហើយលោកក៏រៀបចំខ្លួននឹងធ្វើដំណើរដោយកាន់ដាវនៅដៃលោក។ លោកមានប្រសាសន៍ថា "ខ្ញុំមិនដឹងទេថាខ្មាំងសត្រូវខ្លះទៀតអាចជានៅជិត"។ ប៉ុន្តែគាត់មិនបានជួបអ្នកណាផ្សេងទៀត ក្រៅពីអាប៉ូឡេអុងឡើយនៅតាមជ្រលងភ្នំនេះ។

## ជ្រលងភ្នំនៃម្លប់សេចក្តីស្លាប់

ពេលនេះនៅទីបញ្ចប់នៃជ្រលងភ្នំ ដែលមានឈ្មោះថា ជ្រលងភ្នំនៃសេចក្តីស្លាប់ ដែលគ្រីស្ទានត្រូវដើរកាត់នោះ ពីព្រោះផ្លូវទៅកាន់ទីក្រុងស្ថានសួគ៌ដែលលាតសន្ធឹងនៅកណ្តាលជ្រលងភ្នំនោះ។ ពេលនេះ ជ្រលងភ្នំនេះជាទីដែលស្ងាត់ជ្រងំ ដែលហោរាយេរេមាបានរៀបរាប់ថា "ទីរហោស្ថាន ជាទឹកដីទីរហោស្ថាននិងរណ្តៅ ជាទឹកដីដែលមានគ្រោះអត់ឃ្លាន និងជាម្លប់សេចក្តីស្លាប់ ជាទឹកដីដែលមនុស្ស (មានតែគ្រីស្ទានប៉ុណ្ណោះ) ដែលឆ្លងកាត់តាមនោះ ហើយជាទីដែលគ្មានមនុស្សណារស់នៅសោះ។"

**"គេក៏មិនបានសួរថា ព្រះយេហូវ៉ាដែលនាំយើងរាល់គ្នាឡើងចេញពីស្រុកអេស៊ីបមក ហើយបាននាំយើងដើរកាត់ទីរហោស្ថាន ជាកន្លែងដែលមានសុទ្ធតែវាលខ្សាច់និងជង្ហុក គឺជាទីមានតែដីហួតហែង និងម្លប់នៃសេចក្តីស្លាប់ទទេ ជាកន្លែងឥតមានមនុស្សដើរកាត់ ឬមនុស្សណាអាស្រ័យនៅឡើយ។ តើទ្រង់នៅឯណា?" យេរេមា 2:6**

ពេលនេះគ្រីស្ទានកាន់តែលំបាកទៅ លំបាកជាងការវាយជាមួយនឹងអាប៉ូឡែអុងទៅទៀត ជាលទ្ធផលដែលអ្នកនឹងត្រូវជួប។

ខ្ញុំបានឃើញនៅក្នុងសុបិនរបស់ខ្ញុំបន្ទាប់មកថា នៅពេលដែលគ្រីស្ទានបានទៅដល់ព្រំប្រទល់នៃម្លប់សេចក្តីស្លាប់ នៅទីនោះបានជួបមនុស្សពីរនាក់ ជាកូនៗដែលបាននាំដំណឹងអាក្រក់ពីទឹកដីដែលល្អ ដែលធ្វើឱ្យត្រឡប់ទៅវិញយ៉ាងរហ័ស។

"អ្នកទាំងនោះក៏បង្កបង្កើតរឿងអាក្រក់ពីស្រុកដែលគេបានសង្កេតមើលនោះ ដោយប្រាប់ដល់ពួកកូនចៅអ៊ីស្រាអែលថា ស្រុកដែលយើងបានដើរកាត់ ហើយសង្កេតមើលនោះ ជាស្រុកដែលបង្ហិនបង្ហោចដល់អ្នកដែលអាស្រ័យនៅ។ ឯមនុស្សដែលយើងឃើញទាំងប៉ុន្មានក៏សុទ្ធតែមានមាឌធំៗ។" ជនគណនា 13:32

ដែលគ្រីស្ទានបាននិយាយដូច្នេះទៅកាន់ពួកគេ

គ្រីស្ទាន៖ តើអ្នកកំពុងទៅណា?

បុរសទាំងពីរ៖ ពួកគេបាននិយាយថា "ត្រឡប់ក្រោយៗ ហើយយើងចង់ឱ្យអ្នកធ្វើដូចនេះដែរ ប្រសិនបើជាអ្នកឱ្យរង្វាន់ជាជីវិត ឬជាសេចក្ដីសុខសាន្តនោះ។"

គ្រីស្ទាន៖ គ្រីស្ទានបាននិយាយថា "តើមានបញ្ហាអ្វីទៅ?"

បុរសទាំងពីរ៖ "បញ្ហា?" ពួកគេបានពោលថា "យើងបានធ្វើដំណើរតាមផ្លូវដែលអ្នកកំពុងទៅដែរ ហើយបានទៅដល់ឆ្ងាយ ហើយតាមពិតទៅយើងទៅជិតផុតក៏ត្រឡប់មកវិញ ដោយសារបើយើងបានទៅឆ្ងាយបន្តិច នោះយើងមិនអាចនឹងយកដំណឹងមកប្រាប់អ្នកនៅទីនេះទេ។"

គ្រីស្ទាន៖ តើហេតុអ្វីទៅ គឺយើងស្ទើរតែនៅក្នុងជ្រលងភ្នំនៃម្លប់សេចក្ដីស្លាប់ហើយ។

**"ទោះបើទ្រង់បានបំបាក់បំបែកយើងខ្ញុំ នៅទីរបស់ឆ្កែព្រៃ ហើយគ្របយើងខ្ញុំ ដោយម្លប់នៃសេចក្តីស្លាប់ក៏ដោយ។" ទំនុកដំកើង 44:19**

**"ឯអស់អ្នកដែលអង្គុយនៅទីងងឹត ហើយក្នុងម្លប់នៃសេចក្តីស្លាប់ ជាពួកអ្នកដែលជាប់មានសេចក្តីវេទនា ហើយនឹងចំណងច្រវាក់។" ទំនុកដំកើង 107:10**

ប៉ុន្តែជាការល្អយើងបានមើលទៅខាងមុខយើង ហើយបានឃើញគ្រោះថ្នាក់មុខដែលយើងទៅដល់វា។

គ្រីស្ទានៈ គ្រីស្ទានបានពោលថា "តើអ្នកបានឃើញអ្វីដែរ?"

បុរសទាំងពីរៈ ឃើញ! គឺជ្រលងភ្នំនោះ ដែលងងឹតដូចជារណ្តៅ។ នៅទីនោះយើងក៏បានឃើញយមបាល

**បុរសទាំងពីរៈ** បានឃើញ! ដោយជ្រលងភ្នំនោះ ដែលងងឹតដូចជម្រាលភ្នំ។ យើងក៏បានឃើញនៅទីនោះយមបាល សត្វរុយ និងសត្វនាគរណ្តៅ។ យើងក៏បានស្លាប់ឮនៅក្នុងជ្រលងភ្នំនោះនូវសម្លេង ដែលស្រែកថ្ងូរឥតឈប់ឈរ ដូចប្រជាជនមានទុក្ខវេទនាដែលគ្មាននរណាអាចវាស់បាន។ ហើយនៅលើជ្រលងភ្នំនោះមានពពកដ៏គួរឱ្យសង្វេគនៃភាពច្របូកច្របល់។ សេចក្តីស្លាប់ក៏បានត្រដាងស្លាបរបស់វាលើនោះដែរ។ និយាយម៉្យាងវាគួរអោយខ្លាចណាស់ ដោយគ្មានសណ្តាប់ធ្នាប់។

"សូមឱ្យថ្ងៃដែលខ្ញុំកើតមកត្រូវវិនាសទៅ គឺជាយប់ដែលគេប្រកាសថា មានកូនមកចាប់ផ្ទៃនោះ។" យ៉ូប 3:5

"ជាស្ថានដែលងងឹតឈឹងដូចជាយប់ជ្រៅ ជាទីម្លប់នៃសេចក្តីស្លាប់ ដែលឥតមានរបៀបអ្វី ជាកន្លែងដែលទាំងពន្លឺ ក៏ដូចជាកណ្តាលអាធ្រាតដែរ។" យ៉ូប 10:22

គ្រីស្ទាន៖ បន្ទាប់មកគ្រីស្ទាននិយាយថា "ខ្ញុំមិនទាន់យល់ឃើញនូវឡើយ ដោយអ្វីដែលអ្នកបាននិយាយ តែនោះជាផ្លូវរបស់ខ្ញុំទៅកាន់ស្ថានដែលប្រាថ្នាចង់បាន។"

បុរសទាំងពីរ៖ "សុំឱ្យវាជាផ្លូវរបស់អ្នកចុះ យើងនឹងមិនរើសយកវាធ្វើជារបស់យើងឡើយ" ដូច្នេះពួកគេក៏បានចែកផ្លូវទៅ ហើយគ្រីស្ទានបានទៅតាមផ្លូវរបស់គាត់ តែគាត់នៅតែកាន់ដាវនៅជាប់នឹងដៃរបស់គាត់ដដែល ដោយខ្លាចថាគាត់នឹងត្រូវគេធ្វើបាប។

បន្ទាប់មកខ្ញុំបានឃើញសុបិនរបស់ខ្ញុំថា រហូតមកដល់ជ្រលងភ្នំនេះ ដែលខាងស្តាំដៃនោះមានរណ្តៅជ្រៅ។ រណ្តៅនោះគឺជាកន្លែងដែលមនុស្សខ្វាក់បានដឹកនាំមនុស្សខ្វាក់គ្រប់វ័យឱ្យចូលទៅ ហើយបានស្លាប់ទាំងពីរនាក់នៅទីនោះ។ ជាថ្មីម្តងទៀត មើលខាងឆ្វេងដៃ ក៏មានភក់ដ៏គ្រោះថ្នាក់ ដែលសូម្បីតែមនុស្សល្អដួលដែរ ក៏មិនអាចរកបាតសម្រាប់នឹងជើងរបស់គាត់ឈរបានដែរ។ គ្រានោះស្តេចដាវីឌក៏បបានដួលម្តងដែរ។ ហើយគ្មាននរណាម្នាក់

សង្ស័យថាបានបាក់បែកខ្ទេចខ្ទីឡើយ ហើយនឹងមានអ្នកដែលអាចយកគាត់ចេញពីទីនោះបានដែរ ។

**"សូមស្រង់ទូលបង្គំឡើងចេញពីល្បាប់ កុំឱ្យទូលបង្គំផុងចុះទៅឡើយ សូមប្រោសឱ្យទូលបង្គំបានរួចពីពួក ដែលស្អប់ទូលបង្គំ ហើយពីទឹកជ្រៅផង។"**
**ទំនុកដំកើង 69:14**

ផ្លូវនៅទីនេះក៏មានផ្លូវចង្អៀតខ្លាំងផងដែរ ហេតុដូច្នេះហើយគ្រីស្ទានល្អកាន់តែផ្តោតទៅលើវាថែមទៀត។ ព្រោះនៅពេលដែលគាត់បានស្វែងរកនៅទីងងឹត ដើម្បីចៀសវាងពីរណ្តៅនៅដៃម្ខាង គាត់បានត្រៀមខ្លួនរួចហើយដើម្បីបោះចូលទៅក្នុងភក់ដៃម្ខាងទៀត។ នៅពេលដែលគាត់ព្យាយាមគេចខ្លួនចេញពីភក់ដោយគ្មានការប្រុងប្រយ័ត្នខ្ពស់ នោះគាត់ក៏បានត្រៀមខ្លួនធ្លាក់ចូលប្រឡាយភក់ជាស្រេច។ គាត់បន្តដំណើរទៅមុខទៀត ហើយខ្ញុំបានឮគាត់ស្រែកថ្ងូរយ៉ាងខ្លាំង។ ក្រៅពីគ្រោះថ្នាក់ដូចដែលបានរៀបរាប់ខាងលើ ផ្លូវនៅទីនេះងងឹតយ៉ាងខ្លាំងហើយនៅពេលដែលគាត់លើកជើងឡើងឆ្ពោះទៅមុខ នោះគាត់មិនដឹងថាទីណា ឬនៅលើអ្វី ដែលគាត់គួរដាក់វាបន្ទាប់ទេ។

ប្រហែលជានៅកណ្តាលជ្រលងភ្នំនេះ ខ្ញុំយល់ថាជាមាត់នរក ហើយវាបញ្ឈរនៅផ្លូវនោះយ៉ាងរឹងមាំដែរ។ ឥឡូវនេះគ្រីស្ទានគិតថា តើខ្ញុំត្រូវធ្វើអ្វី? ហើយអណ្តាតភ្លើងនិងផ្សែងនឹងចេញមកយ៉ាងច្រើនសន្ធឹកសន្ធាប់ ដោយមានផ្កាភ្លើងនិងសំលេងរំខាន (អ្វីដែលមិនយកចិត្តទុកដាក់ចំពោះដាវរបស់គ្រីស្ទាន ដូចជាអាប៉ូឡេអុងពីមុនដែរ) ដែលថាគាត់ត្រូវបានគេបង្ខំឱ្យលើកដាវរបស់

គាត់ ហើយយកអាវុធមួយផ្សេងទៀត ដែលគេហៅថា "ការអធិស្ឋានទាំងអស់" ។

**"ព្រមទាំងប្រើសេចក្ដីអធិស្ឋាន និងសេចក្ដីទូលអង្វរគ្រប់យ៉ាង ដើម្បីអធិស្ឋានដោយព្រះវិញ្ញាណរាល់ពេលរាល់វេលា ហើយចាំយាមក្នុងនោះឯង ដោយនូវគ្រប់ទាំងសេចក្ដីខ្ជាប់ខ្ជួន និងសេចក្ដីទូលអង្វរឱ្យពួកបរិសុទ្ធទាំងអស់។" អេភេសូ 6:18**

ដូច្នេះគាត់បានយំនៅត្រចៀករបស់ខ្ញុំថា "ឱព្រះអម្ចាស់អើយ ខ្ញុំសូមអង្វរទ្រង់ឱ្យ រំដោះព្រលឹងរបស់ទូលបង្គំផង!"

**"នោះខ្ញុំបានអំពាវនាវដល់ព្រះនាមព្រះយេហូវ៉ាថា ឱព្រះយេហូវ៉ាអើយ ទូលបង្គំសូមអង្វរដល់ទ្រង់ សូមប្រោសព្រលឹងទូលបង្គំឱ្យរួចផង។" ទំនុកដំកើង 116:4**

ដូច្នេះគាត់បានបន្តដំណើរទៅមុខទៀត ប៉ុន្តែនៅតែមានអណ្ដាតភ្លើងកំពុងឆេះរាលដាលដល់គាត់។ គាត់ក៏បានលឺសំលេងនិងវិលវល់ទៅមក។ ពេលខ្លះគាត់នឹកស្មានថាគាត់នឹងត្រូវបានហែកបំណែកៗ ឬជាន់ឈ្លីដូចភក់ជ្រាំនៅតាមផ្លូវ។ ការមើលឃើញដ៏គួរឱ្យភ័យខ្លាចនេះត្រូវបានបង្ហាញឱ្យឃើញ ហើយសំលេងគួរឱ្យខ្លាចទាំងនេះត្រូវបានស្លាប់ឮ ដោយគាត់នៅចម្ងាយជាច្រើនម៉ាយល៍ជាមួយគ្នា។ ហើយមកដល់កន្លែងមួយដែលគាត់គិតថា គាត់បានឮសម្លេងពពួកសត្វមួយក្រុមកំពុងតែមករកគាត់ គាត់ក៏ឈប់ ហើយចាប់ផ្ដើមធ្វើអ្វីដែលគាត់ត្រូវធ្វើបំផុត។ ពេលខ្លះគាត់បានគិតថានឹងត្រឡប់ក្រោយវិញ។ បន្ទាប់មកគាត់បានគិតថា គាត់ប្រហែលជាមកដល់ពាក់កណ្ដាលជ្រលងភ្នំហើយ។ គាត់ក៏នឹកឃើញពីរបៀបដែលគាត់បានឆ្លងកាត់គ្រោះ

ថ្នាក់ជាច្រើនរួចទៅហើយហើយគ្រោះថ្នាក់នៃការវិលត្រឡប់អាចមានច្រើន ជាងការឆ្ពោះទៅមុខ ដូច្នេះគាត់បានសំរេចចិត្តបន្តដំណើរទៅមុខទៀត។ ប៉ុន្តែពួកសត្វនោះមើលទៅដូចជាជិតមកដល់ហើយកាន់តែជិតហើយ។ ប៉ុន្តែ នៅពេលដែលពួកគេបានមកស្ទើរតែជិតគាត់ហើយនោះ គាត់ក៏បានស្រែក យំដោយសំលេងយ៉ាងខ្លាំងថា "ខ្ញុំនឹងដើរដោយកម្លាំងរបស់ព្រះជាអម្ចាស់"។ ដូច្នេះពួកវាក៏បានត្រលប់ទៅវិញ ហើយមិនបានមកជិតទៀតឡើយ។

រឿងមួយដែលខ្ញុំនឹងមិនអនុញ្ញាតឱ្យរអិលនោះគឺ ខ្ញុំបានកត់សំគាល់ថាសព្វថ្ងៃនេះគ្រីស្ទានដ៏កំសត់មានអារម្មណ៍ច្របូកច្របល់ណាស់ ដែលគាត់មិនស្គាល់សម្លេងរបស់ខ្លួន។ ដូច្នេះក៏ខ្ញុំដឹងអំពីរឿងនេះ លុះពេលដែលគាត់ទៅដល់មាត់រណ្តៅដែលកំពុងឆេះ មនុស្សម្នាក់នៅក្នុងចំណោមមនុស្សអាក្រក់បានដើរតាមពីក្រោយគាត់ ហើយបោះជំហានមកកាន់គាត់យ៉ាងស្ងាត់ៗ ហើយបានពោលពាក្យប្រមាថព្រះជាម្ចាស់យ៉ាងក្រអឺតក្រទមជាខ្លាំង ដែលលោកស្មានថាបានចេញមកពីគំនិតរបស់លោកផ្ទាល់។ នេះបានធ្វើឱ្យគ្រីស្ទាន រឹតតែពិបាកជាងអ្វីៗទាំងអស់ដែលគាត់បានជួបពីមុន! សូម្បីតែគិតថាគាត់គួរតែប្រមាថដល់ទ្រង់ ដែលគាត់ស្រឡាញ់ខ្លាំងពីមុន! ប៉ុន្តែតើគាត់អាចគេចពីការនោះបានទេ ថាគាត់នឹងមិនធ្វើវាទេ។ ប៉ុន្តែគាត់មិនបានសំរេចចិត្ត ហើយក៏មិនបញ្ឈប់ត្រចៀក ហើយក៏មិនដឹងថាការប្រមាថទាំងនោះមកពីណាដែរ។

នៅពេលគ្រីស្ទានបានធ្វើដំណើរក្នុងសភាពមិនសប្បាយរីករាយអស់ពេលល្មមដែរ គាត់បានគិតថាគាត់បានឮសម្លេងបុរសម្នាក់ ដែលដើរនៅខាងមុខ

គាត់និយាយថា "បើទោះជាខ្ញុំដើរកាត់ជ្រលងនៃស្រមោលសេចក្តីស្លាប់ ខ្ញុំនឹងមិនខ្លាចការអាក្រក់ឡើយ ដោយសារទ្រង់គង់នៅជាមួយខ្ញុំ។"

**"អើ ទោះបើទូលបង្គំដើរកាត់ច្រកភ្នំនៃម្លប់សេចក្តីស្លាប់ក៏ដោយ គង់តែមិនខ្លាចសេចក្តីអាក្រក់ណាឡើយ ដ្បិតទ្រង់គង់នៅជាមួយនឹងទូលបង្គំ ព្រនង់ហើយនឹងដំបងរបស់ទ្រង់កំសាន្តចិត្តទូលបង្គំ។" ទំនុកដំកើង 23:4**

បន្ទាប់មកគាត់ក៏រីករាយ ហើយដោយហេតុផលនោះក៏

ទីមួយ ដោយសារគាត់បានប្រមូលពីពេលនោះមកថា មនុស្សដែលកោតខ្លាចដល់ព្រះបាននៅក្នុងជ្រលងភ្នំនេះដូចជាខ្លួនគាត់ដែរ។

ទីពីរ ដោយការនោះគាត់បានយល់ឃើញថា ព្រះបានគង់នៅជាមួយពួកគេ បើទោះជានៅក្នុងសភាពដែលងងឹតនិងវេទនាបែបនោះក៏ដោយ ហើយហេតុអ្វីបានជាមិនមែនខ្ញុំដែរនោះ។ គាត់បានគិតថា បើទោះដោយសារសេចក្តីកំសោយដែលនៅកន្លែងនោះក៏ដោយ តើខ្ញុំមិនអាចដឹងការនោះទេឬអី?

**"មើល ទ្រង់យាងកាត់មុខខ្ញុំ តែខ្ញុំមិនឃើញទេ ទ្រង់ក៏យាងហួសទៅ តែខ្ញុំមិនដឹងសោះ។" យ៉ូប 9:11**

ទីបី ដោយការនោះគាត់សង្ឃឹមថា (គាត់អាចវ៉ាដាច់ពួកគេ) ដើម្បីមានគ្នាទៅ។ ដូច្នេះគាត់ក៏បន្តហៅអ្នកដែលនៅពីមុន។ ប៉ុន្តែគាត់មិនដឹងថាត្រូវឆ្លើយ

យ៉ាងណាទេ ពីព្រោះគាត់ក៏បានគិតតែខ្លួនគាត់តែម្នាក់ឯងដែរ។នោះពេលថ្ងៃក៏មកដល់ បន្ទាប់មកគ្រីស្ទានបាននិយាយថា "ទ្រង់បានប្រែស្រមោលនៃសេចក្ដីស្លាប់ទៅជាពេលព្រឹកព្រលឹមហើយ"។

**"ចូរស្វែងរកព្រះដែលទ្រង់បានបង្កើតផ្កាយកូនមាន់ និងផ្កាយនាយព្រាន ក៏ធ្វើឱ្យម្លប់នៃសេចក្តីស្លាប់ប្រែរជាព្រលឹមស្រាង ហើយឱ្យថ្ងៃត្រឡប់ជាយប់វិញ ព្រមទាំងហៅទឹកសមុទ្រមក រួចចាក់ទៅលើផែនដី។ ព្រះនាមទ្រង់គឺព្រះយេហូវ៉ា។" អេម៉ុស 5:8**

ឥឡូវនេះ ពេលព្រឹកកំពុងតែខិតមកដល់ គាត់បានក្រឡេកមើលទៅក្រោយវិញ។ មិនមានបំណងចង់ត្រឡប់មកវិញទេ ប៉ុន្តែដើម្បីមើលឃើញដោយពន្លឺថ្ងៃ តើគ្រោះថ្នាក់អ្វីដែលគាត់បានឆ្លងកាត់ក្នុងភាពងងឹត។ ដូច្នេះគាត់បានឃើញស្នាមជង្ហុក ដែលនៅជាប់នឹងនៅម្ខាង និងអណ្តូងដែលនៅម្ខាងទៀត។ ហើយផ្លូវដែលតូចចង្អៀតដែលនៅចន្លោះទាំងពីរនោះ។ ឥឡូវនេះគាត់បានឃើញយមបាល និង វិញ្ញាណ និងនាគនៃរណ្ដៅនោះ ប៉ុន្តែនៅឆ្ងាយពីគ្នានោះ ព្រោះពេលជិតភ្លឺ ពួកវាមិនបានចូលមកជិតទេ។ គេបានរកព្រះអង្គឃើញដូចមានចែងទុកក្នុងគម្ពីរថា "ព្រះអង្គឈ្វេងយល់អ្វីៗដែលស្ថិតនៅក្នុងទីងងឹត ហើយព្រះអង្គក៏ចាំងពន្លឺលើស្រមោលនៃសេចក្ដីស្លាប់។"

**"ទ្រង់បើកអស់ទាំងសេចក្ដីជ្រៅជ្រះចេញពីងងឹតមក ក៏នាំយកម្លប់សេចក្ដីស្លាប់ចេញមកដាក់នៅពន្លឺដែរ។" យ៉ូប 12:22**

ឥឡូវនេះ គ្រីស្ទានមានការប៉ះពាល់យ៉ាងខ្លាំងទៅនឹងសេចក្ដីប្រោសលោះរបស់គាត់ ពីគ្រោះថ្នាក់ទាំងអស់នៃផ្លូវតែម្នាក់ឯងរបស់គាត់។ គ្រោះថ្នាក់នេះទោះបីគាត់ខ្លាចវាច្រើនជាងមុនក៏ដោយ ក៏គាត់បានឃើញពួកគេកាន់តែ

ច្បាស់ដែរ ដោយសារពន្លឺនៃថ្ងៃបានធ្វើឱ្យពួកគេលេចច្បាស់មកដល់គាត់ប្រហែលជាពេលនេះព្រះអាទិត្យរះហើយ - នេះជាសេចក្ដីមេត្តាករុណាមួយទៀតចំពោះគ្រីស្ទាន។ អ្នកត្រូវកត់សំគាល់ថា ទោះបីផ្នែកទីមួយនៃជ្រលងភ្នំនៃម្លប់សេចក្ដីស្លាប់ គឺមានគ្រោះថ្នាក់ក៏ដោយ ផ្នែកទីពីរនេះដែលគាត់មិនទាន់ត្រូវទៅក៏ដោយ បើអាចធ្វើបាន វានឹងមានគ្រោះថ្នាក់ច្រើនជាងនេះទៅទៀត។ ពីកន្លែងដែលគាត់ឈរឥឡូវនេះ សូម្បីតែនៅចុងជ្រលងភ្នំក៏ដោយក៏ផ្លូវបានដាក់ពេញដោយអន្ទាក់ អន្ទាក់ជុង និងអួននៅទីនេះ។ វាដូចជាពេលដែលគាត់បានមកដល់ផ្នែកដំបូងនៃផ្លូវ គាត់មានព្រលឹងមួយពាន់ ដោយហេតុដែលពួកគេត្រូវបានគេដេញចោល។ ប៉ុន្តែដូចដែលខ្ញុំបាននិយាយនៅពេលនេះ ព្រះអាទិត្យកំពុងរះ។ បន្ទាប់មកគាត់និយាយថា "ទៀនរបស់គាត់ភ្លឺលើក្បាលខ្ញុំហើយដោយពន្លឺរបស់ទ្រង់ខ្ញុំនឹងឆ្លងកាត់ភាពងងឹត"។

**"គឺកាលចង្កៀងនៃទ្រង់បានភ្លឺមកលើក្បាលខ្ញុំ ហើយខ្ញុំបានដើរកាត់ទីងងឹតដោយសារពន្លឺទ្រង់។" យ៉ូប 29:3**

ដូច្នេះដោយសារពន្លឺនេះ គាត់បានទៅដល់ទីបំផុតនៃជ្រលងភ្នំ។ ឥឡូវនេះ ខ្ញុំបានឃើញនៅក្នុងក្ដីសុបិន្តរបស់ខ្ញុំថា នៅចុងបញ្ចប់នៃជ្រលងភ្នំនេះមានឈាម ឆ្អឹង ផេះនិងសាកសពមនុស្សនៅលាយឡំគ្នា ទាំងអ្នកធ្វើធម្មយាត្រាដែលបានទៅតាមផ្លូវនេះពីមុនផង ហើយខណៈពេលដែលខ្ញុំកំពុងស្វែងរកអ្វីដែលគួរតែជាហេតុផលនោះ។ ខ្ញុំបានឃើញនៅពីមុខខ្ញុំបន្តិចជារូងភ្នំ ដែលមានយក្សពីរ គឺសម្ដេចពោប និងអ្នកកាន់សាសនា ដែលបានរស់នៅក្នុងសម័យចាស់ ដោយសាអំណាចនិងភាពផ្ដាច់ការរបស់ពួកគេ ដែលធ្វើឱ្យមាន ឆ្អឹង ឈាម ផេះជាដើមរបស់មនុស្សដែលនៅទីនោះ ដែលត្រូវបានគេ

សម្លាប់យ៉ាងសាហាវ។ ប៉ុន្តែនៅកន្លែងនេះគ្រីស្ទានបានទៅដោយគ្មានគ្រោះថ្នាក់អ្វីឡើយ ហើយដែលខ្ញុំបានឆ្ងល់ខ្លះដែរ។ ប៉ុន្តែខ្ញុំបានដឹងចាប់តាំងពីសម្តេចពោបបានស្លាប់អស់ជាយូរថ្ងៃហើយ ហើយសម្រាប់ម្នាក់ផ្សេងទៀតទោះបីជាគាត់នៅរស់ក៏ដោយ ដោយសារអាយុហើយនឹងច្រាស់ដ៏មុតរបស់គាត់ ដែលគាត់បានជួបនៅពេលនៅក្មេង គាត់បានទៅជាឆ្កួតនិងស្គឹកសន្លាក់ ដែលពេលនេះគាត់ធ្វើអ្វីមិនច្រើនជាជាងការអង្គុយនៅមាត់រូងភ្នំកំពុងញញឹមដាក់អ្នកធ្វើធម្មយាត្រា នៅពេលពួកគេដើរកាត់នោះ ហើយខាំក្រចករបស់គាត់ ពីព្រោះគាត់មិនអាចមករកពួកគេបាន។

ដូច្នេះខ្ញុំបានឃើញគ្រីស្ទានបានបន្តដំណើរទៅមុខទៀត។ នៅចំពោះមុខបុរសចំណាស់ដែលអង្គុយនៅមាត់រូងគាត់មិនអាចប្រាប់ពីអ្វីដែលត្រូវគិតនោះទេ ជាពិសេសនោះទេព្រោះគាត់បាននិយាយជាមួយគាត់ ទោះបីគាត់មិនអាចទៅតាមគាត់បានក៏ដោយ បាននិយាយថា "អ្នកនឹងមិនទៅណាឡើយ រហូតទាល់តែអ្នកច្រើនទៀតត្រូវបានដុត។" ប៉ុន្តែលោកបានរក្សាភាពស្ងប់ស្ងៀម ហើយបានដាក់ទឹកមុខយ៉ាងល្អវិញ។ ហើយដូច្នេះបានឆ្លងកាត់ទៅនិងមិនបានទទួលការឈឺចាប់ឡើយ។ បន្ទាប់មកគ្រីស្ទានបានច្រៀងចំរៀង

"ឱ ពិភពលោកនៃភាពអស្ចារ្យអើយ! ខ្ញុំមិនអាចនិយាយតិចជាងនេះទេ ថាខ្ញុំនឹងត្រូវបានរក្សានៅក្នុងសេចក្តីទុក្ខព្រួយ ដែលខ្ញុំបានជួបនៅទីនេះ! ឱ មានពរហើយដៃដែលបានរំដោះខ្ញុំពីការនោះ ពីគ្រោះថ្នាក់ដែលនៅក្នុងទីងងឹតអារក្ស នរក និងអំពើបាប ដែលបានមកកាន់ខ្ញុំកាលដែលខ្ញុំនៅក្នុងនោះ។ ពិតណាស់ អន្ទាក់ និងរណ្តៅ និង អន្ទាក់ និងសំណាញ់ ដែលនៅតាមផ្លូវ

របស់ខ្ញុំ ដែលខ្ញុំអាចនឹងត្រូវជាប់ដោយភាពល្ងង់ខ្លៅ ដែលចងរឹត និងទម្លាក់ចុះទៅ តែកាលដែលខ្ញុំនៅរស់ សូមឱ្យព្រះយេស៊ូវបានពាក់មកុដចុះ!”

## សាំញ៉ាំ

លើសពីនោះទៀត ខ្ញុំបានឃើញនៅក្នុងសុបិនរបស់ខ្ញុំថា ពេលដែលគេបន្ដដំណើរទៅ នោះស្មោះត្រង់គាប់ជួនក៏បានមើលទៅម្ខាង ក៏បានឃើញបុរសម្នាក់ឈ្មោះថា សាំញ៉ាំ ដែលកំពុងដើរពីចម្ងាយនៅក្បែរពួកគេ ដោយសារនៅទីនេះមានចន្លោះសម្រាប់ពួកគេដើរ។ គាត់ជាបុរសខ្ពស់ម្នាក់ ហើយហាក់ដូចជាគាត់មកពីចម្ងាយមិនមែននៅក្បែរឡើយ។ ទៅកាន់បុរសនេះស្មោះត្រង់បាននិយាយបែបនេះ

ស្មោះត្រង់៖ មិត្តអើយ តើទៅណា? តើអ្នកកំពុងទៅកាន់ប្រទេសនៃស្ថានសួគ៌មែនទេ?

សាំញ៉ាំ៖ ខ្ញុំកំពុងទៅកន្លែងដូចគ្នាហ្នឹងដែរ។

ស្មោះត្រង់៖ អីចឹងល្អហើយ។ អីចឹងខ្ញុំសង្ឃឹមថានឹងបានអ្នកជាគ្នាដ៏ល្អ។

សាំញ៉ាំ៖ ដោយបំណងល្អនោះខ្ញុំនឹងធ្វើជាអ្នករួមដំណើរជាមួយអ្នក។

ស្មោះត្រង់៖ អីចឹងតោះយើងទៅជាមួយគ្នា ហើយចូរយើងយកពេលមកជជែកគ្នាពីការដែលមានប្រយោជន៍វិញ។

សាំញ៉ាំ៖ ការដែលនិយាយរឿងដែលល្អជាមួយអ្នក ឬអ្នកផ្សេងទៀតសម្រាប់ខ្ញុំជាការដែលគួរទទួលយកបានណាស់។ ហើយរីករាយដែលខ្ញុំបានជួបនឹងអ្នកដែលមានទំនោរទៅរកអំពើល្អ។ ដ្បិតបើនិយាយតាមត្រង់ទៅ

មានមនុស្សតិចទេដែលចង់ចំណាយពេលរបស់ពួកគេ (កាលដែលគេនៅក្នុងការធ្វើដំណើរ) តែគេជ្រើសរើសមកនិយាយពីការដែលគ្មានប្រយោជន៍ជាង ហើយនេះជាបញ្ហាមួយមកដល់ខ្ញុំ។

ស្មោះត្រង់៖ នោះជាការមួយដែលត្រូវទួញសោកជាពិត តើការអ្វីទៅដែលមានតម្លៃសម្រាប់អណ្តាតនិងមាត់របស់មនុស្សនៅលើផែនដី ដែលជាការរបស់ព្រះនៃស្ថានសួគ៌នោះ?

សាំញ៉ាំ៖ ខ្ញុំចូលចិត្តអ្នកខ្លាំងណាស់ ដោយសារការដែលអ្នកនិយាយពេញដោយសេចក្តីជំនឿ។ ហើយខ្ញុំនឹងបន្ថែមលើហ្នឹងទៀតថា តើការអ្វីដែលគួរឱ្យគាប់ចិត្ត និងការអ្វីដែលមានប្រយោជន៍ ដែលត្រូវនិយាយពីការរបស់ព្រះនោះ?

ការអ្វីដែលគួរឱ្យពេញចិត្តនោះ? ការនោះគឺ ប្រសិនបើបុរសម្នាក់មានសេចក្តីអំណរនៅក្នុងការដែលអស្ចារ្យ ឧទាហរណ៍ដូចជា ប្រសិនបើបុរសម្នាក់ចូលចិត្តនិយាយពីប្រវត្តិសាស្ត្រ ឬពីអាថ៌កំបាំងអ្វី ឬប្រសិនបើបុរសម្នាក់ចូលចិត្តនិយាយពីការអស្ចារ្យ ការប្លែកៗ ឬនិមិត្តសញ្ញាផ្សេងៗ។ តើគាត់នឹងរកឃើញការដែលត្រូវបានកត់ត្រាទុកជាសេចក្តីអំណរ និងត្រូវបានរក្សាទុកដោយផ្អែមល្ហែមដូចជានៅក្នុងព្រះគម្ពីរបរិសុទ្ធបាននៅទីណាទៅ?

ស្មោះត្រង់៖ ពិតណាស់ តែដើម្បីទទួលបានប្រយោជន៍ពីការទាំងនោះនៅក្នុងការជជែករបស់យើង នោះជាការដែលយើងនឹងតាក់តែងទេ។

សាំញ៉ាំ៖ ហ្នឹងជាអ្វីដែលខ្ញុំបាននិយាយនោះ ដោយសារការដែលនិយាយរឿងនោះជាការដែលមានប្រយោជន៍។ ធ្វើដូច្នោះមនុស្សនឹងទទួលបានចំណេះដឹងជាច្រើន សម្រាប់ការដែលឥតប្រយោជន៍ខាងលោកិយ និងផលប្រយោជន៍នៃការពីខាងលើ (ជាទូទៅ) ប៉ុន្តែដែលជាក់លាក់នោះ ដោយការនេះម្នាក់នឹងរៀនពីភាពចាំបាច់នៃការកើតជាថ្មី ភាពខ្វះខាតនៃការប្រព្រឹត្តរបស់យើង សេចក្តីត្រូវការនូវសេចក្តីសុចរិតរបស់ព្រះគ្រីស្ទ និងការផ្សេងទៀត។ ក្រៅពីនោះ ដោយការនេះម្នាក់នឹងបានរៀនថាអ្វីដែលត្រូវតែលន់តួបាបដែលត្រូវជឿ ដែលត្រូវអធិស្ឋាន ដែលត្រូវរងវេទនា និងដែលត្រូវចូលចិត្តផង។ ដោយការនេះម្នាក់នឹងបានរៀនពីជាសេចក្តីសន្យាដ៏អស្ចារ្យ និងការលួងលោមចិត្តមកពីដំណឹងល្អ ជាការកំសាន្តចិត្តរបស់គាត់។ លើសពីនោះទៀត ដោយការនេះ ម្នាក់នឹងរៀនបដិសេធគំនិតដែលខុសឆ្គង ទៅដើរតាមសេចក្តីពិត និងណែនាំដល់មនុស្សល្ងង់ផង។

ស្មោះត្រង់៖ ការទាំងនេះសុទ្ធតែពិត ហើយខ្ញុំរីករាយនឹងស្តាប់ការទាំងនេះពីអ្នក។

សាំញ៉ាំ៖ អាក្រក់ណាស់! សេចក្តីប្រថ្នានេះជាហេតុដែលមនុស្សតិចតួចណាស់យល់ពីសេចក្តីត្រូវការខាងសេចក្តីជំនឿ ហើយភាពចាំបាច់នៃការប្រព្រឹត្តរបស់ព្រះគុណនៅក្នុងព្រលឹង ដើម្បីទទួលបានជីវិតអស់កល្បជានិច្ច។ តែរស់នៅតាមក្រិត្យវិន័យដោយមិនដឹងខ្លួន ដោយការនោះមនុស្សមិនអាចទទួលបាននគរស្ថានសួគ៌។

ស្មោះត្រង់៖ តែ ដោយការទុកចោលរបស់អ្នកនោះ ចំណេះដឹងខាងស្ថានសួគ៌នៃការទាំងនេះជាអំណោយទានរបស់ព្រះ គ្មានមនុស្សណាដែលទទួលបានដោយការប្រព្រឹត្តរបស់មនុស្សឡើយ ឬដោយការជជែករបស់ពួកគេនោះឡើយ។

សាំញ៉ាំ៖ ការទាំងនេះខ្ញុំបានដឹងច្បាស់ណាស់។ ដោយសារមិនមានអ្នកដែលបានទទួលអ្វី ក្រៅពីការដែលផ្ដល់មកពីស្ថានសួគ៌នោះទេ។ ការទាំងនេះជាព្រះគុណ មិនមែនដោយការប្រព្រឹត្តឡើយ។ ខ្ញុំអាចឱ្យខគម្ពីរដល់អ្នករាប់រយដែលនឹងបញ្ជាក់អះអាងពីការនេះ។

ស្មោះត្រង់៖ "ល្អហើយអីចឹង" ស្មោះត្រង់បាននិយាយថា "តើអ្វីទៅជាការមួយដែលយើងនឹងរកឃើញនៅក្នុងការជជែកគ្នារបស់ពួកយើងនៅពេលនេះ?"

សាំញ៉ាំ៖ អ្វីដែលអ្នកនឹងនិយាយ នោះខ្ញុំនឹងនិយាយពីការពីស្ថានសួគ៌ ឬការពីផែនដី។ ការពីសីលធម៌ ឬការបែបផ្សាយដំណឹងល្អ ពីការបរិសុទ្ធ ឬការដែលស្មោគគ្រោក ដែលពីអតីតកាល ឬការដែលនឹងត្រូវមក ការដែលមកពីសាសន៍ដទៃ ឬការដែលនៅផ្ទះ ការដែលសំខាន់ជាង ឬការដែលតាមកាលៈទេសៈ។ ដែលត្រូវបានផ្ដល់មកជាប្រយោជន៍ដល់យើង។

ស្មោះត្រង់៖ ពេលនេះស្មោះត្រង់ចាប់ផ្ដើមឆ្ងល់ ហើយក៏បោះជំហានទៅរកគ្រីស្ទាន (ដោយសារតែគាត់បានដើរតែឯងរហូតមក) បាននិយាយទៅកាន់គាត់ថា (តែនិយាយដោយថ្នមៗ) "តើអ្នករួមដំណើរដ៏ក្លាហានយ៉ាងណាហ្នឹងដែលយើងមាន! ពិតណាស់បុរសនេះនឹងធ្វើឱ្យការធ្វើធម្មយាត្រានេះល្អឥតខ្ចោះ។"

គ្រីស្ទានៈ ដូចនោះគ្រីស្ទានក៏បានញញឹមដោយស្រគត់ស្រគុំ ហើយនិយាយថា "បុរសនេះដែលបានធ្វើឱ្យអ្នកត្រូវសណ្ដំដោយសារអណ្ដាតនៃមនុស្សម្តែអ្នកនេះដែលមិនបានស្គាល់គាត់សោះ។"

ស្មោះត្រង់ៈ អីចឹង តើអ្នកស្គាល់គាត់ទេ?

គ្រីស្ទានៈ ស្គាល់គាត់! ស្គាល់គាត់ជាងដែលគាត់ស្គាល់ខ្លួនឯងផង។

ស្មោះត្រង់ៈ សូមប្រាប់មក តើគាត់ជាអ្វី?

គ្រីស្ទានៈ ឈ្មោះរបស់គាត់គឺសាំញ៉ាំ។ គាត់រស់នៅក្នុងស្រុករបស់យើង ឆ្ងល់ថាអ្នកបែរជាមិនស្គាល់គាត់វិញ ខ្ញុំគ្រាន់តែគិតថាស្រុករបស់យើងវាធំទូលាយបន្តិច។

ស្មោះត្រង់ៈ តើគាត់ជាកូនរបស់អ្នកណា? ហើយគាត់រស់នៅម្តុំណាដែរ?

គ្រីស្ទានៈ គាត់ជាកូនប្រុសរបស់ម្នាក់ឈ្មោះ និយាយបានល្អ។ គាត់រស់នៅជួរដែលនិយាយឡិឡូក់ ហើយគាត់ត្រូវបានស្គាល់ដោយគ្រប់គ្នានូវឈ្មោះសាំញ៉ាំនៅក្នុងជួរដែលនិយាយឡិឡូក់ ហើយមិនយកឈ្នះអណ្ដាតដ៏ពូកែរបស់គាត់ គាត់ជាមនុស្សដែលគួរឱ្យអាណិត។

ស្មោះត្រង់ៈ ពិតណាស់ គាត់ហាក់ដូចជាមនុស្សដែលល្អណាស់។

គ្រីស្ទានៈ គឺសម្រាប់តែអ្នកដែលមិនបានស្គាល់គាត់ច្បាស់ប៉ុណ្ណោះ ដោយសារជាល្អបំផុតនៅក្រៅប្រទេស នៅក្បែរផ្ទះវិញគាត់អាក្រក់ណាស់។

ការដែលអ្នកនិយាយថាគាត់ជាមនុស្សល្អ បាននាំឱ្យគំនិតរបស់ខ្ញុំគិតដល់ អ្វីដែលខ្ញុំបានសង្កេតនៅក្នុងកិច្ចការរបស់អ្នកផាត់ពណ៌ ដែលរូបភាពរបស់គាត់បានបង្ហាញមកយ៉ាងស្រស់ស្អាតពីចម្ងាយ តែនៅយ៉ាងជិតវិញ មិនគួរឱ្យពេញចិត្តសោះ។

ស្មោះត្រង់៖ តែខ្ញុំបានគិតថាអ្នកគ្រាន់តែនិយាយលេងប៉ុណ្ណោះ ដោយសារអ្នកញញឹម។

គ្រីស្ទាន៖ ខ្ញុំមិនបាននិយាយលេងសើចឡើយ បើទោះជាខ្ញុំញញឹមក៏ដោយនៅក្នុងបញ្ហានេះ ឬខ្ញុំត្រូវចោទប្រកាន់អ្នកណាម្នាក់ដោយខុសឆ្គងនោះឡើយ។ ខ្ញុំចង់ផ្តល់នូវការរកឃើញដែលច្រើនជាងនេះពីគាត់។ បុរសនេះគឺសម្រាប់គ្នាណាទាំងអស់ ការជជែកទាំងអស់ ដូចដែលគាត់និយាយជាមួយអ្នកពេលនេះ នោះគាត់នឹងនិយាយនៅពេលដែលគាត់នៅកន្លែងផឹកស៊ី ហើយកាលណាមានគ្រឿងស្រវឹងច្រើននៅមកុដរបស់គាត់ នឹងមានការទាំងនេះកាន់តែច្រើននៅក្នុងមាត់របស់គាត់ សាសនាមិនមាននៅក្នុងចិត្ត ឬនៅផ្ទះ ឬនៅក្នុងការសន្ទនារបស់គាត់ទេ អ្វីទាំងអស់ដែលនៅលើអណ្តាតរបស់គាត់និងសាសនារបស់គាត់ គឺជាការបង្កើតសម្លេងនឹងការនោះ។

ស្មោះត្រង់៖ អ្នកនិយាយអីចឹង! អីចឹងខ្ញុំត្រូវបុរសនេះបោកខ្លាំងហើយ។

គ្រីស្ទាន៖ ត្រូវបញ្ឆោត! អ្នកនឹងប្រាកដពីវា។ចូរចង់ចាំសុភាសិតដែលថា "ពួកគេចេះតែនិយាយ តែមិនធ្វើសោះ។ តែនគររបស់ព្រះមិនមែននៅក្នុងពាក្យសំដីទេ តែនៅក្នុងអំណាចវិញ។"

“អ្វីៗដែលគេបង្រៀនអ្នករាល់គ្នា ចូរស្តាប់ ហើយយកទៅប្រតិបត្តិតាមទៅ តែកុំយកតម្រាប់តាមអំពើដែលគេប្រព្រឹត្តឡើយ ដ្បិតគេមិនប្រតិបត្តិតាមសេចក្តីដែលគេបង្រៀននោះទេ។” **ម៉ាថាយ 23:3**

“ដ្បិតព្រះរាជ្យរបស់ព្រះជាម្ចាស់មិនមែនស្ថិតនៅលើពាក្យសម្តីទេ គឺស្ថិតនៅលើការប្រព្រឹត្តវិញ។” **កូរិនថូសទី១** 4:20

គាត់និយាយពីការអធិស្ឋាន ការលន់តួបាប សេចក្តីជំនឿ និងការកើតជាថ្មី។ តែគាត់ដឹងតែពីការនិយាយពីរឿងទាំងនោះប៉ុណ្ណោះ។ ខ្ញុំបាននៅក្នុងគ្រួសាររបស់គាត់ ហើយបានសង្កេតមើលគាត់ទាំងនៅក្នុងផ្ទះនិងខាងក្រៅផង។ ហើយខ្ញុំដឹងថាអ្វីដែលខ្ញុំបាននិយាយពីគាត់សុទ្ធតែជាការពិត។ ផ្ទះរបស់គាត់ជាសាសនាដែលទទេរ ប្រៀបបីដូចនឹងរសជាតិនៃផ្នែកសរបស់ស៊ុតដែរ។ មិនមានការអធិស្ឋាន ហើយក៏មិនមានសញ្ញានៃការប្រែចិត្តពីអំពើបាបដែរ។ គ្រឹះប្រភេទនេះបម្រើព្រះបានប្រសើរជាគាត់ផង។ គាត់ជាស្នាមប្រឡាក់ ជាការចោទប្រកាន់ និងជាសេចក្តីអាម៉ាសរបស់សាសនាដល់អស់អ្នកដែលស្គាល់គាត់។

“អ្នកអួតអាងលើក្រឹត្យវិន័យ តែអ្នកបែរជាបង្អាប់កិត្តិយសព្រះជាម្ចាស់ ដោយប្រព្រឹត្តល្មើសក្រឹត្យវិន័យ។ ដូចមានចែងទុកមកថា *ព្រោះតែអ្នករាល់គ្នាបានជាសាសន៍ដទៃប្រមាថព្រះនាមរបស់ព្រះជាម្ចាស់*។” **រ៉ូម 2:23, 24**

វាពិបាកនឹងមានពាក្យល្អៗនៅទីបញ្ចប់នៃទីក្រុងដែលគាត់រស់នៅណាស់

ដោយសារគាត់។ ដូច្នេះមនុស្សទូទៅដែលស្គាល់គាត់តែងនិយាយថា "អ្នកបរិសុទ្ធនៅខាងក្រៅ និងជាអារក្សនៅក្នុងផ្ទះ។" គ្រួសារដែលក្រីក្ររបស់គាត់ក៏ឃើញថាដូច្នោះដែរ។ គាត់ជាមនុស្សឈ្លើយ ស្រែកគំហកដាក់ ហើយមិនមានហេតុផលដល់អ្នកបម្រើរបស់គាត់ ដែលពួកគេមិនចេះធ្វើសម្រាប់គាត់ ឬនិយាយទៅគាត់ឡើយ។ អ្នកដែលមានការជាមួយគាត់ និយាយថា ជាការប្រសើរជាងដែលទៅនិយាយជាមួយនឹងជនជាតិតួគីជាងនិយាយជាមួយគាត់។ ដោយសារនៅក្នុងដៃរបស់ពួកគេមានការដោះស្រាយដែលត្រឹមត្រូវជាង។ សាំញ៉ាំនេះ បើអាចទោរួច នឹងធ្វើលើសពីពួកគេទៅទៀត ដែលបោកប្រាស់ លួងលោម ហើយយកឈ្នះពួកគេ។ ក្រៅពីនោះ គាត់បានប្រដៅកូនៗរបស់គាត់ឱ្យដើរតាមជំហានរបស់គាត់។ ហើយប្រសិនបើគាត់រកឃើញភាពភ័យខ្លាចដោយល្ងង់ខ្លៅនៅក្នុងពួកគេ (ដូចនោះគាត់ហៅថាជារូបរាងលេចមកដំបូងនៃសតិល្អ) គាត់ហៅពួកគេថាជាមនុស្សល្ងីល្ងើនិងល្ងង់ខ្លៅ ហើយនឹងប្រើពួកគេច្រើនទៀត ឬដោយនិយាយណែនាំពួកគេនៅមុខអ្នកដទៃ។ សម្រាប់ផ្នែករបស់ខ្ញុំ ខ្ញុំមានគំនិត គឺដោយជីវិតទុច្ចរិតរបស់គាត់ វាបានធ្វើឲ្យមនុស្សជាច្រើនត្រូវជំពប់ដួលនិងដួល។ ប្រសិនបើព្រះមិនហាមឃាត់ទេ មនុស្សជាច្រើនទៀតនឹងត្រូវវិនាសផងដែរ។

ស្មោះត្រង់៖ ពិតណាស់ បងប្អូនរបស់ខ្ញុំអើយ ខ្ញុំជឿអ្នកហើយ មិនមែនដោយសារអ្នកនិយាយថាអ្នកស្គាល់គាត់នោះទេ តែដោយសារ ដូចជាគ្រីស្ទានអ្នកបានធ្វើការរាយការណ៍ពីមនុស្ស។ ដោយសារខ្ញុំមិនអាចគិតបានថាអ្នកនិយាយពីការទាំងនេះដោយបំណងអាក្រក់ឡើយ តែដោយសារវាដូចជាអ្វីដែលអ្នកនិយាយហើយ។

គ្រីស្ទានៈ ខ្ញុំមិនបានស្គាល់គាត់ជាងអ្នកនោះទេ ខ្ញុំអាចនឹងគិតពីគាត់ដូចដែលអ្នកបានគិតពីដំបូងដែរ។ គាត់បានទទួលដំណឹងទាំងនេះនៅដៃរបស់ពួកគេដែលជាសត្រូវរបស់សាសនា ខ្ញុំគួរតែបានគិតថាវាជាការចោទប្រកាន់ (ដែលជាញឹកញាប់ចេញមកពីមាត់របស់មនុស្សអាក្រក់ដែលចូលទៅក្នុងគំនិតរបស់មនុស្សនិងការអះអាងរបស់ពួកគេ)។ ប៉ុន្តែការទាំងនេះនិងការជាច្រើនទៀតសុទ្ធតែអាក្រក់ដូចគ្នា ដែលដោយសារការយល់ដឹងរបស់ខ្ញុំនោះខ្ញុំអាចបញ្ជាក់ថាគាត់មានកំហុសនោះ។ ក្រៅពីនោះ មនុស្សល្អមានសេចក្តីអាម៉ាស់នឹងគាត់។ ពួកគេមិនអាចនឹងហៅគាត់ថាបងប្អូនឬជាមិត្តបានឡើយ ដោយស្មោះរបស់គាត់នៅក្នុងចំណោមពួកគេធ្វើឱ្យពួកគេអៀនខ្មាស់ប្រសិនបើពួកគេស្គាល់គាត់!

ស្មោះត្រង់៖ ពិតណាស់ ខ្ញុំឃើញថាការនិយាយនិងការធ្វើជាការពីរផ្សេងគ្នា។ ហើយបន្ទាប់មក ខ្ញុំគួរតែសង្កេតមើលការខុសប្លែកគ្នានេះ។

គ្រីស្ទានៈ ជាការពីរផ្សេងគ្នាពិតមែន ហើយដែលប្លែកគ្នាដូចជាព្រលឹងនិងរូបកាយដែរ។ ប្រសិនបើរូបកាយមិនមានព្រលឹង នោះជាសាកសពវិញ។ ដូច្នេះ ប្រសិនបើមានតែ "ការនិយាយ" តែមួយ នោះវាជាសាកសពដូចគ្នាដែរ។ ព្រលឹងរបស់សាសនាជាផ្នែកនៃការប្រព្រឹត្តនោះឯង។ "សាសនាដែលបរិសុទ្ធនិងមិនបំភ្លៃ នៅចំពោះព្រះនិងព្រះវរបិតាជាការនេះ គឺការទៅសួរសុខទុក្ខក្មេងកំព្រា និងស្រីមេម៉ាយនៅពេលដែលមានទុក្ខលំបាក និងការរក្សាខ្លួនឲ្យពីលោកិយ។"

**"ចូរប្រតិបត្តិតាមព្រះបន្ទូល កុំគ្រាន់តែស្តាប់ទាំងបញ្ឆោតចិត្តខ្លួនឯងប៉ុណ្ណោះ**

ឡើយ។ អ្នកណាស្តាប់ព្រះបន្ទូលហើយ មិនប្រតិបត្តិតាម អ្នកនោះប្រៀបបាន នឹងមនុស្សម្នាក់ឆ្លុះកញ្ចក់មើលមុខខ្លួន។ លុះពិនិត្យមើលរួចហើយ ក៏ចេញទៅ ស្រាប់តែភ្លេចមិនដឹងថាមុខខ្លួនឯងដូចម្តេចផង។ រីឯអ្នកដែលយកចិត្តទុកដាក់ ពិនិត្យមើលក្រឹត្យវិន័យដ៏គ្រប់លក្ខណៈ ជាក្រឹត្យវិន័យដែលផ្តល់សេរីភាព ហើយព្យាយាមប្រតិបត្តិតាមយ៉ាងជិតដល់ គឺមិនគ្រាន់តែស្តាប់ រួចភ្លេចអស់ ទៅ អ្នកនោះនឹងមានសុភមង្គលក្នុងកិច្ចការដែលខ្លួនធ្វើជាមិនខាន។ ប្រសិន បើនរណាម្នាក់នឹកស្មានថាខ្លួនជាអ្នកកាន់សាសនា តែមិនចេះទប់អណ្តាតខ្លួន អ្នកនោះបញ្ឆោតខ្លួនឯងហើយ ហើយសាសនាដែលខ្លួនកាន់នោះ ក៏គ្មាន ប្រយោជន៍អ្វីដែរ។ រីឯសាសនាដ៏បរិសុទ្ធ ឥតខ្ចោះនៅចំពោះព្រះភ័ក្ត្រព្រះបិតា ជាម្ចាស់វិញ គឺស្ថិតនៅលើការទៅសួរសុខទុក្ខក្មេងកំព្រា និងស្ត្រីមេម៉ាយដែល មានទុក្ខលំបាក ព្រមទាំងស្ថិតនៅលើការរក្សាខ្លួនឲ្យផុតពីអំពើសៅហ្មងរបស់ លោកីយ៍នេះ។” យ៉ាកុប 1:22-27

ស្មោះត្រង់៖ អឺចឹង ប្រសិនជាអ្នកចង់ ចូរបកស្រាយពីសញ្ញាសម្គាល់ផ្សេងទៀតនៃកិច្ចការរបស់ព្រះគុណដែលបង្ហាញមកនៅទីនេះ។

សាំញ៉ាំ៖ ទេ ដោយសារខ្ញុំឃើញថាយើងមិនត្រូវគ្នាសោះ។

ស្មោះត្រង់៖ អឺចឹង បើអ្នកមិននិយាយទេ តើអ្នកអាចឱ្យខ្ញុំនិយាយបានទេ?

សាំញ៉ាំ៖ អ្នកអាចប្រើសិរីភាពរបស់អ្នកបាន។

ស្មោះត្រង់៖ កិច្ចការរបស់ព្រះគុណបង្ហាញខ្លួនមកទាំងដល់អ្នកដែលមានវា ឬដល់អ្នកដែលចោទត្រូវវាចោទប្រកាន់ផងដែរ។ សម្រាប់អ្នកដែលមានព្រះគុណ នោះវានឹងផ្តល់នូវការផ្លាស់ប្រែចេញពីអំពើបាប ជាពិសេសភាពពុករលួយខាងធម្មជាតិរបស់គេ និងអំពើបាបដែលមិនព្រមជឿ ដែលដោយសារការទាំងនោះដែលគាត់នឹងត្រូវជំនុំជំរះ ប្រសិនបើគាត់មិនបានទទួលព្រះគុណពីព្រះហស្តរបស់ព្រះដោយសេចក្តីជំនឿលើអង្គព្រះយេស៊ូវគ្រីស្ទ។ រូបភាពនិងអត្ថន័យនៃការទាំងនេះធ្វើឱ្យគាត់មានសេចក្តីអាម៉ាសនិងទូញសោកដោយសារអំពើបាប ហើយឱ្យគាត់បានរកឃើញថែមទៀតពីព្រះអង្គសង្គ្រោះនៃលោកិយនេះ និងភាពចាំបាច់បំផុតនៅក្នុងការចូលទៅជិតទ្រង់ដើម្បីបានជីវិត ដោយសារការនោះគាត់នឹងស្រេកឃ្លានចង់បានទ្រង់ ដែលស្រេកឃ្លានជាដើម។ សេចក្តីសន្យាត្រូវបានបង្កើតមក។ ឥឡូវនេះ យោងតាមកម្លាំងនិងភាពកំសោយនៃសេចក្តីជំនឿរបស់គាត់នៅក្នុងព្រះសង្គ្រោះរបស់គាត់ នោះក៏ដូចជាសេចក្តីអំណរនិងសេចក្តីសុខសាន្តរបស់គាត់ដែរ ក៏ដូចជាសេចក្តីស្រឡាញ់របស់គាត់ដល់ភាពបរិសុទ្ធ ក៏ដូចជាបំណងប្រាថ្នារបស់គាត់ចង់

ស្គាល់ទ្រង់ថែមទៀត ហើយក៏ដូចជាចង់បម្រើទ្រង់នៅក្នុងលោកិយនេះ។ បើទោះជាខ្ញុំនិយាយថាវាបង្ហាញមកបែបនេះនៅក្នុងមនុស្សម្នាក់នោះ តែវាកើតឡើងដោយកម្រដែលគាត់អាចសរុបបានថាវាជាកិច្ចការនៃព្រះគុណ ពីព្រោះភាពពុករលួយរបស់គាត់ពេលនេះ និងដោយសារហេតុផលដែលគាត់បានបំភ្លៃ ដែលធ្វើឱ្យគាត់កាត់ស្រាយបញ្ហានេះមិនបានត្រឹមត្រូវ។ ដូច្នេះនៅក្នុងគាត់ដែលមានកិច្ចការនេះ នោះត្រូវមានការជំនុំជំរះឱ្យបានត្រឹមត្រូវ មុនពេលគាត់អាចសរុបសេចក្ដីបាននឹងធឹងថា វាជាកិច្ចការនៃព្រះគុណ។

**"កាលណាទ្រង់បានយាងមកហើយ នោះនឹងសំដែងឱ្យមនុស្សលោកដឹងច្បាស់ ពីអំពើបាប ពិសេចក្ដីសុចរិត ហើយពីសេចក្ដីជំនុំជំរះ។ គឺពីអំពើបាបដោយព្រោះគេមិនជឿដល់ខ្ញុំ។" យ៉ូហាន 16:8, 9**

**"វេទនាណាស់ខ្ញុំ តើអ្នកណានឹងជួយខ្ញុំឱ្យរួច ពីតួសេចក្ដីស្លាប់នេះទៅបាន។" រ៉ូម 7:24**

**"អ្នកណាដែលជឿ ហើយទទួលបុណ្យជ្រមុជទឹក នោះនឹងបានសង្គ្រោះ តែអ្នកណាដែលមិនព្រមជឿ នោះនឹងត្រូវទោសវិញ។" ម៉ាកុស 16:16**

**"តើឯងបានពិចារណា ឃើញទទឹងនិងបណ្ដោយនៃផែនដីឬ ចូរប្រាប់មកចុះ បើឯងដឹងសេចក្ដីទាំងអស់នេះហើយ។" ទំនុកដំកើង 38:18**

"ក្រោយដែលទ្រង់បានទាញញាក់ទូលបង្គំមកវិញ នោះទូលបង្គំបានប្រែគំនិតឡើងជាពិត កាលដែលទូលបង្គំទទួលបានសេចក្តីប្រៀនប្រដៅហើយ នោះក៏វាយទះភ្លៅខ្លួន ទូលបង្គំមានសេចក្តីខ្មាស អើក៏ជ្រប់មុខផង ពីព្រោះទូលបង្គំធន់រងសេចក្តីអាម៉ាសខ្មាសនៃវ័យក្មេង។" យេរេមា 31:19

"យើងដឹងថាមនុស្សមិនរាប់ជាសុចរិត ដោយប្រព្រឹត្តតាមក្រឹត្យវិន័យនោះឡើយ គឺដោយសេចក្តីជំនឿជឿដល់ព្រះយេស៊ូវគ្រីស្ទវិញ ហេតុនោះបានជាយើងជឿដល់ព្រះគ្រីស្ទយេស៊ូវ ដើម្បីឱ្យបានរាប់ជាសុចរិត ដោយសារសេចក្តីជំនឿជឿដល់ព្រះគ្រីស្ទ នោះមិនមែនដោយការប្រព្រឹត្តតាមក្រឹត្យវិន័យទេ ពីព្រោះគ្មានមនុស្សណាបានរាប់ជាសុចរិត ដោយប្រព្រឹត្តតាមក្រឹត្យវិន័យឡើយ។" កាឡាទី 2:16

"ហើយគ្មានសេចក្តីសង្គ្រោះ ដោយសារអ្នកណាទៀតសោះ ដ្បិតនៅក្រោមមេឃ គ្មាននាមឈ្មោះណាទៀតបានប្រទានមកមនុស្សលោក ឱ្យយើងរាល់គ្នាបានសង្គ្រោះនោះឡើយ។" កិច្ចការ 4:12

"មានពរហើយអស់អ្នកដែលស្រេកឃ្លាននូវសេចក្តីសុចរិត ដ្បិតអ្នកទាំងនោះនឹងបានឆ្អែត។" ម៉ាថាយ 5:6

"ទ្រង់ក៏មានបន្ទូលមកខ្ញុំថា ស្រេចហើយអញជាអាល់ផា និងអូមេកា គឺជាដើមហើយជាចុង បើអ្នកណាស្រេក អញនឹងឱ្យអ្នកនោះផឹកពីរន្ធទឹកនៃជីវិត ឥតយកថ្លៃ។" វិវរណៈ 21:6

"ដ្បិតយើងបានសុចរិតដោយមានចិត្តជឿ ហើយក៏បានសង្គ្រោះដោយមាត់ទទួលថ្លែងប្រាប់។" រ៉ូម 10:10

"បងប្អូនអើយ ចូរត្រាប់តាមខ្ញុំគ្រប់គ្នា ហើយពិចារណាមើលឱ្យស្គាល់ពួកអ្នកដែលដើរ ដូចជាយើងបានធ្វើក្បួនឱ្យអ្នករាល់គ្នាហើយ។" ភីលីព 3:17

"មានពរហើយអស់អ្នកដែលមានចិត្តបរិសុទ្ធ ដ្បិតអ្នកនោះនឹងបានឃើញព្រះ។" ម៉ាថាយ 5:8

សម្រាប់ការផ្សេងទៀត វាបង្ហាញមកដូច្នេះ
1. ដោយសារការសារភាពសេចក្ដីជំនឿរបស់គាត់នៅក្នុងព្រះយេស៊ូវគ្រីស្ទបែបពិសោធន៍។ 2. ដោយជីវិតដែលឆ្លើយតបទៅនឹងការសារភាព ដែលរស់នៅក្នុងជីវិតដែលបរិសុទ្ធ ចិត្តបរិសុទ្ធ គ្រួសារដែលបរិសុទ្ធ (ប្រសិនបើគាត់មានគ្រួសារ) ហើយដោយការសន្ទនាដែលបរិសុទ្ធនៅក្នុងលោកនេះ ដែលជាទូទៅបង្រៀនគាត់ឱ្យស្អប់អំពើបាបរបស់គាត់ខាងក្នុង និងខ្លួនគាត់ដោយសារការទាំងនោះជាសម្ងាត់ ត្រូវលុបបំបាត់វាចេញពីក្រុមគ្រួសារ ហើយលើកស្ទួយភាពបរិសុទ្ធនៅក្នុងលោកិយនេះវិញ មិនមែនគ្រាន់តែនិយាយតែម្យ៉ាងនោះទេ ដែលដូចជាមនុស្សកំពុត ឬមនុស្សសាំញ៉ាំធ្វើនោះទេ តែដោយការប្រព្រឹត្តដោយសេចក្ដីជំនឿនិងសេចក្ដីស្រឡាញ់ដោយអំណាចរបស់ព្រះបន្ទូល។

"បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ចូរកាន់តាមបញ្ញាត្តិរបស់ខ្ញុំចុះ។" យ៉ូហាន 14:15

"អ្នកណាដែលថ្វាយដង្វាយជាសេចក្តីអរព្រះគុណ នោះក៏លើកដំកើងអញដែរ ហើយអញនឹងសម្តែងសេចក្តីសង្គ្រោះរបស់ព្រះដល់អ្នកណាដែលរៀបផ្លូវរបស់ខ្លួនឱ្យត្រង់។" ទំនុកដំកើង 50:23

"កាលពីដើមត្រចៀករបស់ទូលបង្គំបានគ្រាន់តែឮថ្លែងពីទ្រង់ប៉ុណ្ណោះ តែឥឡូវនេះ ភ្នែកទូលបង្គំបានឃើញទ្រង់ជាក់វិញ។ បានជាទូលបង្គំខ្ពើមដល់ខ្លួន ហើយក៏ប្រែចិត្ត ដោយក្រាបនៅក្នុងធូលីដី ហើយនឹងផេះ។" យ៉ូប 42:5, 6

"នៅក្នុងស្រុកនោះ ឯងរាល់គ្នានឹងនឹកចាំពីអស់ទាំងអំពើ និងកិរិយាទាំងប៉ុន្មានរបស់ខ្លួន ជាការដែលនាំឱ្យឯងស្មោគគ្រោក នោះឯងរាល់គ្នានឹងខ្ពើមខ្លួន ដោយព្រោះអំពើអាក្រក់ទាំងប៉ុន្មាន ដែលឯងបានធ្វើនោះ។" អេសេគាល 20:43

ហើយពេលនេះ លោកអើយ សម្រាប់ការរៀបរាប់ដ៏ខ្លីនេះពីកិច្ចការនៃព្រះគុណ និងការបង្ហាញការនេះ ប្រសិនបើអ្នកមានការជំទាស់នោះ ក៏និយាយមក។ បើមិនមានទេ សូមឱ្យខ្ញុំបានបកស្រាយដល់អ្នកនូវសំណួរទីពីរទៀតវិញ។

សាំញ៉ាំ៖ ទេ ចំណែកខ្ញុំវិញពេលនេះមិនមានអ្វីត្រូវជំទាស់ទេ តែខ្ញុំត្រូវស្តាប់វិញ។ អីចឹងសូមឱ្យខ្ញុំបានស្តាប់នូវសំណួរទីពីររបស់អ្នកវិញ។

ស្មោះត្រង់៖វាគឺការនេះ។ តើអ្នកបានបទពិសោធន៍នៃការបកស្រាយបំបូង របស់ការនេះទេ? ហើយតើជីវិតនិងការសន្ទនារបស់អ្នកបានបង្ហាញដូចគ្នាទេ? ឬសាសនារបស់អ្នកឈរតែនៅលើពាក្យសម្ដីនិងនៅក្នុងអណ្ដាត ហើយមិននៅក្នុងទង្វើនិងសេចក្ដីពិតទេឬយ៉ាងណា? សូមអ្នកមេត្តាឆ្លើយប្រាប់ខ្ញុំពីការនេះផង សូមកុំនិយាយលើសពីអ្វីដែលអ្នកដឹងពីព្រះខាងលើទ្រង់នឹងមានបន្ទូលថាអាម៉ែនទៅកាន់ការនោះ ហើយគ្មានអ្វីក្រៅពី ការដែលសតិរបស់អ្នកអាចបញ្ជាក់ពីអ្នកបាន ដោយសារមិនមែនជាម្នាក់ដែលសរសើរខ្លួនឯងដែលត្រូវទទួលស្គាល់នោះទេ តែជាអ្នកដែលព្រះអម្ចាស់ជាអ្នកសរសើរវិញ។ ក្រៅពីនោះទៀត ការដែលនិយាយថាខ្ញុំអញ្ចេះឬអញ្ចុះនោះ កាលដែលការសន្ទនានរបស់ខ្ញុំនិងអ្នកជិតខាងរបស់ខ្ញុំប្រាប់ថាខ្ញុំកុហក់វិញនោះ នោះវាជាការដ៏អាក្រក់បំផុត។

សាំញ៉ាំ៖ បន្ទាប់មកសាំញ៉ាំពីដំបូងចាប់ផ្ដើមអៀន តែក៏បានធូរស្បើយ ដូច្នេះគាត់ក៏ឆ្លើយតបថា "អ្នកបានមានបទសោធន៍ហើយពេលនេះ ទៅដល់ឧត្តមគតិ និងព្រះផង។ ហើយការដែលសុំដល់ទ្រង់នូវភាពត្រឹមត្រូវពីអ្វីដែលបាននិយាយនោះ។ ការនិយាយបែបនេះខ្ញុំមិនចង់បានទេ ហើយខ្ញុំក៏មិនឆ្លើយនឹងសំណួរបែបនោះដែរ ដោយសារខ្ញុំមិនរាប់ខ្លួនថាមានទាក់ទងនឹងការនោះទេ លើកលែងតែអ្នកគិតថាខ្លួនសួរសំណួរនិងឆ្លើយផង ហើយបើទោះជាអ្នកគួរតែធ្វើដូច្នោះក៏ដោយ ខ្ញុំនៅតែមិនព្រមឱ្យអ្នកធ្វើជាចៅក្រមរបស់ខ្ញុំឡើយ។ តែសូមអ្នកប្រាប់ខ្ញុំផង ថាហេតុអ្វីបានជាអ្នកសួរសំណួរបែបនេះ?"

ស្មោះត្រង់៖ ដោយសារខ្ញុំបានឃើញអ្នកផ្ដោះទៅនិយាយ ហើយដោយសារខ្ញុំមិនបានដឹងថាអ្នកមានតែទំនោរទៅរក។ ក្រៅពីនោះ បើប្រាប់អ្នកត្រង់ទៅ

ខ្ញុំបានឮពីអ្នកថា សាសនារបស់អ្នកគឺនៅក្នុងការជជែក។ ហើយការសន្ទនារបស់អ្នកដែលផ្តល់ការសារភាពដោយមាត់នេះនូវការកុហក។ គេនិយាយថាអ្នកជាស្នាមនៅក្នុងចំណោមគ្រីស្ទាន ហើយសាសនាបង្ហាញមកកាន់តែអាក្រក់ដោយសារការសន្ទនាដែលអាក្រក់របស់អ្នក ដែលមានមនុស្សមួយចំនួនបានជំពប់ដួលដោយសារផ្លូវទុច្ចរិតរបស់អ្នករួចទៅហើយ ហើយថាមានមនុស្សជាច្រើនទៀតដែលកំពុងមានគ្រោះថ្នាក់នឹងត្រូវវិនាសដូចគ្នា។ សាសនារបស់អ្នក ហើយនិងផ្ទះប្រមឹក និងសេចក្តីលោភលន់ និងភាពមិនស្អាត និងការស្បថ និងការកុហក និងរក្សាគូរកនដែលឥតប្រយោជន៍ និងការផ្សេងទៀត។ល។ នឹងឈរជាមួយគ្នា។ សុភាសិតត្រូវណាស់ដែលនិយាយពីអ្នក ដែលនិយាយពីស្រីសំផឹង ដែលនិយាយថា "នាងជាសេចក្តីអាម៉ាស់ដល់មនុស្សស្រីទាំងអស់" ដូច្នេះអ្នកជាសេចក្តីអាម៉ាសដល់អ្នកដែលសារភាពទាំងអស់។

សាំញ៉ាំ៖  ក្នុងកាលដែលអ្នករួចរាល់នឹងទាញយករឿងចេញមកហើយ ដើម្បីនឹងកាត់ទោសដោយរហ័សដូចដែលអ្នកបានធ្វើហើយនោះ ខ្ញុំមិនអាចធ្វើអ្វីបានក្រៅពីសរុបថា អ្នកជាមនុស្សម្នាក់ដែលពេញដោយកំហឹងនិងសេចក្តីសោកសៅ ដែលមិនសាកសមនឹងពិភាក្សាជាមួយឡើយ ហើយនិយាយលាយចេញទៅ!

គ្រីស្ទាន៖ បន្ទាប់មកគ្រីស្ទានក៏បានចេញមក ហើយនិយាយជាមួយបងប្អូនរបស់គាត់ថា "ខ្ញុំបានប្រាប់អ្នកថាវានឹងកើតឡើង។ ពាក្យពេចន៍របស់អ្នកនិងតណ្ហារបស់គាត់នឹងមិនត្រូវគ្នាឡើយ។ គាត់សុខចិត្តចាកចេញពីអ្នក ជាជាងកែប្រែជីវិតរបស់គាត់។ តែគាត់បានទៅបាត់ហើយ ដូចដែលខ្ញុំបាននិយាយ

ហើយ ចូរឱ្យគាត់ទៅចុះ។ ការបាត់បង់មិនមែនជារបស់អ្នកណាឡើយ តែជារបស់គាត់វិញ។ គាត់បានជួយយើងកុំឱ្យនឹងពិបាកដើរចេញពីគាត់ហើយដោយសារគាត់នៅតែបន្តដូចដែលខ្ញុំបានគិតរួចហើយ។ គាត់ជាយ៉ាងណានោះគាត់នឹងត្រូវបានលុបចេញពីគ្នារបស់យើង។ ក្រៅពីនោះ ដូចជាពួកសាវកបាននិយាយថា "ចូរដកខ្លួនរបស់អ្នកចេញពីមនុស្សបែបនោះ។"

ស្មោះត្រង់៖ តែខ្ញុំរីករាយដែលយើងមានការជជែកគ្នាបន្តិចនេះជាមួយគាត់។ គាត់អាចនឹងគិតពីវាម្តងទៀត។ ទោះជាយ៉ាងណា ខ្ញុំបានដោះស្រាយយ៉ាងច្បាស់ជាមួយគាត់ហើយ ហើយខ្ញុំបានរួចផុតពីឈាមរបស់គាត់ហើយប្រសិនបើគាត់ស្លាប់។

គ្រីស្ទាន៖ អ្នកធ្វើបានល្អហើយដែលបាននិយាយច្បាស់ៗជាមួយគាត់ដូចដែលអ្នកបានធ្វើនោះ។ មានតែការដោះស្រាយដោយស្មោះត្រង់តិចបណ្តោះសព្វថ្ងៃនេះ ហើយវាបានធ្វើឱ្យសាសនាត្រូវជាស្អុយគគ្រុកនៅក្នុងច្រមុះរបស់មនុស្សជាច្រើនបែបនេះហើយ។ ដោយសារមានល្ងីល្ងើតាប៉ែបែបនេះ ដែលសាសនារបស់គេមានតែនៅក្នុងពាក្យសម្តីដែលទុច្ចរិតហើយអសារឥតការនៅក្នុងការសន្ទនារបស់ពួកគេ ដែល(ទទួលស្គាល់ច្រើននៅក្នុងចំណោមការប្រកបរបស់ពួកបរិសុទ្ធ) ដែលធ្វើឱ្យលោកិយជំពប់ដួលដែលធ្វើឱ្យមានស្នាមដល់គ្រីស្ទាន ហើយធ្វើឱ្យទុកព្រួយដល់ភាពស្មោះត្រង់។ ខ្ញុំប្រាថ្នាចង់ឱ្យមនុស្សទាំងអស់នឹងដោះស្រាយជាមួយមនុស្សបែបនោះដូចដែលអ្នកបានធ្វើដែរ។ បន្ទាប់មកពួកគេនឹងអាចកាន់តែសុខស្រួលថែមទៀតជាមួយនឹងសាសនា ឬជាគ្នារបស់ពួកបរិសុទ្ធនឹងទៅជាក្តៅសម្រាប់ពួកគេវិញ។

បន្ទាប់មកស្មោះត្រង់បាននិយាយថា

"របៀបដែលសាំញ៉ាំបានទាញបន្ទាត់របស់គាត់មកដំបូង។ ការដែលគាត់និយាយដោយក្លាហានយ៉ាងណា! កាលដែលគាត់ស្មានថានឹងដេញអ្នកផ្សេងទៀតដែលនៅមុខគាត់ទៅយ៉ាងណា! តែបន្តិចមកកាលដែលស្មោះត្រង់និយាយជាកិច្ចការចេញពីចិត្ត ដូចជាព្រះច័ន្ទដែលឆ្លងផុតថ្ងៃពេញបូរមីចូលទៅក្នុងរលកនោះ ហើយដូចនេះមានតែអ្នកដែលធ្វើកិច្ចការចេញពីចិត្តទេដែលដឹង។"

ដូច្នេះពួកគេបានដើរបន្តទៅទៀតដោយជជែកគ្នាពីអ្វីដែលពួកគេបានឃើញនៅតាមផ្លូវ ហើយធ្វើឱ្យដំណើររបស់ពួកគេកាន់តែស្រួល ជាផ្លូវដែលដោយគ្មានចម្ងល់អាចនឹងគួរឱ្យធុញទ្រាន់បំផុត ដោយសារពេលនោះពួកគេបានឆ្លងកាត់ទីរហោស្ថាន។

## ការជម្រុញលើកទឹកចិត្តនិងការទស្សទាយន៍របស់អ្នកផ្សាយដំណឹងល្អ

នៅពេលនេះកាលដែលគេទៅជិតផុតទីរហោស្ថានហើយនោះ ស្មោះត្រង់បានយកភ្នែកមើលមកក្រោយ ហើយបានឃើញម្នាក់ដែលលកំពុងតែដេញតាមពួកគេ ហើយគាត់បានស្គាល់គាត់។ "អូ" ស្មោះត្រង់បាននិយាយទៅកាន់បងប្អូនរបស់គាត់ថា "តើអ្នកណាដែលមកនោះ?" បន្ទាប់មកគ្រីស្ទានបានមើលទៅ ហើយនិយាយថា "គឺជាសំឡាញ់របស់ខ្ញុំឈ្មោះ អ្នកផ្សាយដំណឹងល្អ"។ "អេ ជាសំឡាញ់របស់ខ្ញុំដែរតើ" ស្មោះត្រង់បានពោលដូច្នេះ "គាត់ជាអ្នកដែលប្រាប់ខ្ញុំឱ្យមកតាមផ្លូវទៅកាន់ឃ្លោងទ្វារនេះ។" ពេលនេះអ្នកផ្សាយដំណឹងល្អបានមកទាន់ពួកគេ ហើយបានរាក់ទាក់ជាមួយពួកគេ។

អ្នកផ្សាយដំណឹងល្អ៖ សូមឱ្យសេចក្ដីសុខសាន្តបាននៅជាមួយនឹងអ្នក សំឡាញ់របស់ខ្ញុំអើយ ហើយសូមឱ្យសេចក្ដីសុខសាន្តបាននៅជាមួយអ្នកដែលជួយដល់អ្នកដែរ!

គ្រីស្ទាន៖ សូមស្វាគមន៍ ស្វាគមន៍ សំឡាញ់ផ្សាយដំណឹងល្អរបស់ខ្ញុំអើយ! ទឹកមុខរបស់អ្នកនាំឱ្យខ្ញុំចង់ចាំពីសេចក្ដីសប្បុរសរបស់អ្នកពីបុរាណ និងពលកម្មដែលមិនចេះហត់របស់អ្នកសម្រាប់ការល្អដ៏អស់កល្បជានិច្ចរបស់ខ្ញុំ។

ស្មោះត្រង់៖ "ហើយស្វាគមន៍មួយពាន់ដង" ស្មោះត្រង់បានពោលដូច្នេះ "មានគ្នាដូចជាអ្នក អូអ្នកផ្សាយដំណឹងល្អអើយ តើជាការដែលយើងប្រាថ្នាចង់បានយ៉ាងណាទៅសម្រាប់អ្នកធ្វើធម្មយាត្រាដ៏កំសត់ដូចជាយើងនេះ!"

អ្នកផ្សាយដំណឹងល្អ៖ បន្ទាប់មកអ្នកផ្សាយដំណឹងល្អបាននិយាយថា "តើមានអ្វីកើតឡើងដល់អ្នកដែរ មិត្តអើយ តាំងពីយើងចែកផ្លូវគ្នាមកនោះ? តើអ្នកបានជួបជាមួយអ្វីខ្លះ ហើយតើអ្នកបានប្រព្រឹត្តបែបម៉េចដែរ?"

បន្ទាប់មកគ្រីស្ទាននិងស្មោះត្រង់បានប្រាប់គាត់គ្រប់រឿងដែលបានកើតឡើងដល់ពួកគេនៅតាមផ្លូវ ហើយពីសេចក្តីលំបាកអ្វីខ្លះនិងលំបាកយ៉ាងណាខ្លះដែលគេបានជួបរហូតមកដល់ទីនោះ។

អ្នកផ្សាយដំណឹងល្អ៖ "ខ្ញុំពិតជាមានអំណរណាស់" អ្នកផ្សាយដំណឹងល្អបានិយាយបែបនេះ "មិនមែនដែលអ្នកបានជួបនឹងទុក្ខលំបាកទេ តែដោយអ្នកបានយកឈ្នះបាន និងដោយការដែលអ្នកមានផង (មិនថាដោយមានសេចក្តីកំសោយយ៉ាងច្រើនក៏ដោយ) នៅតែបន្តនៅតាមផ្លូវរហូតមកដល់ថ្ងៃនេះ។ ខ្ញុំបាននិយាយហើយថាខ្ញុំរីករាយពិតពីការនេះ ហើយដោយយល់អ្នកនិងខ្ញុំផង។ ខ្ញុំបានសាបព្រោះ ហើយអ្នកបានច្រូតកាត់ ហើយថ្ងៃនោះនឹងមកដល់ដែលអ្នកដែលសាបព្រោះនិងអ្នកដែលច្រូតកាត់នឹងអរសប្បាយជាមួយគ្នា។ គឺប្រសិនបើអ្នកនៅបន្ត ដោយសារដល់ពេលវេលា នោះអ្នកនឹងច្រូតកាត់បាន ប្រសិនបើអ្នកមិនរសាយចិត្តទេ។ មកុដនៅចំពោះអ្នក ហើយវាមិនចេះខូចទេ។ ដូច្នេះចូរអ្នករត់ទៅនោះអ្នកនឹងបានទទួលវា។ មានមនុស្សមួយចំនួនដែលចេញមកចង់បានមកុដនេះ ហើយបន្ទាប់ពីគេបានចេញមកឆ្ងាយដើម្បីវាហើយ មានអ្នកផ្សេងទៀតមកហើយដណ្តើមវាយកពីគេទៅ! ដូច្នេះសូមកាន់ឱ្យជាប់នូវអ្វីដែលអ្នកមាន កុំឱ្យអ្នកណាយកមកុដរបស់អ្នកឡើយ។ "

"អ្នកណាដែលច្រូតនោះបានរង្វាន់ ក៏ប្រមូលផលសម្រាប់ជីវិតដ៏នៅអស់កល្បជានិច្ច ដើម្បីឱ្យអ្នកដែលព្រោះ និងអ្នកដែលច្រូត បានអរសប្បាយផងគ្នា។" យ៉ូហាន 4:36

"កុំឱ្យយើងណាយចិត្តនឹងធ្វើការល្អឡើយ ដ្បិតបើមិនរសាយចិត្តទេ នោះដល់កំណត់យើងនឹងច្រូតបានហើយ។" កាឡាទី 6:9

"តើអ្នករាល់គ្នាមិនដឹងទេឬអី ថាពួកអ្នកដែលរត់នៅទីប្រណាំង គេរត់ទាំងអស់គ្នា ប៉ុន្តែមានតែមួយទេដែលបានរង្វាន់ ដូច្នេះ ចូររត់បែបឱ្យបានរង្វាន់ចុះ។ ហើយអស់អ្នកដែលតយុទ្ធគ្នា គេខំអត់សង្កត់ចិត្តគ្រប់ជំពូក គឺធ្វើដូច្នេះដើម្បីឱ្យបានតែភ្ញួងជ័យដែលត្រូវពុករលួយ ទៃយើងរាល់គ្នាវិញ គឺឱ្យបាមកុដមួយដែលមិនចេះពុករលួយឡើយ ។ បានជាខ្ញុំខំរត់យ៉ាងដូច្នោះ មិនបែបដូចជាមិនស្គាល់ផ្លូវទេ ខ្ញុំក៏ខំប្រដាល់យ៉ាងដូច្នោះដែរ មិនមែនដូចជាដាល់ខ្យល់ទេ។ គឺខ្ញុំវាយដំរូបកាយខ្ញុំ ទាំងបង្ខំឱ្យចុះចូល ក្រែងក្រោយដែលខ្ញុំបានប្រដៅមនុស្សឯទៀតហើយ នោះខ្លួនខ្ញុំត្រូវចោលចេញវិញ។" កូរិនថូសទី១ 9:24-27

"មើល អញមកជាឆាប់ហើយ ចូរកាន់ខ្ជាប់តាមសេចក្ដីដែលឯងមានហើយចុះ ដើម្បីកុំឱ្យអ្នកណាយកមកុដរបស់ឯងបានឡើយ។" វិវរណៈ 3:11

អ្នកមិនទាន់ចេញផុតពីគ្រាប់កាំភ្លើងរបស់អារក្សនូវឡើយទេ អ្នកមិនទាន់បានប្រយុទ្ធដោយចេញឈាមនូវឡើយ ដែលព្យាយាមប្រឆាំងទាស់នឹងអំពើ

បាប។ សូមឱ្យអាណាចក្ររបស់ព្រះបាននៅខាងមុខអ្នក ហើយជឿរឹងមាំនូវការដែលអ្នកមើលមិនឃើញ។ សូមកុំឱ្យអ្វីដែលនៅម្ខាងនៃលោកិយនេះចូលទៅក្នុងខ្លួនអ្នកឡើយ។ ហើយលើសពីនោះទៀត មើលទៅក្នុងចិត្តរបស់អ្នកឱ្យបានល្អ និងតណ្ហារបស់អ្នកផង ដោយសារពួកវាជាសេចក្តីបញ្ឆោតលើសជាងការទាំងអស់ ហើយក៏អាក្រក់បំផុត។ ចូរដាក់មុខរបស់អ្នកដូចជាកាំបិតមុតស្រួច។ អ្នកមានគ្រប់ចេស្តាទាំងនៅស្ថានសួគ៌និងនៅផែនដីនៅខាងអ្នកហើយ។"

បន្ទាប់មកគ្រីស្ទានបានអរគុណគាត់ដែលបានផ្តល់ការជម្រុញលើកទឹកចិត្ត ហើយបានប្រាប់គាត់ទាំងប៉ុន្មាន ដែលពួកគេចង់ឱ្យគាត់និយាយច្រើនទៀតប្រាប់ពួកគេ សម្រាប់ជាចំនួយរបស់ពួកគេដល់ទីបំផុតនៃផ្លូវ ហើយលើសពីនោះទៀត ដោយថាពួកគេបានដឹងច្បាស់ថា គាត់ជាហោរាម្នាក់ ហើយអាចប្រាប់ពួកគេពីការដែលអាចនឹងកើតឡើងដល់ពួកគេ ហើយពីរបៀបដែលពួកគេអាចនឹងគេចផុតនិងយកឈ្នះលើការទាំងនោះ។ ដែលស្មោះត្រង់បានសំណូមពរនិងយល់ស្របផងដែរ។ ដូច្នេះអ្នកផ្សាយដំណឹងល្អបានចាប់ផ្តើមដូចតទៅ

អ្នកផ្សាយដំណឹងល្អ៖ កូនរបស់ខ្ញុំអើយ អ្នកបានស្តាប់ឮព្រះបន្ទូលនៃសេចក្តីពិតនៃដំណឹងល្អ ដែលអ្នកត្រូវ "ដោយឆ្លងកាត់សេចក្តីលំបាកវេទនាជាច្រើនដើម្បីចូលទៅក្នុងនគរស្ថានសួគ៌។" ហើយម្តងទៀត នៅគ្រប់ទីក្រុងទាំងអស់ចំណងនិងសេចក្តីទុក្ខលំបាកដែលនៅជាប់នឹងអ្នក ហើយដូច្នេះអ្នកមិនត្រូវសង្ឃឹមថាអ្នកនឹងធ្វើធម្មយាត្រានេះដោយគ្មានជួបការទាំងនេះឡើយ នៅក្នុងប្រភេទមួយចំនួនឬបែបផ្សេងទៀត។ អ្នកបានរកឃើញអ្វីមួយពីសេចក្តីពិតពី

ទីបន្ទាល់ទាំងនេះដែលនៅលើអ្នករួចរាល់ហើយ ហើយច្រើនទៀតនឹងមកតាមភ្លាម។ ដោយសារពេលនេះ ដូចដែលអ្នកឃើញថា អ្នកស្ទើរតែចេញផុតពីទីរហោស្ថាននេះហើយ ហើយដូច្នេះអ្នកនឹងទៅដល់ក្រុងមួយភ្លាម ដែលអ្នកនឹងជួបពីមួយទៅមួយនៅចំពោះអ្នក ហើយនៅក្រុងនោះអ្នកនឹងមិនងាយនឹងត្រូវសត្រូវធ្វើបាបណាស់ ជាសត្រូវដែលនឹងខិតខំប្រឹងប្រែងយ៉ាងខ្លាំងតែពួកគេនឹងសម្លាប់អ្នក។ តែអ្នកត្រូវប្រាកដថា មានម្នាក់ឬអ្នកទាំងពីរត្រូវតែបោះត្រានូវទីបន្ទាល់ដែលអ្នកកាន់ដោយនូវឈាមនោះ តែអ្នកត្រូវតែស្មោះត្រង់រហូតដល់ស្លាប់ចុះ នោះស្តេចទ្រង់នឹងប្រទានមកុដជីវិតដល់អ្នក។ អ្នកដែលនឹងត្រូវស្លាប់នៅទីនោះ តើទោះជាការស្លាប់មិនមែនតាមបែបធម្មជាតិក៏ដោយ ហើយសេចក្តីឈឺចាប់របស់គាត់អាចជាខ្លាំងក៏ដោយ គាត់នៅតែប្រសើរជាងអ្វីដែលជារបស់គ្នាគាត់ផង មិនមែនដោយសារត្រឹមតែគាត់នឹងមកដល់ទីក្រុងបរិសុទ្ធឆាប់នោះទេ តែដោយសារគាត់នឹងគេចផុតពីសេចក្តីលំបាកជាច្រើនដែលអ្នកផ្សេងទៀតនឹងជួបរហូតដល់ផុតនៃការធ្វើដំណើរនេះ។ តែនៅពេលដែលអ្នកមកដល់ក្រុង ហើយនឹងឃើញថាត្រូវបានសម្រេចអ្វីដែលខ្ញុំបាននិយាយទាក់ទងរួចហើយនៅទីនេះ បន្ទាប់មកចូរចង់ចាំពីមិត្តរបស់អ្នក ហើយធ្វើខ្លួនដូចជាមនុស្សប្រុស ហើយតាំងចិត្តរក្សាព្រលឹងរបស់អ្នកសម្រាប់ព្រះរបស់អ្នកដោយធ្វើការល្អ ដូចសម្រាប់ព្រះអាទិករដ៏ស្មោះត្រង់ផង។

## ពិព័រណ៍នៃការឥតប្រយោជន៍

បន្ទាប់មកខ្ញុំបានឃើញនៅក្នុងសុបិនរបស់ខ្ញុំថា នៅពេលដែលពួកគេចេញផុតពីវាលរហោស្ថាន ពេលនេះពួកគេបានឃើញទីក្រុងមួយនៅចំពោះពួកគេ ហើយឈ្មោះរបស់ទីក្រុងនោះគឺ "ការឥតប្រយោជន៍"។ ហើយនៅទីក្រុងនោះ មានការរក្សាយ៉ាងត្រឹមត្រូវដែលហៅថា "ពិព័រណ៍នៃការឥតប្រយោជន៍"។ វាត្រូវបានរក្សាពេញមួយឆ្នាំហើយ។ វាមានឈ្មោះថា ពិព័រណ៍នៃការឥតប្រយោជន៍ ដោយសារទីក្រុងដែលវាត្រូវបានរក្សាវាស្រាលជាង ការឥតប្រយោជន៍ហើយក៏ដោយសារអ្វីដែលនៅទីនោះត្រូវបានលក់អស់ ឬអ្វីដែលចេញមកពីទីនោះជាការអសាឥតការទទេរ។ ប្រៀបដូចជាពាក្យរបស់អ្នកប្រាជ្ញពោលថា "ការទាំងអស់ដែលចេញមកជាការឥតប្រយោជន៍។"

"អស់ទាំងសាសន៍រាប់ដូចជាទទេសោះនៅចំពោះទ្រង់ ទ្រង់រាប់គេទុកដូចជាតិចជាងសូន្យទៅទៀត ហើយជាឥតប្រយោជន៍ផង។" **អេសាយ 40:17**

"ការឥតប្រយោជន៍ទទេៗ នេះជាពាក្យរបស់គ្រូប្រដៅពោលទុកថា ការឥតប្រយោជន៍ទទេៗ គ្រប់ទាំងអស់សុទ្ធតែអត់ប្រយោជន៍ទទេ" **សាស្តា 1:2**

"យើងបានឃើញបណ្តាការដែលមានធ្វើនៅក្រោមថ្ងៃ ហើយមើល ការទាំងនោះសុទ្ធតែឥតប្រយោជន៍ទទេ ក៏ជាអសារឥតការផង" **សាស្តា 1:14**

“គ្រានោះ យើងបានត្រួតមើលគ្រប់ទាំងការដែលដៃយើងបានធ្វើ និងការនឿយហាត់ដែលយើងបានខំបង្កើតនោះ ហើយមើល សុទ្ធតែឥតប្រយោជន៍ ហើយអសារឥតការទទេ ឥតមានផលប្រយោជន៍អ្វីនៅក្រោមថ្ងៃឡើយ។” សាស្ដា 2:11

“ហេតុនោះ យើងបានស្អប់ជីវិត ពីព្រោះការដែលបានធ្វើនៅក្រោមថ្ងៃ ជាការលំបាកដល់យើង ដ្បិតការទាំងអស់សុទ្ធតែឥតប្រយោជន៍ ហើយជាអសារឥតការទទេ។” សាស្ដា 2:17

“អើ បើមនុស្សណារស់នៅជាយូរឆ្នាំ នោះគួរឱ្យ មានសេចក្ដីអំណរចំពោះគ្រប់ឆ្នាំទាំងនោះចុះ តែត្រូវឱ្យ នឹកដល់អស់ទាំងថ្ងៃ ដែលមានសេចក្ដីងងឹតដែរ ពីព្រោះនឹងមានជាច្រើនទៀត គ្រប់ទាំងអស់ដែលត្រូវមក សុទ្ធតែជាការឥតប្រយោជន៍ទទេ។” សាស្ដា 11:8

នេះមិនមែនជាការដែលត្រូវសាងមកថ្មីៗនេះទេ តែជាការដែលមាននៅតាំងតែពីបុរាណមកម្ល៉េះ។ ខ្ញុំនឹងបង្ហាញពីប្រភពដើមរបស់វា។

ស្ទើរតែប្រាំពាន់ឆ្នាំមុខមកម្ល៉េះ មានអ្នកធ្វើធម្មយាត្រាម្នាក់ដែលដើរទៅកាន់ទីក្រុងបរិសុទ្ធ ដូចជាបុរសស្មោះត្រង់ទាំងពីរនាក់នេះដែរ និងបីលសេប៉ុល អាប៉ូឡេអ៊ុង និង ពួកកងទ័ព ជាមួយនឹងបក្សពួករបស់ពួកគេ ដោយមើលឃើញផ្លូវដែលអ្នកធ្វើធម្មយាត្រារៀបចំមក ដែលផ្លូវរបស់ពួកគេឆ្លងកាត់ទីក្រុងរបស់អសាឥតការ នោះពួកគេត្រូវបង្ខំឱ្យរៀបចំភារកិច្ចនៅទីនេះ ជាកិច្ចការ

ដែលត្រូវលក់របស់ទាំងអស់ដែលឥតប្រយោជន៍គ្រប់ប្រភេទ ហើយដែលវាត្រូវនៅជាប់ជាយូរឆ្នាំ។ ដូច្នេះដោយសារកិច្ចការនេះសុទ្ធតែជាទំនេញដែលលក់ចេញ ដូចជាផ្ទះ ដី ជំនួញ ទីកន្លែង កិត្តិយស អ្វីដែលប្រាថ្នាចង់បានតំណែង ប្រទេស នគរ តណ្ហា សេចក្ដីរីករាយ និងការអរសប្បាយគ្រប់ប្រភេទ ប្រៀបដូចជាស្ត្រីសំផឹង មេស្រីខូច ប្រពន្ធ ប្ដី កូន ចៅហ្វាយ អ្នកបម្រើជីវិត ឈាម រូបរាងកាយ ព្រលឹង ប្រាក់ មាស គុជ ថ្មមានតម្លៃ និងអ្វីក្រៅពីនោះទៀត។

ហើយលើសពីនោះទៀត នៅក្នុងកិច្ចការនេះមានអ្នកបោកបញ្ឆោតគ្រប់ពេលវេលា ការបោកប្រាស់ ល្បែងស៊ីសង ការលេងសើច សេចក្ដីល្ងង់ខ្លៅសត្វស្វាអេបស៍ មនុស្សខិលខូច និងការបោកប្រាស់ និងការគ្រប់ប្រភេតដូចនោះ។

នេះជាការដែលនឹងត្រូវឃើញផងដែរ ដែលវាមិនមានប្រយោជន៍អ្វីទាំងអស់គឺការលួចប្លន់ ការសម្លាប់ សេចក្ដីកំផឹត ស្បថដោយខុសឆ្គង និងអ្វីដែលមានឈាមក្រហម។

ហើយដូចជានៅក្នុងកិច្ចការផ្សេងទៀតដែលមានពេលតិចបំផុត មានជួរជាច្រើននិងផ្លូវមួយចំនួន នៅក្រោមឈ្មោះដែលសាកសមរបស់ពួកគេ នៅកន្លែងដែលទំនេញទាំងនោះត្រូវលក់ចេញទៅ។ ដូច្នេះនៅទីនេះអ្នកមានទីកន្លែង ជួរ ផ្លូវនានាដែលសាកសម (ដូចជា ប្រទេស និងនគរផ្សេងៗ) ជាកន្លែងដែលទំនេញនៃជំនួញនោះត្រូវរកឃើញយ៉ាងរហ័សបំផុត។ នេះគឺជាជួររបស់ពួកអង់គ្លេស ជួររបស់បារាំង ជួររបស់អ៊ីតាលី ជួរអេស្បាញ ជួរអាឡឺ

ម៉ង់ ជាកន្លែងដែលការឥតប្រយោជន៍ជាច្រើនត្រូវលក់ចេញ។ តែសម្រាប់ជំនួញផ្សេងទៀតវិញ ផលិតផលណាមួយដែលជាមេលើអស់ទាំងជំនួយ ដូច្នេះទំនេញរបស់ក្រុងរ៉ូម ហើយនឹងទំនេញរបស់នាងត្រូវបានគេផ្សព្វផ្សាយយ៉ាងខ្លាំងនៅក្នុងជំនួញនេះ។ មានតែជនជាតិអស់គ្លេសយើងទេ និងអ្នកផ្សេងទៀតមិនបានចូលចិត្តទីនោះឡើយ។

ពេលនេះដូចដែលខ្ញុំបាននិយាយហើយ ផ្លូវទៅកាន់ទីក្រុងបរិសុទ្ធលាតសន្ធឹងតាមទីក្រុងនេះ ជាកន្លែងដែលមានជំនួញខាងសេចក្ដីតណ្ហាត្រូវបានរក្សា ហើយអ្នកដែលចូលទៅទីក្រុងនោះ ហើយមិនដើរតាមក្រុងនេះ នោះត្រូវចាកចេញពីលោកិយនេះទៅ។

**"តែពាក្យនោះមិនសំដៅចំពោះមនុស្សកំផិតរបស់ផងលោកីយ៍នេះ ឬមនុស្សលោភ មនុស្សប្លន់កំហែង ឬមនុស្សថ្វាយបង្គំរូបព្រះនោះទេ ដ្បិតបើដូច្នោះនោះត្រូវតែចេញឱ្យ ផុតពីលោកីយ៍នេះទៅ" កូរិនថូសទី១ 5:10**

ស្ដេចលើទាំងស្ដេចផ្ទាល់ កាលនៅទីនេះបានឆ្លងកាត់ក្រុងនេះទៅកាន់ប្រទេសរបស់ទ្រង់ផ្ទាល់ ហើយនៅថ្ងៃដែលភ្លឺចេសផងដែរ ហើយតាមខ្ញុំគិតវាជាប៊ីលសេប៊ុល ដែលជាមេនៃជំនួញនេះ ដែលបានអញ្ជើញគាត់ឱ្យទិញការឥតប្រយោជន៍របស់វាទាំងនេះ។ ដែលនឹងធ្វើឱ្យវាបានក្លាយជាមេលើជំនួញនេះ ចង់ឱ្យគេផ្ដល់ការគោរពដល់វានៅពេលដែលគេឆ្លងកាត់ទីក្រុងនោះ។ ហើយដោយសារទ្រង់ជាម្នាក់ដែលមានកិត្តិយស បីលសេប៊ុលបាននាំទ្រង់ពីផ្លូវមួយទៅផ្លូវមួយ ហើយបង្ហាញទ្រង់នូវគ្រប់នគរនៃផែនដីទាំង

អស់នៅក្នុងពេលដ៏ខ្លី ដែលថា បើអាចទៅរួចត្រូវគេល្បួងឱ្យបាន ព្រះដ៏មានពរនេះបានបញ្ចុះតម្លៃនិងទិញការដែលឥតប្រយោជន៍មួយចំនួនពីគេ។ តែទ្រង់មិនមានគំនិតចង់បានទំនិញទាំងនោះទេ ដូច្នេះក៏បានចាកចេញពីទីក្រុងនោះដោយមិនបានបន្សល់ទុកអ្វីច្រើនសូម្បីតែក៏មិនទុកនៅលើការឥតប្រយោជន៍ទាំងនោះដែរ។

"មួយទៀត អារក្សបាននាំទ្រង់ទៅលើកំពូលភ្នំយ៉ាងខ្ពស់ ក៏បង្ហាញអស់ទាំងនគរក្នុងលោកីយ៍ និងសិរីលំអរបស់នគរទាំងនោះថ្វាយទ្រង់ទត" ម៉ាថាយ 4:8

"អារក្សក៏នាំទ្រង់ទៅលើកំពូលភ្នំយ៉ាងខ្ពស់ បង្ហាញនគរនៅលោកីយ៍ទាំងអស់ក្នុង១ភ្លែតនោះ។ ហើយទូលថា ខ្ញុំនឹងឱ្យ អំណាច និងសិរីលំអនៃនគរទាំងនេះដល់អ្នក ដ្បិតបានប្រគល់មកខ្ញុំហើយ ខ្ញុំនឹងឱ្យ ដល់អ្នកណាស្រេចនឹងចិត្តខ្ញុំ។ ដូច្នេះ បើអ្នកក្រាបថ្វាយបង្គំខ្ញុំ នោះទាំងអស់នឹងបានជារបស់អ្នក" លូកា 4:5-7

ដូច្នេះជំនួញនេះជាការពីបុរាណ ដែលជាប់ជាយូរអង្វែងហើយជាជំនួញមួយយ៉ាងធំ។

ពេលនេះអ្នកធ្វើធម្មយាត្រាទាំងនេះ ដូចដែលខ្ញុំបាននិយាយហើយ ថាត្រូវតែឆ្លងកាត់តាមជំនួញនេះ ដូច្នេះពួកគេបានឆ្លងកាត់មែន។ តែមើលទៅ បើទោះជាពួកគេបានចូលទៅក្នុងជំនួញនោះ មានមនុស្សជាច្រើនដែលនៅក្នុង

ជំនួញនោះមានការភ្ញាក់ផ្អើល ហើយទីក្រុងផ្ទាល់ប្រៀបដូចជានៅក្នុង ចលាចលមកក្បែរពួកគេ នោះដោយសារហេតុផលមួយចំនួន។ ដោយសារ

ទីមួយ អ្នកធ្វើធម្មយាត្រាស្លៀកពាក់សំលៀកបំពាក់មួយប្រភេទដែលខុសពីសំលៀកបំពាក់របស់អ្នកផ្សេងទៀតដែលធ្វើជំនួញនោះ។ ដូច្នេះមនុស្សដែលធ្វើជំនួញនោះធ្វើការសម្លឹងមើលពួកគេយ៉ាងខ្លាំង។ អ្នកខ្លះនិយាយថាពួកគេជាមនុស្សល្ងង់ អ្នកខ្លះថាពួកគេជាមនុស្សឆ្កួត ហើយអ្នកខ្លះទៀតថាជាពួកដែលចម្លែក។

ទីពីរ ហើយនៅពេលដែលពួកគេកំពុងតែគិតឆ្ងល់ពីសំលៀកបំពាក់របស់ពួកគេ ដូច្នេះពួកគេក៏គិតដូចគ្នាទៅលើពាក្យសម្តីរបស់ពួកគេផងដែរ។ ដោយសារមានមនុស្សតិចទេដែលអាចយល់នូវអ្វីដែលពួកគេនិយាយ។ ជាធម្មតាពួកគេនិយាយភាសារបស់ពួកកាណាន តែពួកគេនៅរក្សាជំនួញនោះជាមនុស្សនៅក្នុងលោកិយនេះ ដូច្នេះចាប់ពីចុងម្ខាងនៃជំនួញទៅម្ខាងទៀតពួកគេហាក់ដូចជាពួកមនុស្សព្រៃពីមនុស្សម្នាក់ទៅម្នាក់ទៀត។

**“គឺនិយាយតាមតែប្រាជ្ញានៃព្រះវិញ ជាសេចក្តីអាថ៌កំបាំងដ៏លាក់ទុក ដែលព្រះបានគិតគូ តាំងពីមុនអស់ទាំងកល្ប សម្រាប់ជាសិរីល្អដល់យើងរាល់គ្នា។ គ្មានចៅហ្វាយណាក្នុងលោកីយ៍នេះបានស្គាល់សេចក្តីអាថ៌កំបាំងនោះឡើយ បើបានស្គាល់ នោះគេមិនបានឆ្កាងព្រះអម្ចាស់ដ៏មានសិរីទេ” កូរិនថូស ទី១ 2:7, 8**

ទីបី តែការដែលធ្វើឱ្យពួកអ្នកធ្វើជំនួញភ្ញាក់ផ្អើលខ្លាំងនោះគឺ អ្នកធ្វើធម្មយាត្រាទាំងនេះមិនសូវមានទំនេញរបស់ពួកគេសោះ ពួកគេមិនចង់នឹងមើលទៅកាន់របស់ទាំងអស់នោះផង ហើយប្រសិនបើស្រែកហៅឱ្យទិញ ពួកគេនឹងយកដៃបិតត្រចៀក ហើយស្រែកថា "សូមបង្វែរភ្នែករបស់ខ្ញុំកុំឱ្យមើលការដែលឥតប្រយោជន៍ទាំងនេះ។" ហើយបានសម្លឹងមើលទៅខាងលើ ដែលជាសញ្ញាថាជំនួញរបស់ពួកគេនិងការធ្វើដំណើររបស់ពួកគេគឺនៅស្ថានសួគ៌។

"សូមបង្វែរភ្នែកទូលបង្គំមិនឱ្យ មើលការឥតប្រយោជន៍ ហើយប្រោសឱ្យ ទូលបង្គំមានកម្លាំងឡើងក្នុងផ្លូវទ្រង់" **ទំនុកដំកើង 119:37**

"ចុងបំផុតរបស់គេជាសេចក្តីហិនវិនាស គេយកពោះគេទុកជាព្រះ ហើយយកសេចក្តីគួរខ្មាសរបស់គេ ទុកជាសិរីល្អ វិញ គេនឹកតែពីរបស់នៅផែនដីនេះ។ ឯយើងរាល់គ្នា យើងជាសាសន៍ស្ថានសួគ៌វិញ ក៏នៅចាំព្រះអម្ចាស់យេស៊ូវគ្រីស្ទ ជាព្រះអង្គសង្គ្រោះ ទ្រង់យាងមកពីស្ថាននោះឯង" **ភីលីព 3:19, 20**

មានម្នាក់និយាយដោយចំអក សម្លឹងមើលរទេះរបស់មនុស្ស ហើយនិយាយទៅកាន់ពួកគេ ដើម្បីនឹងនិយាយទៅកាន់ពួកគេថា "តើអ្នកនឹងទិញអ្វី?" ប៉ុន្តែពួកគេបានមើលទៅកាន់គាត់យ៉ាងម៉ឹងម៉ាត់ ហើយនិយាយថា "យើងទិញសេចក្តីពិត។"

**“ចូរទិញសេចក្តីពិតចុះ កុំឱ្យ លក់ចេញឡើយ អើទាំងប្រាជ្ញា សេចក្តីដំបូន្មាន និងយោបល់ផង។” សុភាសិត 23:23**

ដោយការនោះមានឱកាសដែលត្រូវមើលងាយដល់បុរសទាំងនោះថែមទៀត អ្នកខ្លះចំអក អ្នកខ្លះធ្វើទុក្ខបុកម្នេញ ខ្លះនិយាយខិតមកជិត ហើយខ្លះទៀតហៅរកអ្នកផ្សេងទៀតមកវាយពួកគេ។ ជាចុងក្រោយ រឿងក៏ត្រូវជាអ៊ូអរហើយមានការច្របូកច្របល់ជាខ្លាំងនៅទីជំនួញនោះ ខ្លាំងពេលរហូតដល់គ្មានរបៀបរៀបរយសោះ។ ឥឡូវមានពាក្យដែលនាំមកដល់អ្នកធំបំផុតនៅទីជំនួញនោះ ដែលគាត់បានចេញមកយ៉ាងរហ័ស ហើយឈ្លោះប្រកែកជាមួយនឹងមិត្តដែលគាត់ទុកចិត្តបំផុត ឱ្យយកបុរសទាំងនេះទៅធ្វើការស៊ើបសួរ អំពីអ្នកដែលជំនួញស្ទើរតែត្រូវក្រឡាប់ចាក់។ ដូច្នេះពួកគេក៏ត្រូវយកទៅស៊ើបសួរ ហើយអ្នកដែលអង្គុយនៅខាងលើបានសួរពួកគេថា ពួកគេមកពីពេលណា តើពួកគេទៅណា ហើយតើពួកគេធ្វើអ្វីនៅទីនោះនៅក្នុងសំលៀកបំពាក់ដែលខុសប្លែកពីគេនេះ?

បន្ទាប់មកបុរសទាំងពីរប្រាប់ពួកគេថា ពួកគេជាអ្នកធ្វើធម្មយាត្រា និងជាអ្នកបរទេសនៅក្នុងផែនដីនេះ ហើយពួកគេកំពុងទៅកាន់ប្រទេសរបស់ពួកគេដែលជាប្រទេសយេរូសាឡិមស្ថានសួគ៌។

“ពួកអ្នកទាំងនោះបានស្លាប់ក្នុងសេចក្តីជំនឿ ឥតទទួលសេចក្តីដែលបានសន្យាទាំងប៉ុន្មានទេ តែគេបានឃើញពីចម្ងាយ ហើយក៏ទទួលគំនាប់ដែរ ទាំងយល់ព្រមថា ខ្លួនគេជាអ្នកដទៃ ដែលគ្រាន់តែសំណាក់ នៅផែនដីប៉ុណ្ណោះ។ ពួកអ្នកដែលនិយាយដូច្នោះ នោះសម្តែងថា គេជាអ្នករកស្រុកសម្រាប់ខ្លួនគេ

ពិត។ ហើយបើសិនជាគេរឭកស្រុក ដែលគេទើបនឹងចេញមកនោះ នោះគេនឹងមានឱកាសត្រឡប់ទៅវិញបាន។ តែឥឡូវនេះ គេសង្វាតចង់បានស្រុក១ដ៏ប្រសើរជាង គឺខាងស្ថានសួគ៌វិញ បានជាព្រះទ្រង់គ្មានសេចក្តីខ្មាស ដោយគេហៅទ្រង់ជាព្រះនៃគេនោះឡើយ ដ្បិតទ្រង់បានរៀបចំទីក្រុង១ឱ្យ គេហើយ។"
**ហេព្រើរ 11:13-16**

ហើយពួកគេមិនទុកឱកាសអោយអ្នកក្រុងនិងអ្នកលក់ដូរធ្វើបាបពួកគេឡើយ ហើយទុកអោយពួកគេធ្វើដំណើរទៅ។ លើកលែងតែ ព្រោះនៅពេលដែលមនុស្សម្នាក់សួរពួកគេពីអ្វីដែលពួកគេនឹងទិញ ពួកគេបាននិយាយថាពួកគេនឹងទិញសេចក្តីពិត។ ប៉ុន្តែអ្នកដែលត្រូវបានតែងតាំងឱ្យពិនិត្យមើលពួកគេមិនជឿថា ពួកគេជាអ្នកចេះដឹងតែឆ្កួត ឬក៏អ្វីមួយផ្សេងទៀត ដូចជាបានមកធ្វើឱ្យមានភាពច្របូកច្របល់នៅក្នុងពិព័រណ៍នោះទេ។ ពួកគេចាប់ពួកគេវាយធ្វើបាប ហើយលាបធូលីដីដាក់ពួកគេ រួចដាក់ពួកគេចូលក្នុងទ្រុងឱ្យពួកគេបានសម្តែងការចាប់អារម្មណ៍ចំពោះមនុស្សទាំងអស់ដែលនៅក្នុងពិព័រណ៍។ ដូច្នេះនៅទីនោះ ពួកគេបាននៅទីនោះអស់ពេលមួយរយៈ ហើយត្រូវបានគេធ្វើឱ្យទៅដូចជាវត្ថុនៃកីឡារបស់មនុស្ស ឬការស្អប់ខ្ពើមឬការសងសឹកវិញ។ ហើយម្នាក់ដែលធំអស្ចារ្យជាងគេនៅពិព័រណ៍បានសើចរហូតនូវអ្វីដែលបានកើតឡើងដល់ពួកគេ។

ប៉ុន្តែមនុស្សទាំងពីរមានភាពអត់ធ្មត់និងមិនបង្ហាញការតក់ស្លុតអ្វីទេ តែផ្ទុយទៅវិញប្រទានពរ និងនិយាយពាក្យល្អៗសម្រាប់អំពើអាក្រក់ និងមានចិត្តល្អចំពោះការដែលធ្វើឱ្យគេរងរបួសវិញ ដែលបានធ្វើមនុស្សខ្លះនៅក្នុងពិព័រណ៍

ដែលបានសង្កេតនិងមិនសូវប្រកាន់ដូចអ្នកដទៃទៀត បានចាប់ផ្តើមត្រួតពិនិត្យ ស្តីបន្ទោសប្រភេទមូលដ្ឋាននៃការធ្វើបាបជាបន្តទៅកាន់បុរសទាំងពីរ។ ហេតុដូច្នេះ ក្នុងសភាពដែលខឹងសម្បារពួកគេមករកបុរសទាំងពីរម្តងទៀត ដោយរាប់ពួកគេជាមនុស្សអាក្រក់ដូចដូចបុរសនៅក្នុងទ្រុងដែរ ហើយប្រាប់ពួកគេថាពួកគេហាក់ដូចជាច្របូកច្របល់ ហើយគួរតែធ្វើជាអ្នកចូលរួមនៃសំណាងអាក្រក់របស់ពួកគេ។ ម្នាក់ទៀតឆ្លើយថា ទាល់តែពួកគេអាចមមើលឃើញបាន ពួកគេក៏នៅស្ងៀមហើយដឹងខ្លួន ហើយមិនបង្កគ្រោះថ្នាក់ដល់អ្នកណាឡើយ។ ហើយថាមានមនុស្សជាច្រើនដែលបានជួញដូរនៅក្នុងពិព័រណ៍របស់ពួកគេ ដែលសក្តិសមនឹងត្រូវគេដាក់ចូលក្នុងទ្រុង ហើយមានការចំអកឡុកឡឺយឱ្យផងដែរ ច្រើនជាងបុរសដែលពួកគេបានធ្វើបាបទៅទៀត។ ដូច្នេះបន្ទាប់ពីពាក្យផ្សេងៗគ្នាបានកន្លងផុតទៅទាំងសងខាង បុរសទាំងនោះបានប្រព្រឹត្តខ្លួនជាមនុស្សឆ្លាតតាំងពីពេលនោះហើយដឹងខ្លួនឡើងវិញនៅចំពោះពួកគេ។ ពួកគេបានឈ្លោះប្រកែកគ្នានិងធ្វើបាបគ្នាទៅវិញទៅមក។

បន្ទាប់មកបុរសកំសត់ទាំងពីរនេះត្រូវបាននាំយកមកនៅចំពោះអ្នកត្រួតពិនិត្យម្តងទៀត និងមានការចោទប្រកាន់ថាមានទោសដែលបង្កការចលាចលមុននេះនៅក្នុងពិព័រណ៍។ ដូច្នេះគេបានវាយដំពួកគេដោយគ្មានអាណិតហើយព្យួរដែកនៅលើពួកគេ ហើយដឹកពួកគេដោយច្រវ៉ាក់លើក្រោមនៅកន្លែងពិព័រណ៍ធ្វើជាគម្រូ និងជាការភ័យខ្លាចដល់អ្នកផ្សេងទៀត ដើម្បីកុំឱ្យអ្នកផ្សេងទៀតនិយាយអ្វីសម្រាប់ពួកគេទៀត ឬចូលរួមបក្សពួកជាមួយពួកគេទៀត។ ប៉ុន្តែគ្រីស្ទាននិងស្មោះត្រង់ប្រព្រឹត្តខ្លួនកាន់តែមានប្រាជ្ញាថែម

ទៀត ហើយបានទទួលសេចក្តីអាម៉ាស់ដែលដាក់មកលើពួកគេដោយសេចក្តីស្លូតបូតនិងការអត់ធ្មត់ ដែលពួកគេបានឈ្នះ បើប្រៀបធៀបទៅនឹងអ្នកផ្សេងទៀត មនុស្សមួយចំនួននៅក្នុងពិព័រណ៍។ ការនេះបានធ្វើឱ្យមនុស្សមួយបក្សទៀតខឹងសម្បារយ៉ាងខ្លាំង ខ្លាំងរហូតដល់ពួកគេចង់បញ្ចប់ជីវិតរបស់បុរសទាំងពីរ។ ដូច្នេះពួកគេបានធ្វើការគម្រាមថា ទ្រុងឬដែលត្រូវប្តូរវេនគ្នា តែពួកគេនឹងត្រូវស្លាប់ដោយសារការធ្វើបាបដែលពួកគេបានធ្វើ និងដោយសារការបញ្ឆោតដល់មនុស្សដែលនៅពិព័រណ៍។

បន្ទាប់មកពួកគេត្រូវយកទៅដាក់ក្នុងទ្រុងម្តងទៀត រហូតដល់បានធ្វើបន្ថែមទៀតដាក់ពួកគេ។ ដូច្នេះពួកគេបានដាក់ពួកគាត់ចូលទៅក្នុង ហើយធ្វើឱ្យជើងរបស់ពួកគេជាប់ទៅនឹងរនាំង។

ដូច្នេះនៅទីនេះពួកគេបាននឹងឃើញម្តងទៀត នូវអ្វីដែលពួកគេបានឮចេញពីសំឡាញ់ស្មោះត្រង់របស់ពួកគេឈ្មោះអ្នកផ្សាយដំណឹងល្អ ហើយពួកគេបានបញ្ជាក់ច្បាស់លាស់នៅក្នុងផ្លូវរបស់ពួកគេនិងការរងទុក្ខរបស់ពួកគេដោយសារការដែលបានប្រាប់មកដល់ពួកគេថានឹងត្រូវកើតឡើង។ ពេលនេះពួកគេក៏ត្រូវបានកំសាន្តចិត្តរៀងៗខ្លួន ដែលចំណែករបស់ពួកគេគឺត្រូវតែរងទុក្ខ ហើយដែលគេត្រូវតែទទួលបានការដែលល្អបំផុត។ ដូច្នេះម្នាក់ៗបានប្រាថ្នាដោយសម្ងាត់រៀងៗខ្លួនថា ពួកគេនឹងមានចិត្តប្រាថ្នាចង់បានការល្អនោះជាង តែបានតាំងខ្លួនរបស់ពួកគេទៅរកព្រះអង្គដែលគ្រប់គ្រងលើការទាំងអស់វិញ ដោយមានសេចក្តីស្កប់ស្កល់នៅក្នុងសភាពដែលពួកគេបានជួបនេះ រហូតដល់ពួកគេអាចយកឈ្នះបាន។

## ការលំបាកវេទនា

បន្ទាប់ម ពេលវេលាដ៏សាកសមមួយត្រូវបានកំណត់ទុក ពួកគេបាននាំមកពួកគេទៅកាន់សេចក្តីលំបាកវេទនារបស់ពួកគេ ដើម្បីជាសេចក្តីជំនុំជំរះរបស់ពួកគេ។ នៅដែលពេលមកដល់ ពួកគេត្រូវបាននាំមកនៅចំពោះខ្មាំងសត្រូវរបស់ពួកគេ និងត្រូវចោទប្រកាន់។ ឈ្មោះរបស់ចៅក្រមនោះគឺ ព្រះអម្ចាស់ដែលស្អប់ការល្អ។ សេចក្តីចោទប្រកាន់របស់ពួកគេមានធាតុតែមួយទេ បើទោះជាវាមានទ្រង់ទ្រាយខុសគ្នាក៏ដោយ តែខ្លឹមសារកឺដូចគ្នា។

ដែលថាពួកគេជាសត្រូវ និងជាអ្នករំខាននៃជំនួញរបស់ពួកគេ ដែលពួកគេបានបង្ករចរលាចលនិងការបែកបាក់គ្នានៅក្នុងទីក្រុង ហើយបានដណ្តើមយកមួយបក្សធ្វើជារបស់គេជាគំនិតមួយដ៏គ្រោះថ្នាក់បំផុត ដែលមានការប៉ុនប៉ងនៃច្បាប់ក្រឹតក្រមរបស់ស្តេចរបស់ពួកគេ។

បន្ទាប់មកស្មោះត្រង់ចាប់ឆ្លើយថា អ្នកដែលតាំងខ្លួនទាស់នឹងមួយអង្គដែលខ្ពស់ជាងអ្នកដែលខ្ពស់បំផុតនោះ "ហើយ" គាត់បាននិយាយថា "សម្រាប់ការរំខាននោះ ខ្ញុំមិនបានបង្ករឡើងទេ ដោយសារខ្ញុំជាមនុស្សខាងសេចក្តីសុខសាន្តវិញ។ បក្សពួកដែលមកតាមយើងវិញ មកតាមដោយសារបានសម្លឹងមើលទៅកាន់សេចក្តីពិតនិងភាពស្អាតស្អំរបស់យើង ហើយពួកគេគ្រាន់តែប្រែចេញពីការអាក្រក់ជាងមកគ្រាន់បើបន្តិចប៉ុណ្ណោះ។ ចំណែកស្តេចដែលអ្នកនិយាយនោះ ក្នុងកាលដែលគេជាប៊ីលសេប៊ុល ជាសត្រូវរបស់ព្រះអម្ចាស់របស់យើង ខ្ញុំទាស់នឹងគេ ហើយនិងទេវតារបស់គេទាំងអស់។"

សេចក្តីប្រកាសត្រូវបានចេញមកថា ពួកគេត្រូវនិយាយសម្រាប់ព្រះអម្ចាស់របស់ពួកគេទាស់នឹងអ្នកទោសដែលនៅក្នុងគុក ត្រូវតែបង្ហាញមកនូវភស្តុតាងរបស់ពួកគេ។ ដូច្នេះក៏មានសាក្សីចូលមកចំនួនបីនាក់គឺ ច្រណែន លោភលន់ជឿលើអាភិនិហារ និង អរគុណដោយរើស។ ពួកគេត្រូវបានសួរថា តើពួកគេបានស្គាល់អ្នកទោសដែលនៅក្នុងគុកទេ? និងអ្វីដែលពួកគេបាននិយាយសម្រាប់ព្រះអម្ចាស់ជាស្តេចរបស់ពួកគេទាស់នឹងគេ?

ច្រណែន៖ បន្ទាប់មកច្រណែនក៏ឈរចេញមក ហើយនិយាយបែបនេះ "លោកម្ចាស់ខ្ញុំអើយ ខ្ញុំបានស្គាល់បុរសម្នាក់នេះពីយូរណាស់មកហើយ ហើយនឹងអះអាងសេចក្តីសម្បថរបស់ខ្ញុំនៅចំពោះតុដ៏មានកិត្តិយសនេះដែលថាគាត់"

ព្រះអម្ចាស់ស្អប់ការល្អ ជាចៅក្រម៖ ចាំសិន ចូរផ្តល់សេចក្តីសម្បថរបស់គាត់ដល់គាត់ទៅ!

ដូច្នេះពួកគេបានស្បថជាមួយទ្រង់។ បន្ទាប់មកគាត់និយាយថា "លោកម្ចាស់ខ្ញុំអើយ បុរសនេះមិនដូចនឹងឈ្មោះដែលសាកសមនឹងគាត់ទេ ជាមនុស្សម្នាក់ក្នុងចំណោមមនុស្សដែលចម្លែកបំផុតនៅក្នុងប្រទេសរបស់យើង។ គាត់មិនខ្វល់ពីស្តេចឬពីប្រជាជននោះឡើយ ឬច្បាប់ ឬទំនៀមទម្លាប់ឡើយ តែធ្វើគ្រប់យ៉ាងដែលគាត់អាចធ្វើបានដើម្បីកាន់កាប់មនុស្សទាំងអស់ដោយភាពច្បាស់លាស់នៃការមិនគោរពដល់ជាតិសាសន៍ ដែលជាទូទៅគាត់ហៅគោលការណ៍នេះថា ជាសេចក្តីជំនឿនិងភាពបរិសុទ្ធ។ ហើយជាទូទៅ ខ្ញុំបានឮគាត់ផ្ទាល់ម្តងអះអាងថាសាសនាគ្រីស្ទាននិងទំនៀមទម្លាប់របស់ទី

ក្រុងរបស់យើងនៃសេចក្តីឥតប្រយោជន៍ ផ្ទុយគ្នាស្រឡះ ហើយមិនត្រូវផ្សារភ្ជាប់គ្នាបានឡើយ។ ដោយនិយាយថា ព្រះអម្ចាស់របស់ខ្ញុំ គាត់បានធ្វើភ្លាមមិនត្រឹមតែដាក់ទោសដល់គ្រប់ទាំងការដែលយើងធ្វើគួរឱ្យសរសើរនោះទេ តែពួកគេនៅក្នុងការដែលធ្វើការទាំងនោះទៀត។"

ចៅក្រមៈ បន្ទាប់មកចៅក្រមបាននិយាយទៅកាន់គាត់ថា "តើមានអ្នកណាមានអ្វីដែលត្រូវនិយាយទៀតទេ?"

ច្រណែនៈ "លោកម្ចាស់ខ្ញុំអើយ ខ្ញុំអាចនិយាយបានច្រើនទៀត កុំឱ្យតែខ្ញុំបានគួរឱ្យធុញនៅក្នុងសាលក្រមនេះចុះ។ តែយ៉ាងណាបើត្រូវការ នៅពេលដែលសុភាពបុរសម្នាក់ទៀតផ្តល់ភស្តុតាងរបស់គាត់មក ជាជាងការអ្វីដែលត្រូវការដែលនឹងរៀបរាប់ពីគាត់ នោះខ្ញុំនឹងពង្រីកទីបន្ទាល់របស់ខ្ញុំថែមទៀតទាស់នឹងគាត់។" ដូច្នេះគាត់ត្រូវបានប្រាប់ឱ្យឈរនៅក្បែរនោះ។

បន្ទាប់មកពួកគេបានហៅ លោកជឿលើអាភិនីហារមក ហើយប្រាប់គាត់ឱ្យមើលទៅកាន់អ្នកទោស ពួកគេក៏បានសួរទៅកាន់គាត់ពីអ្វីដែលគាត់អាចនិយាយសម្រាប់លោកម្ចាស់ដែលជាស្តេចរបស់ពួកគេទាស់នឹងគាត់? បន្ទាប់មកពួកគេសួរគាត់ ដូច្នេះគាត់ចាប់និយាយថា
លោកជឿលើអាភិនីហារៈ លោកម្ចាស់ខ្ញុំអើយ ខ្ញុំមិនមានទំនាក់ទំនងអ្វីអស្ចារ្យជាមួយបុរសនេះនោះទេ ខ្ញុំក៏មិនប្រាថ្នាចង់មានចំណេះដឹងអ្វីច្រើនទៀតពីគាត់នោះដែរ។ យ៉ាងណាក៏ដោយ ខ្ញុំដឹងថា គាត់ជាមនុស្សម្នាក់ដែលអាចធ្វើឱ្យស្លាប់បាន ដោយមានការពិភាក្សាគ្នាខ្លះនៅថ្ងៃមួយនោះដែលខ្ញុំបាននិយាយជាមួយគាត់នៅក្នុងទីក្រុងនេះ កាលនោះ បាននិយាយជាមួយគាត់

ខ្ញុំបានឮគាត់និយាយថាសាសនារបស់យើងជាការទទេរ ហើយមិនអាចនឹងផ្គាប់ព្រះហឫទ័យដល់ព្រះបានឡើយ។ ការនិយាយរបស់គាត់ លោកម្ចាស់អើយ ភាពជាម្ចាស់របស់ទ្រង់បានស្គាល់អ្វីដែលចាំបាច់ដែលនឹងត្រូវតាមមកហើយគឺ ថាយើងនៅតែថ្វាយបង្គំដោយឥតប្រយោជន៍ នៅតែរស់នៅក្នុងអំពើបាប ហើយជាចុងក្រោយនឹងត្រូវជំនុំជំរះ ហើយនេះជាអ្វីដែលខ្ញុំត្រូវនិយាយហើយ។

បន្ទាប់មកអរគុណដោយរើសត្រូវបានសាកសួរ ហើយត្រូវប្រាប់ឱ្យ និយាយអ្វីដែលគាត់បានដឹងជំនួសមុខឱ្យម្ចាស់របស់គេដែលជាស្តេចទាស់នឹងអ្នកទោសនៅក្នុងគុក។

អរគុណរើសៈ លោកម្ចាស់ខ្ញុំអើយ និងសុភាពបុរសទាំងអស់គ្នា ខ្ញុំបានស្គាល់បុរសនេះជាយូរណាស់មកហើយ ហើយបានឮគាត់និយាយការដែលគាត់មិនត្រូវនិយាយ។ ដោយសារគាត់បានបះបោរទាស់នឹងស្តេចដ៏ថ្លៃថ្នូរបឺលសេប៊ុលរបស់យើង ហើយបាននិយាយដោយស្អប់ខ្ពើមដល់មិត្តសំឡាញ់ដែលមានកេរ្តិ៍ឈ្មោះរបស់យើង ដែលមានឈ្មោះដូចជា លោកម្ចាស់បុរសចំណាស់ លោកម្ចាស់នៃសេចក្តីអំណរខាងសាច់ឈាម លោកម្ចាស់ដែលឡូយឆាយ លោកម្ចាស់បំណងប្រាថ្នាការឥតប្រយោជន៍ លោកម្ចាស់ចាស់របស់ខ្ញុំលោកមិនល្មោភកាម លោកមានសេចក្តីលោភលន់ ជាមួយនឹងអ្នកខ្ពង់ខ្ពស់ផ្សេងៗទៀត ហើយគាត់បាននិយាយថែមទៀតថា ប្រសិនបើមនុស្សទាំងអស់មានគំនិតដូចគាត់ បើអាចទៅរួច នឹងមិនមានអ្នកធំណាមួយនឹងបន្តរស់នៅក្នុងទីក្រុងនេះទៀតឡើយ។ ក្រៅពីនោះ គាត់មិនខ្លាចនឹងបះបោរទាស់នឹងលោកម្ចាស់ឡើយ ដែលទ្រង់ត្រូវបានតែងតាំងធ្វើជា

ចៅក្រមនេះ ដោយហៅទ្រង់ថាអ្នកទាស់ដែលមិនកោតខ្លាចព្រះ ដោយប្រើពាក្យសម្ដីផ្សេងទៀតដែលអង្អាប់ដល់ឈ្មោះ សម្រាប់នឹងនិយាយប៉ះពាល់យ៉ាងខ្លាំងបំផុតដល់អ្នកមានមុខមាត់នៅទីក្រុងរបស់យើង។

នៅពេលអរគុណដោយរើសនេះបានប្រាប់ពីរឿងរបស់គាត់មក ចៅក្រមបានបង្វែរការអធិប្បាយរបស់គាត់ទៅកាន់អ្នកទោសដែលនៅក្នុងគុក ដោយពោលថា "ឯងជាអ្នកបះបោរ ខុសឆ្គង និងជនក្បត់! តើឯងបានឮអ្វីដែលសុភាពបុរសស្មោះត្រង់ទាំងនេះបាននិយាយទាស់នឹងឯងទេ?"

ស្មោះត្រង់៖ តើខ្ញុំអាចនិយាយការពារខ្លួនបន្តិចបានទេ?

ចៅក្រម៖ ស៊ីរ៉ា ស៊ីរ៉ា! ឯងមិនសមនឹងរស់បន្តទៀតឡើយ តែបើសម្លាប់ភ្លាមៗនៅទីនេះ ដែលមនុស្សទាំងអស់នឹងឃើញភាពទន់ភ្លន់របស់យើងទៅកាន់ឯង ចូរឱ្យយើងបានស្ដាប់ឯងដែលជាជនបះបោរចម្លែកនេះនឹងមានអ្វីនឹងត្រូវនិយាយសិនចុះ។

ស្មោះត្រង់៖ 1. ខ្ញុំនិយាយដោយឆ្លើយនូវអ្វីដែលលោកច្រណែនបាននិយាយថា ខ្ញុំមិនដែលនិយាយអ្វីក្រៅពីនេះឡើយគឺថា អ្វីដែលជាច្បាប់ ឬក្រឹត្យវិន័យ ឬទំនៀមទម្លាប់ ឬមនុស្ស ដែលទាស់នឹងព្រះបន្ទូលរបស់ព្រះ គឺផ្ទុយស្រលះទៅនឹងសាសនាគ្រីស្ទ។ ប្រសិនបើខ្ញុំបាននិយាយអ្វីក្រៅពីនេះ សូមប្រាប់នូវកំហុសរបស់ខ្ញុំផង ហើយខ្ញុំនៅទីនេះរួចរាល់នឹងធ្វើការបដិសេធវិញនៅចំពោះអ្នក។

2. សម្រាប់ទីពីរវិញគឺ លោកជឿលើអភិនីហារ និងការចោទប្រកាន់របស់គាត់ទាស់នឹងខ្ញុំ។ ខ្ញុំនិយាយតែប៉ុណ្ណោះទេ ថាការថ្វាយបង្គំព្រះត្រូវការសេចក្ដីជំនឿមកពីព្រះ តែមិនមានសេចក្ដីជំនឿមកពីព្រះណាក្រៅពីការបើកសម្ដែងរបស់ព្រះពីបំណងព្រះហឫទ័យរបស់ព្រះឡើយ។ ដូច្នេះ អ្វីដែលជាចាក់ចូលមកនៅក្នុងការថ្វាយបង្គំព្រះ ដែលមិនស្របតាមការបើកសម្ដែងរបស់ព្រះមិនអាចនឹងធ្វើឡើងបានឡើយ តែដោយសេចក្ដីជំនឿរបស់មនុស្ស ដែលជាសេចក្ដីជំនឿដែលមិនផ្ដល់នូវជីវិតអស់កល្បជានិច្ចឡើយ។

3. ទៅកាន់លោក អរគុណដោយរើសវិញ ដែលបាននិយាយ ខ្ញុំនិយាយថាការវាងពីពាក្យសម្ដី ដែលថាខ្ញុំបាននិយាយទាស់បែបអីចឹង ថាស្ដេចរបស់ក្រុងនេះ ជាមួយនឹងមនុស្សមួយហ្វូងទៀត ជាបរិវាររបស់គាត់ ដោយនូវឈ្មោះសុភាពបុរសម្នាក់នេះ គឺសុទ្ធតែសាកសមនឹងនៅក្នុងស្ថាននរកជាជាងនៅក្នុងទីក្រុងនិងប្រទេសនេះ ហើយដូច្នេះសូមព្រះអម្ចាស់ផ្ដល់សេចក្ដីមេត្តាដល់ខ្ញុំផង!

បន្ទាប់មកចៅក្រមបានហៅទៅកាន់គណៈវិនិច្ឆ័យ--ជាអ្នកដែលកំពុងឈរនៅទីនោះ ដើម្បីនិងស្ដាប់និងសង្កេតមើល "សុភាពបុរសម្នាក់ក្នុងចំណោមគណៈវិនិច្ឆ័យ អ្នកឃើញហើយថាបុរសនេះដែលបង្កនូវការច្របូលច្របល់នៅក្នុងទីក្រុងនេះ អ្នកក៏បានឮដែរថាសុភាពបុរសដែលថ្លៃថ្នូទាំងនេះបានធ្វើបន្ទាល់ទាស់នឹងគាត់ អ្នកក៏បានឮចម្លើយនិងការសារភាពរបស់គាត់ដែរ ពេលនេះវាស្ថិតនៅលើទ្រូងរបស់អ្នកហើយថានឹងឆ្កាងគាត់ ឬសង្គ្រោះជីវិតរបស់គាត់នោះ តែខ្ញុំគិតថានឹងណែនាំអ្នកនៅក្នុងក្រឹត្យវិន័យ។

"មានទង្វើមួយដែលបានធ្វើឡើងនៅក្នុងសម័យរបស់ស្តេចផារ៉ោនឱប្រេគ្គត ជាអ្នកបម្រើរបស់ស្តេចយើង ដើម្បីកុំឱ្យអ្នកដែលមានសាសនាខុសគ្នាត្រូវបានលូតលាស់ធំធាត់ខ្លាំងពេកសម្រាប់ទ្រង់នោះឡើយ នោះពួកប្រុសៗរបស់គេនឹងត្រូវបោះចោលទៅក្នុងទន្លេទៅ។"

"តែសាសន៍អ៊ីស្រាអែលគេបង្កើតកូនដុះដាលចម្រើនជាច្រើនឡើង ក៏បានទៅជាស្តុកស្តម្ភឡើងសន្ធឹក ទាំងនៅកុះករពេញក្នុងស្រុកនោះ។នៅគ្រានោះ មានស្តេចថ្មី១អង្គសោយរាជ្យឡើងនៅស្រុកអេស៊ីព្ទ ស្តេចនោះមិនបានស្គាល់យ៉ូសែបទេ។ ទ្រង់មានព្រះបន្ទូលទៅបណ្តារាស្ត្ររបស់ទ្រង់ថា មើល ពួកសាសន៍អ៊ីស្រាអែលគេមានគ្នាច្រើន ក៏ស្តុកស្តម្ភជាងពួកយើងហើយ។ ចូរយើងប្រព្រឹត្តនឹងគេដោយប្រាជ្ញា ក្រែងគេចម្រើនជាច្រើនឡើង ហើយបើកាលណាកើតមានចម្បាំង នោះគេនឹងចូលទៅខាងពួកខ្មាំងសត្រូវ ដើម្បីច្បាំងនឹងយើងវិញ រួចចេញពីស្រុកបាត់ទៅ។ ដូច្នេះ គេក៏ដាក់ឱ្យ មាននាយតម្រួត សម្រាប់នឹងធ្វើទុក្ខដល់ពួកអ៊ីស្រាអែលដោយការនឿយលំបាកជាច្រើន ពួកអ៊ីស្រាអែលបានកសាងក្រុងពីថំ និងរ៉ាមសេស សម្រាប់ជាឃ្លាំងថ្វាយផារ៉ោន។ ប៉ុន្តែដែលធ្វើទុក្ខគេប៉ុណ្ណា នោះគេក៏ចម្រើនជាច្រើន ទាំងសាយពេញពាសឡើងប៉ុណ្ណោះដែរ ហើយសាសន៍អេស៊ីព្ទមានសេចក្តីធុញទ្រាន់ ដោយព្រោះសាសន៍អ៊ីស្រាអែល។ក៏ចាប់ប្រើគេឱ្យ ធ្វើការយ៉ាងតឹងរ៉ឹង។ ព្រមទាំងធ្វើឱ្យជីវិតគេ មានសេចក្តីជូរល្វីង ដោយការលំបាកវេទនា គឺប្រើឱ្យ ធ្វើបាយអ និងឥដ្ឋ ព្រមទាំងការនៅចម្ការគ្រប់មុខផង ឯការដែលគេចាប់ប្រើឱ្យ ធ្វើទាំងប៉ុន្មាននោះសុទ្ធតែការយ៉ាងតឹងរ៉ឹងទាំងអស់។ រួចស្តេចស្រុកអេស៊ីព្ទទ្រង់ក៏បង្គាប់ដល់ពួកឆ្មបសាសន៍ហេព្រើរ ដែល១ឈ្មោះនាងស៊ីប្រា ហើយ១ទៀត

ឈ្មោះនាងពូអា ថាកាលណានាងទៅកាន់ពោះនៃពួកស្រីសាសន៍ហេព្រើរ ដែលសម្រាលកូន នោះក្នុងកាលដែលគេកំពុងតែសម្រាល បើជាកូននោះប្រុស ចូរសម្លាប់វាទៅ តែបើសិនជាស្រី នោះត្រូវទុកឱ្យ រស់នៅចុះ។ ប៉ុន្តែ ឆ្មបទាំងនោះជាអ្នកកោតខ្លាចដល់ព្រះ គេមិនបានធ្វើតាមបង្គាប់នៃស្តេចស្រុកអេស៊ីព្ទនោះឡើយ គឺបានទុកកូនប្រុសៗឱ្យ រស់នៅវិញ។ ឯស្តេចស្រុកអេស៊ីព្ទក៏ហៅឆ្មបទាំងនោះមកសួរថា ហេតុអ្វីបានជាធ្វើយ៉ាងដូច្នេះ គឺដែលទុកកូនប្រុសៗឱ្យ រស់នៅនេះ។ ឆ្មបទូលឆ្លើយទៅផារ៉ោនថា គឺពីព្រោះពួកស្រីសាសន៍ហេព្រើរមិនមែនដូចជាស្រីសាសន៍អេស៊ីព្ទទេ គេរហ័សណាស់ ដ្បិតឆ្មបមិនទាន់ទាំងមកដល់ផង នោះគេបានសម្រាលរួចជាមុនទៅហើយ។ដូច្នេះ ព្រះទ្រង់ក៏ប្រទានពរដល់ឆ្មបទាំងនោះ ឯពួកសាសន៍អ៊ីស្រាអែលគេកាន់តែចម្រើនជាច្រើនឡើង ត្រឡប់ទៅជាមានកម្លាំងគ្រប់ជំពូក។ ហើយដោយព្រោះពួកឆ្មបនោះមានសេចក្តីកោតខ្លាចដល់ព្រះ បានជាទ្រង់ចម្រើនពូជឱ្យ គេ។”

**និក្ខមនំ 1:7-22**

ក៏មានទង្វើមួយកើតឡើងនៅក្នុងសម័យរបស់ស្តេចនេកាប៊ូនេសាឱប្រេ្គត ជាអ្នកបម្រើរបស់ស្តេចយើងមួយទៀត ដែលថាអ្នកណាដែលមិនក្រាបចុះ និងថ្វាយបង្គំរូបមាស នឹងត្រូវបោះចូលទៅក្នុងគុកភ្លើងដ៏ក្តៅសន្ធោសន្ធៅ។

“រីឯស្តេចនេប៊ូក្នេសាទ្រង់ធ្វើរូបមាស១ មានកំពស់៦០ហត្ថ ទទឹង៦ហត្ថ ទ្រង់បញ្ឈររូបនោះនៅវាលឌូរ៉ាក្នុងខេត្តបាប៊ីឡូន។ រួចស្តេចនេប៊ូក្នេសាទ្រង់ចាត់ឱ្យទៅប្រមូលពួកចៅហ្វាយខេត្ត ពួកភូឈួយ ពួកចៅហ្វាយស្រុក ពួកចៅក្រម ពួកមេឃ្លាំង ពួកបាឡាត់ ពួកនាយកនគរបាល និងអស់ទាំងពួកមន្ត្រីខេត្តទាំង

ប៉ុន្មាន ឱ្យ គេប្រមូលគ្នាមកឯបុណ្យឆ្លងរូប ដែលស្តេចនេប៊ូក្នេសាតាំងឡើង នោះ។ ដូច្នេះ ពួកចៅហ្វាយខេត្ត ពួកភូឈ្មួយ ពួកចៅហ្វាយស្រុក ពួកចៅក្រម ពួកមេឃ្លាំង ពួកបាឡាត់ ពួកនាយកនគរបាល និងអស់ទាំងពួកមន្ត្រីខេត្ត ក៏មូលគ្នាមកឯបុណ្យឆ្លងរូបនោះ ដែលស្តេចនេប៊ូក្នេសាតាំងឡើង គេក៏ឈរនៅចំពោះរូបដែលទ្រង់តាំងទុកនោះ។ រួចមានអ្នក១ស្រែកប៉ាវប្រកាស ជាសំឡេងយ៉ាងខ្លាំងថា ម្នាលជនទាំងឡាយ ព្រមទាំងសាសន៍ដទៃ និងមនុស្សគ្រប់ភាសាអើយ មានសេចក្តីបង្គាប់ដល់អ្នករាល់គ្នាដូច្នេះថា។ វេលាណាដែលអ្នករាល់គ្នាឮស្នូរត្រែ ខ្លុយ ស៊ុង ចាប៉ី ពិណ និងប៉ី ហើយដន្ត្រីគ្រប់យ៉ាង នោះត្រូវក្រាបថ្វាយបង្គំដល់រូបមាស ដែលព្រះករុណាទ្រង់បានតាំងឡើងទៅ។ បើអ្នកណាមិនក្រាបថ្វាយបង្គំទេ នោះនឹងត្រូវបោះទៅកណ្តាលគុកភ្លើង ដែលកំពុងឆេះយ៉ាងសន្ធៅនៅវេលានោះឯង។ ដូច្នេះ នៅវេលានោះ កាលជនទាំងឡាយបានឮស្នូរត្រែ ខ្លុយ ស៊ុង ចាប៉ី ពិណ និងដន្ត្រីគ្រប់យ៉ាងហើយ នោះជនទាំងឡាយព្រមទាំងសាសន៍ដទៃ និងមនុស្សគ្រប់ភាសាផង ក៏ក្រាបថ្វាយបង្គំដល់រូបមាស ដែលស្តេចនេប៊ូក្នេសាបានតាំងទុកនោះ។នៅគ្រានោះ មានពួកខាល់ដេខ្លះចូលទៅជិតប្តឹងពីពួកសាសន៍យូដា។ គេទូលដល់ស្តេចនេប៊ូក្នេសាថា បពិត្រព្រះករុណា សូមឱ្យ ទ្រង់មានព្រះជន្មតរៀងទៅ។ បពិត្រព្រះករុណាទ្រង់បានចេញព្រះរាជបង្គាប់ថា អស់មនុស្សណាដែលឮស្នូរត្រែ ខ្លុយ ស៊ុង ចាប៉ី ពិណ ប៉ី និងដន្ត្រីគ្រប់យ៉ាង នោះត្រូវតែក្រាបថ្វាយបង្គំដល់រូបមាសនេះ។ ហើយថា បើអ្នកណាមិនក្រាបថ្វាយបង្គំទេ នោះត្រូវបោះទៅក្នុងគុកភ្លើងដែលឆេះយ៉ាងសន្ធៅ។ រីឯក្នុងពួកអ្នកដែលទ្រង់បានតាំងឡើង លើក្រសួងការខេត្តបាប៊ីឡូន នោះមានពួកសាសន៍យូដាខ្លះ គឺសាដ្រាក់ មែសាក់ និងអ័បេឌ-នេកោ ទាំង៣នាក់នោះ បពិត្រព្រះករុណា គេមិនបានស្តាប់បង្គាប់ទ្រង់ទេ គេក៏

មិនទាំងគោរពប្រតិបត្តិដល់ព្រះនៃទ្រង់ ឬថ្វាយបង្គំដល់រូបមាស ដែលទ្រង់បានតាំងឡើងនោះដែរ។ហេតុនោះ នេប៊ូក្នេសាទ្រង់មានសេចក្ដីក្រោធ និងសេចក្ដីឃោរឃៅយ៉ាងក្រៃលែង ក៏បង្គាប់ឱ្យ គេនាំសាដ្រាក់ មែសាក់ និងអ័បេឌ-នេកោមក ដូច្នេះ គេក៏នាំអ្នកទាំង៣នោះចូលមកនៅចំពោះស្ដេច។នេប៊ូក្នេសាទ្រង់មានព្រះបន្ទូលសួរគេថា ម្នាលសាដ្រាក់ មែសាក់ និងអ័បេឌ-នេកោ តើដោយបំណងចិត្តឬ ដែលឯងរាល់គ្នាមិនគោរពដល់ព្រះនៃយើង ឬថ្វាយបង្គំដល់រូបមាសដែលយើងបានតាំងឡើងហើយនោះ។ ឥឡូវនេះ បើឯងរាល់គ្នាប្រុងប្រៀបក្នុងវេលាណាដែលឮសូរត្រែ ខ្លុយ ស៊ុង ចាប៉ី ពិណ ប៉ី និងដន្ត្រីគ្រប់យ៉ាង ឱ្យ បានក្រាបថ្វាយបង្គំដល់រូបមាសដែលយើងបានធ្វើនេះ នោះបានហើយ តែបើមិនថ្វាយបង្គំទេ នោះនឹងត្រូវបោះឯងទៅក្នុងគុកភ្លើង ដែលឆេះយ៉ាងសន្ធៅ នៅវេលានោះឯង តើមានព្រះឯណាដែលអាចនឹងដោះឯងរាល់គ្នា ឱ្យ រួចពីកណ្ដាប់ដៃយើងបាន។ តែសាដ្រាក់ មែសាក់ និងអ័បេឌ-នេកោទូលឆ្លើយដល់ស្ដេចថា បពិត្រព្រះរាជានេប៊ូក្នេសា យើងខ្ញុំមិនចាំបាច់ទូលឆ្លើយដល់ទ្រង់ពីដំណើរនេះទេ។ បើជាយ៉ាងនោះមែន នោះព្រះនៃយើងខ្ញុំដែលយើងខ្ញុំគោរពប្រតិបត្តិតាម ទ្រង់អាចនឹងជួយឱ្យ ខ្ញុំរួចពីគុកភ្លើង ដែលឆេះយ៉ាងសន្ធៅបានហើយ បពិត្រព្រះករុណា ព្រះអង្គនោះក៏នឹងជួយឱ្យ យើងរួចពីព្រះហស្តទ្រង់ដែរ។ តែបើមិនជួយទេ នោះសូមឱ្យ ទ្រង់ព្រះករុណាជ្រាបថា យើងខ្ញុំមិនព្រមគោរពតាមព្រះរបស់ទ្រង់ឡើយ ក៏មិនព្រមថ្វាយបង្គំដល់រូបមាស ដែលទ្រង់បានតាំងឡើងនោះដែរ។” **ដានីយ៉ែល 3:1-18**

ក៏មានទង្វើដែលកើតឡើងនៅក្នុងសម័យរបស់ស្ដេចដារៀសដែរ ដែលគាត់

ក៏បានធ្វើដូច្នេះដែរ ពេលណាដែលអ្នកណាបានស្រែកហៅទៅកាន់ព្រះអម្ចាស់ណាក្រៅពីព្រះរបស់គាត់ នឹងត្រូវបោះចូលទៅក្នុងរូងសត្វតោហើយ។

"ឯដារីយុសទ្រង់សព្វព្រះទ័យនឹងតាំងចៅហ្វាយខេត្ត១២០នាក់ឡើង ឱ្យ ត្រួតត្រាលើនគរ ជាពួកអ្នកដែលត្រូវផ្សាយចេញទៅនៅពេញក្នុងនគរទាំងមូល។ ហើយឱ្យ មានអធិបតី៣នាក់ត្រួតលើចៅហ្វាយទាំងនោះ ដើម្បីឱ្យ គេរាប់រៀបប្រាប់ដល់ពួក៣នាក់នោះ ប្រយោជន៍មិនឱ្យ ស្តេចត្រូវខ្វះខាតឡើយ ឯដានីយ៉ែលលោកក៏នៅក្នុងពួកអធិបតីនោះដែរ។ រួចមកដានីយ៉ែលបានត្រឡប់ជាកំពូលលើពួកអធិបតី និងពួកចៅហ្វាយទាំងប៉ុន្មាន ដ្បិតលោកមានវិញ្ញាណយ៉ាងស្រួចស្រាល់ ហើយស្តេចទ្រង់គិតនឹងតាំងលោកឱ្យ ត្រួតលើនគរទាំងមូល។ ដូច្នេះ ពួកអធិបតី និងពួកចៅហ្វាយក៏ស្វែងរកហេតុពីដំណើររាជការផែនដី ឱ្យ ទាស់នឹងដានីយ៉ែល តែគេរកឱកាស ឬកំហុសអ្វីមិនបានឡើយ ក៏មិនឃើញមានថ្លស់ធ្លោយ ឬទោសទាស់អ្វីដែរ ពីព្រោះលោកជាមនុស្សស្មោះត្រង់។ ដូច្នេះ ពួកអ្នកទាំងនោះប្រឹក្សាគ្នាថា យើងនឹងរកឱកាសទាស់នឹងឈ្មោះដានីយ៉ែលនេះមិនបានឡើយ វៀរតែរកបានខាងឯក្រឹត្យវិន័យរបស់ព្រះនៃវាប៉ុណ្ណោះ។ ពួកអធិបតី និងពួកចៅហ្វាយទាំងនោះ ក៏នាំគ្នាចូលទៅគាល់ស្តេចទូលដូច្នេះថា បពិត្រព្រះរាជាដារីយុស សូមឱ្យ ទ្រង់បានប្រកបដោយព្រះជន្មចម្រើនជាយឺនយូរតទៅ។ ពួកអធិបតីក្នុងនគរ ពួកចៅហ្វាយខេត្ត ពួកភូឈ្មួយពួកបាឡាត់ និងពួកចៅហ្វាយស្រុក បានជំនុំព្រមគ្នា ចង់តាំងព្រះរាជឱង្ការ១ច្បាប់ គឺជាសេចក្តីបំរាមយ៉ាងតឹងរ៉ឹងថា បើអ្នកណានឹងសូមអ្វីពីព្រះណា ឬពីមនុស្សណាក៏ដោយ វៀរតែសូមពីព្រះរាជាក្នុងរវាង៣០ថ្ងៃ នោះនឹងត្រូវបោះចោលទៅក្នុងរូងសិង្ហ។ បពិត្រព្រះរាជា ដូច្នេះ សូមទ្រង់តាំងច្បាប់ ហើយចុះ

ហត្ថលេខានៅច្បាប់នោះ ប្រយោជន៍មិនឱ្យ ផ្លាស់ប្រែបាន តាមរបៀបច្បាប់នៃសាសន៍មេឌី និងសាសន៍ពើស៊ី ដែលនឹងផ្លាស់ប្តូរមិនបានឡើយ។ ដូច្នេះ ស្តេចដារីយុសទ្រង់ក៏ចុះហត្ថលេខា នៅសំបុត្រជាសេចក្តីបំរាមនោះ។" **ដានីយ៉ែល 6:1-9**

ពេលនេះធាតុនៃច្បាប់ក្រឹត្យក្រមទាំងនេះ អ្នកបះបោរនេះធ្វើល្មើសហើយមិនត្រឹមតែនៅក្នុងគំនិត (ដែលមិនត្រូវមានផង) តែក៏នៅក្នុងពាក្យសម្តីនិងទង្វើផង ដែលមិនត្រូវបន្ធូរបន្ថយទោសឱ្យឡើយ។

"ដោយសារផារ៉ោន ច្បាប់របស់ទ្រង់បានបង្កើតមកនៅលើសេចក្តីសង្ស័យដើម្បីការពារការបង្ករគ្រោះថ្នាក់ មិនមានទោសពេលណាដែលលេចមកទេ តែនៅទីនេះមានទោសមួយលេចឡើង។ ដោយសារទីពីរ ទីបី អ្នកបានឃើញការឈ្លោះប្រកែកទាស់នឹងសាសនារបស់យើង និងដោយសារការឃុបឃិតដែលកាត់បានសារភាព គាត់សាកសមនឹងស្លាប់។"

បន្ទាប់មកអ្នកjury បានចេញក្រៅ ដែលមានឈ្មោះថា លោកមនុស្សខ្វាក់ លោកមិនល្អសោះ លោកឃោឃៅ លោកស្រឡាញ់កាមតណ្ហា លោករស់ដោយធូររលុង លោកជាមេ លោកគំនិតខ្ពស់ លោកភាពជាសត្រូវ លោកកុហក លោកសាហាវ លោកស្អប់ពន្លឺ និងលោកគ្មានក្តីអាណិតអាសូរ ដែលជាអ្នកបានផ្តល់ការសម្រេចរៀងៗខ្លួនទាស់នឹងគាត់នៅក្នុងចំណោមពួកគេ ហើយបន្ទាប់មកបានសរុបដោយមិនច្បាស់លាស់ នាំឱ្យគាត់មានទោសនៅចំពោះចៅក្រម។ ជាដំបូងនៅក្នុងចំណោមពួកគេ លោកមនុស្សខ្វាក់ជា

មនុស្សដំបូងបាននិយាយថា "ខ្ញុំឃើញច្បាស់ថាមនុស្សនេះជាអ្នកមានជំនឿខុសឆ្គង។ បន្ទាប់មកលោកមិនមានការល្អសោះថា "សូមឱ្យមនុស្សបែបនេះចេញបាត់ពីផែនដីនេះទៅ" "អេហ៍" លោកឃោឃៅនិយាយថា "ដោយខ្ញុំស្អប់រូបរាងគ្រប់យ៉ាងរបស់គាត់ណាស់" បន្ទាប់មកលោកស្រឡាញ់កាមតណ្ហានិយាយថា "ខ្ញុំមិនអាចទ្រាំនឹងគាត់បានឡើយ" "ខ្ញុំក៏ទ្រាំមិនបានដែរ" លោកធូររលុងនិយាយបែបនេះ "ដោយសារគាត់តែងតែកាត់ទោសដល់ផ្លូវរបស់ខ្ញុំ" "ចូរឆ្កាងវាទៅ ឆ្កាងទៅ!" លោកជាមេបាននិយាយថា "ជាច្រាស់ដ៏អាក្រក់" លោកគំនិតខ្ពស់និយាយដូច្នេះ។ "ចិត្តរបស់ខ្ញុំឡើងទាស់នឹងគេ" លោកភាពជាសត្រូវនិយាយមក។ "គេជាមនុស្សចង្រៃ លោកកុហកបាននិយាយមក។ "ការឆ្កាងជាការល្អពន់ពេលសម្រាប់វាហើយ" លោកគ្មានសេចក្ដីមេត្តានិយាយដូច្នេះ "ខ្ញុំនឹងមានគ្រប់យ៉ាងដែលលោកិយនឹងផ្ដល់មកខ្ញុំ ខ្ញុំនឹងមិនត្រូវរូវជាមួយនឹងវាឡើយ ដូច្នេះចូរយើងយកកំហុសវាចេញមកឱ្យមានទោសដល់ស្លាប់ចុះ" ហើយគេក៏ធ្វើដូច្នោះ ដូច្នេះពេលនេះគាត់ត្រូវគេធ្វើទោសពីទីដែលគាត់កំពុងនៅទៅទីដែលគាត់បានមក ហើយនៅទីនោះគាត់ត្រូវបានគេសម្លាប់ដោយសេចក្ដីស្លាប់ដ៏ឃោឃៅបំផុតដែលធ្លាប់មាន។

ដូច្នេះពួកគេបាននាំគាត់ចេញ ដើម្បីនឹងធ្វើដាក់គាត់ទៅច្បាប់របស់ពួកគេ ហើយដំបូងពួកគេបានធ្វើទុក្ខបុកម្នេញគាត់ ហើយបន្ទាប់មកពួកគេវាយដំគាត់ បន្ទាប់មកពួកគេភ្លាស់សាច់របស់គាត់ដោយកាំបិត បន្ទាប់មកពួកគេបានចោលគាត់នឹងដុំថ្ម ហើយបានចាក់គាត់នឹងដាវរបស់ពួកគេ ហើយជាចុងក្រោយបង្អស់ពួកគេបានដុតគាត់ទៅជាផេះនៅគំនរនោះ។ ដូច្នេះស្មោះត្រង់ក៏មកដល់ទីបញ្ចប់របស់គាត់។ ពេលនេះខ្ញុំបានឃើញថា មានរទេះជា

ច្រើននិងសេះមួយចំនួនដែលរងចាំស្មោះត្រង់នៅខាងក្រោយ ដែលជាអ្នកភ្លាមៗដែលពួកសត្រូវបានផ្ដាច់ជីវិតគាត់នោះ បានយកទៅក្នុងរទេះ ហើយត្រូវបានយកឡើងឆ្ពោះទៅលើពពកតែម្ដង ជាមួយនឹងសម្លេងត្រែ ជាផ្លូវដ៏លឿនបំផុតទៅកាន់ឃ្លោងទ្វារស្ថានសួគ៌។ តែសម្រាប់គ្រីស្ទានវិញ គាត់មានភាពធូរស្បើយបន្តិច ហើយត្រូវបានយកទៅដាក់នៅក្នុងគុកវិញ ដូច្នេះគាត់បន្តនៅទីនោះមួយកន្លែង។ ប៉ុន្តែមួយអង្គដែលគ្រប់គ្រងលើការទាំងអស់ មានអំណាចដោយសារកំហឹងរបស់ទ្រង់នៅក្នុងព្រះហស្តរបស់ទ្រង់ ក៏បានហ៊ុមព័ទ្ធជុំវិញគ្រីស្ទាន ដោយសារពេលនេះ គាត់ក៏បានគេចរួចខ្លួនហើយទៅតាមផ្លូវរបស់គាត់ទៅ។

ហើយគាត់បានដើរទៅទាំងច្រៀងថា

"ពិតណាស់ស្មោះត្រង់អើយ អ្នកបានសារភាពដោយស្មោះត្រង់ទៅកាន់ព្រះអម្ចាស់របស់អ្នកហើយ ជាទ្រង់នឹងប្រទានពរដល់អ្នក នៅពេលដែលអ្នកដែលគ្មានជំនឿ នឹងទទួលបានសេចក្ដីអំណរដោយអសារឥតការទទេ ដែលកំពុងតែស្រែកនៅក្នុងបញ្ហាដែលមកពីស្ថាននរក ចូរច្រៀងឡើងស្មោះត្រង់អើយច្រៀងឡើង! ហើយសូមឱ្យឈ្មោះរបស់អ្នកនៅជានិច្ច បើទោះជាពួកគេសម្លាប់អ្នកក៏ដោយ តែអ្នកនៅតែនៅរស់នៅឡើយ។"

ពេលនេះខ្ញុំបានឃើញនៅក្នុងសុបិនរបស់ខ្ញុំថា គ្រីស្ទានមិនមែនទៅមុខតែម្នាក់ឯងទេ ដោយសារមានម្នាក់ឈ្មោះពេញដោយក្ដីសង្ឃឹម (ដោយបង្កើតបានមកដោយការសង្កេតមើលទៅគ្រីស្ទាននិងស្មោះត្រង់ នៅក្នុងពាក្យសម្ដីនិងការប្រព្រឹត្តរបស់ពួកគេ នៅក្នុងសេចក្ដីរងទុក្ខរបស់ពួកគេនៅទីតាំង

ពិព័រណ៍នោះ) ដែលបានដាក់ខ្លួនមកតាមគាត់ ហើយបានតាំងសញ្ញាធ្វើជាបងប្អូននឹងគ្នា ដែលបានប្រាប់គាត់ថានឹងធ្វើជាគ្នារបស់គាត់។ ដូច្នេះម្នាក់បានស្លាប់ដើម្បីនឹងធ្វើបន្ទាល់ពីសេចក្តីពិត និងអ្នកផ្សេងទៀតបានលេចឡើងពីផេះរបស់គាត់ដើម្បីធ្វើជាគ្នាជាមួយនឹងគ្រីស្ទាននៅក្នុងការធ្វើធម្មយាត្រារបស់គាត់។ ពេញដោយសង្ឃឹមម្នាក់នេះក៏បានប្រាប់គ្រីស្ទានថា មានមនុស្សជាច្រើនទៀតនៅឯពិព័រណ៍ចង់ចំណាយពេលរបស់ពួកគេនិងមកតាម។

25

## លោកដល់ទីបញ្ចប់

ដូច្នេះខ្ញុំឃើញថា ភ្លាមនោះបន្ទាប់ពីពួកគេបានចេញផុតពីកន្លែងជំនួញនោះ ពួកគេតាមទាន់ម្នាក់ដែលកំពុងដើរនៅខាងមុខពួកគេ គាត់មានឈ្មោះថា ដល់ទីបញ្ចប់។ ដូច្នេះពួកគេនិយាយទៅគាត់ថា "តើលោកជាមនុស្សមកពីប្រទេសណាដែរ?" គាត់បានប្រាប់ពួកគេថា គាត់មកពីក្រុង សម្ដីត្រឹមត្រូវ ហើយគាត់កំពុងទៅកាន់ទីក្រុងស្ថានសួគ៌ (តែមិនបានប្រាប់ឈ្មោះគាត់ដល់ពួកគេទេ)។

គ្រីស្ទាន៖ ‟មកពីក្រុងសម្ដីត្រឹមត្រូវ″ គ្រីស្ទានបានពោលថា "តើមានមនុស្សល្អណារស់នៅទីនោះទេ?"

**‟កាលណាអ្នកនោះពោលពាក្យល្អ នោះកុំឱ្យជឿឱ្យសោះ ដ្បិតនៅក្នុងចិត្តគេមានសេចក្ដីគួរស្អប់ខ្ពើម៧មុខ។″ សុភាសិត 26:25**

ដល់ទីបញ្ចប់៖ ‟បាទ″ ដល់ទីបញ្ចប់បាននិយាយថា ‟ខ្ញុំសង្ឃឹម។″

គ្រីស្ទាន៖ ‟សូមលោក ប្រាប់មកថា ខ្ញុំនឹងហៅលោកថាយ៉ាងម៉េច?″ គ្រីស្ទានបាននិយាយ។

ដល់ទីបញ្ចប់៖ ខ្ញុំជាជនប្លែកមុខសម្រាប់អ្នក ហើយអ្នកក៏ជាមនុស្សប្លែកមុខសម្រាប់ខ្ញុំដែរ។ ប្រសិនបើអ្នកនឹងដើរតាមផ្លូវនេះ ខ្ញុំរីករាយនឹងមានអ្នកជាគ្នា។ បើអត់ទេនោះ ខ្ញុំនឹងត្រូវស្កប់ចិត្តដែរ។

គ្រីស្ទានៈ "ទីក្រុងនៃសម្ដីត្រឹមត្រូវ" គ្រីស្ទាននិយាយថា "ខ្ញុំធ្លាប់ឮដែរ ហើយខ្ញុំចាំថា គេនិយាយថាជាទីដែលមានស្ដុកស្ដម្ភ។"

ដល់ទីបញ្ចប់ៈ បាទ ខ្ញុំអាចអះអាងការនេះដល់អ្នកបាន ហើយខ្ញុំមានបងប្អូនអ្នកមានជាច្រើននៅទីនោះ។

គ្រីស្ទានៈ សូមប្រាប់មកថាអ្នកណាជាសាច់ញាតិរបស់អ្នកនៅទីនោះ ប្រសិនបើបុរសម្នាក់នឹងមានភាពក្លាហាន?

ដល់ទីបញ្ចប់ៈ ស្ទើរតែពេញទីក្រុងទាំងមូល ហើយជាទូទៅ លោកម្ចាស់របស់ខ្ញុំឈ្មោះ វង្វង់មូល លោកម្ចាស់ពេលលំបាកវេទនា លោកម្ចាស់សម្ដីត្រឹមត្រូវ (ចេញពីបុព្វបុរសរបស់ពួកគេដែលទីក្រុងដាក់ឈ្មោះជាលើកដំបូង) ហើយលោកមនុស្សនិយាយរអិល លោកបែរមុខដាក់ផ្លូវសងខាង លោកគ្រប់យ៉ាង និងបុរសនៅភូមិរបស់យើងលោកអណ្ដាតពីរ ជាប្អូនប្រុសរបស់ម្ដាយខ្ញុំផ្ទាល់ខាងឪពុករបស់ខ្ញុំ។ ហើយបើប្រាប់អ្នកការពិតទៅ ខ្ញុំបានក្លាយជាសុភាពបុរសម្នាក់ដែលមានគុណតម្លៃល្អ តែតាទួតរបស់ខ្ញុំជាបុរសនៅទឹកម្នាក់ គាត់មើលទៅម្ខាង តែបែរជាអុំទៅម្ខាងផ្សេងទៀត ហើយខ្ញុំទទួលបានទឹកដីរបស់ខ្ញុំដោយមុខរបរដូចគ្នានោះ។

គ្រីស្ទានៈ តើអ្នករៀបការហើយឬនៅ?

ដល់ទីបញ្ចប់ៈ បាទ។ ប្រពន្ធរបស់ខ្ញុំជាស្ត្រីគ្រប់លក្ខណ៍ម្នាក់ ជាកូនស្រីរបស់ស្ត្រីគ្រប់លក្ខណ៍ម្នាក់។ នាងជាកូនស្រីរបស់អ្នកនាង ធ្វើសម្ដែងម្នាក់។ ដូច្នេះនាងបានមកពីគ្រួសារមួយដ៏មានកេរ្ដិ៍ឈ្មោះ ហើយបានមកដល់ការបង្កាត់

មួយដូចនេះ ដែលនាងដឹងពីរបៀបយកវាទៅដល់គ្រប់គ្នា ទាំងទៅដល់ស្តេច និងកសិករផង។ "ពិតណាស់ដែលយើងខុសគ្នាខាងសាសនាពីអ្នកដែលមានប្រភពដែលតឹងរឹងជាង។ តែនៅក្នុងចំនុចតូចពីរ ទីមួយ យើងមិនដែលជំនះទាស់នឹងខ្យល់ឬរលកឡើយ។ ទីពីរ យើងតែងតែស្វាហាប់បំផុតនៅពេលសាសនានៅក្នុងស្បែកជើងប្រាក់នេះ យើងចូលចិត្តដើរជាមួយគាត់នៅតាមផ្លូវប្រសិនបើព្រះអាទិត្យរះ ហើយមនុស្សអបអរសោរទរវា។"

បន្ទាប់មកគ្រីស្ទានបានឈានទៅខាងបន្តិចដើម្បីដើរតាមពេញដោយសង្ឃឹម ពោលថា "វារត់នៅក្នុងគំនិតរបស់ខ្ញុំថា ម្នាក់នេះជាដល់ទីបញ្ចប់ មកពីសម្តីត្រឹមត្រូវ ហើយប្រសិនបើជាវាមែននោះ យើងពិតជាមានមនុស្សដែលមិនស្មោះត្រង់នៅក្នុងក្រុមដែលនៅមកដល់ផ្នែកទាំងនេះហើយ។" បន្ទាប់មកពេញដោយសង្ឃឹមនិយាយថា "ចូរសួរគាត់ទៅ ខ្ញុំគិតថាគាត់មិនខ្មាសនឹងឈ្មោះរបស់គេទេ។" ដូច្នេះគ្រីស្ទានដើរមករកគាត់ម្តងទៀត ហើយនិយាយថា "លោក អ្នកនិយាយហាក់ដូចជាអ្នកដឹងអ្វីមួយច្រើនជាងអ្នកនៅលោកិយទាំងអស់ដឹង ហើយប្រសិនបើខ្ញុំមិនបានចំណាំខុសទេនោះ ខ្ញុំគិតថាខ្ញុំបានទាយបានខ្លះពីអ្នកហើយ។ តើមិនមែនឈ្មោះរបស់អ្នកហៅថា លោកដល់ទីបញ្ចប់ មកពីសម្តីត្រឹមត្រូវទេឬ?"

ដល់ទីបញ្ចប់៖ ហ្នឹងមិនមែនជាឈ្មោះរបស់ខ្ញុំទេ តែពិតទៅវាគ្រាន់តែជាឈ្មោះហៅក្រៅមួយដែលអ្នកខ្លះហៅ ដែលមិនត្រូវនៅជាប់នឹងខ្ញុំឡើយ។ ហើយខ្ញុំត្រូវតែស្កប់ចិត្តដែលទទួលវាមកដូចជាការរិះគន់ ដូចជាមនុស្សល្អផ្សេងទៀតបានទទួលឈ្មោះរបស់គេមុនខ្ញុំនោះដែរ។

គ្រីស្ទាន៖ តែតើអ្នកមិនដែលផ្តល់ឱកាលដល់មនុស្សហៅអ្នកនូវឈ្មោះនេះទេឬ?

ដល់ទីបញ្ចប់៖ ទេ មិនធ្លាប់ទេ! ឱកាសដ៏អាក្រក់បំផុតដែលខ្ញុំបានបានឱ្យគេហៅឈ្មោះខ្ញុំដូចនេះ ដែលខ្ញុំតែងតែឈានទៅដល់ការសន្មត់របស់ខ្ញុំដោយផ្លូវបច្ចុប្បន្ននេះថា អ្វីដែលកើតឡើងហើយ និងឱកាសរបស់ខ្ញុំដែលនឹងទទួលបាននោះ តែប្រសិនបើការនោះត្រូវទម្លាក់មកលើខ្ញុំ សូមឱ្យខ្ញុំបានរាប់ការទាំងនោះថាជាពរវិញ តែសូមកុំឱ្យមនុស្សស្អប់ខ្ពើមផ្តល់នូវការរិះគន់ដល់ខ្ញុំនោះឡើយ។

គ្រីស្ទាន៖ ខ្ញុំបានគិតថាថាអ្នកពិតជាបុរសម្នាក់ដែលខ្ញុំបានឮ ហើយបានប្រាប់អ្នកនូវអ្វីដែលខ្ញុំគិត ខ្ញុំខ្លាចថាឈ្មោះនេះជាឈ្មោះរបស់អ្នកយ៉ាងសមរម្យជាង អ្នកចង់ឱ្យយើងគិតបែបនោះ។

ដល់ទីបញ្ចប់៖ ពិតណាស់ ប្រសិនបើអ្នកស្រម៉ៃបែបនេះ ខ្ញុំមិនជួយអ្វីមិនបានឡើយ។ អ្នកត្រូវតែរកឃើញខ្ញុំថាជាគ្នាដែលល្អ ប្រសិនបើអ្នកនៅតែទទួលស្គាល់ថាខ្ញុំជាគ្នារបស់អ្នក។

គ្រីស្ទាន៖ប្រសិនអ្នកទៅជាមួយយើង អ្នកត្រូវតែទៅប្រឆាំងនឹងខ្យល់និងរលក ដែលខ្ញុំយល់ថានឹងទាស់ជាមួយនឹងគំនិតរបស់អ្នក។ អ្នកត្រូវតែមានសាសនាទាំងនៅក្នុងកាលគាត់មានសំលៀកបំពាក់រហែក ក៏ដូចជាពេលដែលគាត់មានស្បែកជើងប្រាក់ផង។ ហើយឈរនៅក្បែរគាត់ផងនៅពេល

ដែលគាត់ត្រូវដាក់ច្រវាក់ដែក ក៏ដូចជាពេលដែលគាត់ដើរនៅផ្លូវដោយមានការសាទរផង។

ដល់ទីបញ្ចប់៖ អ្នកមិនត្រូវបង្ខំឬធ្វើម្ចាស់លើសេចក្តីជំនឿរបស់ខ្ញុំឡើយ។ ចូរចេញពីខ្ញុំឱ្យមានសេរីភាពរបស់ខ្ញុំវិញ ហើយឱ្យខ្ញុំបានទៅជាមួយអ្នកផង។

គ្រីស្ទាន៖ មិនទៅមុខសូម្បីតែមួយជំហានទៀតឡើយ លើកលែងតែអ្នកនឹងធ្វើតាមអ្វីដែលខ្ញុំបានពន្យល់នេះ។

ដល់ទីបញ្ចប់៖ បន្ទាប់មកដល់ទីបញ្ចប់និយាយថា "ខ្ញុំនឹងមិនចោលគោលការណ៍ចាស់របស់ខ្ញុំឡើយ ក្នុងកាលដែលវាមិនមានគ្រោះថ្នាក់ និងមានប្រយោជន៍ផង។ ប្រសិនបើខ្ញុំមិនទៅជាមួយអ្នក ខ្ញុំត្រូវធ្វើអ្វីដែលខ្ញុំបានធ្វើពីមុនពេលអ្នកមកទាន់ខ្ញុំ ទោះទៅតែម្នាក់ឯង រហូតដល់មានអ្នកខ្លះមកទាន់ខ្ញុំនឹងបានធ្វើជាគ្នាខ្ញុំដោយរីករាយ។"

ពេលនេះខ្ញុំបានឃើញនៅក្នុងសុបិនរបស់ខ្ញុំថាគ្រីស្ទាននិងពេញដោយសង្ឃឹមបានបដិសេធគាត់ ហើយបានរក្សាគម្លាតពីគាត់។ តែម្នាក់ក្នុងពួកគេបានបែរក្រោយ ហើយបានឃើញបុរសបីនាក់ដើរតាមលោកដល់ទីបញ្ចប់។ ហើយមើលទៅនៅពេលដែលពួកគេមកទាន់គាត់ គាត់បានធ្វើឱ្យពួកគេឱនចុះទាបបំផុត ហើយពួកគេក៏បានផ្តល់ការសរសើរដល់គាត់។ ឈ្មោះរបស់ពួកគេគឺ លោកកាន់តាមលោកិយ លោកស្រឡាញ់លុយ និងលោកសង្គ្រោះទាំងអស់ ជាមនុស្សដែលលោកដល់ទីបញ្ចប់បានស្គាល់ពីមុនមក ដោយសារក្នុងភាគតិចរបស់ពួកគេ ពួកគេជាអ្នករៀនជាមួយគ្នា ហើយបាន

រៀនជាមួយនឹងលោករអ៊ូរទាំ ជាចាងហ្វាងសាលានៅក្នុងស្រឡាញ់ផលប្រយោជន៍ ដែលជាផ្សារនៅក្រុងមួយនៅប្រទេសនៃសេចក្តីលោភលន់ នៅភាគខាងជើង។ ចាងហ្វាងសាលានេះបានបង្រៀនដល់ពួកគេពីសិល្បៈនៃការទទួលបានទាំងដោយកំលាំងបាយ ការបោកបញ្ឆោត ដោយការបញ្ចួរការកុហក់ ឬដោយការបន្លំជាសាសនា ហើយមនុស្សបួននាក់នេះរៀនបានពូកែយ៉ាងខ្លាំងនៅក្នុងសិល្បៈនៃចៅហ្វាយរបស់គេ ដូច្នេះពួកគេម្នាក់ៗបានរក្សាសាលារៀនបែបនេះដោយផ្ទាល់។

ពិតណាស់ នៅពេលដែលពួកគេបានរាក់ទាក់គ្នាទៅវិញទៅមករួចហើយ លោកស្រឡាញ់លុយ និងលោកដល់ទីបញ្ចប់និយាយថា "តើពួកគេជាអ្នកណាដែលនៅខាងមុខយើងនោះ?" ដោយសារគ្រីស្ទាននិងពេញដោយសង្ឃឹមត្រូវបានពួកគេមើលឃើញនៅឡើយ។

ដល់ទីបញ្ចប់៖ ពួកគេជាមនុស្សពីរនាក់ដែលមកពីប្រទេសឆ្ងាយដែល កំពុងទៅធ្វើធម្មយាត្រា។

ស្រឡាញ់លុយ៖ ព្រះអើយ! ហេតុអ្វីបានជាពួកគេមិនចាំសិន នោះយើងនឹងបានគ្នាយ៉ាងល្អ។ ដោយសារពួកគេហើយនឹងយើង និងអ្នកលោកអើយ ខ្ញុំសង្ឃឹមថាយើងទាំងអស់គ្នានឹងបានធ្វើធម្មយាត្រាជាមួយគ្នា?

ដល់ទីបញ្ចប់៖ យើងកំពុងធ្វើធម្មយាត្រាពិតមែន។ តែបុរសដែលនៅខាងមុខយើងពិតជារឹងរូសណាស់ ហើយពួកគេស្រឡាញ់ទំនោររបស់របស់ពួកគេខ្លាំងណាស់ ហើយមិនសូវឱ្យតម្លៃដល់ភាពជាគូរកនរបស់អ្នកផ្សេងឡើយ

ដែលទោះបីជាមនុស្សម្នាក់ក៏មិនដែលបានកោតខ្លាចព្រះខ្លាំងអីចឹងដែរ តែប្រសិនបើគេមិនទៅតាមពួកគេគ្រប់យ៉ាងទេ ពួកគេនឹងបោះគាត់ចោលចេញពីក្រុមរបស់ពួកគេ។

លោកសង្គ្រោះទាំងអស់៖ អាក្រក់ណាស់។ តែយើងបានអានពីអ្នកខ្លះដែលសុចរិតខ្លាំង និងសេចក្ដីសុចរិតរបស់មនុស្សដែលយកឈ្នះជាមួយនឹងពួកគេដែលកាត់ទោសនិងដាក់ទោសតែខ្លួនពួកគេ។ តែសូមប្រាប់ខ្ញុំមកថា ការអ្វីហើយរបៀបណាខ្លះដែលជាការខុសគ្នាជាមួយអ្នកទៅ?

ដល់ទីបញ្ចប់៖ ដោយសារបន្ទាប់ពីបែបបទរឹងរុសរបស់ពួកគេមក បានសន្មត់ថាវាជាតួនាទីរបស់ពួកគេដែលត្រូវរុសរាន់ទៅធ្វើដំណើររបស់ពួកគេនៅក្នុងគ្រប់អាកាសធាតុទាំងអស់។ ហើយខ្ញុំវិញត្រូវរងចាំខ្យល់និងរលក។ ពួកគេប្រាថ្នាគ្រប់យ៉ាងសម្រាប់ព្រះ ហើយខ្ញុំវិញប្រមូលផលប្រយោជន៍ទាំងអស់មកដើម្បីនឹងទំនុកបម្រុងជីវិតនិងសម្បត្តិរបស់ខ្ញុំ។ ពួកគេសម្រាប់នឹងកាន់តាមគំនិតទោរទន់របស់ពួកគេ បើទោះជាមនុស្សទាំងអស់ទាស់នឹងពួកគេក៏ដោយ តែខ្ញុំវិញសម្រាប់សាសនារហូតទាល់តែដល់ពេលណាដែលខ្ញុំនៅមានសុវត្ថិភាពខ្ញុំនឹងទ្រាំទ្រ។ ពួកគេសម្រាប់សាសនាទាំងនៅសំលៀកបំពាក់កន្ទបនិងក្នុងការមើលងាយ តែខ្ញុំសម្រាប់មួយអង្គដែលទ្រង់ដើរនៅក្នុងស្បែកជើងមាសរបស់ទ្រង់នៅក្នុងពន្លឺព្រះអាទិត្យ និងមានទាំងសារអបអរសាទរផង។

លោកកាន់តាមលោកិយ៖ អេ សុំឈប់នៅទីនោះសិនហើយ លោកដល់ទីបញ្ចប់អើយ ដោយសារ សម្រាប់ខ្ញុំវិញ ខ្ញុំមានតែរាប់គាត់ថាជាមនុស្សល្ងង់

ដែល មានសេរីភាពរក្សាអ្វីដែលគាត់មានហើយ ដែលល្ងង់ឱ្យត្រូវបាត់បង់បាន។ ចូរយើងឆ្លាតដូចជាសត្វពស់ នេះជាការល្អដែលត្រូវធ្វើចំបើងទាន់មានព្រះអាទិត្យចែងចាំង អ្នកឃើញហើយថាសត្វឃ្មុំនៅតែដេកនៅពេលរដូវរងាហើយចាប់ធ្វើការនៅពេលដែលនាងអាចទទួលបានផលដោយអំណរប៉ុណ្ណោះ។ ជូនកានព្រះបញ្ជូនភ្លៀងមក ហើយជួនកាលថ្ងៃក្តៅមក ប្រសិនបើគេល្ងង់ទៅឆ្លងកាត់ទីមួយហើយ តែចូរយើងបានស្តប់ចិត្តដែលដើរនៅពេលអាកាសធាតុល្អជានិច្ចជាមួយយើង។ ចំណែកខ្ញុំវិញ ខ្ញុំចូលចិត្តសាសនានោះខ្លាំងដោយឈតជាមួយនឹងសុវត្ថិភាពនៃព្រះពររបស់ព្រះមកដល់យើង។ តើអ្នកនឹងស្រម៉ៃបានថា ការនោះត្រូវបានគ្រប់គ្រងដោយហេតុផលរបស់ទ្រង់នៅក្នុងកាលដែលព្រះបានផ្តល់ដល់យើងនូវការល្អនៅក្នុងជីវិតនេះ តែទ្រង់ចង់ឱ្យយើងរក្សាការទាំងនោះដោយយល់ដល់ព្រះនាមទ្រង់នោះ? លោកអ័ប្រាហាំនិងស្តេចសាឡូម៉ូនក្លាយជាអ្នកមាននៅក្នុងសាសនា។ ហើយយ៉ូបនិយាយថា "ថាមនុស្សល្អនឹងរក្សាទុកមានដូចជាធូលីដី។" តែគាត់មិនបានដូចជាមនុស្សទាំងពីរនាក់ខាងមុខយើងទេ ប្រសិនបើពួកគេដូចជាអ្វីដែលអ្នកបានរៀបរាប់នោះ។

លោកសង្គ្រោះទាំងអស់៖ ខ្ញុំគិតថាយើងទាំងអស់គ្នាសុទ្ធតែយល់ស្របនៅក្នុងបញ្ហានេះ។ ដូច្នេះមិនត្រូវការនិយាយអ្វីទៀតឡើយ។

លោកស្រឡាញ់លុយ៖ ទេ ពិតជាមិនត្រូវការនិយាយពីរឿងនេះទៀតឡើយដោយសារអ្នកដែលមិនជឿព្រះគម្ពីរឬហេតុផលនោះ (ហើយអ្នកឃើញហើយថាយើងមានទាំងពីរនៅខាងយើង) ក៏មិនទាំងស្គាល់ពីសេរីភាពរបស់ខ្លួនឯង ឬមិនស្វែងរកសុវត្ថិភាពរបស់ខ្លួនផងនោះ។

លោកដល់ទីបញ្ចប់៖ បងប្អូនអើយ យើងទាំងអស់គ្នាដូចដែលអ្នកឃើញហើយ កំពុងតែនៅក្នុងធម្មយាត្រា ហើយសម្រាប់ការផ្លាស់ប្តូរដ៏ប្រសើររបស់យើងពីការអាក្រក់ៗវិញ សូមឱ្យខ្ញុំបានបកស្រាយដល់អ្នកនូវសំណួរនេះសិន។

ប្រសិនបើបុរសម្នាក់ ជាអ្នកអធិប្បាយ ឬជាអ្នកធ្វើជំនួញ គួរតែមានផលប្រយោជន៍ក្រាលនៅចំពោះគាត់ ឱ្យទទួលបានព្រះពរល្អនៅក្នុងជីវិតរបស់គាត់ តែបើទៅរួច តែគាត់មិនអាចមកដល់ព្រះពរទាំងនោះបានលើកលែងតែនៅក្នុងការលេចមកខាងក្រៅរបស់គាត់យ៉ាងហោចណាស់ គាត់ក្លាយជាខ្លាំងខ្លាឡើងមិនធម្មតានៅក្នុងចំណុចខ្លះដែលគាត់មិនដែលជួបសោះពីមុនមក តើគាត់នឹងមិនប្រើវិធីនេះដើម្បីទៅដល់ទីបញ្ចប់របស់គាត់ ហើយនៅតែជាមនុស្សស្មោះត្រង់ទៀតទេឬយ៉ាងណា?

លោកស្រឡាញ់លុយ៖ ខ្ញុំមើលឃើញមូលដ្ឋាននៃសំណួររបស់អ្នក ហើយជាមួយនឹងសេចក្តីល្អរបស់សុភាពបុរសនេះ ខ្ញុំនឹងស្រវ៉ាទាញយកចម្លើយមួយដល់អ្នក។ ហើយដំបូង ដើម្បីនឹងនិយាយទៅកាន់សំណួររបស់អ្នកដែលទាក់ទងនឹងអ្នកអធិប្បាយផ្ទាល់នោះ ឧបមាថាអ្នកអធិប្បាយ ជាមនុស្សម្នាក់ដែលមានគុណតម្លៃ តែមានផលប្រយោជន៍តែបន្តិចបន្តួច តែនៅក្នុងភ្នែករបស់គាត់ពេញដោយខ្លាញ់និងបំណងប្រថ្នាដ៏ធំនោះ ពេលនេះគាត់ក៏មានឱកាសនិងទទួលបានការនោះដែរ តែដោយច្បាស់លាស់ថែមទៀតដោយការអធិប្បាយជាញឹកញាប់ថែមទៀតនិងខ្លាំងខ្លាថែមទៀត ហើយដោយសារបំណងប្រាថ្នារបស់មនុស្សទាមទារការនោះ ដោយការផ្លាស់ប្តូរគោលការណ៍មួយចំនួនរបស់គាត់។ ចំណែកខ្ញុំវិញ ខ្ញុំមិនឃើញមានហេតុផល ដែល

មនុស្សម្នាក់នឹងធ្វើវាឡើយ ដែលធ្វើឱ្យគាត់ទទួលបានការត្រាស់ហៅឡើយ ។ អេ ហើយបញ្ហាដែលសំខាន់ថែមទៀតនោះ គឺគាត់នៅតែជាមនុស្សស្មោះត្រង់ដដែល។ តើហេតុអ្វីទៅ?

1. សេចក្ដីប៉ងប្រាថ្នារបស់គាត់ចង់បានផលប្រយោជន៍ធំថែមទៀតគឺវាស្របច្បាប់ហើយ (វាមិនអាចនឹងប្រឆាំងគ្នាឡើយ) ក្នុងកាលដែល ការនេះបានដាក់នៅចំពោះគាត់ដោយផែនការរបស់ព្រះ ដូច្នេះ គាត់អាចទទួលយកវាបានបើគាត់អាចយកបាន ដោយមិនបាច់សួរ ដោយយល់ដល់សតិប្រាជ្ញា។

2. ក្រៅពីនោះ បំណងប្រាថ្នារបស់គាត់ដែលចង់បានដំណែងដោយទិញ ធ្វើឱ្យគាត់កាន់តែច្បាស់លាស់ថែមទៀត កាន់តែក្លាយជាអ្នកអធិប្បាយយ៉ាងក្លៀវក្លាថែមទៀត ហើយអ្វីផ្សេងៗទៀត ដូច្នេះនឹងធ្វើឱ្យគាត់ក្លាយជាមនុស្សប្រសើរជាងមុន។ ពិតណាស់ ធ្វើឱ្យគាត់កាន់តែអភិវឌ្ឍខាងផ្នែករបស់គាត់ដែលស្របតាមគំនិតរបស់ព្រះផង។

3. ពេលនេះដើម្បីសម្រេចតាមបំណងរបស់មនុស្សរបស់គាត់ដោយបង្ហាញគំនិតខុសគ្នានោះ ដើម្បីនឹងបម្រើពួកគេ គោលការណ៍មួយចំនួនរបស់គាត់ការវែកញែកនេះ ទីមួយ ថាគាត់មានបំណងនៅក្នុងការបដិសេធខ្លួនឯង ទីពីរ ក្នុងបែបបទមួយដែលពេញចិត្ត ទីបី ដែលកាន់តែសាកសមនឹងតួនាទីជាអ្នកអធិប្បាយថែមទៀត។

4. ខ្ញុំសន្មត់ថា អ្នកអធិប្បាយនោះដែលផ្លាស់ប្ដូរការតូចមួយសម្រាប់ការធំមិនគួរត្រូវបានគេកាត់ទោសថាជាអ្នកលោភលន់ទេ តែ ក្នុងកាលដែលគាត់មានការរីកចម្រើននៅក្នុងផ្នែករបស់គាត់និងការបង្កើតរបស់គាត់វិញ គាត់គួរតែត្រូវបានរាប់ថាជាមនុស្សម្នាក់ដែលដេញតាមការត្រាស់ហៅរបស់គាត់និងឱកាសដែលដាក់នៅក្នុងដៃដើម្បីនឹងធ្វើការល្អ។

ហើយពេលនេះចំពោះផ្នែកទីពីរនៃសំណួរវិញ ដែលទាក់ទងនឹងអ្នកធ្វើជំនួញដែលអ្នកនិយាយនោះ ឧបមារថាមនុស្សម្នាក់ក្រីក្រនៅក្នុងលោកិយនេះ តែដោយក្លាយជាអ្នកជឿសាសនាវិញ គាត់អាចនឹងបត់បែនទីផ្សាររបស់គាត់ អាចជានឹងយកប្រពន្ធអ្នកមាន ឬយកអតិថិជនច្រើននិងប្រសើរថែមទៀតមកកាន់ហាងរបស់គាត់ ចំពោះខ្ញុំវិញ ខ្ញុំមិនឃើញហេតុផលអ្វី ក្រៅពីថាការនេះបានធ្វើឡើងដោយស្របច្បាប់ហើយ។ ដោយសារហេតុអ្វីទៅ?

1. ការដែលក្លាយជាអ្នកកាន់សាសនាជាសីលធម៌មួយ ដោយវិធីនោះមនុស្សការបានក្លាយទៅជាបែបនោះទៅ។

2. វាមិនមែនខុសច្បាប់ដែលយកប្រពន្ធអ្នកមាននោះដែរ ឬដែលរកអតិថិជនច្រើនមកកាន់ហាងរបស់ខ្ញុំឡើយ.

3. ក្រៅពីនោះ អ្នកដែលទទួលបានការទាំងនេះដោយក្លាយខ្លួនជាអ្នកកាន់សាសនា គាត់ទទួលបានអ្វីដែលល្អពីអ្នកដែលល្អ ដោយបានក្លាយជាល្អខ្លួនឯងផ្ទាល់។ ដូច្នេះនេះជាប្រពន្ធល្អម្នាក់ ហើយអតិថិជនល្អ និងបានចំណេញល្អ ហើយការទាំងបានដោយក្លាយជាអ្នកកាន់សាសនា ដែលជាការល្អ។ ដូច្នេះ ការដែលក្លាយជាអ្នកកាន់សាសនា ដើម្បីទទួលបានការទាំងនេះ ជាបែបបទដែលល្អនិងមានផលប្រយោជន៍មួយ។

ចម្លើយនេះដែលលោកស្រឡាញ់លុយនិយាយទៅកាន់លោកដល់ទីបញ្ចប់នោះ ត្រូវបានគេទាំងអស់គ្នាសារទរឱ្យយ៉ាងខ្លាំង។ ដូច្នេះពួកគេសន្មត់ការមូលថា ជាការដែលល្អនិងមានផលប្រយោជន៍។ ហើយដោយសារ ក្នុងកាល

ដែលពួកគេគិតថា គ្មានអ្នកណាអាចទាស់នឹងការនោះបានឡើយ ហើយដោយសារគ្រីស្ទាននិងពេញដោយសង្ឃឹមនៅអាចហៅពួនៅឡើយ ពួកគេយល់ព្រមគ្នាដោយរីករាយនឹងធ្វើបាបដល់ពួកគេដោយសំណួររំពេចណាណាដែលពួកគេទៅទាន់ពួកគេ ក្រៅពីនោះទៀតគឺដោយសារពួកគេបានប្រឆាំងនឹងលោកដល់ទីបញ្ចប់ពីមុនមក។ ដូច្នេះពួកគេបានស្រែកហៅពួកគេ ហើយពួកគេក៏ឈប់ ហើយឈរនៅស្ងៀមរហូតដល់ពួកគេតាមមកទាន់។ តែពួកគេសន្មត់ពេលដែលពួកគេដើរទៅថា មិនមែនលោកដល់ទីបញ្ចប់ តែជាលោកកាន់តាមលោកិយចំណាស់វិញដែលនឹងត្រូវសួរសំណួរទៅកាន់ពួកគេ ដោយសារពួកគេគិតថា ចម្លើយរបស់ពួកគេទៅកាន់គាត់នឹងមិនមានអ្វីសេសសល់ដែលនឹងបង្កាត់ភ្លើងរវាងលោកដល់ទីបញ្ចប់ និងពួកគេដែលនៅដាច់គ្នាខាងមុខបន្តិចនេះនោះឡើយ។

ដូច្នេះពួកគេបានមកទាន់គ្នា ហើយបន្ទាប់ពីបានរាក់ទាក់គ្នាបន្តិចមក លោកកាន់តាមលោកិយបានសួរសំណួរទៅកាន់គ្រីស្ទាននិងគ្នារបស់គាត់ ហើយប្រាប់ឱ្យពួកគេឆ្លើយមកប្រសិនបើពួកគេអាចឆ្លើយបាន។

គ្រីស្ទាន៖ បន្ទាប់មកគ្រីស្ទាននិយាយថា "សូម្បីតែកូនក្មេងនៅក្នុងសាសនាក៏អាចឆ្លើយសំណួររាប់ម៉ឺនដូចនេះបានដែរ។ ប្រសិនបើវាមិនស្របច្បាប់នៅក្នុងការដើរតាមព្រះគ្រីស្ទដើម្បីបាននំបុ័ងដូច្នេះទេ ដូចជាការនេះ

"ក្រោយមក ព្រះយេស៊ូវទ្រង់ឆ្លងសមុទ្រកាលីឡេ គឺជាសមុទ្រទីបេរាស។ ហើយមានហ្វូងមនុស្សជាធំតាមទ្រង់ទៅ ដោយបានឃើញទីសម្គាល់ទាំងប៉ុន្មាន ដែលទ្រង់ប្រោសដល់ពួកជំងឺ។ នោះព្រះយេស៊ូវទ្រង់យាងឡើង

ទៅលើភ្នំ គង់ជាមួយនឹងពួកសិស្សនៅទីនោះ។ រីឯបុណ្យរំលង ជាបុណ្យរបស់សាសន៍យូដា ក៏ជិតដល់ហើយ។ ឯព្រះយេស៊ូវទ្រង់ងើបព្រះនេត្រឡើង ឃើញមនុស្សកកកុញមកឯទ្រង់ នោះទ្រង់មានព្រះបន្ទូលទៅភីលីពថា យើងនឹងទិញនំបុ័ងពីណាមក ឱ្យមនុស្សទាំងអស់នេះបានបរិភោគ។ ទ្រង់មានព្រះបន្ទូលសួរដូច្នេះ ដើម្បីនឹងល្បងលគាត់ទេ ព្រោះទ្រង់ជ្រាបការ ដែលទ្រង់គិតធ្វើហើយ។ ភីលីពទូលឆ្លើយថា ទោះបើទិញនំបុ័ងអស់៨០រៀល ក៏មិនគ្រាន់ឱ្យគ្រប់គ្នា សូម្បីតែបន្តិចបន្តួចផង។ មានសិស្សទ្រង់ម្នាក់ ឈ្មោះអនទ្រេ ជាប្អូនស៊ីម៉ូន-ពេត្រុស គាត់ទូលទ្រង់ថា។ នៅទីនេះមានក្មេងម្នាក់ មាននំបុ័ងម្សៅឱក ៥ និងត្រីតូច២ ប៉ុន្តែ ដែលមានប៉ុណ្ណោះ តើមានប្រយោជន៍អ្វី ដល់មនុស្សច្រើនទាំងម៉្លេះ។ ព្រះយេស៊ូវមានព្រះបន្ទូលថា ចូរឱ្យមនុស្សទាំងអស់អង្គុយទៅ រីឯនៅទីនោះ មានស្មៅច្រើន ដូច្នេះ គេក៏នាំគ្នាអង្គុយ មានចំនួនប្រហែលជា៥ពាន់នាក់។ រួចព្រះយេស៊ូវទ្រង់យកនំបុ័ងនោះអរព្រះគុណ រួចចែកទៅឱ្យពួកសិស្ស គេក៏ចែកដល់ពួកអ្នកដែលអង្គុយ បានចែកទាំងត្រីតូចនោះបែបដូច្នោះដែរ តាមតែគេចង់បាន។ លុះគេបានឆ្អែតគ្រប់គ្នាហើយ នោះទ្រង់មានព្រះបន្ទូលទៅពួកសិស្សថា ចូរប្រមូលចំណិតដែលសល់នៅ ដើម្បីកុំឱ្យបាត់អ្វីឡើយ។ ក្រោយដែលបរិភោគរួចហើយ នោះគេប្រមូលចំណិតនំបុ័ងម្សៅឱកដែលសល់ពី៥ដុំនោះ ដាក់ពេញបាន១២កន្ត្រក។ កាលមនុស្សទាំងប៉ុន្មានបានឃើញទីសម្គាល់ ដែលព្រះយេស៊ូវធ្វើនោះ គេក៏និយាយថា លោកនេះប្រាកដជាហោរានោះ ដែលត្រូវមកក្នុងលោកីយ៍មែន។ ដូច្នេះ ព្រះយេស៊ូវក៏ថយឡើងទៅលើភ្នំ តែ១អង្គទ្រង់វិញទៀត ពីព្រោះទ្រង់ជ្រាបថា គេគិតមកចាប់ទ្រង់ដោយកម្លាំង ដើម្បីនឹងតាំងឡើងជាស្តេច។ លុះព្រលប់ហើយ ពួកសិស្សទ្រង់ចុះទៅឯសមុទ្រ។ ក៏ចុះទូកឆ្លងទៅកាពើណិម ពេលនោះងងឹតហើយ តែព្រះ

យេស៊ូវមិនទាន់មកដល់នៅឡើយ។ សមុទ្រក៏មានរលក បោកដោយខ្យល់បក់ជាខ្លាំង។ កាលគេបានចែវទៅប្រហែលជា៥ ឬ៦គីឡូម៉ែត្រហើយ នោះស្រាប់តែគេឃើញព្រះយេស៊ូវ ទ្រង់យាងលើសមុទ្រមកជិតទូក ហើយគេមានសេចក្តីភ័យខ្លាច។ តែទ្រង់មានព្រះបន្ទូលថា កុំភ័យអី គឺខ្ញុំទេតើ។ នោះគេក៏ព្រមទទួលទ្រង់មកក្នុងទូក ស្រាប់តែទូកបានដល់ស្រុកដែលគេប៉ងនឹងទៅ។ស្អែកឡើង កាលហ្វូងមនុស្ស ដែលនៅត្រើយសមុទ្រម្ខាង បានឃើញថា នៅទីនោះគ្មានទូកណាទៀត ក្រៅពីទូក១ ដែលពួកសិស្សទ្រង់បានជិះ ហើយថា ព្រះយេស៊ូវមិនបានជិះទូកនោះ ទៅជាមួយនឹងពួកសិស្សទេ គឺពួកសិស្សបានចេញទៅតែគ្នាគេ។ (ប៉ុន្តែ មានទូកខ្លះទៀត មកពីស្រុកទីបេរាស ជិតកន្លែងដែលគេបានបរិភោគនំបុ័ង ក្រោយដែលព្រះអម្ចាស់បានអរព្រះគុណរួចហើយ)។ ដូច្នេះ កាលហ្វូងមនុស្សមិនឃើញព្រះយេស៊ូវ ឬពួកសិស្សទ្រង់នៅទីនោះ គេក៏ជិះទូកទៅឯកាពើណិម ដើម្បីនឹងរកទ្រង់។ កាលឃើញទ្រង់នៅឯត្រើយម្ខាងហើយ នោះគេទូលសួរថា លោកគ្រូ លោកមកដល់ទីនេះពីកាលណា។ ព្រះយេស៊ូវមានព្រះបន្ទូលឆ្លើយទៅគេថា ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នករាល់គ្នារកខ្ញុំ មិនមែនដោយព្រោះបានឃើញទីសម្គាល់ទេ គឺដោយព្រោះតែបានបរិភោគនំបុ័ងឆ្អែតប៉ុណ្ណោះ។ កុំឱ្យខំប្រឹងឱ្យបានតែអាហារ ដែលតែងតែពុករលួយនោះឡើយ ចូរខំឱ្យបានអាហារ ដែលនៅស្ថិតស្ថេរ ដរាបដល់ជីវិតអស់កល្បជានិច្ចវិញ ជាអាហារដែលកូនមនុស្សនឹងឱ្យមកអ្នករាល់គ្នា ដ្បិតគឺកូនមនុស្សនេះហើយ ដែលព្រះវរបិតាដ៏ជាព្រះ ទ្រង់បានដៅចំណាំទុក។ ដូច្នេះ គេទូលសួរទ្រង់ថា ដែលនឹងធ្វើការរបស់ព្រះ តើត្រូវធ្វើដូចម្តេចខ្លះ។ ព្រះយេស៊ូវមានព្រះបន្ទូលឆ្លើយថា ឯការរបស់ព្រះ គឺឱ្យអ្នករាល់គ្នាបានជឿដល់អ្នកដែលព្រះបានចាត់ឱ្យមក។ នោះគេទូលសួរទ្រង់ថា បើ

ដូច្នេះ តើលោកនឹងធ្វើទីសម្គាល់ណាឱ្យយើងខ្ញុំឃើញផង ដើម្បីឱ្យបានជឿដល់លោក តើលោកធ្វើការអ្វីខ្លះ។ ពួកអយ្យកោយើងខ្ញុំបានបរិភោគនំម៉ាន៉ានៅទីរហោស្ថាន ដូចជាមានសេចក្តីចែងទុកមកថា លោកបានឱ្យនំប៉័ងពីស្ថានសួគ៌ មកឱ្យគេបរិភោគ។ ឯព្រះយេស៊ូវទ្រង់មានព្រះបន្ទូលតបថា ប្រាកដមែនខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា មិនមែនលោកម៉ូសេ ដែលឱ្យនំប៉័ង ពីស្ថានសួគ៌នោះមកអ្នករាល់គ្នាទេ តែឯនំប៉័ងដ៏ពិត ដែលមកពីស្ថានសួគ៌ នោះគឺព្រះវរបិតាខ្ញុំ ដែលប្រទានមកអ្នករាល់គ្នាវិញ។ ដ្បិតនំប៉័ងរបស់ព្រះ គឺជាព្រះអង្គដែលយាងចុះពីស្ថានសួគ៌មក ព្រមទាំងប្រទានឱ្យមនុស្សលោកបានជីវិតផង។ ដូច្នេះ គេទូលទ្រង់ថា លោកម្ចាស់អើយ សូមឱ្យនំប៉័ងនោះមកយើងខ្ញុំជានិច្ច។ ព្រះយេស៊ូវមានព្រះបន្ទូលថា ខ្ញុំជានំប៉័ងជីវិត អ្នកណាដែលមកឯខ្ញុំនោះនឹងមិនឃ្លានទៀតឡើយ ហើយអ្នកណាដែលជឿដល់ខ្ញុំ ក៏មិនត្រូវស្រេកដែរ។ ប៉ុន្តែ ខ្ញុំបានប្រាប់អ្នករាល់គ្នារួចហើយថា អ្នករាល់គ្នាបានឃើញខ្ញុំ តែមិនជឿទេ។ អស់អ្នកណាដែលព្រះវរបិតាប្រទានមកខ្ញុំ នោះនឹងមកឯខ្ញុំ ហើយអ្នកណាដែលមកឯខ្ញុំ ខ្ញុំក៏មិនដែលចោលទៅក្រៅឡើយ។ ពីព្រោះខ្ញុំបានចុះពីស្ថានសួគ៌មក មិនមែននឹងធ្វើតាមចិត្តខ្ញុំទេ គឺតាមបំណងព្រះហឫទ័យនៃព្រះវិញ ដែលទ្រង់ចាត់ឱ្យខ្ញុំមក។ ឯបំណងព្រះហឫទ័យនៃព្រះវរបិតា ដែលចាត់ឱ្យខ្ញុំមក នោះគឺមិនចង់ឱ្យខ្ញុំបាត់អ្នកណា ក្នុងគ្រប់អស់ទាំងមនុស្ស ដែលទ្រង់ប្រទានមកខ្ញុំនោះឡើយ គឺទ្រង់ចង់ឱ្យខ្ញុំប្រោសទាំងអស់ឱ្យរស់ឡើង នៅថ្ងៃចុងបំផុតវិញ។ នេះហើយជាបំណងព្រះហឫទ័យនៃព្រះវរបិតាខ្ញុំ គឺឱ្យអស់អ្នកណាដែលឃើញព្រះរាជបុត្រា ហើយក៏ជឿដល់ទ្រង់ បានជីវិតដ៏នៅអស់កល្បជានិច្ច ហើយខ្ញុំនឹងឱ្យអ្នកនោះរស់ឡើងវិញ នៅថ្ងៃចុងបំផុត។ នោះពួកសាសន៍យូដា គេឌុកដាន់ទ្រង់ ពីព្រោះទ្រង់មានព្រះបន្ទូលថា ខ្ញុំជានំប៉័ង ដែល

ចុះពីស្ថានសួគ៌មក។ គេនិយាយថា អ្នកនេះ តើមិនមែនឈ្មោះយេស៊ូវ ជាកូនយ៉ូសែប ដែលយើងស្គាល់ឪពុកម្ដាយគាត់ទេឬអី ចុះដូចម្ដេចឡើយបានជាគាត់និយាយថា គាត់ចុះពីស្ថានសួគ៌មកដូច្នេះ។ នោះព្រះយេស៊ូវមានព្រះបន្ទូលទៅគេថា កុំឱ្យរទូរទាំក្នុងពួកអ្នករាល់គ្នាឡើយ។ គ្មានអ្នកណាអាចនឹងមកឯខ្ញុំបានទេ លើកតែព្រះវរបិតា ដែលចាត់ខ្ញុំឱ្យមក ទ្រង់ទាញនាំគេប៉ុណ្ណោះ ហើយខ្ញុំនឹងឱ្យអ្នកនោះរស់ឡើងវិញ នៅថ្ងៃចុងបំផុតដែរ។ នៅក្នុងគម្ពីរពួកហោរាមានសេចក្ដីចែងទុកមកថា ព្រះទ្រង់នឹងបង្រៀនគេទាំងអស់គ្នា ដូច្នេះអស់អ្នកណាដែលឮព្រះវរបិតា ហើយបានរៀនពីទ្រង់ នោះក៏មកឯខ្ញុំ។ នេះមិនមែនថា មានអ្នកណាដែលឃើញព្រះវរបិតានោះឡើយ មានតែព្រះអង្គដែលយាងមកពីព្រះប៉ុណ្ណោះ ព្រះអង្គនោះទើបទ្រង់បានឃើញព្រះវរបិតាមែន។ ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នកណាដែលជឿដល់ខ្ញុំនោះមានជីវិតអស់កល្បជានិច្ច។ ខ្ញុំជានំប៉័ងជីវិត។ពួកអយ្យកោអ្នករាល់គ្នាបានបរិភោគនំម៉ាន៉ា នៅទីរហោស្ថាន ហើយក៏ស្លាប់អស់ទៅ។ ឯនំប៉័ងដែលខ្ញុំនិយាយនេះ គឺជានំប៉័ងដែលចុះពីស្ថានសួគ៌មក ដើម្បីឱ្យអ្នកណា ដែលបរិភោគមិនត្រូវស្លាប់ឡើយ។ ខ្ញុំជានំប៉័ងដ៏រស់ ដែលចុះពីស្ថានសួគ៌មក បើអ្នកណាបរិភោគនំប៉័ងនេះ នោះនឹងរស់នៅអស់កល្បជានិច្ច ឯនំប៉័ងដែលខ្ញុំឱ្យ គឺជារូបសាច់ខ្ញុំ ដែលខ្ញុំនឹងឱ្យជំនួសជីវិតមនុស្សលោក។ ដូច្នេះ ពួកសាសន៍យូដាគេជជែកគ្នាថា ធ្វើដូចម្ដេចឱ្យអ្នកនេះអាចនឹងឱ្យសាច់ខ្លួន មកយើងបរិភោគបាន។ នោះព្រះយេស៊ូវមានព្រះបន្ទូលទៅគេថា ប្រាកដមែនខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បើអ្នករាល់គ្នាមិនពិសាសាច់ ហើយមិនផឹកឈាមរបស់កូនមនុស្ស នោះអ្នករាល់គ្នាគ្មានជីវិតនៅក្នុងខ្លួនទេ។ អ្នកណាដែលបរិភោគសាច់និងឈាមរបស់ខ្ញុំ នោះមានជីវិតដ៏នៅអស់កល្បជានិច្ច ហើយខ្ញុំនឹងឱ្យអ្នក

នោះរស់ឡើងវិញ នៅថ្ងៃចុងបំផុត។ ពីព្រោះសាច់ខ្ញុំជាអាហារពិត ហើយឈាមខ្ញុំក៏ជាគ្រឿងផឹកពិតប្រាកដ។ អ្នកណាដែលបរិភោគសាច់ និងឈាមរបស់ខ្ញុំ នោះនៅក្នុងខ្ញុំ ហើយខ្ញុំក៏នៅក្នុងអ្នកនោះដែរ។ អ្នកណាដែលបរិភោគខ្ញុំ អ្នកនោះនឹងរស់ដោយសារខ្ញុំ ដូចជាព្រះវរបិតាដ៏មានព្រះជន្មរស់ ទ្រង់បានចាត់ឱ្យខ្ញុំមក ហើយខ្ញុំក៏រស់នៅដោយសារទ្រង់ដែរ។ នំប៉ុងនេះជានំប៉ុង ដែលចុះពីស្ថានសួគ៌មកជាពិត មិនមែនដូចជាពួកអយ្យកោអ្នករាល់គ្នា បានបរិភោគនំម៉ាន៉ា ហើយក៏ស្លាប់ទៅនោះទេ គឺអ្នកណាដែលបរិភោគនំប៉ុងនេះ នឹងរស់នៅអស់កល្បជានិច្ចវិញ។ ទ្រង់មានព្រះបន្ទូលសេចក្តីទាំងនេះក្នុងសាលាប្រជុំនៅកាពើណិម កំពុងដែលទ្រង់បង្រៀនគេ។ ពួកសិស្សទ្រង់ជាច្រើន ដែលឮសេចក្តីនោះ ក៏និយាយថា ពាក្យនេះពិបាកស្តាប់ណាស់ តើអ្នកណាយល់បាន។" យ៉ូហាន 6:1-60

តើគួរឱ្យកាន់តែស្អប់ខ្ពើមថែមទៀតដែលគេ ធ្វើឱ្យព្រះអង្គនិងសាសនាជាខែលបិទបាំង ដើម្បីទទួលបាននិងរីករាយជាមួយនឹងលោកិយនេះ! យើងក៏មិនបានរកឃើញអ្នកផ្សេងណាដែលក្លែងខ្លួន ជាមនុស្សកំពុត អារក្ស និងមេធ្មប់ ដែលមានគំនិតបែបនេះសោះឡើយ។

"1. អ្នកក្លែងបន្លំ ដោយសារនៅពេលដែលលោក ហាម៉័រនិងលោកសេខេមមានគំនិតទៅកាន់កូនស្រីនិងសត្វរបស់លោកយ៉ាងកុបនោះ ហើយឃើញថាគ្មានផ្លូវណាដែលគេអាចចូរទៅកាន់ពួកគេបាននោះ តែដោយផ្លូវតែមួយគត់គឺការទទួលការកាត់ស្បែក នោះពួកគេនិយាយទៅកាន់គ្នារបស់ពួកគេថា

ប្រសិនបើពួកប្រុសៗរបស់យើងនឹងទទួលការកាត់ស្បែក ដូចជាពួកគេដែរ តើមិនត្រូវឱ្យហ្វូងសត្វរបស់ពួកគេនិងរបស់របររបស់ពួកគេ និងគ្រប់សត្វទាំងអស់របស់ពួកគេក្លាយជារបស់យើងទេឬអី? កូនស្រីៗរបស់ពួកគេនិងហ្វូងសត្វជាអ្វីដែលពួកគេចង់បាន ហើយសាសនារបស់ពួកគេជាកំបាំងមុខដែលគេប្រើដើម្បីចូលមករកពួកគេនោះ។ សូមអានសាច់រឿងទាំងមូលទៅ។

"នោះហាម៉ោរ និងស៊ីគែមជាបុត្រក៏ទៅឯទ្វារក្រុង មានព្រះបន្ទូលនឹងពួកមនុស្សនៅទីក្រុងទ្រង់ថា មនុស្សទាំងនោះគេមានសេចក្តីមេត្រីនឹងយើងទេ ដូច្នេះ ចូរឱ្យគេអាស្រ័យនៅក្នុងស្រុក និងធ្វើជំនួញជួញប្រែចុះ ដ្បិតមើលស្រុកនេះធំល្មមឱ្យគេនៅបាន ចូរយើងយកកូនស្រីរបស់គេមកធ្វើជាប្រពន្ធ ហើយឱ្យកូនស្រីរបស់ពួកយើងទៅគេដែរ។ តែដែលគេនឹងព្រមនៅជាមួយនឹងយើង ហើយត្រឡប់ជាសាសន៍តែ១ នោះលុះត្រាតែកាលណាពួកប្រុសៗទាំងអស់ខាងយើងបានកាត់ស្បែកដូចជាគេដែរ។ ដូច្នេះ តើហ្វូងគោ ទ្រព្យសម្បត្តិ និងសត្វរបស់គេទាំងអស់មិនត្រឡប់មកជារបស់ផងយើងទេឬអី ចូរយើងគ្រាន់តែព្រមតាមគេប៉ុណ្ណោះ នោះគេនឹងនៅជាមួយនឹងយើងហើយ" **លោកុប្បត្តិ 34:20-23**

"2. ពួកកំពុតជាវីស៊ីក៏នៅក្នុងសាសនាបែបនេះដែរ មានការអធិស្ឋានវែងៗ ដែលជាការសម្តែងរបស់ពួកគេ តែដើម្បីនឹងចង់បានផ្ទះរបស់ស្ត្រីមេម៉ាយ ដែលជាគោលបំណងរបស់ពួកគេ ហើយការដាក់ទោសខ្លាំងជាងនេះមកពីព្រះនោះជាសេចក្តីជំនុំជំរះមកដល់ពួកគេ។

“ចូរប្រុងប្រយ័តនឹងពួកអាចារ្យ ដែលគេចូលចិត្តពាក់អាវវែងដើរចុះឡើង ក៏គាប់ចិត្តឱ្យមនុស្សគំនាប់គេនៅទីផ្សារ ហើយចង់អង្គុយកន្លែងមុខគេ ក្នុងសាលាប្រជុំ និងកន្លែងដ៏ប្រសើរបំផុត ក្នុងការស៊ីលៀង។ តែគេឆស៊ីផ្ទះស្រីមេម៉ាយ ទាំងដោះសាខ្លួន ដោយសូត្រធម៌ឱ្យច្រើន អ្នកទាំងនោះឯងនឹងត្រូវទោសធ្ងន់ជាងទៅទៀត។” លូកា 20:46, 47

"3.យ៉ូដាសជាអារក្សក៏នៅក្នុងសាសនានេះដែរ។ គាត់ជាអ្នកកាន់សាសនាសម្រាប់ថង់ប្រាក់ ដែលគាត់នឹងអាចកាន់កាប់នូវអ្វីដែលនៅក្នុងថង់នោះ។ តែគាត់ត្រូវបានវង្វេង ត្រូវបោះបង់ចោល ហើយជាកូនរបស់ស្ថាននរកវិញ។

"4. ស៊ីម៉ូនដែលជាគ្រូអាគមន៍ក៏នៅក្នុងសាសនានេះដែរ។ ដោយសារគាត់ចង់បានព្រះវិញ្ញាណបរិសុទ្ធ ដោយប្រើលុយដែលគាត់មាន ហើយគាត់ទទួលបានការដាក់ទោសពីលោកពេត្រុសដូចតទៅនេះ។

“សូមឱ្យខ្ញុំមានអំណាចនេះផង ដើម្បីឱ្យខ្ញុំដាក់ដៃលើអ្នកណា ឱ្យអ្នកនោះបានទទួលព្រះវិញ្ញាណបរិសុទ្ធដែរ។ តែពេត្រុសឆ្លើយតបថា ចូរឱ្យប្រាក់អ្នកវិនាសទៅជាមួយនឹងអ្នកចុះ ព្រោះអ្នកស្មានថា នឹងយកប្រាក់មកទិញអំណោយទានរបស់ព្រះបានដូច្នេះ។ អ្នកគ្មានភាគគ្មានចំណែកក្នុងការនេះឡើយ ព្រោះចិត្តអ្នកមិនស្មោះត្រង់ចំពោះព្រះទេ។ ដូច្នេះ ចូរប្រែចិត្តចេញពីសេចក្ដីអាក្រក់នេះចុះ ហើយសូមអង្វរដល់ព្រះអម្ចាស់វិញ ក្រែងទ្រង់នឹងអត់ទោសដល់គំនិតក្នុងចិត្តអ្នកបាន” កិច្ចការ 8:19-22

"5. ក៏វាមិនចេញពីក្នុងគំនិតខ្ញុំដែរ តែបុរសនោះបានយកសាសនាសម្រាប់លោកិយ ហើយនឹងបោះបង់សាសនាសម្រាប់លោកិយដែរ។ គឺដូចជាយ៉ូដាសបានកែច្នៃលោកិយដោយធ្វើជាអ្នកកាន់សាសនា ពិតណាស់គាត់ក៏បានលក់សាសនានិងព្រះអម្ចាស់របស់គាត់សម្រាប់ការនោះដូចគ្នា។ ដើម្បីនឹងឆ្លើយនឹងសំណួរកាន់តែច្បាស់លាស់ទៀត ដូចដែលខ្ញុំបានឃើញអ្នកឆ្លើយរួចហើយនោះ ហើយដើម្បីនឹងទទួលបានអំណាចដូចចម្លើយនេះ ការទាំងពីរនេះសុទ្ធតែជាការក្លែងបន្លំ បែបពុតត្បុត និងអាក្រក់ ហើយរង្វាន់របស់អ្នកនឹងបានមកតាមទង្វើរបស់អ្នក។"

បន្ទាប់មកពួកគេឈរសម្លឹងមើលគ្នាទៅវិញទៅមក តែមិនអាចនឹងឆ្លើយតបនឹងគ្រីស្ទានបានឡើយ។ ពេញដោយសង្ឃឹមក៏បានយល់ស្របនឹងភាពត្រឹមត្រូវនៃចម្លើយរបស់គ្រីស្ទានផងដែរ។ ដូច្នេះក៏មានភាពស្ងប់ស្ងាត់យ៉ាងខ្លាំងនៅចំណោមពួកគេ។ លោកដល់ទីបញ្ចប់និងគ្នីគ្នាមានការភ្ញាក់ផ្អើលហើយក៏នៅខាងក្រោយ ដើម្បីឱ្យគ្រីស្ទាននិងពេញដោយសង្ឃឹមបានដើរទៅមុខហួសទៅ។ បន្ទាប់មកគ្រីស្ទាននិយាយទៅកាន់សំឡាញ់របស់គាត់ថា "ប្រសិនបើមនុស្សទាំងនេះមិនអាចឈរនៅចំពោះការកាត់ក្តីរបស់មនុស្សផង តែពួកគេនឹងធ្វើអ្វីបាននៅចំពោះការកាត់ទោសរបស់ព្រះនោះ? ហើយប្រសិនបើពួកគេគ នៅពេលដោះស្រាយជាមួយនឹងភាជនៈដីឥដ្ឋទៅហើយ តើពួកគេនឹងធ្វើអ្វីបានពេលដែលត្រូវស្តីបន្ទោសដោយអណ្តាតភ្លើងដែលត្របាក់លេបវិញនោះ?"

**ដេម៉ាស់**

បន្ទាប់មកគ្រីស្ទាននិងពេញដោយសង្ឃឹមចេញពីពួកគេម្តងទៀត ហើយបានទៅរហូតទាល់តែមកដល់ទីវាលមួយដែលងាយខូចខាតដែលហៅថា ងាយស្រួល ជាកន្លែងដែលពួកគេដើរទៅដោយស្កប់ចិត្តណាស់។ តែទីវាលនោះចង្អៀតពេក ដូច្នេះពួកគេចេញពីនោះយ៉ាងរហ័ស។ ពេលនេះ នៅចំហៀងពីចម្ងាយនៃទីវាលនេះមានមានភ្នំតូចមួយហៅថា លុយ ហើយនៅលើភ្នំនោះមានរណ្តៅប្រាក់ ដែលពីដើមមានពួកគេខ្លះបានទៅតាមផ្លូវនោះ ដោយសារភាពកម្ររបស់វា នោះគេបានត្រឡប់ទៅមើលវា តែទៅជិតមាត់រណ្តៅពេកក៏មានដីដែលបញ្ឆោតនៅខាងក្រោមនោះ ក៏បាក់ ហើយពួកគេក៏ត្រូវបានសម្លាប់ទៅ។ អ្នកខ្លះក៏ត្រូវមានគ្រោះថ្នាក់នៅទីនោះ ហើយរហូតដល់ថ្ងៃស្លាប់ពួកគេមិនអាចខ្លួនរបស់ពួកគេម្តងទៀតឡើយ។

បន្ទាប់មកខ្ញុំបានឃើញនៅក្នុងសុបិនរបស់ខ្ញុំថា ចេញពីផ្លូវបន្តិច នៅទល់នឹងរណ្តៅប្រាក់ មាន ដេម៉ាស់ ឈរនៅទីនោះ (ដូចជាសុភាពបុរស) ដើម្បីនឹងហៅអ្នកធ្វើដំណើរមកមើល គាត់បាននិយាយទៅកាន់គ្រីស្ទាននិងគ្នាគាត់ថា "ហូ បែរមកក្បែរនេះ ខ្ញុំនឹងបង្ហាញការមួយដល់អ្នក។"

គ្រីស្ទាន៖ តើរបស់អ្វីទៅដែលពិតជាសាកសមឱ្យយើងបែរចេញពីផ្លូវទៅមើលនោះ?
ដេម៉ាស់៖ នេះជារណ្តៅប្រាក់ ហើយអ្នកខ្លះបានជីករកកំណប់ក្នុងនេះ។ ប្រសិនបើអ្នកមក ដោយឈឺចាប់តិចតួចទេអ្នកនឹងទទួលបានជាបរិបូរណ៍សម្រាប់ខ្លួនអ្នកវិញ។

ពេញដោយសង្ឃឹមៈ បន្ទាប់មកពេញដោយសង្ឃឹមនិយាយថា "តោះយើងទៅមើលទៅ។"

គ្រីស្ទានៈ "ខ្ញុំមិនទៅទេ" គ្រីស្ទាននិយាយថា "ខ្ញុំបានឮពីទីនេះពីមុខមក ហើយឮថាមនុស្សជាច្រើនត្រូវបានគេសម្លាប់ ហើយក្រៅពីនោះ កំណាប់នោះគឺជាអន្ទាក់ដល់អ្នកដែលស្វែងរកវា ដោយវារាំងពួកគេនៅក្នុងការធ្វើធម្មយាត្រារបស់ពួកគេ។" បន្ទាប់មកគ្រីស្ទានបានហៅទៅកាន់ ដេម៉ាស់ ដោយនិយាយថា "តើកន្លែងនោះមិនគ្រោះថ្នាក់ទេឬ? តើវាមិនបានរាំងមនុស្សជាច្រើននៅក្នុងដំណើរធម្មយាត្រារបស់ពួកគេទេឬ?"

**"ដ្បិតអ៊ីស្រាអែលបានប្រព្រឹត្តដោយរឹងចចេស ដូចជាគោក្រមុំក្រាញ ឥឡូវនេះ តើព្រះយេហូវ៉ាទ្រង់ត្រូវឃ្វាលគេ ដូចកូនចៀម នៅទីវាលធំទូលាយឬអី។ ឯអេប្រាអ៊ីមវាភ្ជាប់ខ្លួនតាមរូបព្រះហើយ តាមតែវាចុះ។ គ្រឿងផឹករបស់គេបានទៅជាជូរហើយ គេប្រព្រឹត្តសេចក្ដីកំផិតជានិច្ច ឯពួកគ្រប់គ្រងលើគេក៏គាប់ចិត្តចំពោះតែអំពើគួរខ្មាស។ ខ្យល់បានក្តោបគេដោយស្លាប គេនឹងត្រូវមានសេចក្តីខ្មាស ដោយព្រោះយញ្ញបូជាទាំងប៉ុន្មានរបស់ខ្លួន។" ហូសេ 4:16-19**

ដេម៉ាស់ៈ"មិនគ្រោះថ្នាក់ប៉ុន្មានទេ លើកលែងតែអស់អ្នកណាដែលមិនប្រយ័ត្នប៉ុណ្ណោះ" តែគាត់និយាយ ទាំងទឹកមុខខ្មាសអៀន

គ្រីស្ទាន៖ បន្ទាប់មកគ្រីស្ទាននិយាយទៅកាន់ពេញដោយសង្ឃឹមថា "តោះយើងកុំឈានសូម្បីតែមួយជំហានទៅឡើយ តែនៅតែដើរតាមផ្លូវរបស់យើងវិញ។"

សង្ឃឹម៖ ខ្ញុំធានាថា នៅពេលដែលលោកដល់ទីបញ្ចប់មកដល់ ប្រសិនបើគាត់ទទួលបានការអញ្ជើញដូចពួកយើង គាត់នឹងបែរចូលទៅមើលនៅទីនោះមិនខានឡើយ។

គ្រីស្ទាន៖ ការនោះគ្មានអ្វីត្រូវសង្ស័យឡើយ ដោយសារគោលការណ៍របស់គាត់នាំទៅរកផ្លូវនោះហើយ ហើយពីមួយរយទល់នឹងមួយថា គាត់នឹងស្លាប់នៅទីនោះ។

ដេម៉ាស់៖ បន្ទាប់លោក ដេម៉ាស់ បានហៅម្តងទៀតនិយាយថា "តើអ្នកមិនគិតចូលមកមើលទេឬអី?"

គ្រីស្ទាន៖ បន្ទាប់មកគ្រីស្ទានឆ្លើយដដែលថា "លោក ដេម៉ាស់អើយ អ្នកជាសត្រូវនឹងផ្លូវត្រឹមត្រូវរបស់ព្រះជាម្ចាស់នៃផ្លូវនេះ ហើយអ្នកត្រូវបានដាក់ទោសរួចហើយដោយចៅក្រមរបស់ព្រះដែលមានគ្រប់អំណាចចេស្តាដែលអ្នកបានបែរចេញ ហេតុអ្វីបានជាអ្នកចង់ឱ្យពួកយើងធ្លាក់ចូលការកាត់ទោសដូចនោះដែរ?

**"ដ្បិតអ្នកដេម៉ាសបានលះចោលខ្ញុំហើយ ដោយគាត់ស្រឡាញ់លោកិយនេះ គាត់បានទៅឯក្រុងថែស្សាឡូនិចហើយ អ្នកក្រេសេនបានទៅឯស្រុកកាឡាទី ហើយអ្នកទីតុសក៏បានទៅកាន់ស្រុកដាល់ម៉ាទា។" ធីម៉ូថេទី២ 4:10**

ក្រៅពីនោះ ប្រសិនបើយើងបែរចេញវិញ ព្រះអម្ចាស់របស់យើងដែលជាស្ដេចនឹងស្អប់ពួផង ហើយនឹងធ្វើឱ្យយើងត្រូវអាម៉ាស់ នៅកន្លែងដែលយើងគួរតែឈរដោយក្លាហាននៅចំពោះទ្រង់។"

ដេម៉ាស់ស្រែកឡើងម្ដងទៀត ដែលថាគាត់ជាម្នាក់នៅក្នុងក្រុមរបស់ពួកគេ ហើយប្រសិនបើពួកគេនឹងបន្តនៅបន្តិចទៀតនោះ គាត់ផ្ទាល់នឹងដើរទៅជាមួយពួកគេដែរ។

គ្រីស្ទាន៖ បន្ទាប់មកគ្រីស្ទាននិយាយថា "តើអ្នកឈ្មោះអ្វី? តើមិនមែនជាឈ្មោះដូចដែលខ្ញុំបានហៅអ្នកទេឬអី?"

ដេម៉ាស់៖ បាទ ឈ្មោះរបស់ខ្ញុំគឺដេម៉ាស់។ ខ្ញុំជាកូនប្រុសរបស់លោកអ័ប្រាហាំ។

គ្រីស្ទាន៖ ខ្ញុំស្គាល់អ្នកដែរ។ គេហាស៊ីជាតាទួតរបស់អ្នក ហើយយូដាសជាឪពុករបស់អ្នក ហើយអ្នកបានដើរតាមជំហានរបស់ពួកគេ។ វាគ្រាន់តែជាការបញ្ឆោតរបស់អារក្សដែលអ្នកប្រើតែប៉ុណ្ណោះ។ ឪពុករបស់អ្នកត្រូវបានព្យួរកដោយសារតែបានក្បត់ ហើយអ្នកមិនសាកសមនឹងរង្វាន់ណាដែលប្រសើរឡើយ។

“ឯកេហាស៊ី ជាអ្នកបម្រើរបស់អេលីសេ ជាអ្នកសំណប់របស់ព្រះ គាត់នឹកថា មើល ចៅហ្វាយអញបានយល់ដល់ណាម៉ាន់ជាសាសន៍ស៊ីរីនោះ ដោយមិនបានទទួលរបស់ស្នងពីដៃលោក ដែលនាំមកជូននោះសោះ អញស្បថដោយនូវព្រះយេហូវ៉ា ដ៏មានព្រះជន្មរស់នៅថា អញនឹងរត់ទៅតាម ហើយទទួលយករបស់ខ្លះពីលោកវិញ។” ពង្សាវតារក្សត្រទី២ 5:20

“នៅគ្រានោះ មានម្នាក់ក្នុងពួក១២នាក់ ឈ្មោះ យូដាស អ៊ីស្ការីយ៉ុត វាទៅឯពួកសង្គ្រាជសួរថា បើបញ្ជូនអ្នកនោះមកលោក តើលោកនឹងឱ្យអ្វីដល់ខ្ញុំ រួចគេសម្រេចនឹងឱ្យប្រាក់៣០រៀលដល់វា។” ម៉ាថាយ 26:14, 15

“ដល់ព្រឹកឡើង ពួកសង្គ្រាជ និងពួកចាស់ទុំនៃបណ្តាជន គេពិគ្រោះគ្នាទាស់នឹងព្រះយេស៊ូវ ដើម្បីនឹងសម្លាប់ទ្រង់។ ក៏ចងទ្រង់ដឹកជញ្ជូនទៅឯចៅហ្វាយស្រុកឈ្មោះ ប៉ុនទាស–ពីឡាត់។ កាលយូដាស ជាអ្នកបញ្ជូនទ្រង់បានឃើញថាទ្រង់ជាប់ទោសដូច្នោះ នោះវានឹកស្តាយ ក៏យកប្រាក់៣០ទៅឱ្យដល់ពួកសង្គ្រាជ និងពួកចាស់ទុំវិញ ដោយពាក្យថា ខ្ញុំបានជាធ្វើបាប ដោយបញ្ជូនឈាមឥតមានទោសហួសទៅហើយ តែគេឆ្លើយថា តើនោះអំពល់អ្វីដល់យើង ការនោះស្រេចនៅឯងទេតើ។ វាក៏បោះប្រាក់ចោលទៅក្នុងព្រះវិហារ រួចចេញទៅក្រៅអួលស្វះស្លាប់ទៅ។” ម៉ាថាយ 27:1-5

ចូរអ្នកដឹលប្រាកដថា ពេលដែលយើងទៅដល់ស្តេច យើងនឹងប្រាប់ទ្រង់ពីទង្វើរបស់អ្នក។

ដូច្នេះពួកគេក៏ទៅតាមផ្លូវរបស់ពួកគេទៅ។

មកដល់ពេលនេះលោកដល់ទីបញ្ចប់និងគ្នីគ្នាបានមកដល់ទីនេះម្តង។ ដំបូងឡើយពួកគេសូមទៅកាន់លោកដេម៉ាស់។ ឥឡូវនេះ មិនថាពួកគេនឹងធ្លាក់ចូលទៅក្នុងរណ្តៅដោយមើលពីម៉ាត់រណ្តៅ ឬពួកគេចុះទៅដើម្បីជីកនោះទេ ឬពួកគេត្រូវរុំព័ទ្ធដោយដីស្អិតនៅបាតរណ្តៅដែលធម្មតាតែងតែឡើងមកនោះទេ ពីការនោះខ្ញុំមិនប្រាកដនោះទេ តែខ្ញុំសង្កេតឃើញថា ពួកគេមិនលេចមកឱ្យឃើញម្តងទៀតនៅតាមផ្លូវឡើយ។ បន្ទាប់មកគ្រីស្ទានច្រៀងថា

"ដល់ទីបញ្ចប់និងដេម៉ាស់ជាប្រាក់ពិតជាយល់ស្របគ្នា។ ម្នាក់ស្រែកហៅហើយម្នាក់ទៀតរត់ ថាគេនឹងបានចែករំលែកលុយរបស់គាត់។ ដូច្នេះអ្នកទាំងពីរនេះមានតែនៅក្នុងលោកិយនេះទេ និងមិនអាចទៅបានលើសនេះឡើយ។"

## ចូរចងចាំពីប្រពន្ធឡុត

ពេលនេះខ្ញុំឃើញថា នៅម្ខាងទៀតនៃវាលនោះ មានអ្នកធ្វើធម្មយាត្រាម្នាក់មកដល់កន្លែងមួយដែលមានបូជនីយដ្ឋានចាស់មួយនៅឈរទីនោះយ៉ាងម៉ាំនៅផ្លូវធំ ពួកគេទាំងពីរមានភាពខ្វល់ខ្វាយដោយរូបភាពនោះ ដោយសារតែភាពចម្លែកនៃរូបរាងនោះ ព្រោះចំពោះពួកគេវាហាក់ដូចជារូបមនុស្សស្រីម្នាក់ដែលបានផ្លាស់ប្រែទៅជារូបរាងនៃសសរមួយ។ ដូច្នេះនៅទីនេះ ពួកគេបានឈរមើលហើយមើលទៀត តែអស់មួយរយៈមកពួកគេមិនអាចប្រាប់បានថាវាជាអ្វី។ ចុងក្រោយ ពេញដោយសង្ឃឹមបានក្រលេកឃើញអក្សរដែលបានសរសេរនៅលើក្បាលនោះដោយអក្សរសរសេរដៃមិនធម្មតាមួយ។ ដោយគាត់មិនមែនជាអ្នកប្រាជ្ញអ្វីក៏ហៅគ្រីស្ទាន (ដោយសារគាត់បានរៀនសូត្រ) ឱ្យមកមើល ក្រែងគាត់អាចទាញយកន័យរបស់វាបាន។ ដូច្នេះគាត់ក៏មកហើយបន្ទាប់ពីបានរៀបអក្សរចូលគ្នាមក គាត់បានរកឃើញការដូច្នេះ "ចូរចង់ចាំប្រពន្ធឡុត!" ដូច្នេះគាត់បានអាចវាប្រាប់ដល់គ្នាគាត់។ បន្តិចមកពួកគេក៏សន្មត់ថា វាជាសសរអំបិលដែលប្រពន្ធឡុតបានប្រែក្លាយទៅដោយសារគាត់បានបែរត្រឡប់មើលក្រោយដោយចិត្តដែលលោភលន់ នៅពេលគាត់កំពុងគេចចេញពីក្រុងសូដុំមរកទីសុវត្ថិភាព។

**"ឯប្រពន្ធឡុតក៏ងាកបែរមើលទៅក្រោយវិញ នោះស្រាប់តែទៅជាបង្គោលអំបិលទៅ។" លោកុប្បត្តិ 19:26**

រូបភាពបន្ទាន់និងគួរឱ្យភ្ញាក់ផ្អើលនោះបានធ្វើឱ្យពួកគេយកឱកាសដើម្បីនឹងជជែកគ្នា។

គ្រីស្ទាន៖ អា បងប្អូនខ្ញុំអើយ នេះជារូបភាពមួយដែលសមហេតុផលណាស់។ វាបានមកស្របពេលបន្ទាប់ពីយើងបានទទួលការអញ្ជើញពីលោកដេម៉ាស់ទៅមើលភ្នំលុយនោះ ដែលចង់ឱ្យយើងឈៀងចូលទៅតាមគាត់ចង់បាន ហើយដែលអ្នកមានទំនោរចង់ទៅដែរនោះបងប្អូនខ្ញុំអើយ។ តាមដែលខ្ញុំដឹងយើងអាចនឹងធ្វើខ្លួនដូចជាស្ត្រីម្នាក់នេះដែរ ធ្វើជារូបតំណាងសម្រាប់ឱ្យអ្នកមកក្រោយមើល។

សង្ឃឹម៖ ខ្ញុំសូមទោសដែលខ្ញុំល្ងីល្ងើ ហើយត្រូវធ្វើឱ្យវង្វេងថាពេលនេះខ្ញុំដូចជាប្រពន្ធឡុត ដោយសារ តើមានអ្វីខុសគ្នារវាងអំពើបាបរបស់នាងនិងអំពើបាបរបស់ខ្ញុំនោះ? នាងគ្រាន់តែមើលទៅក្រោយប៉ុណ្ណោះ ហើយខ្ញុំមានបំណងចង់ទៅមើលផង។ ចូរកាន់ខ្ជាប់នូវព្រះគុណវិញ ហើយសូមឱ្យខ្ញុំត្រូវអាម៉ាស់ ដែលការដូច្នេះមាននៅក្នុងចិត្តរបស់ខ្ញុំ!

គ្រីស្ទាន៖ ចូរយើងកត់ចំណាំនូវអ្វីដែលយើងឃើញនៅទីនេះ សម្រាប់ជាជំនួយដល់យើងនូវវេលាណាវាមកដល់។ ស្ត្រីនេះបានគេចផុតពីការកាត់ទោសមួយ ដោយសារនាងមិនបានដួលចុះដោយការបំផ្លាញក្រុងសូដុំមទេ តែនាងត្រូវបំផ្លាញដោយការមួយផ្សេងទៀត ដូចដែលយើងឃើញហើយ នាងបានក្លាយទៅជាសសរអំបិល។

សង្ឃឹមះ ពិតណាស់ ហើយនាងនឹងក្លាយជាបម្រាមនិងឧទាហរណ៍ដល់យើង បំរាមដែលថាយើងគួរតែជៀសចេញពីអំពើបាបរបស់នាង ឬជាសញ្ញាមួយពីអ្វីដែលជាការកាត់ទោសដែលនឹងត្រូវមកដោយខានមិនបានដោយការប្រយ័ត្ននេះ។ ដូច្នេះ កូរ៉ា ដាថាន់ និងអាប៊ីរ៉ាម ជាមួយនឹងមនុស្ស២៥០នាក់ទៀតត្រូវវិនាសនៅក្នុងអំពើបាបរបស់ពួកគេ ក៏បានក្លាយជាសញ្ញានិងគម្រូដល់អ្នកដទៃទៀតឱ្យប្រយ័ត្នផងដែរ។

**"ហើយកូនរបស់អេលាប គឺនេមូល១ ដាថាន១ អ័ប៊ីរ៉ាម១ គឺដាថាន និងអ័ប៊ីរ៉ាមនេះហើយដែលគេបានហៅមកឯពួកជំនុំ ជាបានលើកគ្នាទាស់នឹងម៉ូសេ ហើយនិងអើរ៉ុន ជាមួយនឹងពួកកូរេ ក្នុងកាលដែលពួកកូរេ បានលើកគ្នាទាស់ទទឹងនឹងព្រះយេហូវ៉ា។ តែដីបានហាឡើង ទទួលស្រូបយកគេជាមួយនឹងកូរេទៅ ក្នុងកាលដែលពួកកូរេនោះត្រូវស្លាប់ ហើយក៏មានភ្លើងឆេះមនុស្ស២៥០នាក់ដែរ ពួកនោះឯងបានត្រឡប់ជាគំរូដល់បណ្តាជន។" ជនគណនា 26:9, 10**

បន្ថែលើសពីនោះទៅទៀត ខ្ញុំនឹងសើចដោយការមួយគឺ របៀបដែលដេម៉ាស់និងគ្នារបស់គាត់អាចឈរដោយទំនុកចិត្តសម្លឹងមើលទ្រព្យសម្បត្តិនោះដែលស្ត្រីម្នាក់នេះបានបែរមើលក្រោយនាងបន្ទាប់មក (ដោយយើងបានអានថានាងមិនបានឈានមួយជំហានចេញពីផ្លូវឡើយ) បានប្រែក្លាយទៅជាបង្គោលអំបិលទៅ ជាពិសេសក្នុងកាលដែលការជំនុំជំរះបានធ្លាក់មកលើនាង បានធ្វើឱ្យនាងក្លាយជាឧទាហរណ៍ជារូបរាងដែលឈរនៅនោះ

ដោយសារពួកគេត្រូវតែមើលឃើញនាង នៅពេលដែលពួកគេងើយភ្នែកឡើង។

គ្រីស្ទាន៖ វាជារឿងមួយដែលយើងគួរតែពិចារណា ហើយវាបានវែកញែកថាចិត្តរបស់ពួកគេកាន់តែចង់បាននៅក្នុងកាលនោះ ហើយខ្ញុំមិនអាននឹងប្រាប់បានថានឹងត្រូវប្រៀបធៀបពួកគេទៅអ្នកណាឱ្យសមទេ ដែលពួកគេបានលួចឆក់លុយនៅក្នុងវត្តមានរបស់ចៅក្រម ឬដែលនឹងកាត់កាបូបលុយនៅក្រោមសសរព្យួរក។ មានគេនិយាយពីមនុស្សនៅក្រុងសូដុំមថា ពួកគេជាមនុស្សមានបាបខ្លាំងណាស់។

**"ឡុតក៏ងើបភ្នែកទៅឃើញវាលទន្លេយ័រដាន់ទាំងអស់ ថាជាស្រុកមានទឹកស្រួលល្អនៅគ្រប់ទីកន្លែង មុនដែលព្រះយេហូវ៉ាបានបំផ្លាញសូដុំម និងកូម៉ូរ៉ា ក៏ដូចជាសួនច្បារផងព្រះយេហូវ៉ា ហើយដូចជាស្រុកអេស៊ីព ដែលនៅសូអារផង។" លោកុប្បត្តិ 13:10**

**"រីឯពួកក្រុងសូដុំម គេជាមនុស្សអាក្រក់ ធ្វើបាបនឹងព្រះយេហូវ៉ាសន្ធឹក។" លោកុប្បត្តិ 13:13**

ដោយសារពួកគេជាមនុស្សមានបាប "នៅចំពោះព្រះ" ដែលនៅចំពោះព្រះនេត្ររបស់ទ្រង់ ហើយក្រៅពីសេចក្តីសប្បុរសដែលទ្រង់បានបង្ហាញដល់ពួកគេ ដោយសារទឹកដីសូដុំមពេលនោះដូចជាសួនច្បារអេដែនផង។ ដូច្នេះការនោះធ្វើឱ្យទ្រង់មានសេចក្តីប្រច័ណ្ឌផង ធ្វើឱ្យមានគ្រោះដែលក្តៅដូចជាភ្លើ

ងរបស់ព្រះអម្ចាស់ចេញមកពីលើមេឃមក។ ហើយវាសមហេតុផលដែលសរុបមកថា ការដូចនេះដែលបានធ្វើបាបនៅចំពោះព្រះនេត្ររបស់ព្រះ ហើយការនោះផងដែរដែលបានធ្វើជាគំរូជាបន្តមកដល់ពួកគេ ហាមពួកគេឱ្យគេចពីវា នឹងត្រូវចូលរួមនៅក្នុងការជំនុំជំរះដ៏សាហាវបំផុត។

សង្ឃឹម៖ គ្មានសង្ស័យឡើយអ្នកបាននិយាយសេចក្តីពិត តែតើវាជាសេចក្តីមេត្តាយ៉ាងណាហ្ន៎ដែលអ្នក ជាពិសេសរូបខ្ញុំមិនបានធ្វើឱ្យខ្លួនទៅជាគំរូដូចនេះនោះ! ការនេះធ្វើឱ្យយើងបានអរព្រះគុណព្រះអម្ចាស់ ឱ្យបានកោតខ្លាចនៅចំពោះទ្រង់ និងឱ្យតែងតែ "ចង់ចាំប្រពន្ធឡុត" ជានិច្ច។

ពេលសម្រាក

ខ្ញុំបានឃើញទៀតថា ពួកគេបានដើរតាមផ្លូវរបស់ពួកគេដល់ទន្លេដែលគួរគាត់ដល់ចិត្តមួយ ដែលស្តេចដាវីឌហៅថា "ទន្លេរបស់ព្រះ" តែយ៉ូហានហៅថា "ទន្លេនៃទឹកជីវិត។"

"ទ្រង់ក៏ថែរក្សា ហើយស្រោចស្រប់ផែនដី ព្រមទាំងធ្វើឲ្យមានផលកាន់តែច្រើនឡើង ដោយទន្លេនៃព្រះមានទឹកពេញ រួចទ្រង់ផ្គត់ផ្គង់ឲ្យមានស្រូវ ដោយរៀបចំផែនដីយ៉ាងនោះ" **ទំនុកដំកើង 65:9**

"**ទេវតា**ក៏បង្ហាញ ឲ្យខ្ញុំឃើញទន្លេទឹកជីវិតថ្លាដូចជាកែវចរណៃ ដែលហូរចេញពីបល្ល័ង្កនៃព្រះ និងកូនចៀម។ ឯនៅកណ្ដាលផ្លូវក្រុងនោះ ហើយនៅមាត់ទន្លេទាំងសងខាង នោះមានដើមជីវិត ដែលបង្កើតផ្លែ១២ដង គឺ១ខែម្ដងៗ ហើយស្លឹកឈើនោះ ក៏សម្រាប់នឹងមើលអស់ទាំងសាសន៍ឲ្យជា" **វិវរណៈ 22:1, 2**

"រួចលោកនាំខ្ញុំវិលទៅឯទ្វារនៃព្រះវិហារវិញ នោះឃើញមានទឹកចេញពីក្រោមមាត់ទ្វារនៃព្រះវិហារខាងកើត ដ្បិតមុខព្រះវិហារបែរទៅទិសខាងកើត ហើយទឹកនោះហូរមកពីខាងក្រោម ពីខាងស្តាំនៃព្រះវិហារ គឺពីខាងត្បូងអាសនៈ។ រួចលោកនាំខ្ញុំចេញទៅតាមផ្លូវនៃទ្វារកំផែងខាងជើង ហើយនាំវាងទៅតាមផ្លូវខាងក្រៅ រហូតដល់ទ្វារកំផែងខាងក្រៅដែលបើកទៅខាងកើត នោះឃើញមានទឹកហូរចេញមកខាងស្តាំ។ លុះបានចេញទៅខាងកើត មនុស្សនោះក៏វាស់១ពាន់ហត្ថ ដោយខ្សែដែលកាន់នៅដៃ នោះលោកឲ្យខ្ញុំលុយកាត់ទឹក ឯទឹកនោះបានត្រឹមភ្នែកគោ។ លោកក៏វាស់១ពាន់ហត្ថទៀត រួចឲ្យខ្ញុំលុយ

កាត់ទៅ ទឹកត្រង់នោះបានត្រឹមក្បាលជង្គង់ រួចលោកវាស់១ពាន់ហត្ថទៀត ក៏ឲ្យខ្ញុំលុយកាត់ទៅ ត្រង់នោះទឹកបានដល់ត្រឹមចង្កេះ។ ក្រោយនោះ លោកវាស់១ពាន់ហត្ថទៀត នោះមានទន្លេដែលខ្ញុំលុយកាត់មិនបាន ដ្បិតទឹកបានខ្ពស់ឡើង ជាទឹកដែលល្មមហែលបាន គឺជាទន្លេដែលលុយពុំបានទេ។ នោះលោកសួរមកខ្ញុំថា កូនមនុស្សអើយ តើបានឃើញហើយឬ រួចលោកនាំខ្ញុំឲ្យត្រឡប់ទៅឯមាត់ទន្លេនោះវិញ។ កាលខ្ញុំបានត្រឡប់ទៅដល់ហើយ នោះឃើញតាមមាត់ទន្លេ មានដើមឈើជាច្រើន ទាំងខាងនេះ និងខាងនោះផង។ លោកក៏ប្រាប់ខ្ញុំថា ទឹកនេះហូរចេញទៅទិសខាងកើតធ្លាក់ចុះទៅដល់ស្រុកវាល រួចនឹងហូរធ្លាក់ទៅឯសមុទ្រ លុះហូរធ្លាក់ទៅក្នុងសមុទ្រហើយ នោះទឹកសមុទ្រនឹងទៅជាល្អវិញ។ ហើយគ្រប់ទាំងសត្វមានជីវិត ដែលរវើកនៅគ្រប់កន្លែងណាដែលទន្លេនោះហូរ នឹងបានរស់នៅ ក៏នឹងមានត្រីយ៉ាងសន្ធឹកដោយព្រោះទឹកទាំងនេះបានហូរទៅដល់ទីនោះ ហើយទឹកសមុទ្រនោះនឹងបានល្អ ឯកន្លែងណាដែលទឹកទន្លេនេះហូរទៅដល់ នោះគ្រប់ទាំងអស់នឹងរស់នៅ។ ពួកនេសាទត្រីនឹងឈរនៅមាត់ទឹកនោះ ចាប់តាំងពីអេន-កេឌី រហូតដល់អេន-អេកលែម ទីនោះនឹងបានជាទីសម្រាប់បង់សំណាញ់ ឯត្រីនៅក្នុងទឹកនោះ នឹងមានយ៉ាងសន្ធឹកគ្រប់បែបតាមពូជ ដូចជាត្រីនៅក្នុងសមុទ្រធំដែរ។ តែទីល្បាប់ និងបឹងនៅទីនោះ នឹងមិនបានសាបល្អវិញទេ កន្លែងទាំងនោះនឹងបានទុកសម្រាប់ធ្វើអំបិលវិញ។ ឯតាមមាត់ច្រាំងទាំងសងខាងទន្លេនោះនឹងមានដុះដើមឈើគ្រប់យ៉ាង សម្រាប់ជាអាហារ ជាដើមដែលស្លឹកមិនស្រពោនឡើយ ហើយមិនដែលខានមានផ្លែដែរ គឺនឹងកើតផ្លែថ្មីរាល់តែខែ ពីព្រោះទឹកនោះចេញពីទីបរិសុទ្ធមក ហើយផ្លែឈើទាំងនោះ នឹងបានសម្រាប់ជាអាហារ ឯស្លឹកក៏សម្រាប់នឹងកែរោគឲ្យជាដែរ។” **អេសេគាល 47:1-12**

ពេលនេះផ្លូវរបស់ពួកគេស្ថិតនៅលើមាត់ទន្លេនោះ។ ដូច្នេះនៅទីនេះ គ្រីស្ទាននិងគ្នាគាត់បានដើរដោយមានអំណរយ៉ាងខ្លាំង។ ពួកគេបានផឹកទឹកពីទន្លេនោះ ដែលធ្វើឱ្យមានអំណរនិងធ្វើវិញ្ញាណដែលនឿយណាយបានសប្បាយឡើងវិញ។ ក្រៅពីនោះ នៅលើមាត់ទន្លេ នៅត្រើយម្ខាងទៀត មានដើមឈើខៀវខ្ចី ដែលមានផលផ្លែគ្រប់ប្រភេទ ហើយស្លឹកឈើនោះល្អធ្វើជាថ្នាំព្យាបាល ពួកគេមានសេចក្តីអំណរយ៉ាងខ្លាំងដោយផលផ្លែនៃដើមឈើនោះ ហើយពួកគេចាកចេញដោយញាំរបស់ទាំងនោះការពារជ្រុលហួសកម្រិត និងជំងឺផ្សេងៗ ដែលគ្រោះថ្នាក់ដល់អស់អ្នកដែលឈាមឡើងក្តៅយ៉ាងខ្លាំង ដោយសារការធ្វើដំណើរ។ ទាំងសងខាងរបស់ទន្លេមានវាលស្មៅស្រស់ស្អាតខ្លាំងដោយមានផ្កា ហើយវាមានពណ៌បៃតងពេញមួយឆ្នាំ។ នៅវាលស្មៅនេះពួកគេបានផ្តេកខ្លួនហើយដេកលក់ទៅ ដោយសារនៅទីនេះពួកគេអាចដេកបានដោយមានសុវត្ថិភាព។

"ព្រះយេហូវ៉ាទ្រង់ជាអ្នកគង្វាលខ្ញុំ ខ្ញុំនឹងមិនខ្វះអ្វីសោះ ទ្រង់ឲ្យខ្ញុំដេកសម្រាកនៅទីមានស្មៅខៀវខ្ចី ទ្រង់នាំខ្ញុំទៅក្បែរមាត់ទឹកដែលហូរគ្រឿនៗ. ទ្រង់កែព្រលឹងខ្ញុំឡើងវិញ ទ្រង់នាំខ្ញុំទៅតាមផ្លូវសុចរិត ដោយយល់ដល់ព្រះនាមទ្រង់។" **ទំនុកដំកើង 23:1-3**

"នោះកូនច្បងរបស់ពួកមនុស្សទាល់ក្រនឹងមានអាហារបរិភោគ ហើយមនុស្សកំសត់ទុគ៌តនឹងដេកទៅដោយសុខសាន្ត តែអញនឹងធ្វើឲ្យពូជពង្សឯងស្លាប់ទៅដោយអំណាត់អត់វិញ ហើយសំណល់នៃឯងនឹងត្រូវគេសម្លាប់បង់" **អេសាយ 14:30**

នៅពេលដែលពួកគេភ្ញាក់ឡើង ពួកគេបានប្រមូលផ្លែពីដើមឈើមក ហើយផឹកទឹកទន្លេម្តងទៀត ហើយបន្ទាប់មកផ្តេកខ្លួនដើម្បីដេកម្តងទៀត។ ដូច្នេះពួកគេធ្វើដូច្នោះអស់ប៉ុន្មានថ្ងៃប៉ុន្មានយប់។ បន្ទាប់មកពួកគេច្រៀងថា

"ចូរអ្នកមើលទៅថាប្រភពទឹកនេះចែងចាំងយ៉ាងណា ដែលបានកំសាន្តចិត្តដល់អ្នកធ្វើធម្មយាត្រា ដែលនៅក្បែរផ្លូវធំ។ វាស្មៅបៃតង ក្រៅពីនោះមានខ្លឹនក្រអូបទៀត បង្កើតរស់ជាតិឆ្ងាញ់ដល់ពួកគេ ហើយអ្នកដែលអាចប្រាប់ថាផ្លែនេះល្អប៉ុណ្ណានោះ នឹងទុកដើមនេះឱ្យបង្កើតផលផ្លែឡើង ហើយនឹងបានលក់ទ្រព្យទាំងអស់ ដើម្បីនឹងមកទិញដីនៅទីនេះ។"

ដូច្នេះនៅពេលដែលពួកគេត្រូវទៅបន្តទៀត ដោយសារតែការធ្វើដំណើររបស់ពួកគេមិនទាន់ចង់នៅឡើយ ពួកគេក៏ញ៉ាំ ហើយផឹក រួចក៏ចាកចេញទៅ។

# ផ្លូវក្បែរវាលស្មៅ

ពេលនេះខ្ញុំមើលនៅក្នុងសុបិនរបស់ខ្ញុំថា ពួកគេមិនទាន់បានទៅឆ្ងាយនៅឡើយ តែទន្លេនិងផ្លូវនោះក៏ត្រូវបែកផ្លូវគ្នា។ ដែលធ្វើឱ្យពួកគេសោកស្តាយមិនតិចឡើយ តែពួកគេមិនបានដើរចេញពីផ្លូវឡើយ។ ពេលនេះផ្លូវចេញពីទន្លេមកវាងពិបាក ហើយជើងរបស់គេក៏ទន់អស់ដោយសារការធ្វើដំណើរ។ ដូច្នេះព្រលឹងរបស់អ្នកធ្វើធម្មយាត្រាមានការធ្លាក់ចុះដោយសារតែផ្លូវនោះ។

**"រួចគេធ្វើដំណើរពីភ្នំហោរដើរទៅ តាមផ្លូវសមុទ្រក្រហម ដើម្បីនឹងវាងព័ទ្ធស្រុកអេដុម តែបណ្តាជនមានចិត្តរវាត ដោយព្រោះផ្លូវនោះ" ជនគណនា 21:4**

យ៉ាងណាពួកគេនៅតែបន្តទៅមុខ ពួកគេប្រាថ្នាចង់បានផ្លូវដែលល្អជាងនេះ។ ឥលូវនេះនៅមុខគេបន្តិច នៅខាងឆ្វេងដៃនៃផ្លូវមានវាលស្មៅមួយ និងជណ្តើរឆ្លងទៅវាលស្មៅនោះ ហើយវាលស្មៅនោះហៅថា "វាលស្មៅក្បែរផ្លូវ។" បន្ទាប់មកគ្រីស្ទាននិយាយទៅកាន់មិត្តគាត់ថា "ប្រសិនបើវាលស្មៅនេះនៅតាមផ្លូវរបស់យើង យើងនឹងចូលទៅ។" បន្ទាប់មកគាត់ទៅកាន់ជណ្តើរមើលហើយឃើញថាផ្លូវនៅក្បែររបងម្ខាងទៀត។ "នេះតាមសេចក្តីប្រាថ្នារបស់ខ្ញុំហើយ" គ្រីស្ទាននិយាយថា "នេះជាផ្លូវទៅស្រួលបំផុតហើយ ពេញដោយសង្ឃឹមអើយ តោះចូរយើងទៅនោះ។"

សង្ឃឹម៖ តែប្រសិនបើផ្លូវនេះនឹងនាំយើងចេញពីផ្លូវនោះ?

គ្រីស្ទាន៖ "ដូចមិនអីចឹងទេ" ម្នាក់ទៀតនិយាយ "មើលទៅ តើវាមិនមែនទៅស្របក្បែរផ្លូវយើងទេឬអី?" ដូច្នេះពេញដោយសង្ឃឹមត្រូវបានមិត្តរបស់គាត់បបួលបាន ក៏ទៅតាមគាត់ទៅម្ខាងទៀតតាមជណ្ដើរ។ នៅពេលដែលពួកគេទៅដល់ម្ខាងទៀត ហើយទៅដល់លើផ្លូវ ពួកគេឃើញថាវាស្រួលសម្រាប់ជើងរបស់ពួកគេ ហើយពួកគេបានសម្លឹងមើលទៅមុខពួកគេ ឃើញមានបុរសម្នាក់កំពុងដើរដូចជាពួកគេដែរ (ហើយឈ្មោះរបស់គាត់គឺ ទំនុកចិត្តដែលអសារឥតការ)។ ដូច្នេះពួកគេក៏ស្រែកហៅគាត់ ហើយសួរគាត់ថាផ្លូវនេះនាំទៅណា? គាត់បាននិយាយថា "ទៅកាន់ឃ្លោងទ្វារស្ថានសួគ៌" "មើលទៅ" គ្រីស្ទាននិយាយថា "តើខ្ញុំមិនបានប្រាប់អ្នកដូច្នេះទេឬ? អ្នកនឹងឃើញថាយើងត្រូវហើយ" ដូច្នេះពួកគេក៏ដើរតាមទៅ ហើយគាត់បានដើរពីមុខពួកគេ។ តែមើលទៅ ពេលយប់ក៏មកដល់ ហើយងងឹតកាន់តែខ្លាំង។ ដូច្នេះពួកគេនៅពីក្រោយមើលគាត់ដែលដើរខាងមុខលែងឃើញ។

ដូច្នេះអ្នកដែលដើរខាងមុខ (លោកទំនុកចិត្តឥតប្រយោជន៍ តាមឈ្មោះនោះ) មើលមិនឃើញផ្លូវខាងមុខគាត់ ក៏ធ្លាក់ចូលទៅក្នុងរណ្ដៅជ្រៅទៅ។

**"ដ្បិតពួកអ្នកដែលដឹកនាំសាសន៍នេះ គេនាំឲ្យវង្វេងទេ ហើយពួកអ្នកដែលគេនាំមុខ នោះក៏ត្រូវបំផ្លាញទៅ" អេសាយ 9:16**

ជារណ្ដៅដែលព្រះអម្ចាស់នៃទឹកដីនោះបង្កើតមកក្នុងគោលបំណង ចាប់មនុស្សល្ងីល្ងើដែលមានសិរីល្អខាងឥតប្រយោជន៍ ហើយត្រូវបានកិនទៅជាបំណែកៗដោយការធ្លាក់ចូលទៅ។

នៅពេលដែលគាត់កំពុងមកកន្លែងដែលពួកគេនៅនោះ គាត់បានសួរពួកគេថា តើពួកគេមកពីណា? ហើយតើពួកគេធ្វើអ្វីនៅទីនោះ? ពួកគេបានប្រាប់គាត់ថា "ពួកគេជាអ្នកធ្វើធម្មយាត្រាដ៏កំសត់ធ្វើដំណើរទៅកាន់ស៊ីយ៉ូន តែត្រូវបាននាំចេញពីផ្លូវរបស់ពួកគេដោយបុរសខ្មៅម្នាក់ដែលពាក់ស ដែលបុរសនោះបានប្រាប់យើងថា "ឱ្យមកតាមគាត់ ដោយសារគាត់កំពុងតែទៅកាន់ទីនោះដែរ។" បន្ទាប់មកគាត់និយាយដោយវាយនឹងរំពាត់ថា "វាជាអ្នកបញ្ឆោរជាសាវកក្លែងក្លាយដែលបានប្រែខ្លួនទៅជាទេវតានៃពន្លឺ។""

**"អ្នកណាដែលបញ្ចើចដល់អ្នកជិតខាង នោះឈ្មោះថា ដាក់លប់សម្រាប់ចាប់ជើងគេទេ។" សុភាសិត 29:5**

**"ឯពួកអ្នកដែលប្រព្រឹត្តអាក្រក់ទាស់នឹងសេចក្ដីសញ្ញា នោះវានឹងនាំបង្ខូចចិត្តគេ ដោយពាក្យបញ្ចើច តែចំណែកពួកអ្នកទាំងប៉ុន្មានដែលស្គាល់ព្រះនៃខ្លួន គេនឹងមានចិត្តរឹងប៉ឹង ហើយនិងប្រតិបត្តិតទៅ" ដានីយ៉ែល 11:32**
**"ដ្បិតមនុស្សយ៉ាងនោះជាសាវកក្លែងក្លាយ ជាអ្នកឆបោក ដែលក្លែងខ្លួនធ្វើជាសាវកនៃព្រះគ្រីស្ទទេ។ ហើយសេចក្ដីនោះមិនជាអស្ចារ្យឡើយ ព្រោះអារក្សសាតាំងក៏ក្លែងខ្លួនធ្វើជាទេវតានៃពន្លឺដែរ" កូរិនថូសទី២ 11:13, 14**

ដូច្នេះគាត់បានស្រាយសំណាញ់ ហើយឱ្យបុរសទាំងពីរចេញទៅ។ បន្ទាប់

មកគាត់និយាយទៅកាន់ពួកគេថា "មកតាមខ្ញុំ នោះខ្ញុំនឹងនាំពួកឯងទៅកាន់ផ្លូវរបស់ពួកឯងម្ដងទៀត។" ដូច្នេះគាត់ក៏បាននាំពួកគេទៅកាន់ផ្លូវដែលពួកគេបែរចេញដើម្បីដើរតាមមនុស្សបញ្ឆោរមកនោះ។ បន្ទាប់មកគាត់បានសួរពួកគេថា "តើអ្នកដេកនៅទីណាពីយប់មិញ?" ពួកគេនិយាយថា "ដេកជាមួយពួកគង្វាលនៅភ្នំនៃសេចក្ដីសម្រាក។" បន្ទាប់មកគាត់សួរពួកគេថា "តើពួកគេមិនបានទទួលក្រដាស់កត់ចំណាំទិសដៅពីពួកគង្វាលទាំងនោះទេឬយ៉ាងណា?" ពួកគេឆ្លើយថា "មាន" "តែតើអ្នកបានអានទេ?" គាត់និយាយ។ ពួកគេឆ្លើយថា "ទេ" គាត់សួរពួកគេថាហេតុអ្វី? ពួកគេឆ្លើយថាពួកគេភ្លេច។ គាត់បានសួរថែមទៀតថា "ថាតើអ្នកគង្វាលមិនបានប្រាប់ពួកគេឱ្យប្រយ័ត្ននឹងមនុស្សបញ្ឆោរទេឬអ្វី?" ពួកគេបានឆ្លើយថា "បានប្រាប់ តែពួកយើងមិនបានគិតស្រម៉ៃដល់សោះ ថាមនុស្សដែលពូកែនិយាយនោះគឺជាវាម្នាក់នោះ។"

**"ដ្បិតមនុស្សបែបយ៉ាងនោះ មិនមែនគោរពប្រតិបត្តិដល់ព្រះគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នាទេ គេបម្រើតែពោះខ្លួនគេវិញ ទាំងបញ្ឆោតចិត្តមនុស្សស្លូតត្រង់ ដោយពាក្យផ្អែមពីរោះ និងពាក្យបញ្ចើចផង" រ៉ូម 16:18**

បន្ទាប់មកខ្ញុំឃើញនៅក្នុងសុបិនរបស់ខ្ញុំថា គាត់បង្គាប់ពួកគេឱ្យដេកចុះ។

**"បើអ្នកមានទោសនោះគួរឱ្យវាយ នោះចៅក្រមត្រូវឱ្យដេកទៅ ហើយឱ្យគេវាយនៅចំពោះមុខ ត្រូវវាយឱ្យគ្រប់ចំនួន ល្មមនឹងទោសអ្នកនោះ" ចោទិយកថា 25:2**

នៅពេលដែលពួកគេធ្វើតាម គាត់បានធ្វើទណ្ឌកម្មពួកគេយ៉ាងឈឺដើម្បីបង្រៀនពួកគេពីផ្លូវល្អដែលពួកគេត្រូវដើរ។

"បើកាលណាមេឃរាំងភ្លៀង ដោយព្រោះគេបានធ្វើបាបនឹងទ្រង់ នោះបើគេអធិស្ឋានតម្រង់មកឯទីនេះ ព្រមទាំងគោរពដល់ព្រះនាមទ្រង់ ហើយលះបង់ចោលអំពើបាបរបស់គេចេញ ដោយព្រោះទ្រង់បានផ្ចាញ់ផ្ចាលគេ។ នោះសូមទ្រង់ប្រោសស្តាប់ពីលើស្ថានសួគ៌ ហើយអត់ទោសចំពោះអំពើបាប របស់ពួកអ្នកបម្រើទ្រង់ គឺជាពួកអ៊ីស្រាអែលជារាស្ត្រទ្រង់ ដោយបង្រៀនឱ្យគេដឹងផ្លូវល្អណាដែលត្រូវដើរ រួចសូមបង្អុរភ្លៀង ឱ្យមកលើស្រុករបស់ទ្រង់ ដែលបានប្រទានមករាស្ត្រទ្រង់ទុកជាមរដកផង។" **របាក្សត្រទី២ 6:26, 27**

ហើយកាលដែលគាត់ធ្វើទណ្ឌកម្មដល់ពួកគេ គាត់បាននិយាយថា "កាលបើខ្ញុំស្រឡាញ់ប៉ុណ្ណា ខ្ញុំស្តីបន្ទោសនិងវាយប្រដៅប៉ុណ្ណោះដែរ ចូរជឿខ្ជាប់ខ្ជួនឡើង ហើយប្រែចិត្តចុះ។"

"អញបន្ទោស ហើយផ្ចាញ់ផ្ចាល ដល់អស់អ្នកណាដែលអញស្រឡាញ់ ដូច្នេះចូរមានចិត្តឧស្សាហ៍ ហើយប្រែចិត្តចុះ" **វិវរណៈ 3:19**

បន្ទាប់ពីការនេះចប់មក គាត់បានប្រាប់ពួកគេឱ្យទៅតាមផ្លូវរបស់ពួកគេ ហើយឱ្យស្តាប់តាមទៅកាន់ទិសដៅមួយទៀតរបស់ពួកគង្វាល។ ដូច្នេះពួក

គេបានអរគុណដល់គាត់ដោយសេចក្ដីសប្បុរសរបស់គាត់ ហើយចេញទៅ ដោយទន់ភ្លន់តាមបណ្ដោយផ្លូវត្រូវទាំងច្រៀងថា

"មកទីនេះ អ្នកដែលដើរតាមផ្លូវនោះ មកមើលថាអ្នកធ្វើធម្មយាត្រាបានបែរ ទាសចេញទៅ! ពួកគេត្រូវចាប់ជាប់នឹងសំណាញ់ ដោយសារពួកគេបានភ្លេច ពីយោបល់ល្អៗ។ នេះជាអ្នកដែលមករំដោះពួកគេពិត តែអ្នកឃើញហើយថា ពួកគេត្រូវវាយប្រដៅឱ្យឈប់។ ចូរឱ្យការនេះបានជាបំរាមដល់អ្នកចុះ!"

## មនុស្សមិនជឿថាមានព្រះ

ពេលនេះបន្តិចក្រោយមក ពួកគេសម្លឹងមើលទៅឃើញពីចម្ងាយឃើញម្នាក់កំពុងដើរមកថ្មមៗតែម្នាក់ឯងតាមផ្លូវធំមកជួបពួកគេ។ បន្ទាប់មកគ្រីស្ទាននិយាយទៅកាន់គ្នាគាត់ថា "ខាងមុននោះជាបុរសម្នាក់ដែលបែរខ្នងដាក់ស៊ីយ៉ូន ហើយគាត់កំពុងតែមកជួបយើងហើយ។"

សង្ឃឹម៖ ខ្ញុំហើយគាត់ហើយ ចូរយើងប្រយ័ត្នខ្លួនយើងវិណានៅពេលនេះ មិនអីចឹងគាត់នឹងដូចជាមនុស្សបញ្ឆោរដែរហើយ។

ដូច្នេះគាត់បានខិតមកជិតហើយជិតទៀត ហើយចុងក្រោយបានមកដល់ពួកគេ។ ឈ្មោះរបស់គាត់គឺ មិនមានព្រះ។ ហើយគាត់បានសួរពួកគេថាទៅណា?

គ្រីស្ទាន៖ យើងកំពុងតែទៅកាន់ភ្នំស៊ីយ៉ូន។

បន្ទាបមកគ្មានព្រះបានសើចយ៉ាងខ្លាំង

គ្រីស្ទាន៖ តើអ្វីទៅជាអត្ថន័យនៃសំណើចរបស់អ្នកនោះ?

គ្មានព្រះ៖ ខ្ញុំសើចដោយសារបានឃើញមនុស្សល្ងង់ដូចជាពួកឯងហ្នឹងហើយដែលត្រូវយកខ្លួនមកធ្វើដំណើរស្ទើស្លាប់ស្ទើរស់នេះ ហើយមិនបានអ្វីទាំងអស់ក្រៅពីការធ្វើដំណើរបានតែការឈឺចាប់ហ្នឹង។

គ្រីស្ទាន៖ ហេតុអ្វីបានជាអ្នកគិតថាយើងនឹងបានទទួលអ្វីនោះ?

គ្មានព្រះ៖ បានទទួល! វាគ្មានកន្លែងណាដូចដែលឯងស្រម៉ៃនៅក្នុងលោកិយនេះឡើយ។

គ្រីស្ទាន៖ តែវាមាននៅពេលដែលលោកិយថ្មីនឹងមកដល់។

គ្មានព្រះ៖ នៅពេលដែលខ្ញុំនៅផ្ទះនៅក្នុងប្រទេសខ្ញុំ ខ្ញុំបានឮដូចដែលឯងបានអះអាងដែរ ហើយបន្ទាប់ពីបានឮហើយក៏បានចេញទៅមើល ហើយបានស្វែងរកទីក្រុងនោះអស់រយៈពេលម្ភៃឆ្នាំហើយ តែមិនបានឃើញអ្វីច្រើនក្រៅពីអ្វីដែលខ្ញុំបានឃើញពេលចេញមកដំបូងនោះទេ។

**"មើលគេសួរទូលបង្គំថា តើព្រះបន្ទូលនៃព្រះយេហូវ៉ានៅឯណា ឱ្យការនោះមកឥឡូវចុះ។" យេរេមា 17:15**
**"ការដែលមនុស្សល្ងីល្ងើខំធ្វើ នោះធ្វើឱ្យខ្លួននឿយហត់គ្រប់គ្នា ពីព្រោះគេមិនដឹង ទៅឯទីក្រុងតាមផ្លូវណាទេ។" សាស្តា 10:15**

គ្រីស្ទាន៖ យើងទាំងបានឮនិងជឿថាមានទីកន្លែងបែបដូច្នោះមែន។

គ្មានព្រះ៖ តើខ្ញុំមិនបានជឿកាលខ្ញុំនៅផ្ទះ ហើយបានមកឆ្ងាយបែបនេះដើម្បីស្វែងរកទេឬអី តែរកមិនឃើញអ្វីសោះ (ហើយខ្ញុំគួរតែបានរកឃើញកន្លែងនោះរួចទៅហើយ ដោយសារខ្ញុំបានចេញមកស្វែងរកវាឆ្ងាយជាងអ្នក) ខ្ញុំត្រឡប់ទៅក្រោយវិញហើយ ហើយខ្ញុំនឹងរកការដែលធ្វើឱ្យខ្ញុំស្រស់ស្រាយឡើងវិញ គឺការទាំងឡាយដែលខ្ញុំបានបោះបង់ចោលដោយសារសង្ឃឹមថានឹងបានឃើញអ្វីដែលខ្ញុំរកមិនឃើញនេះ។

គ្រីស្ទាន៖ បន្ទាប់មកគ្រីស្ទាននិយាយទៅកាន់សង្ឃឹមជាគ្នាគាត់ថា "តើអ្វីដែលអ្នកនេះនិយាយពិតដែរទេ?"

សង្ឃឹម៖ "សូមប្រយ័ត្ន គាត់ជាម្នាក់ក្នុងចំណោមមនុស្សបញ្ឆោត ចូរចាំពីអ្វីដែលបានកើតឡើងដល់យើងដោយសារបានស្តាប់តាមមនុស្សបែបនេះ។ អ្វីទៅ! មិនមានភ្នំស៊ីយ៉ូន! តើយើងមិនបានសម្លឹងឃើញពីភ្នំនៃសេចក្តីសម្រាកឃើញឃ្លោងទ្វារទីក្រុងនោះទេឬអី? ហើយថាតើយើងមិនត្រូវដើរដោយសេចក្តីជំនឿទេឬអីពេលនេះ? ចូរយើងបន្តដំណើរទៀត" សង្ឃឹមនិយាយ "មិនដូច្នោះទេបុរសដែលមានរំពាត់ខ្សែរតីនឹងមកទាន់យើងម្តងទៀត។ អ្នកគួរតែបានបង្រៀនខ្ញុំនូវមេរៀននោះ ដែលខ្ញុំនឹងព័ទ្ធវាជុំវិញត្រចៀករបស់អ្នកថា កូនអញអើយ ចូរចាកចេញទៅកុំស្តាប់តាមការណែនាំដែលធ្វើឱ្យអ្នកធ្វើខុសឡើយចេញពីពាក្យនៃចំណេះដឹង។ ខ្ញុំនិយាយថាបងអើយ កុំព្រមស្តាប់តាមគាត់អី ហើយចូរយើងជឿដល់ការសង្គ្រោះព្រលឹងវិញ។"

**"កូនអើយ ចូរលែងស្តាប់តាមដំបូន្មាន ដែលនាំឱ្យវង្វេងពីផ្លូវនៃដំរិះចេញ។" សុភាសិត 19:27**

**"តែយើងរាល់គ្នាមិនមែនជា ពួកអ្នកដែលថយទៅវិញ ឱ្យត្រូវវិនាសនោះឡើយ គឺជាពួកអ្នកដែលមានសេចក្តីជំនឿ សម្រាប់ឱ្យព្រលឹងបានសង្គ្រោះវិញ។" ហេព្រើរ 10:39**

គ្រីស្ទាន៖ បងប្អូនខ្ញុំអើយ ខ្ញុំមិនបានសួរអ្នកទេ ដោយសារតែខ្ញុំសង្ស័យពីសេ

ចក្តីពិតចេញពីសេចក្តីជំនឿរបស់យើងដោយខ្លួនខ្ញុំទេ។ តែដើម្បីនឹងអះអាងអ្នក ហើយដើម្បីនឹងទាញបានផលផ្លែចេញពីអ្នកនូវភាពស្មោះត្រង់ចេញពីចិត្តរបស់អ្នកវិញ។ សម្រាប់បុរសម្នាក់នេះវិញ ខ្ញុំដឹងថាគាត់ត្រូវបានព្រះនៃលោកិយនេះធ្វើឱ្យខ្វាក់ភ្នែកហើយ។ ចូរអ្នកនិងខ្ញុំបន្តទៅមុខទៀត ដោយដឹងថាយើងមានជំនឿលើសេចក្តីពិត ហើយ "មិនការកុហកនៅក្នុងសេចក្តីពិតទេ។"

**"ខ្ញុំសរសេរផ្ញើមកមិនមែនដោយព្រោះអ្នករាល់គ្នា មិនស្គាល់សេចក្តីពិតទេ គឺដោយព្រោះបានស្គាល់ ហើយក៏ដឹងថា គ្មានសេចក្តីភូតភរណាកើតពីសេចក្តីពិតនោះឡើយ។" យ៉ូហានទី១ 2:21**

សង្ឃឹម៖ ពេលនេះខ្ញុំពិតជាមានអំណរនៅក្នុងសង្ឃឹមនៃសិរីល្អរបស់ព្រះមែន !

ដូច្នេះពួកគេបានបែរចេញពីបុរសម្នាក់នោះ ហើយគាត់បានសើចដាក់ពួកគេ រួចទៅតាមផ្លូវរបស់គាត់ទៅ។

ទឹកដីវេទមន្ត

ខ្ញុំបានឃើញនៅក្នុងសុបិនរបស់ខ្ញុំថា ពួកគេបានទៅរហូតដល់ប្រទេសមួយដែលខ្យល់នៅទីនោះអាចធ្វើឱ្យមនុស្សទៅជាងោកងុយបាន ប្រសិនបើមានមនុស្សប្លែកណាមកទីនោះ។ ហើយនៅទីនេះ ពេញដោយសង្ឃឹមបានក្លាយទៅជាកម្រើមិនសូវបានហើយងងុយដេកយ៉ាងខ្លាំង។ ដូច្នេះគាត់បា

ននិយាយទៅកាន់គ្រីស្ទានថា "ខ្ញុំចាប់ផ្តើមងោកងុយយ៉ាងខ្លាំង ដែលខ្ញុំពិបាកនឹងទប់ភ្នែករបស់ខ្ញុំណាស់ ចូរយើងផ្តេកខ្លួនទៅទីនេះ ហើយដេកមួយត្របក់ទៅ។"

គ្រីស្ទាន៖ "មិនអាចទេ" ម្នាក់ទៀតក៏បាននិយាយថា "ក្រែងថាដេកហើយយើងនឹងមិនភ្ញាក់ឡើងម្តងទៀត។"

សង្ឃឹម៖ ហេតុអ្វីទៅបង ការដេកជាការល្អសម្រាប់មនុស្សដែលធ្វើការអស់កម្លាំង។ យើងនឹងបានស្រស់បស់ឡើងប្រសិនបើយើងបានដេកបន្តិចនោះ។

គ្រីស្ទាន៖ តើអ្នកមិនបានចងចាំថា មានអ្នកគង្វាលម្នាក់បានប្រាប់យើងឱ្យប្រយ័ត្ននឹងទឹកដីមានវេទមន្តទេឬអី? គាត់មានន័យថា យើងត្រូវតែប្រុងប្រយ័ត្ននឹងការដេកលក់។ ដូច្នេះចូរយើងកុំដេកដូចអ្នកផ្សេងអី តែចូរយើងប្រុងប្រយ័ត្ននិងភ្ញាក់ជានិច្ចវិញ។

**"ដូច្នេះត្រូវឱ្យយើងចាំយាម ហើយដឹងខ្លួន មិនត្រូវឱ្យដេកលក់ដូចជាមនុស្សឯទៀតទេ។" ថែស្សាឡូនិចទី១ 5:6**

សង្ឃឹម៖ ខ្ញុំទទួលស្គាល់ថាខ្ញុំជាអ្នកខុសហើយ។ ហើយបើខ្ញុំនៅទីនេះតែម្នាក់ឯង ដោយការដេកលក់នោះខ្ញុំនឹងធ្វើឱ្យខ្លួនមានគ្រោះថ្នាក់ស្លាប់តែម្នាក់ឯងមិនខាន។

**"មានគ្នាពីរនាក់នោះវិសេសជាងនៅតែឯង ពីព្រោះគេមានរង្វាន់យ៉ាងល្អ កើតពីការនឿយហត់របស់ខ្លួន។" សាស្តា 4:9**

មានអ្នកជាគ្នានៅទីនេះជាសេចក្តីមេត្តាដល់ខ្ញុំហើយ ហើយអ្នកនឹងទទួលបានរង្វាន់ដ៏ល្អមួយដោយសារការខិតខំរបស់អ្នក។

គ្រីស្ទាន៖ "ពេលនេះ" បន្ទាប់មកគ្រីស្ទានបាននិយាយថា "ដើម្បីគេចផុតពីភាពងោកងុយនៅទីនេះ ចូរយើងចាប់ផ្តើមជជែកគ្នាវិញ។"

សង្ឃឹម៖ "អស់ពីចិត្តរបស់ខ្ញុំ" ម្នាក់ទៀតនិយាយ

គ្រីស្ទាន៖ តើយើងគួរតែចាប់ផ្តើមពីត្រង់ណា?

សង្ឃឹម៖ ពីកន្លែងដែលព្រះបានចាប់ផ្តើមជាមួយយើង។ តែអ្នកចង់ចាប់ផ្តើមទេ ប្រសិនបើអ្នកចង់នោះ។

គ្រីស្ទាន៖ ខ្ញុំនឹងច្រៀងចម្រៀងនេះដល់អ្នកជាមុនសិន។

"នៅពេលដែលពួកបរិសុទ្ធចាប់ផ្តើមងងុយដេក ចូរឱ្យពួកគេមកទីនេះ ហើយមកស្តាប់អ្នកធ្វើធម្មយាត្រាពីរនាក់នេះជជែកគ្នាចុះ។ ពិតណាស់ ចូរមករៀនពីពួកគេចុះ ឱ្យបានមានប្រាជ្ញាឡើយ ដើម្បីនឹងការពារពីភាពងោកងុយ ភ្នែកងោកងុយ។ ការប្រកបរបស់ពួកបរិសុទ្ធ ប្រសិនបើរៀបចំបានល្អវិញ ក៏នឹងធ្វើឱ្យពួកគេភ្ញាក់ឡើង ជំនួសឱ្យស្ថាននរក។"

គ្រីស្ទានៈ បន្ទាប់មកគ្រីស្ទានចាប់ផ្តើមនិយាយថា "ខ្ញុំនឹងសួរសំណួរមួយដល់អ្នក។ ហេតុអ្វីបានជាអ្នកគិតពីដំបូងថានឹងធ្វើការដែលអ្នកកំពុងធ្វើនេះ?"

សង្ឃឹមៈ តើអ្នកមានន័យថា ខ្ញុំអាចមើលឃើញពីសេចក្តីល្អខាងព្រលឹងរបស់ខ្ញុំពីដំបូងមកបានដោយរបៀបណាមែនទេ?

គ្រីស្ទានៈ បាទ ន័យបែបហ្នឹងហើយ។

សង្ឃឹមៈ ខ្ញុំបានបន្តរីករាយមួយរយៈធំនឹងការទាំងនោះដែលបានឃើញនិងលក់នៅជំនួញរបស់យើងនោះ។ ជាការខ្ញុំពេលនេះខ្ញុំជឿថា (ប្រសិនបើខ្ញុំនៅតែបន្តធ្វើវាទៀត) នឹងបានធ្វើឱ្យខ្ញុំលិចលង់នៅក្នុងស្ថាននរក និងសេចក្តីវិនាសអន្តរាយហើយ។

គ្រីស្ទានៈ តើការទាំងនោះជាអ្វីខ្លះ?

សង្ឃឹមៈ គ្រប់ទាំងទ្រព្យសម្បត្តិនិងភាពសម្បូរសប្បាយនៃលោកិយនេះ។ ខ្ញុំក៏បានរីករាយយ៉ាងខ្លាំងនឹងការបង្ការការរឹករវ ការបេះបោរ ការផឹក ការស្បថ ការកុហក ភាពស្មោគគ្រោក ការបំពានលើថ្ងៃសប្ប័ថ ហើយអ្វីផ្សេងទៀតដែលរកតែបំផ្លាញព្រលឹង។ តែចុងក្រោយខ្ញុំរកឃើញថា ដោយបានស្តាប់និងពិចារណាពីការដែលមកពីព្រះវិញ ដែលតាមការពិតទៅខ្ញុំបានឮពីអ្នក ក៏ដូចជាឮពីលោកស្មោះត្រង់ជាទីស្រឡាញ់ ដែលគាត់ត្រូវបានសម្លាប់ដោយសារសេចក្តីជំនឿរបស់គាត់និងការរស់នៅល្អនៅត្រង់ជំនួញដែលឥតប្រយោជន៍នោះ ដែលចុងក្រោយនៃការទាំងនោះជាសេចក្តីស្លាប់ ហើយ

ដោយសារទាំងនោះបានធ្វើឱ្យសេចក្តីក្រោធរបស់ព្រះធ្លាក់មកលើកូនចៅនៃការមិនស្តាប់បង្គាប់។

**"កាលនោះតើអ្នករាល់គ្នាបានផលអ្វីខ្លះក្នុងអំពើដែលឥលូវអ្នករាល់គ្នាអៀមខ្មាសវិញ ដ្បិតទីបំផុតនៃអំពើទាំងនោះជាសេចក្តីស្លាប់។ តែឥលូវនេះ ដែលព្រះបានប្រោសឱ្យរួចពីបាប ហើយអ្នករាល់គ្នាបានត្រឡប់ជាបាវបម្រើដល់ទ្រង់ នោះអ្នករាល់គ្នាបានផលខាងឯសេចក្តីបរិសុទ្ធវិញ ហើយទីបំផុតនៃអំពើទាំងនោះ គឺជាជីវិតអស់កល្បជានិច្ចផង។ ដ្បិតឈ្នួលរបស់អំពើបាប នោះជាសេចក្តីស្លាប់ តែអំណោយទាននៃព្រះវិញ គឺជាជីវិតដ៏នៅអស់កល្បជានិច្ច ដោយព្រះគ្រីស្ទយេស៊ូវជាព្រះអម្ចាស់នៃយើងរាល់គ្នា។" រ៉ូម 6:21-23**

**"កុំឱ្យអ្នកណាបញ្ឆោតអ្នករាល់គ្នា ដោយពាក្យសម្ដីឥតប្រយោជន៍ឡើយ ដ្បិតគឺដោយព្រោះសេចក្តីទាំងនោះ បានជាសេចក្តីក្រោធរបស់ព្រះបានមកលើមនុស្សរឹងចចេស។" អេភេសូ 5:6**

គ្រីស្ទាន៖ ហើយតើអ្នកពេលនេះបានធ្លាក់ចុះនៅក្រោមអំណាចនៃជំនឿនេះទៀតដែរទេ?

សង្ឃឹម៖ ទេ។ ខ្ញុំមិនមានបំណងចង់ដឹងសេចក្តីទុច្ចរិតនៃអំពើបាបឡើយពេលនេះ ឬការដាក់ទោសដែលនឹងមកតាមក្រោយបន្ទាប់ពីបានប្រព្រឹត្តវានោះឡើយ ដំបូងពេលដែលគំនិតរបស់ខ្ញុំចាប់ផ្តើមរង្គើរដោយសារពាក្យនោះដើម្បីបិទភ្នែករបស់ខ្ញុំទាស់នឹងពន្លឺនោះ។

គ្រីស្ទាន៖ តែអ្វីទៅជាហេតុដែលអ្នកនាំវាមករហូតដល់កិច្ចការដំបូងរបស់ព្រះវិញ្ញាណដែលពេញដោយព្រះពររបស់ព្រះមកលើអ្នកនោះ?

សង្ឃឹម៖ ហេតុផលនោះគឺ 1. ខ្ញុំមិនដឹងថានេះជាកិច្ចការរបស់ព្រះនៅនឹងខ្ញុំ។ ខ្ញុំមិនដែលគិតថា ដោយការភ្ញាក់ដឹងខ្លួនដោយអំពើបាប ថាពីដំបូងព្រះបានចាប់ផ្ដើមនៃការប្រែចិត្តនោះទេ។ 2. អំពើបាបនៅតែផ្អែមខ្លាំងដល់ខាងរូបកាយរបស់ខ្ញុំ។ វត្តមានរបស់បាបនិងកិច្ចការទាំងនោះជាសេចក្តីប្រាថ្នាមកដល់ខ្ញុំ។ 3. ខ្ញុំមិនប្រាប់បានពីរបៀបបែងចែងចេញពីក្រុមចាស់ៗរបស់ខ្ញុំបានវត្តមាននិងទង្វើរបស់ពួកគេជាសេចក្តីប្រាថ្នារបស់ខ្ញុំ។ 4. ម៉ោងដែលការប្រែចិត្តមកដល់ខ្ញុំជាពេលពេញដោយបញ្ហាបំផុត ហើយដែលធ្វើឱ្យចិត្តភ័យញ័រយ៉ាងខ្លាំង ដែលខ្ញុំមិនអាចទ្រាំទ្របាន ទេ តែខ្ញុំមិនសូវជាចាំការទាំងនោះនៅក្នុងចិត្តខ្ញុំប៉ុន្មានទេ។

គ្រីស្ទាន៖ អីចឹង មើលទៅ ជួនកាលអ្នកដកបញ្ហារបស់អ្នកចេញបាន។

សង្ឃឹម៖ បាទ ពិតមែន។ តែវានៅតែមកកាន់គំនិតរបស់ខ្ញុំម្តងទៀត ហើយបន្ទាប់មកខ្ញុំនៅតែអាក្រក់ដដែល កាន់តែអាក្រក់ថែមជាមុនទៀតផង។

គ្រីស្ទាន៖ ហេតុអ្វីទៅ? តើអ្វីដែលនាំអំពើបាបមកកាន់គំនិតរបស់អ្នកម្តងទៀតនោះ?

សង្ឃឹម៖ មានការជាច្រើនដូចជា

1.ប្រសិនបើខ្ញុំបានជួបនឹងមនុស្សល្អណាម្នាក់នៅតាមផ្លូវ ឬ

2. ប្រសិនបើខ្ញុំបានឮនរណាម្នាក់អានព្រះគម្ពីរ ឬ

3. ប្រសិនបើក្បាលរបស់ខ្ញុំចាប់ផ្តើមឈឺ ឬ
4. ប្រសិនបើមានគេប្រាប់ខ្ញុំថា អ្នកជិតខាងខ្លះឈឺ ឬ
5. ប្រសិនបើខ្ញុំបានឮសម្លេងកន្ទឹងដែលថាអ្នកខ្លះត្រូវស្លាប់ ឬ
6. ប្រសិនបើខ្ញុំបានគិតពីការស្លាប់របស់ខ្ញុំ ឬ
7. ប្រសិនបើខ្ញុំបានឮថា សេចក្តីស្លាប់តន់ហាន់បានកើតឡើងដលអ្នកដទៃទៀត។
8. តែជាពិសេសនោះ នៅពេលដែលខ្ញុំបានគិតពីខ្លួនខ្ញុំថា ខ្ញុំនឹងត្រូវទទួលការជំនុំជំរះភ្លាមៗនោះ។

គ្រីស្ទាន៖ ហើយតើមានពេលណាដែលអ្នកអាចដោះបាបចេញដោយស្រួលទេ នៅពេលដែលផ្លូវណាមួយទាំងនេះបានមកដល់អ្នកនោះ?

សង្ឃឹម៖ ទេ មិនយូរប៉ុន្មានទេ ដោយសារបន្ទាប់មក ការទាំងនោះបានកាន់ជាប់នៅក្នុងសតិរបស់ខ្ញុំ។ ហើយបន្ទាប់មក ប្រសិនបើខ្ញុំបានគិតថាត្រឡប់ទៅអំពើបាបវិញ (បើទោះជាគំនិតរបស់ខ្ញុំត្រូវបែរទាស់នឹងវាក៏ដោយ) វានឹងធ្វើទុក្ខបុកម្នេញដល់ខ្ញុំទ្វេរដង។

គ្រីស្ទាន៖ ហើយតើអ្នកធ្វើរបៀបម៉េចទៅ?

សង្ឃឹម៖ ខ្ញុំបានគិតថាខ្ញុំត្រូវតែខិតខំពត់ជីវិតរបស់ខ្ញុំ មិនដូច្នោះទេ ខ្ញុំគិតថាខ្ញុំនឹងត្រូវវិនាសមិនខាន។

គ្រីស្ទាន៖ ហើយតើអ្នកបានខិតខំពត់ដែរទេ?

សង្ឃឹម៖ បាទបាន ហើយបានរត់គេចពីវា មិនត្រឹមតែបានរបស់ខ្ញុំប៉ុណ្ណោះ តែពីពួកដែលធ្វើបាបដែរ។ ហើយបាននាំខ្ញុំទៅតួនាទីខាងសាសនាវិញដូចជា ការអធិស្ឋាន ការអាន ការយំសោកដោយអំពើបាប ការនិយាយសេចក្ដីពិតទៅកាន់អ្នកជិតខាង និងការផ្សេងទៀត។ ការដែលខ្ញុំបានធ្វើទាំងនេះមានទំនាក់ទំនងនឹងការជាច្រើននៅទីនេះណាស់។
គ្រីស្ទាន៖ ហើយតើអ្នកបានគិតត្រឹមត្រូវដោយខ្លួនឯងដែរទេ?

សង្ឃឹម៖ បាទ បានមួយរយៈដែរ តែចុងក្រោយបញ្ហារបស់ខ្ញុំបានមកសង្កត់លើខ្ញុំម្ដងទៀត ហើយមកលើកនៃការផ្លាស់ប្រែរបស់ខ្ញុំ។

គ្រីស្ទាន៖ តើវាកើតឡើងម្ដេចទៅ កាលដែលអ្នកបានផ្លាស់ប្រែរួចហើយពេលនេះ?

សង្ឃឹម៖ មានការបីបួនដែលមកលើខ្ញុំនោះ ជាពិសេសការនិយាយដូចនេះ "គ្រប់ទាំងសេចក្ដីសុចរិតរបស់យើងដូចជាកន្ទបកខ្វក់អីចឹង។" "ដោយកិច្ចការខាងក្រឹត្យវិន័យគ្មានសាច់ឈាមណាត្រូវបានសុចរិតបានឡើយ។" "នៅពេលដែលអ្នកធ្វើគ្រប់ការទាំងអស់ស្រេចហើយ និយាយថា យើងគ្មានប្រយោជន៍អ្វីឡើយ។"

**"ដ្បិតយើងទាំងអស់គ្នាបានត្រឡប់ទៅដូចជាមនុស្ស ដែលមិនស្អាត ហើយអស់ទាំងអំពើសុចរិតរបស់យើងខ្ញុំ ក៏ដូចជាអាវកខ្វក់ហើយ យើងខ្ញុំរាល់គ្នាស្វិតក្រៀមទៅដូចជាស្លឹកឈើ ហើយអំពើទុច្ចរិតរបស់យើងខ្ញុំ ក៏ផាត់យកយើងទៅដូចជាខ្យល់។" អេសាយ 64:6**

"យើងដឹងថា មនុស្សមិនបានរាប់ជាសុចរិត ដោយប្រព្រឹត្តតាមក្រិត្យវិន័យនោះឡើយ គឺដោយសេចក្តីជំនឿ ជឿដល់ព្រះយេស៊ូវគ្រីស្ទវិញ ហេតុនោះបានជាយើងជឿដល់ព្រះយេស៊ូវគ្រីស្ទ ដើម្បីឱ្យបានរាប់ជាសុចរិត ដោយសារសេចក្តីជំនឿដល់ព្រះគ្រីស្ទ នោះមិនមែនដោយការប្រព្រឹត្តតាមក្រិត្យវិន័យទេ ពីព្រោះគ្មានមនុស្សណាបានរាប់ជាសុចរិតដោយប្រព្រឹត្យតាមក្រិត្យវិន័យឡើយ។" កាឡាទី 2:16

"អ្នករាល់គ្នាក៏ដូច្នោះដែរ កាលណាអ្នករាល់គ្នា បានធ្វើតាមបង្គាប់គ្រប់ជំពូកហើយ នោះត្រូវរាប់ថា យើងជាបាវបម្រើឥតកម្រៃដល់ម្ចាស់ទេ ដ្បិតយើងបានធ្វើត្រឹមតែការដែលយើងត្រូវធ្វើប៉ុណ្ណោះ។" លូកា 17:10

ជាមួយមនុស្សដូចនេះជាច្រើនទៀត។ ចាប់ពីពេលដែលខ្ញុំចាប់ផ្តើមរកហេតុផលជាមួយខ្លួនឯងនោះថា ប្រសិនបើសេចក្តីសុចរិតរបស់ខ្ញុំដូចជាកន្ទបកខ្វក់នោះ ប្រសិនបើតាមកិច្ចការខាងក្រឹត្យវិន័យគ្មានមនុស្សណាបានរាប់ជាសុចរិតនោះ ហើយប្រសិនបើបន្ទាប់ពីយើងបានធ្វើការគ្រប់សព្វហើយនោះយើងនៅតែមិនទទួលបានផលប្រយោជន៍អ្វីទៀត អីចឹងមានតែល្ងីល្ងើហើយដែលគិតពីស្ថានសួគ៌ដោយក្រឹត្យវិន័យនោះ។ ខ្ញុំបានគិតបន្ថែមទៀតដូចនេះថា ប្រសិនបើមនុស្សម្នាក់ជំពាក់ ១០០ដោនស៍ទៅក្នុងបំណុលរបស់អ្នកមើលថែហាងមួយ ហើយបន្ទាប់ពីគាត់បានបង់គ្រប់ចំនួនទាំងអស់រួចហើយ តែប្រសិនបើបំណុលចាស់របស់គាត់នៅតែមាននៅក្នុងបញ្ជីរមិនទាន់គូស

ចោលដដែល នោះអ្នកមើលហាងនឹងប្តឹងគាត់ ហើយបោះគាត់ចូលទៅក្នុងគុករហូតដល់គាត់នឹងសងបំណុលរួច។

គ្រីស្ទាន៖ អ៊ីចឹង តើអ្នកយកការនេះមកដាក់លើខ្លួនអ្នកយ៉ាងមិចដែរ?

សង្ឃឹម៖ ខ្ញុំបានគិតមកខ្លួនខ្ញុំដូច្នេះ ខ្ញុំមានអំពើបាបដ៏ធំនៅក្នុងបញ្ជីររបស់ព្រះ ហើយថាពេលនេះការផ្លាស់ប្រែរបស់ខ្ញុំនឹងមិនអាចសងគ្រប់ពិន្ទុដែរ។ ដូច្នេះខ្ញុំគួរតែគិតដដែល នៅក្រោមការកែប្រែរបស់ខ្ញុំពេលនេះ តែតើខ្ញុំអាចមានសេរីភាពចេញពីការដាក់ទោសដែលខ្ញុំបានយកខ្លួនទៅដាក់នៅក្នុងគ្រោះថ្នាក់ដោយសារការបះបោរពីមុនរបស់ខ្ញុំដោយរបៀបណាទៅ?

គ្រីស្ទាន៖ ធ្វើការអនុវត្តមកជីវិតបានល្អ តែសូមនិយាយបន្តទៀតមក។

សង្ឃឹម៖ ការមួយទៀតដែលធ្វើឱ្យខ្ញុំលំបាកនោះគឺ ចាប់តាំងពីការកែប្រែពីមុនរបស់ខ្ញុំមក ប្រសិនបើខ្ញុំមើលទៅលើការល្អបំផុតនូវអ្វីដែលខ្ញុំធ្វើពេលនេះ ខ្ញុំនៅតែឃើញអំពើបាប ដែលលាយឡំខ្លួនរបស់វាជាមួយនឹងការល្អបំផុតដែលខ្ញុំធ្វើ។ ដូច្នេះពេលនេះខ្ញុំត្រូវបង្ខមខ្លួនឱ្យសរុបមកថា ក្រៅពីចំណងពីដើមរបស់ខ្ញុំការបញ្ឆោតខ្លួនរបស់ខ្ញុំ និងតួនាទី នោះខ្ញុំបានធ្វើបាបមួយថ្ងៃគ្រប់គាត់នឹងបញ្ជូនខ្ញុំទៅស្ថាននរកហើយ បើទោះជាជីវិតពីដើមរបស់ខ្ញុំមិនមានកំហុសក៏ដោយ។

គ្រីស្ទាន៖ ហើយតើអ្នកធ្វើអ្វីទៅ?

សង្ឃឹមៈ ធ្វើ! ខ្ញុំមិនអាចប្រាប់បានថានឹងធ្វើអ្វីទេ រហូតដល់ខ្ញុំបានគំនិតរបស់ខ្ញុំបានគិតដល់ស្មោះត្រង់។ ដោយសារគាត់និងខ្ញុំជាអ្នកស្គាល់គ្នាច្បាស់ ហើយគាត់បានប្រាប់ខ្ញុំថា "ថាទាល់តែខ្ញុំអាចធ្វើបាននូវសេចក្ដីសុចរិតរបស់មនុស្សដែលមិនដែលធ្វើបាបសោះ នោះសេចក្ដីសុចរិតរបស់ខ្ញុំឬសេចក្ដីសុចរិតណានៅលើលោកដែលអាចសង្គ្រោះខ្ញុំបានឡើយ។"

គ្រីស្ទានៈ តើអ្នកគិតថាអ្វីដែលគាត់និយាយត្រូវទេ?

សង្ឃឹមៈ បើគាត់បានប្រាប់ខ្ញុំដូច្នេះ នៅពេលដែលខ្ញុំពេញចិត្តនិងស្កប់ស្កល់ជាមួយនឹងការផ្លាស់ប្រែរបស់ខ្ញុំ នោះខ្ញុំបានហៅគាត់ថាជាមនុស្សល្ងង់ដោយសារតែការឈឺចាប់របស់គាត់។ តែពេលនេះ ក្នុងកាលដែលខ្ញុំបានឃើញនូវជំងឺរបស់ខ្ញុំ និងអំពើបាបដែលជ្រែកចូលនៅក្នុងការប្រព្រឹត្តដ៏ល្អបំផុតរបស់ខ្ញុំ ខ្ញុំត្រូវបានបង្ខំឱ្យគិតដូចជាគំនិតរបស់គាត់ដែរ។

គ្រីស្ទានៈ តែតើអ្នកគិតថា ពីដំបូងដែលគាត់ប្រាប់ការនោះដល់អ្នក ថាមានមនុស្សណាដែលនឹងរកឃើញថាគាត់ជាមនុស្សដែលគេនិយាយថាសុចរិតដែលគាត់មិនដែលធ្វើបាបសោះដែរទេ?

សង្ឃឹមៈ ខ្ញុំត្រូវសារភាពថាពាក្យនោះស្ដាប់ទៅដូចជាចម្លែកពីដំបូងឡើយ តែបន្ទាប់ពីនិយាយគ្នាបន្តិតមកហើយបានដើរជាមួយគាត់ ខ្ញុំក៏បានជឿលើការនោះដែរ។

គ្រីស្ទានៈ ហើយតើអ្នកបានសួរថាបុរសនោះជានរណា ហើយតើអ្នកអាចរាប់ជាសុចរិតដោយសារគាត់បានដោយរបៀបណាទៅ?

សង្ឃឹមះ បាទបាន។ គាត់បានប្រាប់ខ្ញុំថា នោះគឺព្រះអម្ចាស់ព្រះយេស៊ូវ ដែលទ្រង់គង់នៅខាងស្តាំដៃរបស់ព្រះដ៏ខ្ពស់បំផុត។

“” ហេព្រើរ 10:11-18

““បើដូច្នេះ យើងនឹងថា លោកអ័ប្រាហាំ ជាអយ្យកោយើង បានអ្វីខ្លះ ខាងឯសាច់ឈាម។ ដ្បិតបើសិនណាជាលោកអ័ប្រាហាំបានរាប់ជាសុចរិត ដោយការដែលលោកប្រព្រឹត្ត នោះលោកមានកន្លែងនឹងអួតខ្លួនហើយ តែមិនមែនចំពោះព្រះទេ។ តើគម្ពីរថាដូចម្តេច គម្ពីរថា “អ័ប្រាហាំបានជឿដល់ព្រះ ហើយសេចក្តីជំនឿនោះ បានរាប់ជាសេចក្តីសុចរិតដល់លោក”។ រីឯអ្នកណាដែលធ្វើការ នោះរង្វាន់មិនរាប់ជាគុណរបស់ថៅហ្វាយទេ គឺទុកជាថ្លៃឈ្នួលវិញទេតើ។ តែចំណែកអ្នកដែលមិនធ្វើការសោះ គឺគ្រាន់តែជឿដល់ព្រះអង្គ ដែលទ្រង់ប្រោសឱ្យមនុស្សទមិឡល្មើសបានសុចរិត នោះសេចក្តីជំនឿរបស់អ្នកនោះ បានរាប់ទុកជាសេចក្តីសុចរិតវិញ។ ដូចជាហ្លួងដាវីឌបានសម្តែងពីសណ្ឋានដ៏មានពរនៃមនុស្ស ដែលព្រះទ្រង់រាប់ជាសុចរិតក្រៅពីការប្រព្រឹត្តថា “មានពរហើយ អ្នកណាដែលការទទឹងច្បាប់របស់ខ្លួនបានអត់ទោសឱ្យ និងបាបខ្លួនបានគ្របបាំង”។ មានពរហើយ មនុស្សណាដែលព្រះអម្ចាស់មិនរាប់ជាមានបាបឡើយ។ដូច្នេះ តើបានពរនោះ ចំពោះតែពួកកាត់ស្បែកតែប៉ុណ្ណោះ ឬពួកមិនកាត់ស្បែកក៏បានដែរ ដ្បិតយើងថាសេចក្តីជំនឿ បានរាប់ទុកជាសេចក្តីសុចរិត ដល់លោកអ័ប្រាហាំ។ ចុះសេចក្តីនោះបានរាប់ដូចម្តេច តើពីកាលលោកបានកាត់ស្បែករួចហើយ ឬនៅឡើយ មិនមែនពីកាលលោកបានកាត់ស្បែកហើយនោះទេ គឺក្នុងកាលដែលមិនទាន់កាត់ស្បែកនៅឡើយវិញ។ ហើយលោកបានទទួលពិធីកាត់ស្បែកនេះ ទុកជាទីសម្គាល់ ជាត្រានៃសេចក្តី

សុចរិត ដែលមកដោយសេចក្ដីជំនឿនោះឯង គឺជាសេចក្ដីជំនឿដែលលោក មានពីកាលមិនទាន់កាត់ស្បែកនៅឡើយ ដើម្បីឱ្យបានធ្វើជាឪពុក ដល់អស់ អ្នកដែលជឿ ឥតកាត់ស្បែកផង ប្រយោជន៍ឱ្យបានរាប់សេចក្ដីសុចរិតនេះដល់ អ្នកទាំងនោះ។ ហើយឱ្យបានធ្វើជាឪពុក ដល់ពួកដែលមិនគ្រាន់តែកាត់ស្បែក ប៉ុណ្ណោះ គឺដែលដើរតាមដាននៃសេចក្ដីជំនឿរបស់លោកអ័ប្រាហាំ ជា អយ្យកោយើងផង ជាសេចក្ដីជំនឿដែលលោកមាន ពីកាលមិនទាន់កាត់ ស្បែកនៅឡើយ។ ដ្បិតសេចក្ដីសន្យាដល់លោកអ័ប្រាហាំ និងពូជលោក ឱ្យ បានលោកីយ៍ជាមរដក នោះមិនមែនដោយសារក្រឹត្យវិន័យទេ គឺដោយសារ សេចក្ដីសុចរិតដែលមកដោយសេចក្ដីជំនឿវិញ។ ពីព្រោះបើសិនជាពួកអ្នក ដែលអាងក្រឹត្យវិន័យបានគ្រងមរដក នោះសេចក្ដីជំនឿបានទៅជាឥតអំពើ វិញ ហើយសេចក្ដីសន្យាក៏ឥតប្រយោជន៍ដែរ។ ឯក្រឹត្យវិន័យ នោះបង្កើត សេចក្ដីក្រោធ ដ្បិតកន្លែងណាដែលគ្មានក្រឹត្យវិន័យ នោះក៏ឥតមានសេចក្ដី រំលងដែរ។ ដូច្នេះ សេចក្ដីសន្យាបានមកដោយសេចក្ដីជំនឿ ដើម្បីឱ្យបានត្រូវ ខាងព្រះគុណ ប្រយោជន៍ឱ្យសេចក្ដីសន្យាបានខ្ជាប់ខ្ជួន ដល់ពូជលោកតទៅ មិនមែនត្រឹមតែពូជដែលអាងក្រឹត្យវិន័យប៉ុណ្ណោះ គឺដល់ទាំងពូជដែលអាង សេចក្ដីជំនឿរបស់លោកអ័ប្រាហាំ ដែលជាអយ្យកោនៃយើងទាំងអស់គ្នាថែម ទៀតផង។ ដូចមានសេចក្ដីចែងទុកមកថា អញបានតាំងឯងឱ្យធ្វើជាឪពុក ដល់សាសន៍ជាច្រើន រីឯនៅចំពោះព្រះ ជាទីជឿរបស់លោក ដែលទ្រង់ប្រោស មនុស្សស្លាប់ឱ្យរស់ឡើងវិញ ទាំងមានព្រះបន្ទូលពីរបស់ដែលគ្មាន ទុកដូចជា មានហើយ នោះលោកជាឪពុករបស់យើងមែន។ ដ្បិតកាលលោកអស់ទី សង្ឃឹមហើយ នោះក៏ចេះតែជឿដោយសង្ឃឹមវិញ ដើម្បីឱ្យបានត្រឡប់ជា ឪពុកដល់សាសន៍ជាច្រើន ដូចសេចក្ដីដែលមានព្រះបន្ទូលទុកមកថា «ពូជ

ឯងនឹងបានដូច្នោះ។ ហើយដោយព្រោះលោកមិនខ្សោយខាងសេចក្តីជំនឿ បានជាលោកមិនគិតពីរូបកាយលោក ដែលរាប់ដូចជាស្លាប់ ដោយមានអាយុប្រហែលជា១០០ឆ្នាំហើយ ឬពីផ្ទៃសារ៉ា ដែលរាប់ដូចជាស្លាប់ដែរនោះទេ។ លោកក៏មិនបានសង្ស័យចំពោះសេចក្តីសន្យារបស់ព្រះ ដោយចិត្តមិនជឿឡើយ គឺរឹតតែមានសេចក្តីជំនឿខ្លាំងឡើង ទាំងសរសើរតម្កើងដល់ព្រះវិញ។ ហើយក៏ជឿជាក់អស់ពីចិត្តថា សេចក្តីអ្វីដែលទ្រង់សន្យា នោះអាចនឹងធ្វើឱ្យសម្រេចបាន។ ហេតុនោះបានជារាប់សេចក្តីជំនឿរបស់លោក ទុកជាសេចក្តីសុចរិតដល់លោក។ ប៉ុន្តែ ដែលថា បានរាប់ដល់លោក។ ដូច្នេះ នោះមិនចែងទុកមកសម្រាប់លោកតែឯងទេ˝

˝រ៉ូម 4:1-23

"ហេតុនោះ ចាប់តាំងពីថ្ងៃ ដែលយើងខ្ញុំឮនិយាយ នោះយើងខ្ញុំក៏អធិស្ឋានឱ្យអ្នករាល់គ្នាឥតឈប់ឈរ ហើយទូលសូម ឱ្យអ្នករាល់គ្នាបានស្គាល់ព្រះហឫទ័យទ្រង់សព្វគ្រប់ ដោយគ្រប់ទាំងប្រាជ្ញា និងចំណេះខាងវិញ្ញាណ។ ដើម្បីឱ្យបានដើរបែបគួរនឹងព្រះអម្ចាស់ ទាំងគាប់ចិត្តដល់មនុស្សទាំងអស់ ឱ្យបានបង្កើតផលក្នុងគ្រប់ទាំងការល្អ ហើយឱ្យស្គាល់ព្រះកាន់តែច្បាស់ឡើង។ ដោយបានគ្រប់ទាំងព្រះចេស្តាចម្រើនកម្លាំង តាមឫទ្ធិបារមីដ៏ឧត្តមរបស់ទ្រង់ ដើម្បីឱ្យបានចេះទ្រាំទ្រ ហើយអត់ធន់គ្រប់យ៉ាងដោយអំណរ។ ព្រមទាំងអរព្រះគុណ ដល់ព្រះវរបិតាដែលទ្រង់បានប្រោស ឱ្យយើងបានគួរនឹងទទួលចំណែកកេរអាករ ក្នុងពួកបរិសុទ្ធនៅទីភ្លឺផង។ ទ្រង់បានប្រោសឱ្យយើងរួចពីអំណាចនៃសេចក្តីងងឹត ហើយផ្លាស់យើងមកក្នុងនគររបស់ព្រះរាជបុត្រាស្ងួនភ្ងានៃទ្រង់។ យើងរាល់គ្នាមានសេចក្តីប្រោសលោះក្នុងព្រះរាជ

បុត្រានោះ គឺជាសេចក្ដីផ្ដាច់បាប ដោយសារព្រះលោហិតទ្រង់។ ដែលទ្រង់ជារូបអង្គ នៃព្រះដ៏មើលមិនឃើញ ជាបងច្បងនៃគ្រប់ទាំងអស់ ដែលព្រះបានបង្កើតមក។ ដ្បិតគឺទ្រង់ហើយ ដែលបង្កើតគ្រប់ទាំងអស់ ទាំងរបស់នៅស្ថានសួគ៌ និងនៅផែនដី ទាំងរបស់ដែលមើលឃើញ ហើយដែលមើលមិនឃើញផង ទោះបើជារាជ្យ ឬអំណាចជាព្រះអម្ចាស់ ឬអំណាចគ្រប់គ្រង ឬអំណាចណាក៏ដោយ នោះសុទ្ធតែកើតមកដោយសារទ្រង់ ហើយសម្រាប់ទ្រង់ទាំងអស់ផង។ ទ្រង់គង់នៅមុនទាំងអស់ ហើយរបស់ទាំងអស់ក៏ស្ថិតស្ថេរ ដោយសារទ្រង។ ទ្រង់ជាសិរសាររបស់រូបកាយ គឺជាពួកជំនុំ ទ្រង់ជាដើម ក៏បានរស់ពីស្លាប់ឡើងវិញមុនគេបង្អស់ ដើម្បីឱ្យទ្រង់បានជាប្រធានក្នុងគ្រប់ទាំងអស់។ ដ្បិតព្រះបានសព្វព្រះហឫទ័យ ឱ្យគ្រប់ទាំងសេចក្តីពោរពេញបានស្ថិតនៅក្នុងទ្រង់។ ហើយឱ្យបានផ្សះផ្សាគ្រប់ទាំងអស់ ឱ្យជានឹងអង្គទ្រង់ ដោយសារព្រះរាជបុត្រានោះ ទោះបើរបស់នៅស្ថានសួគ៌ ឬនៅផែនដីក្តី ទាំងតាំងស្ពានមេត្រី ដោយសារព្រះលោហិតនៃឈើឆ្កាងទ្រង់។ រីឯអ្នករាល់គ្នា ដែលពីដើមត្រូវពង្រាត់ចេញ ហើយជាខ្មាំងសត្រូវក្នុងគំនិត ដោយអំពើអាក្រក់នោះ។ ឥឡូវនេះវិញ ទ្រង់បានផ្សះផ្សាក្នុងរូបសាច់ទ្រង់ ដោយបានទទួលសុគត ដើម្បីនឹងថ្វាយអ្នករាល់គ្នាជាតង្វាយបរិសុទ្ធ ឥតសៅហ្មង ហើយឥតកន្លែងបន្ទោសបាន នៅចំពោះទ្រង់។ នោះគឺបើតិចណាស់ អ្នករាល់គ្នាបានតាំងនៅជាប់លាប់ ហើយមាំមួន ក្នុងសេចក្តីជំនឿដែរ ឥតងាកបែរចេញពីសេចក្តីសង្ឃឹមរបស់ដំណឹងល្អ ដែលអ្នករាល់គ្នាបានឮ ជាដំណឹងដែលបានផ្សាយ ទៅដល់គ្រប់ទាំងមនុស្ស ដែលកើតក្រោមមេឃផង ឯប៉ុលខ្ញុំ ជាអ្នកបម្រើចំពោះដំណឹងល្អនោះដែរ។″ កូឡុស 1:9-23

"សូមសរសើរដល់ព្រះដ៏ជាព្រះវរបិតានៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា ដែលទ្រង់បានបង្កើតយើងឡើងជាថ្មី តាមសេចក្តីមេត្តាករុណាដ៏ធំរបស់ទ្រង់ ដើម្បីឱ្យយើងរាល់គ្នាបានសេចក្តីសង្ឃឹមដ៏រស់ ដោយសារព្រះយេស៊ូវគ្រីស្ទ ទ្រង់រស់ពីស្លាប់ឡើងវិញ។ ហើយឱ្យយើងបានមរដក ដែលមិនចេះពុករលួយ ក៏ឥតសៅហ្មង ហើយមិនដែលស្រពោនឡើយ ជាមរដកដែលបម្រុងទុកឱ្យយើងរាល់គ្នានៅស្ថានសួគ៌។ គឺឱ្យយើងរាល់គ្នា ដែលព្រះចេស្តានៃព្រះកំពុងតែថែរក្សា ដោយសារសេចក្តីជំនឿ សម្រាប់ឱ្យបានសេចក្តីសង្គ្រោះ ដែលប្រុងប្រៀបនឹងសម្តែងមកនៅជាន់ក្រោយបង្អស់នោះ។ អ្នករាល់គ្នាក៏មានសេចក្តីអំណរជាខ្លាំង ក្នុងសេចក្តីសង្គ្រោះនោះ ទោះបើសព្វថ្ងៃនេះត្រូវរងទុក្ខព្រួយជាយូរបន្តិច ដោយកើតមានសេចក្តីល្បួងផ្សេងៗក៏ដោយ" ពេត្រុសទី១ 1:3-6

"ហើយដូច្នេះ" គាត់បាននិយាយថា "អ្នកនឹងត្រូវរាប់ជាសុចរិតដោយសារទ្រង់ទាំងដោយការទុកចិត្តលើអ្វីដែលទ្រង់បានធ្វើដោយអង្គទ្រង់ផ្ទាល់កាលទ្រង់នៅជាសាច់ឈាម ហើយត្រូវបានរងទុក្ខនៅពេលដែលទ្រង់ត្រូវបានគេព្យួរនៅលើដើមឈើផង។" ខ្ញុំបានសួរគាត់បន្តទៀតថា "តើសេចក្តីសុចរិតរបស់បុរសនោះមានឥទ្ធិពលអ្វីមករាប់អ្នកផ្សេងទៀតឱ្យបានសុចរិតនៅចំពោះព្រះបានដោយរបៀបណាទៅ?" ហើយគាត់ប្រាប់ថា "ទ្រង់ជាព្រះដែលមានគ្រប់ចេស្តា ហើយទ្រង់បានធ្វើអ្វីដែលទ្រង់ធ្វើនោះហើយ ហើយទ្រង់បានសុគតផងមិនមែនសម្រាប់អង្គទ្រង់ផ្ទាល់ទេ តែសម្រាប់ខ្ញុំ ដែលកិច្ចការដែលទ្រង់ធ្វើ

និងគុណសម្បត្តិទាំងអស់របស់ទ្រង់ នឹងត្រូវផ្ដល់មកក្នុងខ្ញុំ ប្រសិនបើខ្ញុំជឿដល់ទ្រង់។"

គ្រីស្ទាន៖ តើអ្នកបានធ្វើអ្វីទៅចឹង?

សង្ឃឹម៖ ខ្ញុំធ្វើការជំទាស់នឹងការជឿរបស់ខ្ញុំ ដោយសារខ្ញុំគិតថាទ្រង់នឹងមិនសង្គ្រោះនោះឡើយ។

គ្រីស្ទាន៖ ហើយតើស្មោះត្រង់បាននិយាយអ្វីមកកាន់អ្នក?

សង្ឃឹម៖ គាត់ប្រាប់ខ្ញុំឱ្យទៅរកទ្រង់ ហើយមើលទៅ។ បន្ទាប់មកខ្ញុំនិយាយថា "វាជាការសន្មត់" តែគាត់និយាយថា "ទេ ដោយសារខ្ញុំត្រូវបានអញ្ជើញឱ្យមក។"

**"អស់អ្នកដែលនឿយព្រួយ ហើយផ្ទុកធ្ងន់អើយ ចូរមកឯខ្ញុំ ខ្ញុំនឹងឱ្យអ្នករាល់គ្នាឈប់សម្រាក" ម៉ាថាយ 11:28**

បន្ទាប់មកគាត់បានឱ្យសៀវភៅនៃការបញ្ចុះបញ្ចូលរបស់ព្រះយេស៊ូវ ដើម្បីជម្រុញខ្ញុំឱ្យមកដោយសេរី ហើយគាត់បាននិយាយទាក់ទងនឹងសៀវភៅនោះថាគ្រប់ទាំងចំណុចតូចមួយនិងចំណាងជើងវានៅតែឈរមាំមួនជាងផ្ទៃមេឃនិងផែនដីផង។

"ផ្ទៃមេឃ ហើយផែនដីនឹងកន្លងបាត់ទៅ តែពាក្យខ្ញុំមិនដែលបាត់ឡើយ។" **ម៉ាថាយ 24:35**

បន្ទាប់មកខ្ញុំបានសួរគាត់ នូវអ្វីដែលខ្ញុំត្រូវធ្វើនៅពេលដែលខ្ញុំមក ហើយគាត់បានប្រាប់ខ្ញុំថា ខ្ញុំត្រូវទូលអង្វរដោយលត់ជង្គង់ជាមួយចិត្តនិងព្រលឹងរបស់ខ្ញុំទៅកាន់ព្រះវរបិតាឱ្យបានបើកសម្តែងដល់ខ្ញុំ។

"មកចុះ ចូរយើងឱនកាយថ្វាយបង្គំទាំងអស់គ្នា ចូរយើងលុតជង្គង់នៅចំពោះព្រះយេហូវ៉ា ជាព្រះដ៏បង្កើតយើងខ្ញុំ" **ទំនុកដំកើង 95:6**

"កាលដានីយ៉ែលបានដឹងថា សំបុត្រនោះបានចុះហត្ថលេខាហើយ នោះលោកក៏ចូលទៅក្នុងផ្ទះរបស់លោក (រីឯបង្អួចនៃបន្ទប់របស់លោក ខាងក្រុងយេរូសាឡឹម ក៏នៅចំហ) លោកលុតជង្គង់ចុះអធិស្ឋាន ហើយអរព្រះគុណដល់ព្រះរបស់លោក១ថ្ងៃ៣ដង ដូចជាកាលពីមុន" **ដានីយ៉ែល 6:10**

"នោះឯងរាល់គ្នានឹងអំពាវនាវដល់អញ ហើយនិងទៅអធិស្ឋានដល់អញ រួចអញនឹងយល់ព្រមតាម។ ឯងរាល់គ្នានឹងស្វែងរកអញ ហើយនិងឃើញផង គឺកាលណាឯងស្វែងរកអញឱ្យអស់អំពីចិត្ត" **យេរេមា 29:12, 13**

បន្ទាប់មកខ្ញុំបានសួរគាត់ថែមទៀតថា "តើខ្ញុំត្រូវធ្វើការទូលអង្វរដល់ទ្រង់យ៉ាងដូចម្តេច?" ហើយគាត់និយាយថា "ចូរទៅ នោះអ្នកនឹងរកឃើញទ្រង់

នៅលើបល័ង្កនៃសេចមេត្តា ដែលទ្រង់បានអង្គុយរាប់ឆ្នាំដើម្បីនឹងផ្តល់ការ
លើកលែងនិងការអត់ទោសដល់អស់អ្នកដែលមករកទ្រង់។”

“គឺនៅទីនោះហើយដែលអញនឹងមកជួបនឹងឯង ហើយនិងនិយាយនឹងឯងពីលើទីសន្តោសប្រោស នៅកណ្តាលចេរូប៊ីនទាំង២ដែលនៅលើហឹបនៃទីបន្ទាល់ ដើម្បីប្រាប់ឯងពីអស់ទាំងសេចក្តីដែលអញនឹងបង្គាប់ដល់ពួកកូនចៅអ៊ីស្រាអែល។” និក្ខមនំ 25:22

“គឺទ្រង់មានព្រះបន្ទូលនឹងម៉ូសេថា ចូរហាមដល់អើរ៉ុនបងឯង កុំឱ្យចូលជារាល់ពេលមកក្នុងទីបរិសុទ្ធខាងក្នុងវាំងនន នៅមុខទីសន្តោសប្រោសដែលនៅលើហឹបនោះឡើយ ក្រែងលោត្រូវស្លាប់ ដ្បិតអញនឹងលេចមកក្នុងពពកនៅលើទីសន្តោសប្រោស” លេវីវិន័យ 16:2

“រួចកាលម៉ូសេបានចូលទៅទូលនឹងព្រះ ក្នុងត្រសាលជំនុំ នោះលោកឮសំឡេងមានព្រះបន្ទូលមកពីលើទីសន្តោសប្រោស ដែលនៅលើហឹបនៃសេចក្តីបន្ទាល់ គឺពីកណ្តាលចេរូប៊ីនទាំង២ ហើយលោកក៏ទូលតបនឹងទ្រង់។” ជនគណនា 7:89

“ដូច្នេះ ត្រូវឱ្យយើងរាល់គ្នាមកដល់បល្ល័ង្កនៃព្រះគុណ ដោយក្លាហាន ដើម្បីនឹងទទួលសេចក្តីមេត្តា ហើយរកបានព្រះគុណសម្រាប់នឹងជួយដល់ពេលត្រូវការចុះ។” ហេព្រើរ 4:16

ខ្ញុំបានប្រាប់គាត់ថា ខ្ញុំមិនដឹងនិយាយអ្វីទេនៅពេលដែលខ្ញុំមក ហើយគាត់បានប្រាប់ខ្ញុំឱ្យនិយាយបែបនេះថា "សូមឱ្យព្រះបានមេត្តាដល់ខ្ញុំជាមនុស្សមានបាបម្នាក់ ហើយសូមធ្វើឱ្យខ្ញុំបានដឹងនិងជឿដល់ព្រះយេស៊ូវគ្រីស្ទ ដោយសារខ្ញុំឃើញថា ប្រសិនបើគ្មានសេចក្តីសុចរិតរបស់ទ្រង់ទេ ឬថាបើខ្ញុំមិនមានសេចក្តីជំនឿនៅក្នុងសេចក្តីសុចរិតនោះទេ ខ្ញុំនឹងត្រូវបោះបង់ចោលជាមិនខាន។ ព្រះអម្ចាស់អើយ ខ្ញុំបានឮថាទ្រង់ជាព្រះពេញដោយសេចក្តីមេត្តាករុណា ហើយដែលទ្រង់បានតាំងបុត្រារបស់ទ្រង់ព្រះយេស៊ូវគ្រីស្ទជាព្រះអង្គសង្គ្រោះនៃលោកិយនេះទាំងមូល ហើយលើសពីនោះទៀតថា ទ្រង់នឹងថ្វាយដោយពេញចិត្តដល់មនុស្សមានបាបកំសត់នេះដូចជាខ្ញុំ (ហើយខ្ញុំជាមនុស្សមានបាបពិត)។ ព្រះអម្ចាស់អើយ សូមយកឱកាសនេះ ហើយបង្ហាញព្រះគុណរបស់ទ្រង់នៅក្នុងសេចក្តីសង្គ្រោះនៃព្រលឹងរបស់ទូលបង្គំតាមរយៈបុត្រារបស់ទ្រង់ព្រះយេស៊ូវគ្រីស្ទ។ អាម៉ែន។"

គ្រីស្ទាន៖ ហើយតើអ្នកបានធ្វើដូចដែលអ្វីដែលអ្នកបានប្រាប់មកទេ?

សង្ឃឹម៖ បាតបាន ធ្វើហើយធ្វើទៀត។

គ្រីស្ទាន៖ ហើយតើព្រះវរបិតាបានបង្ហាញព្រះរាជបុត្រាដល់អ្នកទេ?

សង្ឃឹម៖ ទេ ពីដំបូងអត់ទេ ក៏មិនមែនទីពីរ មិនមែនទីបី មិនមែនទីបួន មិនមែនទីប្រាំ មិនមែនទីប្រាំមួយដូចគ្នា។

គ្រីស្ទាន៖ តើអ្នកធ្វើអ្វីទៅអីចឹង?

សង្ឃឹម៖ អ្វី? ខ្ញុំមិនអាចប្រាប់ថានឹងធ្វើអ្វីនោះឡើយ។

គ្រីស្ទាន៖ តើអ្នកមិនមានគំនិតនឹងបោះបង់ចោលការអធិស្ឋានទេឬអី?

សង្ឃឹម៖ បាទ ហើយបានប្រាប់មួយរយដងទ្វេផង។

គ្រីស្ទាន៖ ហើយតើអ្វីទៅជាហេតុផលដែលអ្នកមិនបោះបង់ចោលនោះ?

សង្ឃឹម៖ ខ្ញុំបានជឿថាវាជាការពិតដូចដែលគេបានប្រាប់ខ្ញុំមកមែន។ ថាក្រៅពីសេចក្តីសុចរិតរបស់ព្រះគ្រីស្ទនេះ នោះលោកិយទាំងមូលមិនអាចសង្គ្រោះខ្ញុំបានឡើយ។ ហើយដូច្នេះ ខ្ញុំគិតមកខ្លួនខ្ញុំថា ប្រសិនបើខ្ញុំមិនធ្វើ ខ្ញុំនឹងស្លាប់។ ហើយខ្ញុំអាចស្លាប់បានតែនៅនឹងបល្ល័ង្កនៃព្រះគុណប៉ុណ្ណោះ។ ដោយការទាំងអស់នេះមកដល់គំនិតរបស់ខ្ញុំថា "ប្រសិនបើខ្ញុំរង់ចាំ រងចាំវា ពីព្រោះវានឹងមកមែនពិត និងមិនរងចាំឡើយ។"

**"ដ្បិតការជាក់ស្តែងនេះ ទុកសម្រាប់ដល់វេលាកំណត់ ក៏កំពុងស្រូតឱ្យដល់ពេលនោះហើយ នៅគ្រានោះ នឹងមិនកុហកទេ បើសិនជាបង្អង់យូរ ក៏ចូររង់ចាំចុះ ដ្បិតនឹងមកជាពិត ឥតរារង់ឡើយ។" ហាបាគុក 2:3**

ដូច្នេះខ្ញុំបន្តអធិស្ឋានរហូតដល់ព្រះវរបិតាបង្ហាញព្រះរាជបុត្រាដល់ខ្ញុំ។

គ្រីស្ទាន៖ ហើយតើត្រូវបានបង្ហាញមកអ្នកយ៉ាងម៉េចទៅ?

សង្ឃឹមៈ ខ្ញុំមិនបានឃើញទ្រង់ដោយភ្នែកខាងរូបកាយរបស់ខ្ញុំឡើយ តែដោយភ្នែកនៃការយល់ដឹងរបស់ខ្ញុំវិញ។

"ដើម្បីឱ្យភ្នែកចិត្តរបស់អ្នករាល់គ្នាបានភ្លឺឡើង ប្រយោជន៍ឱ្យបានដឹងថា ដែលទ្រង់ហៅអ្នករាល់គ្នា នោះមានសេចក្តីសង្ឃឹមជាយ៉ាងណា ហើយថា សិរីល្អដ៏ប្រសើរក្រៃលែងនៃមរដកទ្រង់ ក្នុងពួកបរិសុទ្ធជាយ៉ាងណាផង។ ហើយថា ព្រះចេស្តាដ៏ខ្លាំងលើសលន់របស់ទ្រង់ ដល់យើងរាល់គ្នាដែលជឿជាយ៉ាងណាដែរ តាមដែលកម្លាំងទ្រង់ដ៏មានឫទ្ធិបានពូកែនឹងធ្វើ" **អេភេសូ 1:18, 19**

ហើយវាដូច្នោះឯង។ ថ្ងៃមួយខ្ញុំសោកសៅពេក ខ្ញុំគិតថាសោកសៅជាងពេលណាទាំងអស់នៅក្នុងជីវិតរបស់ខ្ញុំ ហើយសេចក្តីសោកសៅនេះតាមរយៈ ការដែលឃើញថ្មីៗនៃភាពសម្បើមនិងភាពអប្រិយនៃបាបរបស់ខ្ញុំ។ ហើយកាលដែលខ្ញុំមិនឃើញអ្វីទាំងអស់ក្រៅពីស្ថាននរក និងការដាក់ទោសអស់កល្បជានិច្ចនៃព្រលឹងរបស់ខ្ញុំភ្លាមនោះក្នុងកាលដែលខ្ញុំគិតនោះ ខ្ញុំបានឃើញព្រះអម្ចាស់យេស៊ូវបានមើលមកក្រោមពីស្ថានសួគ៌មើលមកខ្ញុំហើយនិយាយថា "ចូរជឿដល់ព្រះយេស៊ូវគ្រីស្ទ នោះអ្នកនឹងបានសង្គ្រោះ។"

"គេក៏ប្រាប់គាត់ថា ចូរជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទទៅ នោះនឹងបានសង្គ្រោះហើយ ព្រមទាំងពួកគ្រួសារលោកផង" **កិច្ចការ 16:31**

តែខ្ញុំបានឆ្លើយថា "ព្រះអម្ចាស់អើយ ខ្ញុំជាមនុស្សដ៏មានបាបខ្លាំងណាស់" ហើយទ្រង់ឆ្លើយថា "ព្រះគុណរបស់ខ្ញុំគ្រប់គ្រាន់ដល់ឯងហើយ។"

**"តែទ្រង់មានព្រះបន្ទូលមកខ្ញុំថា គុណរបស់អញល្មមដល់ឯងហើយ ដ្បិតកម្លាំងអញបានពេញខ្នាត ដោយសេចក្តីកំសោយ ដូច្នេះ ខ្ញុំនឹងស៊ូអួតពីសេចក្តីកំសោយរបស់ខ្ញុំ ដោយអំណរជាខ្លាំង ដើម្បីឱ្យព្រះចេស្តានៃព្រះគ្រីស្ទបានសណ្ឋិតនៅនឹងខ្ញុំ" កូរិនថូសទី២ 12:9**

បន្ទាប់មកខ្ញុំនិយាយថា "តែព្រះអម្ចាស់អើយ តើជឿអ្វីទៅ" ហើយបន្ទាប់មកខ្ញុំបានឃើញថានិយាយដូច្នេះ "អ្នកណាដែលមកឯខ្ញុំនឹងមិនត្រូវឃ្លានឡើយ ហើយអ្នកណាដែលជឿដល់ខ្ញុំនិងមិនត្រូវស្រេកឡើយ។"

**"ព្រះយេស៊ូវមានព្រះបន្ទូលថា ខ្ញុំជានំប៉័ងជីវិត អ្នកណាដែលមកឯខ្ញុំ នោះនឹងមិនឃ្លានទៀតឡើយ ហើយអ្នកណាដែលជឿដល់ខ្ញុំ ក៏មិនត្រូវស្រេកដែរ" យ៉ូហាន 6:35**

ថាការជឿនិងមកតែមួយទេ ហើយអ្នកដែលមក នោះគឺរត់ចេញនៅក្នុងចិត្តនិងសេចក្តីស្រឡាញ់របស់គាត់នូវសេចក្តីសង្គ្រោះដោយព្រះគ្រីស្ទ នោះគាត់ជាអ្នកជឿដល់ព្រះគ្រីស្ទពិត។ បន្ទាប់មកទឹលបានបញ្ឈរនៅក្នុងភ្នែករបស់ខ្ញុំ ហើយខ្ញុំបានសួរថែមទៀតថា "តែ ព្រះអម្ចាស់អើយ តើមនុស្សមានបាបខ្លាំង

ដូចជាខ្ញុំនឹងត្រូវបានទទួលនៅចំពោះទ្រង់ និងបានសង្គ្រោះដែរទេ?" ហើយខ្ញុំបានឮទ្រង់មានបន្ទូលថា "ហើយអ្នកណាដែលមករកខ្ញុំ ខ្ញុំនឹងមិនបោះបង់ចោលឡើយ។"

**"អស់អ្នកណាដែលព្រះវរបិតាប្រទានមកខ្ញុំ នោះនឹងមកឯខ្ញុំ ហើយអ្នកណាដែលមកឯខ្ញុំ ខ្ញុំក៏មិនដែលចោលទៅក្រៅឡើយ" យ៉ូហាន 6:37**

បន្ទាប់មកខ្ញុំនិយាយថា "ព្រះអម្ចាស់អើយ តើខ្ញុំត្រូវគិតដល់ទ្រង់ពេលដែលខ្ញុំមករកទ្រង់ដូចម្តេច ថាសេចក្តីជំនឿខ្ញុំនឹងនៅកន្លែងដែលត្រឹមត្រូវចំពោះទ្រង់នោះ?" បន្ទាប់មកទ្រង់មានបន្ទូលថា "ព្រះយេស៊ូវគ្រីស្ទយាងមកលើលោកិយនេះដើម្បីសង្គ្រោះមនុស្សមានបាប។"

**"ពាក្យនេះគួរជឿ ហើយគួរទទួលគ្រប់យ៉ាង គឺថា ព្រះគ្រីស្ទយេស៊ូវទ្រង់បានយាងមកក្នុងលោកីយ៍ ដើម្បីនឹងជួយសង្គ្រោះមនុស្សមានបាប ដែលខ្ញុំនេះជាលេខ១ក្នុងពួកគេ" ធីម៉ូថេទី១ 1:15**

"ទ្រង់ជាចុងបញ្ចប់នៃក្រិត្យវិន័យសម្រាប់សេចក្តីសុចរិតដល់គ្រប់គ្នាដែលជឿ។"

**"បើដូច្នេះ យើងនឹងថា លោកអ័ប្រាហាំ ជាអយ្យកោយើង បានអ្វីខ្លះ ខាងឯសាច់ឈាម។ ដ្បិតបើសិនណាជាលោកអ័ប្រាហាំបានរាប់ជាសុចរិត ដោយការដែលលោកប្រព្រឹត្ត នោះលោកមានកន្លែងនឹងអួតខ្លួនហើយ តែមិនមែន**

ចំពោះព្រះទេ។ តើគម្ពីរថាដូចម្ដេច គម្ពីរថា "អ័ប្រាហាំបានជឿដល់ព្រះ ហើយសេចក្ដីជំនឿនោះ បានរាប់ជាសេចក្ដីសុចរិតដល់លោក"។ រីឯអ្នកណាដែលធ្វើការ នោះរង្វាន់មិនរាប់ជាគុណរបស់ចៅហ្វាយទេ គឺទុកជាថ្លៃឈ្នួលវិញទេតើ។ តែចំណែកអ្នកដែលមិនធ្វើការសោះ គឺគ្រាន់តែជឿដល់ព្រះអង្គ ដែលទ្រង់ប្រោសឱ្យមនុស្សទមិឡល្មើសបានសុចរិត នោះសេចក្ដីជំនឿរបស់អ្នកនោះ បានរាប់ទុកជាសេចក្ដីសុចរិតវិញ។ ដូចជាហ្លួងដាវីឌបានសម្ដែងពីសណ្ឋានដ៏មានពរនៃមនុស្ស ដែលព្រះទ្រង់រាប់ជាសុចរិតក្រៅពីការប្រព្រឹត្តថា "មានពរហើយ អ្នកណាដែលការទទឹងច្បាប់របស់ខ្លួនបានអត់ទោសឱ្យ និងបាបខ្លួនបានគ្របបាំង"។ មានពរហើយ មនុស្សណាដែលព្រះអម្ចាស់មិនរាប់ជាមានបាបឡើយ។ដូច្នេះ តើបានពរនោះ ចំពោះតែពួកកាត់ស្បែកតែប៉ុណ្ណោះ ឬពួកមិនកាត់ស្បែកក៏បានដែរ ដ្បិតយើងថាសេចក្ដីជំនឿ បានរាប់ទុកជាសេចក្ដីសុចរិត ដល់លោកអ័ប្រាហាំ។ ចុះសេចក្ដីនោះបានរាប់ដូចម្ដេច តើពីកាលលោកបានកាត់ស្បែករួចហើយ ឬនៅឡើយ មិនមែនពីកាលលោកបានកាត់ស្បែកហើយនោះទេ គឺក្នុងកាលដែលមិនទាន់កាត់ស្បែកនៅឡើយវិញ។ ហើយលោកបានទទួលពិធីកាត់ស្បែកនេះ ទុកជាទីសម្គាល់ ជាត្រានៃសេចក្ដីសុចរិត ដែលមកដោយសេចក្ដីជំនឿនោះឯង គឺជាសេចក្ដីជំនឿដែលលោកមានពីកាលមិនទាន់កាត់ស្បែកនៅឡើយ ដើម្បីឱ្យបានធ្វើជាឪពុក ដល់អស់អ្នកដែលជឿ ឥតកាត់ស្បែកផង ប្រយោជន៍ឱ្យបានរាប់សេចក្ដីសុចរិតនេះដល់អ្នកទាំងនោះ។ ហើយឱ្យបានធ្វើជាឪពុក ដល់ពួកដែលមិនគ្រាន់តែកាត់ស្បែកប៉ុណ្ណោះ គឺដែលដើរតាមដាននៃសេចក្ដីជំនឿរបស់លោកអ័ប្រាហាំ ជាអយ្យកោយើងផង ជាសេចក្ដីជំនឿដែលលោកមាន ពីកាលមិនទាន់កាត់ស្បែកនៅឡើយ។ ដ្បិតសេចក្ដីសន្យាដល់លោកអ័ប្រាហាំ និងពូជលោក ឱ្យ

បានលោកីយ៍ជាមរដក នោះមិនមែនដោយសារក្រឹត្យវិន័យទេ គឺដោយសារសេចក្ដីសុចរិតដែលមកដោយសេចក្ដីជំនឿវិញ។ ពីព្រោះបើសិនជាពួកអ្នកដែលអាងក្រឹត្យវិន័យបានគ្រងមរដក នោះសេចក្ដីជំនឿបានទៅជាឥតអំពើវិញ ហើយសេចក្ដីសន្យាក៏ឥតប្រយោជន៍ដែរ។ ឯក្រឹត្យវិន័យ នោះបង្កើតសេចក្ដីក្រោធ ដ្បិតកន្លែងណាដែលគ្មានក្រឹត្យវិន័យ នោះក៏ឥតមានសេចក្ដីរំលងដែរ។ ដូច្នេះ សេចក្ដីសន្យាបានមកដោយសេចក្ដីជំនឿ ដើម្បីឱ្យបានត្រូវខាងព្រះគុណ ប្រយោជន៍ឱ្យសេចក្ដីសន្យាបានខ្ជាប់ខ្ជួន ដល់ពូជលោកតទៅ មិនមែនត្រឹមតែពូជដែលអាងក្រឹត្យវិន័យប៉ុណ្ណោះ គឺដល់ទាំងពូជដែលអាងសេចក្ដីជំនឿរបស់លោកអ័ប្រាហាំ ដែលជាអយ្យកោនៃយើងទាំងអស់គ្នាថែមទៀតផង។ ដូចមានសេចក្ដីចែងទុកមកថា អញបានតាំងឯងឱ្យធ្វើជាឪពុកដល់សាសន៍ជាច្រើន រីឯនៅចំពោះព្រះ ជាទីជឿរបស់លោក ដែលទ្រង់ប្រោសមនុស្សស្លាប់ឱ្យរស់ឡើងវិញ ទាំងមានព្រះបន្ទូលពីរបស់ដែលគ្មាន ទុកដូចជាមានហើយ នោះលោកជាឪពុករបស់យើងមែន" រ៉ូម 4:1-17

"ទ្រង់បានសុគតសម្រាប់អំពើបាបរបស់យើង ហើយរស់ឡើងវិញសម្រាប់ការរាប់ជាសុចរិតរបស់យើង។"

"ដែលទ្រង់ត្រូវគេបញ្ជូនទៅឱ្យមានទោស ដោយព្រោះអំពើរំលងរបស់យើងរាល់គ្នា ហើយបានប្រោសឱ្យមានព្រះជន្មរស់ឡើងវិញ ប្រយោជន៍ឱ្យយើងរាល់គ្នាបានរាប់ជាសុចរិត។" រ៉ូម 4:25

"ទ្រង់ស្រឡាញ់យើង និងបានលាងសម្អាតយើងចេញពីបាបរបស់យើង ដោយព្រះលោហិតរបស់ទ្រង់ផ្ទាល់។"

**"ហើយអំពីព្រះយេស៊ូវគ្រីស្ទជាស្មរបន្ទាល់ស្មោះត្រង់ ដែលកើតពីពួកស្លាប់មកមុនគេបង្អស់ ជាអធិបតីលើអស់ទាំងស្តេចនៅផែនដី រីឯព្រះអង្គដែលទ្រង់ស្រឡាញ់យើងរាល់គ្នា ហើយបានលាងយើងដោយព្រះលោហិតទ្រង់ ឱ្យបានរួចពីបាប" វិវរណៈ 1:5**

"ទ្រង់ជាអង្គផ្សះផ្សារវាងព្រះនិងយើង។"

**"ពីព្រោះមានព្រះតែ១ ហើយមានអ្នកសង្រួបសង្រួមតែ១ នៅកណ្តាលព្រះ និងមនុស្ស គឺជាមនុស្សដ៏ជាព្រះគ្រីស្ទយេស៊ូវនោះ" ធីម៉ូថេទី១ 2:5**

"ទ្រង់រស់នៅដើម្បីនឹងធ្វើការទូលអង្វរជំនួសយើង។"

**"ដោយហេតុនោះបានជាទ្រង់អាចនឹងជួយសង្គ្រោះសព្វគ្រប់បាន ដល់មនុស្សទាំងអស់ ដែលចូលទៅឯព្រះ ដោយសារទ្រង់ ដ្បិតទ្រង់មានព្រះជន្មរស់នៅជានិច្ច ដើម្បីនឹងជួយអង្វរជំនួសគេ។" ហេព្រើរ 7:25**

ចេញពីអ្វីដែលខ្ញុំបានប្រមូលមក ខ្ញុំត្រូវតែរកសេចក្តីសុចរិតនៅក្នុងព្រះអង្គមួយអង្គនេះ សម្រាប់ជាការស្អប់ស្អល់ដល់អំពើបាបរបស់ខ្ញុំដោយសារ

លោហិតរបស់ទ្រង់ ដែលអ្វីដែលទ្រង់បានធ្វើនៅក្នុងការស្តាប់បង្គាប់ ទៅកាន់ក្រិត្យវិន័យរបស់ព្រះវរបិតារបស់ទ្រង់ ហើយការដែលបានចុះចូលនៅក្នុងការដាក់ទោសផង មិនមែនសម្រាប់ខ្លួនទ្រង់ឡើយ តែសម្រាប់អស់អ្នកណាដែលនឹងទទួលយកសម្រាប់សេចក្តីសង្គ្រោះរបស់គេ ហើយចេះអរគុណ។ ហើយពេលនេះចិត្តរបស់ខ្ញុំពេញដោយអំណរ ភ្នែករបស់ខ្ញុំពេលដោយទឹកភ្នែក ហើយសេចក្តីស្រឡាញ់របស់ខ្ញុំបានរត់បែរមកស្រឡាញ់ព្រះនាម រាស្រ្ត និងផ្លូវរបស់ព្រះយេស៊ូវគ្រីស្ទ។

គ្រីស្ទាន៖ នេះជាការបើកសម្តែងរបស់ព្រះគ្រីស្ទដល់ព្រលឹងអ្នកពិតមែន។ តែសូមប្រាប់ខ្ញុំប្រាកដមកថាតើការនេះមានឥទ្ធិពលអ្វីដល់ព្រលឹងរបស់អ្នកវិញ។

សង្ឃឹម៖ វាធ្វើឱ្យខ្ញុំឃើញថា លោកិយទាំងមូល មានទាំងសេចក្តីសុចរិតទាំងនោះ កំពុងតែនៅក្នុងភាពនៃការដាក់ទោសពិត។ វាបានធ្វើឱ្យខ្ញុំឃើញថាព្រះវរបិតា ដោយសារទ្រង់សុចរិត នោះទ្រង់អាចរាប់ជាសុចរិតដល់អ្នកមានបាបណាដែលមកបានដោយត្រឹមត្រូវ។ វាបានធ្វើឱ្យខ្ញុំខ្មាសពីអំពើអាក្រក់នៃជីវិតពីដើមរបស់ខ្ញុំណាស់ ហើយបានធ្វើឱ្យខ្ញុំដឹងពីភាពល្ងង់ខ្លៅរបស់ខ្ញុំផ្ទាល់ ដោយសារមិនដែលមានគំនិតណាមកក្នុងចិត្តខ្ញុំមុននេះ ដែលបង្ហាញខ្ញុំដូចនេះ ពីសម្រស់របស់ព្រះយេស៊ូវគ្រីស្ទឡើយ។ វាបានធ្វើឱ្យខ្ញុំស្រឡាញ់ជីវិតបរិសុទ្ធ និងប្រាថ្នាចង់ធ្វើអ្វីដែលគួរឱ្យគោរព និងសិរីល្អដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទ។ បាទ ហើយខ្ញុំគិតថាពេលនេះខ្ញុំមានឈាមរាប់លីត្រនៅក្នុងខ្លួន ដែលខ្ញុំអាចនឹងបង្ហូរវាទាំងអស់ដោយយល់ដល់ព្រះនាមព្រះអម្ចាស់យេស៊ូវ។

## លូង់ខ្លៅបង្ហាញភាពលូង់ខ្លៅរបស់ខ្លួន

បន្ទាប់មកខ្ញុំបានឃើញថាពេញដោយសង្ឃឹមបានមើលមកក្រោយហើយ បានឃើញលូង់ខ្លៅ ជាម្នាក់ដែលពួកគេទុកចោលពីក្រោយ គាត់បានមក តាម។ "មើលទៅ" គាត់បាននិយាយទៅកាន់គ្រីស្ទានថា "មើលទៅក្មេងដែល នៅពីចម្ងាយនោះនឹងនៅតែដើរតាមពីក្រោយដល់ណាទៀត។"

គ្រីស្ទានៈ អេ អេ ខ្ញុំឃើញគាត់ហើយ។ គាត់មិនខ្វល់ពីបក្សពួកដូចយើងទេ។

សង្ឃឹមៈតែខ្ញុំគិតថាវាមិនធ្វើឱ្យគាត់មានគ្រោះថ្នាក់ទេ បើគាត់ដើរមក ដំណាលយើងដល់ទីនេះដែរ។

គ្រីស្ទានៈ ពិតហើយ តែខ្ញុំធានាថាគាត់គិតដូច្នោះមែន។

សង្ឃឹមៈ "ខ្ញុំគិតថាគាត់អីចឹងមែន តែយ៉ាងណាក៏ដោយ ចូរយើងចាំគាត់ផ ង។" ដូច្នេះពួកគេក៏បានរងចាំមែន។

គ្រីស្ទានៈ បន្ទាប់មកគ្រីស្ទាននិយាយទៅគាត់ថា "មកនេះមក ហេតុអ្វីបានជា នៅក្រោយខ្លាំងម្ល៉េះ?"

លូង់ខ្លៅៈ ខ្ញុំសប្បាយដែលដើរម្នាក់ឯង ប្រសើរជាងមានគ្នាឆ្ងាយណាស់ លើកលែងតែខ្ញុំចូលចិត្តវាជាងប៉ុណ្ណោះ។

គ្រីស្ទាន៖ បន្ទាប់មកគ្រីស្ទាននិយាយទៅកាន់ពេញដោយសង្ឃឹម (និយាយតិចៗ)ថា "តើខ្ញុំមិនបានប្រាប់ទេថាគាត់មិនខ្វល់ពីយើងបានជាគ្នាទេ? តែយ៉ាងណាក៏ដោយ គាត់និយាយថា "មក ហើយចូរយើងនិយាយគ្នាក្នុងកាលដែលមកកន្លែងដាច់ស្រយាលនេះ។" រួចបានបង្វែនិយាយទៅរកល្ងង់ខ្លៅវិញ គាត់បាននិយាយថា "ចូរមក អ្នកយ៉ាងម៉េចហើយ? តើជំហររវាងព្រះនិងព្រលឹងរបស់អ្នកពេលនេះយ៉ាងម៉េចហើយ?"

ល្ងង់៖ ខ្ញុំសង្ឃឹមថាល្អ។ ដោយសារខ្ញុំតែងតែមានអារម្មណ៍ល្អ ដែលចូលក្នុងគំនិតរបស់ខ្ញុំ ដែលមកកំសាន្តចិត្តខ្ញុំពេលដែលខ្ញុំដើរ។

គ្រីស្ទាន៖ តើអារម្មណ៍ល្អអីទៅ? សូមប្រាប់ពួកយើងមើល។

ល្ងង់៖ គឺខ្ញុំបានគិតពីព្រះនិងស្ថានសួគ៌។

គ្រីស្ទាន៖ អារក្សនិងវិញ្ញាណដែលត្រូវទទួលទោសក៏គិតដូចតែគ្នាហ្នឹង។

ល្ងង់៖ តែខ្ញុំបានគិត ហើយខ្ញុំប្រាថ្នាចង់បានផង។

គ្រីស្ទាន៖ មនុស្សជាច្រើនដែលដូចជាមិនមកទីនោះក៏គិតដូចគ្នា។ ព្រលឹងរបស់មនុស្សកំជិលប្រាថ្នាចង់បាន ហើយតែមិនមានអ្វីទាំងអស់។

**"ព្រលឹងនៃមនុស្សខ្ជិលច្រអូសប្រាថ្នាចង់បាន តែមិនបានអ្វីសោះ ឯព្រលឹងនៃមនុស្សព្យាយាម នោះនឹងបានជាបរិបូរវិញ។" សុភាសិត 13:4**

លូង់៖ តែខ្ញុំបានគិត ហើយបានបោះបង់ចោលរបស់ទាំងអស់។

គ្រីស្ទាន៖ នោះខ្ញុំសង្ស័យថា ការចាកចេញពីរបស់អស់ទាំងនោះជាការលំបាកមួយ។ ពិតណាស់ ជាបញ្ហាលំបាកជាងគេដែលមនុស្សជាច្រើនបានដឹង។ តែហេតុអ្វី ឬដោយសារអ្វី ដែលអ្នកត្រូវបានអូសទាញថាអ្នកបានបោះបង់គ្រប់ទាំងអស់សម្រាប់ព្រះនិងស្ថានសួគ៌នោះ?

លូង់៖ ចិត្តរបស់ខ្ញុំប្រាប់ខ្ញុំដូច្នោះ។

គ្រីស្ទាន៖ មនុស្សឆ្លាតនិយាយថា "អ្នកដែលទុកចិត្តលើចិត្តរបស់ខ្លួនជាមនុស្សល្ងង់។"

**"អ្នកណាដែលទីពឹងតែចិត្តខ្លួនឯង នោះជាអ្នកល្ងីល្ងើហើយ តែអ្នកណាដែលប្រព្រឹត្តដោយប្រាជ្ញាវិញ នោះនឹងបានប្រោសឱ្យរួច។" សុភាសិត 28:26**

លូង់៖ និយាយពីចិត្តដែលទុច្ចរិតទេតើ តែចិត្តខ្ញុំវិញល្អហ្នឹង។

គ្រីស្ទាន៖ តែតើអ្នកមានអ្វីមកអះអាងដែរ?

លូង់៖ វាបានកំសាន្តចិត្តខ្ញុំនៅក្នុងសង្ឃឹមពីស្ថានសួគ៌។

គ្រីស្ទាន៖ មានតែតាមរយៈសេចក្តីបោកបញ្ឆោតប៉ុណ្ណោះ ដោយសារចិត្តរបស់មនុស្សអាចនឹងផ្តល់ការកំសាន្តចិត្តដល់ម្នាក់នៅក្នុងសង្ឃឹមពីការដែលគាត់មានមិនមានហេតុដែលសង្ឃឹមសោះ។

ល្ងង់៖ តែចិត្តនិងជីវិតរបស់ខ្ញុំយល់ស្របជាមួយគ្នា ហើយដូច្នេះសេចក្តីសង្ឃឹមរបស់ខ្ញុំជាគ្រឹះល្អហើយ។

គ្រីស្ទាន៖ តើអ្នកណាប្រាប់អ្នកថាចិត្តនិងជីវិតរបស់អ្នកយល់ស្របគ្នានោះ?

ល្ងង់៖ ចិត្តរបស់ខ្ញុំប្រាប់មកអីចឹង។

គ្រីស្ទាន៖ "ចូរសួរគ្នារបស់ខ្ញុំចុះថាខ្ញុំជាចោរទេ។" ចិត្តរបស់អ្នកប្រាប់អ្នកអញ្ចឹង! ក្រៅពីព្រះបន្ទូលរបស់ព្រះធ្វើបន្ទាល់ពីការនោះ នោះទីបន្ទាល់ណាផ្សេងទៀតមិនមានតម្លៃអ្វីឡើយ។

ល្ងង់៖ តែតើមិនមែនជាចិត្តដែលល្អទេឬ ដែលមានគំនិតល្អៗនោះ? ហើយតើមិនមែនជាជីវិតល្អទេឬ ដែលជាជីវិតមួយតាមបញ្ញាត្តិរបស់ព្រះនោះ?

គ្រីស្ទាន៖ បាត ចិត្តដែលល្អនោះហើយដែលមានគំនិតល្អ ហើយជីវិតល្អនោះហើយដែលតាមបញ្ញាត្តិរបស់ព្រះ តែវាជាការមួយដែលមានការទាំងនេះ ហើយការមួយទៀតដែលគ្រាន់តែគិតអីចឹងប៉ុណ្ណោះ។

ល្ងង់៖ សូមអ្នកប្រាប់មកថា តើអ្វីដែលអ្នករាប់ថាគំនិតល្អៗ ហើយជីវិតអ្វីដែលតាមបញ្ញាត្តិរបស់ព្រះនោះ?

គ្រីស្ទាន៖ មានគំនិតល្អៗដែលជាប្រភេទអ្នកមុជទៅ ខ្លះពាក់ព័ន្ធនឹងខ្លួនយើង ខ្លះពីព្រះ ខ្លះទៀតពីព្រះគ្រីស្ទ និងខ្លះទៀតពីការផ្សេងៗ។

ល្វង់៖ តើអ្វីទៅជាគំនិតល្អៗទាក់ទងនឹងខ្លួនយើង?

គ្រីស្ទាន៖ ដូចជាការដែលស្របនឹងព្រះបន្ទូលរបស់ព្រះ។

ល្វង់៖ នៅពេលណាដែលគំនិតរបស់យើងយល់ស្របនឹងព្រះបន្ទូលរបស់ព្រះនោះ?

គ្រីស្ទាន៖ នៅពេលដែលយើងធ្វើការកាត់ទោសដូចគ្នានោះមកលើខ្លួនយើងដែលព្រះបន្ទូលផ្តល់មក។ ឱ្យខ្ញុំពន្យល់ថា ព្រះបន្ទូលរបស់ព្រះនិយាយពីមនុស្សនៅក្នុងស្ថានភាពទូទៅថា "មិនមានអ្នកណាដែលសុចរិតឡើយ មិនមានអ្នកណាដែលធ្វើល្អឡើយ" ព្រះបន្ទូលក៏និយាយទៀតថា "គ្រប់ទាំងការស្រមើស្រម៉ៃរបស់ចិត្តមនុស្សមានតែការអាក្រក់ និងវានៅបន្តជានិច្ច។"

**"ដូច្នេះ តើដូចម្តេច យើងល្អជាគេឬទេ មិនមែនទេ ដ្បិតយើងខ្ញុំបានចោទប្រកាន់រួចហើយថា ទោះទាំងសាសន៍យូដា និងសាសន៍ក្រេកផង សុទ្ធតែនៅក្រោមអំពើបាប។ ដូចមានសេចក្តីចែងទុកមកថា គ្មានអ្នកណាសុចរិតសោះ សូម្បីតែម្នាក់ក៏គ្មានផង។ គ្មានអ្នកណាដែលយល់ គ្មានអ្នកណាដែលស្វែងរកព្រះ។ គ្រប់គ្នាបានបែរចេញ ហើយត្រឡប់ជាឥតប្រយោជន៍ទាំងអស់គ្នា គ្មានអ្នកណាដែលប្រព្រឹត្តតាមសេចក្តីសប្បុរសសោះ តែម្នាក់ក៏គ្មានផង។ បំពង់កគេជាផ្នូរខ្មោចនៅចំហ គេប្រើអណ្តាតគេសម្រាប់នឹងបញ្ឆោត ឯនៅបបូរមាត់គេមានសុទ្ធតែពិសពស់ហានុមាន ហើយមាត់គេមានពេញដោយសេចក្តីបណ្តា**

**សា និងសេចក្តីជូរចត់ ជើងគេរហ័សនឹងកំចាយឈាម នៅអស់ទាំងផ្លូវរបស់គេមានសុទ្ធតែសេចក្តីវិនាស និងសេចក្តីទុក្ខលំបាក។ គេមិនបានស្គាល់ផ្លូវសុខសាន្តសោះ ក៏គ្មានសេចក្តីកោតខ្លាចចំពោះព្រះ នៅភ្នែកគេឡើយ។៉ រ៉ូម 3:9-18**

**"ពីព្រោះគ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ។៉ រ៉ូម 3:23**

**"ព្រះយេហូវ៉ាឃើញថា ការអាក្រក់របស់មនុស្សបានចំរើនជាច្រើនឡើងនៅផែនដី ហើយអស់ទាំងគំនិតក្នុងចិត្តគេក៏សុទ្ធតែអាក្រក់ជានិច្ចដូច្នោះ។៉ លោកុប្បត្តិ 6:5**

ហើយម្តងទៀត "ការស្រមើស្រម៉ៃនៃចិត្តរបស់មនុស្សម្នាក់គឺវាអាក្រក់តាំងពីតូចមក។៉ បន្ទាប់មកពេលនេះ ពេលណាដែលយើងគិតដូច្នោះពីខ្លួនយើងមានអារម្មណ៍ដូច្នោះ បន្ទាប់មកនោះគំនិតរបស់យើងបានល្អហើយ ពីព្រោះវាស្របតាមព្រះបន្ទូលរបស់ព្រះ។

ល្ងង់៖ ខ្ញុំនឹងមិនជឿថាចិត្តរបស់ខ្ញុំអាក្រក់អីចឹងទេ។

គ្រីស្ទាន៖ ដូច្នោះអ្នកមិនដែលមានគំនិតល្អណាមួយទាក់ទងនឹងខ្លួនអ្នកនៅក្នុងជីវិតរបស់អ្នកទេ។ តែសូមឱ្យខ្ញុំបាននិយាយតទៀត។ កាលដែលព្រះបន្ទូលផ្តល់ការជំនុំជំរះដល់ចិត្តរបស់យើង នោះព្រះបន្ទូលក៏ផ្តល់ការកាត់ទោសដល់ផ្លូវរបស់យើងដូចគ្នា។ ហើយនៅពេលដែលគំនិតនៃចិត្តរបស់យើងនិងផ្លូវប្រព្រឹត្តស្របគ្នានឹងការការទោសដែលព្រះបន្ទូលផ្តល់ឱ្យទាំងពីរ

នោះ នោះការទាំងពីរនោះល្អហើយ ដោយសារយល់ស្របទៅនឹងព្រះបន្ទូលរបស់ព្រះ។

លូង់៖ ចូរបង្ហាញអត្ថន័យរបស់អ្នកមើល។

គ្រីស្ទាន៖ ដោយសារព្រះបន្ទូលរបស់ព្រះមានបន្ទូលថាផ្លូវរបស់មនុស្សជាផ្លូវដែលវៀចវេរ មិនល្អ តែខូចអាក្រក់។ ព្រះបន្ទូលថា វាពីធម្មជាតិមកគឺនៅក្រៅពីផ្លូវល្អ ដែលពួកគេមិនបានដឹងសោះ។

**"តែចំណែកមនុស្សដែលបែរទៅតាមផ្លូវខ្វិចខ្វៀនរបស់ខ្លួនវិញ នោះព្រះយេហូវ៉ាទ្រង់នឹងនាំគេចេញទៅ ជាមួយនឹងពួកអ្នកដែលប្រព្រឹត្តអំពើទុច្ចរិត។ សូមឱ្យសេចក្ដីសុខគ្រប់លើសាសន៍អ៊ីស្រាអែលផង។" ទំនុកដំកើង 125:5**

**"ផ្លូវគេសុទ្ធតែក្ងិកក្ងក់ ហើយផ្លូវច្រករបស់គេក៏ទាសចេញ។" សុភាសិត 2:15**

**"ដូច្នេះ តើដូចម្ដេច យើងល្អជាគេឬទេ មិនមែនទេ ដ្បិតយើងខ្ញុំបានចោទប្រកាន់រួចហើយថា ទោះទាំងសាសន៍យូដា និងសាសន៍ក្រេកផង សុទ្ធតែនៅក្រោមអំពើបាប។ ដូចមានសេចក្ដីចែងទុកមកថា គ្មានអ្នកណាសុចរិតសោះ សូម្បីតែម្នាក់ក៏គ្មានផង។ គ្មានអ្នកណាដែលយល់ គ្មានអ្នកណាដែលស្វែងរកព្រះ។ គ្រប់គ្នាបានបែរចេញ ហើយត្រឡប់ជាឥតប្រយោជន៍ទាំងអស់គ្នា គ្មានអ្នកណាដែលប្រព្រឹត្តតាមសេចក្ដីសប្បុរសសោះ តែម្នាក់ក៏គ្មានផង។ បំពង់កគេជាផ្នូរខ្មោចនៅចំហ គេប្រើអណ្ដាតគេសម្រាប់នឹងបញ្ឆោត ឯនៅបបូរមាត់គេមានសុទ្ធតែពិសពស់ហានុមាន ហើយមាត់គេមានពេញដោយសេចក្ដីបណ្ដាសា និងសេចក្ដីជូរចត់ ជើងគេរហ័សនឹងកំចាយឈាម នៅអស់ទាំងផ្លូវរបស់**

**គេមានសុទ្ធតែសេចក្តីវិនាស និងសេចក្តីទុក្ខលំបាក។ គេមិនបានស្គាល់ផ្លូវសុខសាន្តសោះ ក៏គ្មានសេចក្តីកោតខ្លាចចំពោះព្រះ នៅភ្នែកគេឡើយ។" រ៉ូម 3:9-18**

ពេលនេះ នៅពេលបុរសម្នាក់នោះគិតដូច្នេះ ខ្ញុំនិយាយថា នៅពេលដែលគាត់ធ្វើត្រូវ ហើយដោយចិត្តបន្ទាបចុះក៏គិតដូច្នេះ បន្ទាប់មកគាត់មានគំនិតល្អពីផ្លូវរបស់គាត់ផ្ទាល់ ពីព្រោះគំនិតរបស់គាត់ពេលនេះយល់ស្របជាមួយនឹងការកាត់ទោសរបស់ព្រះបន្ទូលរបស់ព្រះ។

ល្ងង់៖ តើអ្វីជាគំនិតល្អអំពីព្រះនោះ?

គ្រីស្ទាន៖ ទោះបីជា (ដូចដែលខ្ញុំនិយាយពាក់ព័ន្ធនឹងខ្លួនយើង) នៅពេលដែលគំនិតរបស់យើងពីព្រះស្របជាមួយនឹងអ្វីដែលព្រះបន្ទូលថាពីគាត់ ហើយនោះជាពេលដែលយើងគិតពីរូបអង្គទ្រង់និងលក្ខណៈរបស់ទ្រង់ ដូចដែលព្រះបន្ទូលបានបង្រៀន តែខ្ញុំមិនអាចនិយាយបានទូលំទូលាយទេពេលនេះ។ តែដើម្បីនិយាយពីទ្រង់ដោយទាក់ទងនឹងយើងថា នោះយើងមានគំនិតដែលត្រឹមត្រូវពីព្រះ នៅពេលដែលយើងគិតថាទ្រង់ស្គាល់យើងជាងដែលយើងស្គាល់ខ្លួនឯង ហើយអាចឃើញអំពើបាបនៅក្នុងយើង នៅពេលនិងកន្លែងណាដែលយើងមិនអាចឃើញនៅក្នុងខ្លួងយើងសោះ។ នៅពេលដែលយើងគិតថាទ្រង់ស្គាល់គំនិតដ៏ជ្រៅរបស់យើង និងជម្រៅចិត្តរបស់យើងទាំងអស់តែងតែបើកចំហរនៅចំពោះព្រះនេត្រទ្រង់។ ហើយនៅពេលដែលយើងគិតថាគ្រប់ទាំងសេចក្តីសុចរិតរបស់យើងនោះស្អុយរលួយ

នៅក្នុងវន្តច្រមុះ ហើយដូច្នេះទ្រង់មិនអាចទ្រាំនឹងមើលឃើញឈរនៅចំពោះទ្រង់នៅក្នុងទំនុកចិត្តណាឡើយបើទោះជាយើងសម្តែងមកយ៉ាងល្អបំផុតក៏ដោយ។

លូង់៖ តើអ្នកគិតថាខ្ញុំលូង់បែបហ្នឹងដែលគិតថាព្រះមិនអាចមើលឃើញវែងឆ្ងាយជាងខ្លួនឬ? ឬថាខ្ញុំនឹងមករកព្រះដោយកិច្ចការដែលសម្តែងយ៉ាងល្អបំផុតឬ?

គ្រីស្ទាន៖ អ្នកគិតយ៉ាងណាអំពីបញ្ហានេះ?

លូង់៖ ហេតុផលនោះគឺ បើនិយាយឱ្យខ្លីទៅ ខ្ញុំគិតថាខ្ញុំត្រូវជឿដល់ព្រះគ្រីស្ទសម្រាប់ការរាប់ជាសុចរិតវិញ។

គ្រីស្ទាន៖ អ្នកគិតថាត្រូវជឿដល់ព្រះគ្រីស្ទយ៉ាងម៉េចកើត កាលដែលអ្នកមិនឃើញមានអ្វីដែលត្រូវការទ្រង់ផងនោះ! អ្នកមើលមិនឃើញជម្ងឺរបស់អ្នកទាំងដើមនិងការដែលប្រព្រឹត្តផងនោះ តែបែជាមានគំនិតបែបនេះពីខ្លួនអ្នកដែលអ្នកបានធ្វើដែលបង្ហាញយ៉ាងច្បាស់ថាអ្នកជាម្នាក់ ដែលមិនដែលមើលឃើញពីការចាំបាច់នៃសេចក្តីសុចរិតផ្ទាល់របស់ព្រះគ្រីស្ទ ដើម្បីនឹងរាប់អ្នកជាសុចរិតនៅចំពោះព្រះឡើយ។ តើអ្នកនិយាយថា "ខ្ញុំជឿព្រះគ្រីស្ទ" បានយ៉ាងដូចម្តេចទៅ?

លូង់៖ ខ្ញុំជឿដល់ការទាំងនោះគ្រប់គ្រាន់ហើយ។

គ្រីស្ទាន៖ តើអ្នកជឿយ៉ាងម៉េចដែរ?

លូង់៖ ខ្ញុំជឿថាព្រះគ្រីស្ទសុគតសម្រាប់អ្នកមានបាប ហើយថា ខ្ញុំនឹងបានរាប់ជាសុចរិតនៅចំពោះព្រះចេញពីបណ្ដាសា តាមរយៈការទទួលដោយព្រះគុណរបស់ទ្រង់នូវការស្ដាប់បង្គាប់ដល់ក្រិត្យវិន័យរបស់ទ្រង់។ ឬដូច្នេះ ព្រះគ្រីស្ទធ្វើឱ្យតួនាទីបែបសាសនារបស់ខ្ញុំឱ្យបានទទួលយកនៅចំពោះព្រះវរបិតាទ្រង់ដោយសារគុណតម្លៃនៃសេចក្ដីមេត្តារបស់ទ្រង់ នោះខ្ញុំនឹងបានរាប់ជាសុចរិត។

គ្រីស្ទាន៖ ចូរឱ្យខ្ញុំបានឆ្លើយនឹងការសារភាពនៃសេចក្ដីជំនឿរបស់អ្នកនេះ។
1. អ្នកជឿដោយសេចក្ដីជំនឿដែលនឹកស្មាន ដោយសារសេចក្ដីជំនឿនេះមិនមានរៀបរាប់នៅក្នុងព្រះបន្ទូលឡើយ។

2. អ្នកជឿដោយសេចក្ដីជំនឿខុសឆ្គង ពីព្រោះវាបានដកការរាប់ជាសុចរិតចេញពីសេចក្ដីសុចរិតផ្ទាល់របស់ព្រះគ្រីស្ទ ហើយបានលើកវាមកដាក់ជារបស់អ្នកវិញ។

3. សេចក្ដីជំនឿនេះមិនបានធ្វើឱ្យព្រះគ្រីស្ទាជាអ្នករាប់ជាសុចរិតរបស់អ្នកទេ តែដោយសារកិច្ចការរបស់អ្នកវិញ និងដោយសារខ្លួនអ្នកដោយសារកិច្ចការរបស់អ្នកធ្វើ ហើយវាជាការខុសឆ្គងហើយ។

4. ដូច្នេះ សេចក្ដីជំនឿនេះគឺបោកបញ្ឆោតទេ ហើយការនេះហើយដែលនឹងទុកឱ្យអ្នកនៅក្រោមសេចក្ដិក្រោធរបស់ព្រះនៅក្នុងថ្ងៃរបស់ព្រះដ៏មានគ្រប់អំណាចចេស្ដាផង។ ដោយសារសេចក្ដីជំនឿដែលរាប់ជាសុចរិតដាក់ព្រលឹង

(ដែលមានញាញនៃការសភាពនៃបាត់បង់របស់វាដោយសារក្រឹត្យវិន័យ) នៅលើហោះទៅរកទីជំរកនៃសេចក្ដីសុចរិតរបស់ព្រះគ្រីស្ទ ដែលសេចក្ដីសុចរិតរបស់ទ្រង់មិនមានជាកិច្ចការនៃព្រះគុណ ដែលកាត់ធ្វើសម្រាប់ការរាប់ជាសុចរិតនូវការស្តាប់បង្គាប់របស់អ្នកឱ្យបានទទួលនៅចំពោះព្រះ។ តែការស្តាប់បង្គាប់ផ្ទាល់ខ្លួនទៅកាន់ក្រឹត្យវិន័យនៅក្នុងការប្រព្រឹត្តនិងការរងទុក្ខសម្រាប់យើងជាអ្វីដែលទាមទារពីដៃរបស់យើង។ សេចក្ដីសុចរិតនេះ ខ្ញុំនិយាយថា ជាសេចក្ដីជំនឿពិតទទួលយក នៅក្រោមសំពត់ដែលរុំព្រលឹង ហើយដោយវាបានបង្ហាញថាមិនមានស្នាមនៅចំពោះព្រះសោះ វាត្រូវបានទទួលយក ហើយគ្មានកំហុសចេញពីការដាក់ទោសរបស់ព្រះ។

ល្ងង់៖ អ្វីហ្នឹង! តើអ្នកចង់ឱ្យយើងទុកចិត្តលើអ្វីដែលព្រះគ្រីស្ទនៅក្នុងអង្គទ្រង់បានធ្វើដោយគ្មានយើងឬយ៉ាងណា? ការយល់ស្របនេះនឹងបន្ធូបង្ហៀរនៃតណ្ហារបស់យើង ហើយបន្ធូរបន្ថយយើងឱ្យរស់នៅតាមដែលយើងចង់បាន ។ ដោយសារ តើវាជាបញ្ហាអ្វីទៅថាយើងរស់យ៉ាងម៉េចនោះ ប្រសិនបើយើងនឹងបានរាប់ជាសុចរិត ដោយសារសេចក្ដីសុចរិតរបស់ព្រះគ្រីស្ទផ្ទាល់ នៅពេលដែលយើងជឿនោះ?

គ្រីស្ទាន៖ ល្ងង់ខ្លៅជាឈ្មោះរបស់អ្នកពិត ហើយអ្នកល្ងង់ដូចជាឈ្មោះរបស់អ្នកមែន។ សូម្បីតែចម្លើយរបស់អ្នកបង្ហាញនូវអ្វីដែលខ្ញុំថានេះ។ អ្នកមិនស្គាល់ថាសេចក្ដីសុចរិតដែលរាប់ជាសុចរិតថាជាអ្វី ហើយមិនដឹងពីរបៀបរក្សានូវព្រលឹងរបស់អ្នក តាមរយៈជំនឿនោះ ចេញពីសេចក្ដីក្រោធដ៏ធ្ងន់របស់ព្រះនោះ។ ហើយអ្នកមិនដឹងពីឥទ្ធិពលនៃសេចក្ដីជំនឿដែលបានសង្គ្រោះនៅក្នុងសេចក្ដីសុចរិតនេះរបស់ព្រះគ្រីស្ទ ដែលជាការឱនចុះនិងយក

ឈ្នះលើចិត្តទៅកាន់ព្រះនៅក្នុងព្រះគ្រីស្ទ ដែលស្រឡាញ់ព្រះនាមទ្រង់ ព្រះបន្ទូលទ្រង់ ផ្លូវ និងរាស្ត្ររបស់ទ្រង់ ហើយមិនដូចអ្វីអ្នកមនុស្សល្ងង់ដូចអ្នកស្រមើស្រម៉ៃឡើយ។

សង្ឃឹមៈ ចូរសួរគាត់ទៅមើល ថាតើព្រះគ្រីស្ទធ្លាប់បើសម្តែងពីស្ថានសួគ៌មកដល់គាត់ទេ។

ល្ងង់ៈ អ្វីហ្នឹង! អ្នកជាមនុស្សនៃការបើកសម្តែង! ខ្ញុំជឿថាអ្នកដែលអ្នកទាំងពីរ និងអ្នកផ្សេងទៀតនិយាយអំពីបញ្ហានេះ គឺគ្រាន់តែជាផលផ្លែនៃខួរក្បាលដែលបែករាយមាយប៉ុណ្ណោះ។

សង្ឃឹមៈ ព្រះគ្រីស្ទត្រូវបានលាក់នៅក្នុងព្រះពីការយល់ដឹងពីធម្មជាតិរបស់សាច់ឈាមនោះ គឺថាទ្រង់មិនស្គាល់បានដោយមនុស្សណាដោយបានសង្គ្រោះឡើយ លើកលែងតែព្រះវរបិតាបង្ហាញទ្រង់ដល់ពួកគេ។

ល្ងង់ៈ នោះជាសេចក្តីជំនឿរបស់អ្នក តែមិនមែនខ្ញុំឡើយ។ របស់ខ្ញុំវិញគឺ ខ្ញុំមិនបានសង្ស័យទេ ថាវាល្អដូចជាអ្នកឬអត់ បើទោះជាខ្ញុំមាននៅក្នុងក្បាលរបស់ខ្ញុំពីការចម្លែកៗជាច្រើនដូចអ្នកដែរ។

គ្រីស្ទានៈ សូមឱ្យខ្ញុំបាននិយាយបន្តិច។ អ្នកមិនគួរនិយាយពីបញ្ហានេះដោយធូរៗឡើយ ដោយខ្ញុំនឹងអះអាងដោយរឹងប៉ឹងថា (សូម្បីតែគ្នាខ្ញុំក៏បានធ្វើដែរ) ថាគ្មានអ្នកណាអាចស្គាល់ព្រះគ្រីស្ទយេស៊ូវបានឡើយ តែមានតែដោយការបើកសម្តែងរបស់ព្រះវរបិតាប៉ុណ្ណោះ។ បាទ គឺសេចក្តីជំនឿផង ដែលព្រលឹង

នឹងកាន់ជាប់នឹងព្រះគ្រីស្ទ (បើវាត្រឹមត្រូវ) ត្រូវតែបាននាំមកដោយភាពអស្ចារ្យបំផុតនៃអំណាចដ៏មានគ្រប់ចេស្តារបស់ទ្រង់។

"គ្រប់សេចក្តីទាំងអស់បានប្រគល់មកខ្ញុំពីព្រះវរបិតានៃខ្ញុំ ហើយគ្មានអ្នកណាស្គាល់ព្រះរាជបុត្រាទេ មានតែព្រះវរបិតាតែ១ ក៏គ្មានអ្នកណាស្គាល់ព្រះវរបិតាដែរ មានតែព្រះរាជបុត្រាហើយនឹងអ្នកណា ដែលព្រះរាជបុត្រាសព្វព្រះហឫទ័យចង់បើកឱ្យស្គាល់ទ្រង់ផងប៉ុណ្ណោះ។" ម៉ាថាយ 11:27

"ហេតុនោះបានជាខ្ញុំប្រាប់ឱ្យអ្នករាល់គ្នាដឹងថា មិនដែលមានអ្នកណានិយាយដោយនូវព្រះវិញ្ញាណនៃព្រះថាព្រះយេស៊ូវត្រូវបណ្តាសានោះឡើយ ក៏គ្មានអ្នកណាអាចនឹងថា ព្រះយេស៊ូវទ្រង់ជាព្រះអម្ចាស់ដែរ លើកតែដោយនូវព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះ។" កូរិនថូសទី១ 12:3

"ដើម្បីឱ្យភ្នែកចិត្តរបស់អ្នករាល់គ្នាបានភ្លឺឡើង ប្រយោជន៍ឱ្យបានដឹងថា ដែលទ្រង់ហៅអ្នករាល់គ្នា នោះមានសេចក្តីសង្ឃឹមជាយ៉ាងណា ហើយថា សិរីល្អដ៏ប្រសើរក្រៃលែងនៃមរដកទ្រង់ ក្នុងពួកបរិសុទ្ធជាយ៉ាងណាផង។" អេភេសូ 1:18

កិច្ចការនៃជំនឿដែលខ្ញុំយល់ថាវាល្ងីល្ងើ អ្នកមិនដែលដឹងសោះ។ ចូរភ្ញាក់ខ្លួនឡើង ហើយមើលទៅកាន់សេចក្តីអាក្រក់វេទនារបស់អ្នកទៅ ហើយហោះទៅកាន់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ហើយដោយសេចក្តីសុចរិតរបស់ទ្រង់

ដែលជាសេចក្ដីសុចរិតរបស់ព្រះ (ដោយសារទ្រង់ផ្ទាល់ជាព្រះ) នោះអ្នកនឹងត្រូវបានដោះឱ្យរួចពីការដាក់ទោសបាប។

ល្ងង់៖ អ្នកទៅដូចជាលឿនពេកហើយ ខ្ញុំមិនអាចតាមទាន់អ្នកទេ។ អ្នកបន្តទៅមុនទៀតចុះ ហើយខ្ញុំនឹងសម្រាកមួយភ្លែតនៅក្រោយ។

បន្ទាប់មកពួកគេនិយាយថា៖

‶ពិតណាស់ ល្ងង់អើយ តើអ្នកនៅតែល្ងង់ដដែលឬយ៉ាងណា ដែលអ្នកបានមើលស្រាលដល់យោបល់ល្អៗដែលផ្ដល់មកអ្នកដប់ដងរួចទៅហើយនោះ? ហើយប្រសិនបើអ្នកមិនព្រមទទួលយកវា អ្នកត្រូវដឹងថាការអាក្រក់អ្វីដែលអ្នកបានធ្វើដូច្នេះ។ ចូរចង់ចាំចុះមនុស្សអើយ ឱ្យទាន់ពេល អឹតមើល កុំភ័យខ្លាចឡើយ។ បើដើរតាមយោបល់ល្អបានត្រឹមត្រូវនឹងបានសង្គ្រោះ ដូច្នេះចូរស្ដាប់ចុះ តែប្រសិនបើអ្នកមើលស្រាលវា អ្នកនឹងក្លាយជាមនុស្សបរាជ័យ ឱល្ងង់អើយ ខ្ញុំហានធានាជាមួយអ្នក។″

ដូច្នេះគ្រីស្ទានបានណែនាំខ្លួនរបស់គាត់ដល់គ្នារបស់គាត់ដូច្នេះ៖

គ្រីស្ទាន៖ អីចឹង ចូរមកមិត្តពេញដោយសង្ឃឹមល្អរបស់ខ្ញុំអើយ ខ្ញុំយល់ថាអ្នកនិងខ្ញុំត្រូវតែដើរទៅតែពីរនាក់យើងម្ដងទៀតហើយ។

## សេចក្តីកោតខ្លាចដែលត្រឹមត្រូវ

ដូច្នេះខ្ញុំបានឃើញនៅក្នុងសុបិនរបស់ខ្ញុំថាពួកគេបានដើរទៅមុខ ហើយល្ងង់បានដើរមកដោយលោតកញ្ជ្រោងតាមក្រោយ។ បន្ទាប់មកគ្រីស្ទាននិយាយទៅកាន់គ្នារបស់គាត់ថា "វាបានធ្វើឱ្យខ្ញុំអាណិតដល់បុរសកំសត់ម្នាក់នេះណាស់ វាពិតជាអាក្រក់ដល់គាត់ហើយដល់ទីបំផុត។"

សង្ឃឹមៈ មានមនុស្សដូច្នេះយ៉ាងសម្បូរបែបនៅក្នុងក្រុងរបស់យើង ទាំងគ្រួសារ ពិតណាស់ គ្រប់ពេញតាមផ្លូវទាំងអស់ (ហើយទាំងពួកអ្នកធ្វើធម្មយាត្រាផងដែរ)។ ហើយប្រសិនបើមានច្រើននៅចំណោករបស់យើង តើអ្នកគិតថានឹងមានប៉ុន្មាននៅកន្លែងដែលគាត់កើតនោះ?

គ្រីស្ទានៈ ពិតណាស់ព្រះបន្ទូលនិយាយដូច្នេះថា "គេបានធ្វើឱ្យភ្នែករបស់ពួកគេខ្វាក់ ដើម្បីកុំឱ្យពួកគេមើលឃើញ។" តែពេលនេះពួកគេមានតែពីរនាក់ តើអ្នកគិតដូចម្តេចពីមនុស្សបែបនោះ? តើអ្នកគិតថាពួកគេពេលខ្លះដឹងពីអំពើបាបអីដូច្នោះ ចុងក្រោយ ក៏ភ័យខ្លាចដល់សភាពគ្រោះថ្នាក់របស់ពួកគេទេឬអី?

សង្ឃឹមៈ ទេ សូមអ្នកឆ្លើយសំណួរនេះដោយខ្លួនអ្នកទៅ ព្រោះអ្នកជាមនុស្សមានវ័យចាស់ជាង។

គ្រីស្ទានៈ បន្ទាប់មកខ្ញុំនិយាយថាជួនកាល (តាមដែលខ្ញុំគិត) ពួកគេអាចគិតបាន តែពួកគេធ្វើជាមិនដឹងពីធម្មជាតិមក មិនយល់ថាការយល់ដឹងបែបនោះសំដៅដល់ការល្អដល់ពួកគេនោះទេ។ ហើយដូច្នេះពួកគេខំស្វែងរកដើម្បីនឹង

គ្រប់បាំងការទាំងនោះយ៉ាងខ្លាំង ហើយបន្ទុបញ្ជោរខ្លួនពួកគេតាមផ្លូវនៃចិត្តរបស់ពួកគេដោយសន្ទត់។

សង្ឃឹម៖ ខ្ញុំពិតជាជឿដូចអ្វីដែលអ្នកនិយាយមែន ថាសេចក្តីភ័យខ្លាចសំដៅដល់ការល្អដល់មនុស្សមែន ហើយដែលធ្វើឱ្យពួកគេបានត្រឹមត្រូវនៅពេលចាប់ផ្តើមរបស់ពួកគេដែលមកកាន់ការធ្វើធម្មយាត្រា។

គ្រីស្ទាន៖ គ្មានការអ្វីដែលត្រូវសង្ស័យនោះទេថាវាពិតជាត្រឹមឬអត់នោះទេ។ ដោយសារព្រះបន្ទូលថា "សេចក្តីកោតខ្លាចដល់ព្រះអម្ចាស់ជាដើមចមនៃប្រាជ្ញា។"

**"រួចមានបន្ទូលដល់មនុស្សយើងថា មើល សេចក្តីកោតខ្លាចដល់ព្រះអម្ចាស់នោះហើយជាប្រាជ្ញា ហើយដែលថយឆ្ងាយពីការអាក្រក់នោះឯងជាយោបល់។" យ៉ូប 28:28**

**"ឯសេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា នោះជាដើមចមនៃប្រាជ្ញា អស់អ្នកដែលកាន់តាម នោះមានយោបល់ល្អ សេចក្តីសរសើរនៃទ្រង់ជាប់នៅអស់កល្បជានិច្ច។" ទំនុកដំកើង 111:10**

**"សេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា នោះជាដើមចមនៃដំរិះ តែមនុស្សឥតបើគិត គេមើលងាយប្រាជ្ញា និងសេចក្តីប្រៀនប្រដៅវិញ។" សុភាសិត 1:7**

**"សេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ាជាដើមចមនៃប្រាជ្ញា ហើយការដែលស្គាល់ដល់ព្រះដ៏បរិសុទ្ធ នោះគឺជាយោបល់។" សុភាសិត 9:10**

សង្ឃឹមៈ តើអ្នកនឹងបកស្រាយបីសេចក្តីកោតខ្លាចដែលត្រឹមត្រូវយ៉ាងដូចម្តេចទៅ?

គ្រីស្ទានៈ សេចក្តីភ័យខ្លាចដែលពិតឬត្រឹមត្រូវ ត្រូវបានបង្ហាញមកដោយការបីយ៉ាង

1. ដោយការលេចមករបស់វា។ វាបង្ករឱ្យមានការយល់ដឹងដែលសង្គ្រោះពីអំពើបាប។

2. វាបណ្តេញព្រលឹងឱ្យកាន់ជាប់ទៅនឹងព្រះគ្រីស្ទដើម្បីទទួលបានការសង្គ្រោះ។

3. វាបង្កើតនិងនៅបន្តនៅក្នុងព្រលឹងនូវការគោរពដល់ព្រះយ៉ាងខ្លាំង ដល់ព្រះបន្ទូលទ្រង់ និងផ្លូវរបស់ទ្រង់ផង។ រក្សាវាឱ្យបានល្អ ហើយធ្វើឱ្យវាខ្លាចនឹងបែរចេញពីការនោះ ការបែរទៅខាងស្តាំឬខាងឆ្វេង ទៅកាន់ការណាមួយដែលនឹងមិនសរសើរដល់ព្រះ ដែលបំបែកសេចក្តីសុខសាន្តរបស់វា ដែលធ្វើឱ្យព្រះវិញ្ញាណពិបាកព្រះទ័យ ឬការដែលធ្វើឱ្យសត្រូវនិយាយដោយរិះគន់នោះឡើយ។

សង្ឃឹមៈ និយាយបានល្អណាស់។ ខ្ញុំជឿថាអ្នកបាននិយាយការពិត។ តើយើងពេលនេះស្ទើរតែឆ្លងផុតទឹកដីដែលមានមន្តអាគមន៍ហើយមែនទេ?

គ្រីស្ទានៈ ហេតុអ្វីទៅ តើអ្នកមិនការនឿយណាយនឹងការជជែកគ្នានេះហើយមែនទេ?

សង្ឃឹមៈ ទេ តែខ្ញុំចង់ដឹងថាយើងកំពុងនៅទីណា។

គ្រីស្នា៖ យើងត្រូវទៅមិនលើសពីពីរឃោជន៍ទៀតទេ។ តែចូរយើងត្រឡប់មករឿងរបស់យើងវិញ។ ពេលនេះល្ងង់មិនបានដឹងថាការញុះញង់ដូចនេះមានបំណងនឹងធ្វើឱ្យគេភ័យខ្លាច ហើយជាការល្អសម្រាប់គេនោះទេ ហើយដូច្នេះគេស្វែងរកនឹងបំបាត់វាចេញ។

សង្ឃឹម៖ តើពួកគេរកនឹងបំបាត់ការទាំងនោះដោយរបៀបណាទៅ?

គ្រីស្នា៖ 1. ពួកគេគិតថាសេចក្ដីកោតខ្លាចទាំងនោះត្រូវបាននាំមកដោយអារក្ស (បើទោះជាការពិតទៅវាមកពីព្រះទេ)។ ហើយដោយគិតដូច្នេះ ពួកគេបានបដិសេធការនោះ ដូចជាការដែលនាំឱ្យពួកគេបរាជ័យអីចឹង។
2. ពួកគេក៏គិតថាសេចក្ដីកោតខ្លាចទាំងនេះមានបំណងបង្ខូចដល់សេចក្ដីជំនឿរបស់ពួកគេ (នៅពេលដែលមនុស្សកំសត់ដូចជាពួកគេ ថាពួកគេមិនមានអ្វីទាំងអស់) ហើយដូច្នេះពួកគេបានធ្វើឱ្យចិត្តរបស់ពួកគេរឹងឡើងទាស់នឹងការភ័យខ្លាចនោះ។
3. ពួកគេសន្មត់ថាពួកគេមិនត្រូវខ្លាចនោះទេ ហើយដូច្នេះជំនួសឱ្យការភ័យខ្លាច បំភ្លៃដោយទំនុកចិត្តតាមការសន្មត់។

4. ពួកគេឃើញថាសេចក្ដីកោតខ្លាចទាំងនេះមានបំណងយកចេញពីពួកគេនូវ សេចក្ដីបរិសុទ្ធផ្ទាល់ខ្លួនចាស់ដែលគួរអាណិតរបស់ពួកគេ ហើយដូច្នេះពួកគេក៏បដិសេធការភ័យខ្លាចទាំងនោះដោយកម្លាំងរបស់ពួកគេ។ សង្ឃឹម៖ ខ្ញុំដឹងការអ្វីមួយពីការនោះដោយខ្លួនខ្ញុំផ្ទាល់ ដោយសារពីមុនខ្ញុំបានដឹងខ្លួនខ្ញុំ ខ្ញុំក៏ធ្លាប់បែបនោះដែរ។

ត្រឡប់ក្រោយ

គ្រីស្ទាន៖ អីចឹង យើងនឹងចាកចេញពីអ្នកជិតខាងល្ងង់របស់យើងពេលនេះ ឱ្យគាត់នៅតែឯងចុះ ហើយនឹងនិយាយពីសំណួរដែលមានប្រយោជន៍មួយទៀតវិញ។

សង្ឃឹម៖ ចេញពីចិត្តរបស់ខ្ញុំ នោះអ្នកគួរតែចាប់ផ្ដើមចុះ។

គ្រីស្ទាន៖ អីចឹង តើអ្នកមិនបានដឹងទេឬ កាលពីប្រហែលជាដប់ឆ្នាំមុន ម្នាក់ឈ្មោះបណ្ដោះអាសន្ននៅបំបន់របស់អ្នក ជាម្នាក់ដែលខ្លាំងពូកែនៅក្នុងសាសនានៅក្នុងតំបន់នោះ?

សង្ឃឹម៖ ស្គាល់គាត់? បាទ គាត់ស្នាក់នៅក្នុងទីខ្វះព្រះគុណ ជាក្រុងមួយដែលនៅប្រហែលពីរយោជន៍ចេញពីទីស្មោះត្រង់ ហើយគាត់ស្នាក់នៅក្បែរម្នាក់ឈ្មោះថាបែរក្រោយ។

គ្រីស្ទាន៖ ត្រូវហើយ គាត់បានស្នាក់នៅក្រោមដំបូលផ្ទះតែមួយជាមួយគាត់។ ដូច្នេះបុរសនោះមានការភ្ញាក់ដឹងខ្លួនយ៉ាងខ្លាំងម្ដងដែរ។ ខ្ញុំជឿថាពេលនោះគាត់មានការមើលឃើញខ្លះនូវអំពើបាបរបស់គាត់ ហើយព្រមទាំងឈ្នួលរបស់វាផង។

សង្ឃឹម៖ ខ្ញុំគិតដូចជាអ្នកដែរ ដោយសារ (ផ្ទះរបស់ខ្ញុំនៅមិនឆ្ងាយជាងបីយោជន៍ពីគាត់ទេ) ជាញឹកញាប់គាត់តែងតែមករកខ្ញុំ ហើយមកដោយទឹកភ្នែកយ៉ាងខ្លាំងផង។ ពិតណាស់ ខ្ញុំពិតជាអាណិតបុរសនោះណាស់ ហើយ

មិនមែនគ្មានសង្ឃឹមសោះដល់គាត់នោះឡើយ តែគេនឹងដឹងថា មិនមែនគ្រប់គ្នាដែលស្រែកថា "ព្រះអម្ចាស់ ព្រះអម្ចាស់!"

គ្រីស្ទាន៖ គាត់បានប្រាប់ខ្ញុំម្តង ថាគាត់បានសម្រេចនឹងធ្វើធម្មយាត្រាដូចដែលយើងធ្វើនៅពេលនេះដែរ។ តែរំពេចនោះគាត់បានស្គាល់ម្នាក់ឈ្មោះថាសង្គ្រោះខ្លួនឯង ហើយបន្ទាប់មកគាត់បានក្លាយជាមនុស្សចម្លែកដល់ខ្ញុំ។

សង្ឃឹម៖ ពេលនេះ ក្នុងកាលដែលយើងជជែកពីគាត់ ចូរយើងសួររកហេតុផលដែលគាត់បានបែរចេញភ្លាមៗនិងអ្វីផ្សេងទៀតនោះ។

គ្រីស្ទាន៖ វាពិតជាមានប្រយោជន៍ណាស់ តែសូមអ្នកធ្វើការចាប់ផ្តើមចុះ។

សង្ឃឹម៖ អីចឹង មានហេតុផលបួនយ៉ាងនៅក្នុងការកាត់ស្រាយរបស់ខ្ញុំពីការនោះ

1. បើទោះជាសតិរបស់បុរសនោះមានការភ្ញាក់ដឹងខ្លួនក៏ដោយ តែគំនិតរបស់គេមិនបានផ្លាស់ប្រែឡើយ។ ដូច្នេះ នៅពេលដែលអំណាចនៃកំហុសត្រូវរសាយបាត់ទៅ ដែលជាអ្វីធ្វើឱ្យគេថយចេញពីសាសនា។ ដូច្នេះពួកគេក៏ត្រឡប់ទៅរកផ្លូវរបស់គេម្តងទៀតដោយខ្លួនឯង។ យើងទាំងបានឃើញថាឆ្កែក៏ធុញនឹងអ្វីដែលវាស៊ីដែរ កាលណាដែលជម្ងឺរបស់គាត់បានឈ្នះនោះ វានឹងក្អួតនិងបោះចោលទាំងអស់ ហើយមិនមែនគេធ្វើដូច្នេះដោយគំនិតដែលមានសិរីភាពនោះទេ (ប្រសិនបើយើងនឹងនិយាយថាឆ្កែមានគំនិត) តែដោយសារ

វាធ្វើឱ្យមានបញ្ហាដល់ក្រពះរបស់វា។ តែពេលនេះ នៅពេលដែលក្រពះរបស់វាលែងឈឺ ហើយវាស្រួលបួលឡើងនោះ សេចក្តីប៉ងប្រាថ្នារបស់វាមិនដាច់ចេញពីកំអួតរបស់វាឡើយ វាក៏ត្រឡប់ក្រោយរួចលិឌកំអួតនោះវិញ។ ហើយដូច្នេះវាត្រូវបានសរសេរមកពិតមែនថា "ឆ្កែត្រឡប់ទៅរកកំអួតរបស់វាម្តងទៀត"។

**"តែមានការកើតមកដល់គេ ដូចជាពាក្យទំនៀមពិតដែលថា ឆ្កែបានត្រឡប់ទៅស៊ីកំអួតវា ឯជ្រូកញីដែលគេលាងស្អាតហើយ បានទៅននៀលនៅក្នុងខ្ទាចវិញ។" ពេត្រុសទី២ 2:22**

ការនេះ ខ្ញុំនិយាយថា ពិតជាក្តៅណាស់សម្រាប់ស្ថានសួគ៌ ដោយសីលធម៌នៃញាណតែមួយមុខនិងសេចក្តីភ័យខ្លាចនៃការធ្វើទុក្ខនៃស្ថាននរក ដូចជាញាណនៃស្ថាននរករបស់ពួកគេនមិងសេចក្តីកោតខ្លាចនៃការកាត់ទោសធ្វើឱ្យបារម្ភនិងត្រជាក់ទៅ ដូច្នេះសេចក្តីប៉ងប្រាថ្នារបស់ពួកគេដែលចង់បានស្ថានសួគ៌និងសេចក្តីសង្គ្រោះក៏ទៅជាត្រជាក់ដែរ។ ដូច្នេះវាក៏កន្លងបាត់ទៅថានៅពេលដែលកំហុសរបស់ពួកគេនិងភាពភ័យខ្លាចបានកន្លងបាត់ទៅសេចក្តីប៉ងប្រាថ្នារបស់ពួកគេដែលចង់បានស្ថានសួគ៌និងសុភមង្គលក៏ស្លាប់ហើយពួកគេត្រឡប់ទៅរកផ្លូវរបស់ពួកគេវិញម្តងទៀត។

2. ហេតុផលមួយទៀតគឺ ពួកគេមានការភ័យខ្លាចតាមគេតាមឯងដោយគ្មានការពិចារណាដែលធ្វើជាមេលើពួកគេ។ ពេលនេះខ្ញុំនិយាយពីសេចក្តីកោត

ខ្លាចដែលពួកគេមានពីមនុស្ស "សេចក្តីភ័យខ្លាចដល់មនុស្សនោះជាអន្ទាក់។
"

**"ការដែលខ្លាចចំពោះមនុស្ស នោះនាំឱ្យជាប់អន្ទាក់ តែអ្នកណាដែលទុកចិត្ត ដល់ព្រះយេហូវ៉ាពិត នោះនឹងបានសុខវិញ។" សុភាសិត 29:25**

ដូច្នេះ បើទោះជាពួកគេហាក់ដូចជាក្តៅចង់បានស្ថានសួគ៌ ដរាបណាដែលអណ្តាតភ្លើងនៃស្ថាននរកនៅក្បែរត្រចៀករបស់ពួកគេ តែនៅពេលដែលសេចក្តីភ័យខ្លាចនោះបានកន្លងផុតទៅបន្តិចទៅ ពួកគេក៏បាននាំខ្លួនទៅរកគំនិតទីពីរ។ និយាយទៅថា វាល្អដែលឆ្លាតវៃ ហើយមិនរត់នោះ (ដោយសារពួកគេមិនដឹងថាជាអ្វី) ការប្រថុយប្រថាននឹងការបាត់បង់ទាំងអស់ ឬយ៉ាងហោចណាស់ពីការដែលនាំខ្លួនរបស់ពួកគេទៅក្នុងបញ្ហាដែលគេមិនផុតនិងមិនចាំបាច់នោះ ហើយដូច្នេះពួកគេបានធ្លាក់ចូលទៅជាមួយនឹងលោកិយម្តងទៀតទៅ។

3. សេចក្តីអាម៉ាសដែលចូលទៅក្នុងសេចក្តីកុហករបស់សាសនាក៏ជាការរារាំងនៅផ្លូវរបស់ពួកគេដែរ។ ពួកគេពេញដោយអំណួតនិងឆ្មើងឆ្មៃ ហើយសាសនានៅក្នុងភ្នែករបស់ពួកគេវាទាបថោកនិងគួរឱ្យអាម៉ាស់ណាស់។ ដូច្នេះ នៅពេលដែលពួកគេបាត់នូវអារម្មណ៍ពីស្ថាននរកនិងសេចក្តីក្រោធដែលនឹងត្រូវមក ពួកគេក៏ត្រឡប់ទៅរកផ្លូវពីដើមរបស់ពួកគេវិញ។

4. កំហុស និងការដែលសញ្ជឹងគិតពីសេចក្តីភ័យខ្លាចធ្វើឱ្យពួកគេមានទុក្ខ

លំបាកជាខ្លាំង។ ពួកគេមិនចូលចិត្តមើលឃើញនូវសេចក្តីលំបាកវេទនារបស់ពួកគេមុនពេលដែលវាមកដល់នោះឡើយ។ បើទោះជានូវរូបភាពដំបូងរបស់វាក៏ដោយ ប្រសិនបើពួកគេចូលចិត្តរូបភាពដូច្នោះ នោះពួកគេនឹងបានហោះទៅកន្លែងដែលពួកសុចរិតនឹងហោះទៅដែរហើយនឹងមានសុវត្ថិភាព។ តែដោយសារតែពួកគេធ្វើដូចដែលអ្វីដែលខ្ញុំបានលើកមកពីមុននោះ ទាំងបានបដិសេធនូវគំនិតដែលមានកំហុសនិងការភ័យខ្លាចផង។ ដូច្នេះ នៅរំពេចណាដែលពួកគេរួចផុតពីការភ្ញាក់ខ្លួនអំពីសេចក្តីភ័យខ្លាចនិងសេចក្តីក្រោធរបស់ព្រះនោះ ពួកគេក៏ធ្វើឱ្យចិត្តរបស់ពួកគេរឹងឡើងដោយអំណរផង ហើយក៏ជ្រើសរើសយកផ្លូវណាដែលនឹងធ្វើឱ្យចិត្តរបស់ពួកគេកាន់តែរឹងឡើងផង។

គ្រីស្ទានៈ អ្នកទៅជិតដល់នូវជំនួញនោះហើយ ដោយសារបាតនៃការទាំងអស់នោះគឺជា ការចង់បានការផ្លាស់ប្តូរនៅក្នុងគំនិតនិងបំណងរបស់ពួកគេ។ ហើយដូច្នេះពួកគេប្រៀបដូចជាអ្នកទោសដែលឈរនៅចំពោះចៅក្រមដែរ។ គាត់រំជើបរំជួលហើយភ័យញ័រ ហើយមើលទៅដូចជាធ្វើការលន់តួបាបចេញពីចិត្តផង។ តែបាតនៃការទាំងអស់នោះគឺ សេចក្តីភ័យខ្លាចដល់បង្ហៀរ មិនមែនដល់ទិសដៅនៃទោសកំហុសនោះឡើយ ដូចជាបង្ហាញមកច្បាស់ហើយដោយសារ ចូរឱ្យមនុស្សនេះមានសេរីភាព ហើយគាត់នឹងក្លាយជាចោរហើយជាមនុស្សចង្រៃដដែល តែបើសិនជាគំនិតរបស់គាត់បានផ្លាស់ប្តូរវិញនោះគាត់មិនមិនដូច្នោះឡើយ។

សង្ឃឹមៈ ពេលនេះខ្ញុំបានបង្ហាញអ្នកពីហេតុផលនៃការបែរត្រឡប់ទៅវិញដែលអ្នកបានបង្ហាញពីបែបបទនោះប្រាប់ដល់ខ្ញុំ

គ្រីស្ទាន៖ ដូច្នេះខ្ញុំនឹងបង្ហាញប្រាប់អ្នកដោយពេញចិត្ត
1. ពួកគេបានទាញយកគំនិតទាំងអស់របស់ពួកគេចេញមក ពីការដែកពួកគេអាចចងចាំពីព្រះ ពីសេចក្ដីស្លាប់ និងការកាត់ទោសដែលនឹងត្រូវមកដល់។

2. បន្ទាប់មកពួកគេបានបោះចោលដោយកម្រិតនៃតួនាទីផ្ទាល់ខ្លួន ដូចជាការអធិស្ឋាននៅក្នុងបន្ទប់បិទជិត ការដាក់កំហិតដល់តណ្ហារបស់ពួកគេ ការមើល សេចក្ដីទុក្ខសោកដោយបាប និងការបែបនោះ។

3. បន្ទាប់មកពួកគេបានគេចចេញពីបក្សពួករបស់គ្រីស្ទានដែលរស់រវើកនិងកក់ក្ដៅ។

4. បន្ទាប់មកទៀតពួកគេចាប់ផ្ដើមទៅជាត្រជាក់នៅក្នុងតួនាទីជាសាធារណៈ ដូចជា ការស្ដាប់ ការអាន ការជួបជុំដែលគោរពកោតខ្លាចដល់ព្រះ និងការបែបដូចនោះ។

5. បន្ទាប់មកពួកគេចាប់ផ្ដើមបង្កើតប្រហោង ដូចដែលយើងនិយាយថា វាមាននៅក្នុងអាវក្រៅរបស់អ្នកគោរពកោតខ្លាចព្រះមួយចំនួន ហើយដោយបែបអាក្រក់ផង ដែលពួកគេអាចនឹងមានពណ៌ស្រដៀងនោះ ដើម្បីបោះបង់ចោលនូវសាសនា (ដោយសារភាពកំសោយមួយចំនួនដែលពួកគេផ្ដុំឡើងនៅក្នុងពួកគេ) នៅខាងក្រោយខ្នងរបស់ពួកគេ។

6. បន្ទាប់មកពួកគេចាប់ផ្តើមស្តាប់តាម និងចូលខ្លួនជាមួយមនុស្សខាងសាច់ឈាម ធូររលុង និងព្រៃផ្សៃ។

7. បន្ទាប់មកពួកគេទុកឱកាសដល់គំនិតខាងសាច់ឈាមនិងឃោឃៅដោយសំងាត់។ ហើយពួកគេរីករាយប្រសិនបើពួកគេអាចឃើញការដូច្នេះនៅក្នុងអ្នកដែលត្រូវបានរាប់ថាស្មោះត្រង់ នោះពួកគេអាចនឹងធ្វើវាដោយក្លាហានតាមរយៈគំរូរបស់ពួកគេ។

8. បន្ទាប់ពីនេះពួកគេចាប់ផ្តើមប្រទ្បែងលេងជាមួយនឹងបាបបន្តិចបន្តួចដោយបើកចំហរ។

9. ហើយបន្ទាប់មក ក៏ត្រូវធ្វើចិត្តឱ្យរឹងទ្បើង ពួកគេក៏បង្ហាញរូបរាងពិតរបស់ពួកគេចេញមក។ ដូច្នេះ ដោយត្រូវបានបោះទម្លាក់ម្តងទៀតចូលទៅក្នុងជង្ហុកនៃសេចក្តីវេទនា លើកលែងតែការអស្ចារ្យនៃព្រះគុណទប់ស្កាត់វា នោះពួកគេនឹងត្រូវវិនាសអស់កល្បជានិច្ចនៅក្នុងសេចក្តីបញ្ឆោតរបស់ពួកគេផ្ទាល់។

## ប្រទេសនៃអ្នកដែលមានប្តី

ពេលនេះ ខ្ញុំបានឃើញនៅក្នុងសុបិនរបស់ខ្ញុំថា មកដល់ពេលនេះ អ្នកធ្វើធម្មយាត្រាបានចេញផុតពីទឹកដីដែលមានមន្តអាគមន៍ ហើយកំពុងតែចូលទៅក្នុងប្រទេសនៃអ្នកមានប្តី។

"ឯងមិនត្រូវគេហៅថា ទីក្រុងចោលបង់ ហើយដីឯងក៏មិនត្រូវហៅថា ទីស្ងាត់ជ្រងំទៀតឡើយ គឺឯងនឹងត្រូវហៅថា ទីស្រឡាញ់ ហើយដីរបស់ឯងថាជាអ្នកមានប្តីវិញ ពីព្រោះព្រះយេហូវ៉ាទ្រង់មានសេចក្តីរីករាយចំពោះឯង ហើយដីឯងនឹងបានរៀបការ" **អេសាយ 62:4**

ដែលខ្យល់របស់ពួកគេផ្អែមនិងគួរជាទីពេញចិត្តណាស់។ ហើយផ្លូវដម្រង់កាត់តាមនោះតែម្តង នោះពួកគេក៏បានកំសាន្តចិត្តរបស់ពួកគេនៅទីនោះមួយគ្រាផងដែរ។ ហើយនៅទីនេះ ពួកគេបានឮសម្លេងបក្សីយំបន្តរហូត ហើយបានឃើញផ្ការាល់ថ្ងៃលេចមកនៅក្នុងផែនដី ហើយបានឮសម្លេងរបស់សត្វអណ្តើកនៅក្នុងទឹកដីនោះផងដែរ។

"ស្ងួនសំឡាញ់របស់ខ្ញុំបានមានព្រះបន្ទូលនឹងខ្ញុំថា មាសសំឡាញ់អើយ ចូរក្រោកឡើង ស្រស់ប្រិមប្រិយអើយ ចូរចេញមក។ ដ្បិតមើល រដូវរងាកន្លងទៅហើយ ភ្លៀងក៏រាំងស្រឡះហើយដែរ។ ផ្កាទាំងប៉ុន្មានកំពុងតែលេចឡើងនៅផែនដី ពេលដែលសត្វហើរយំកញ្ជ្រៀវបានមកដល់ ក៏ឮសំឡេងលលកនៅក្នុងស្រុកយើងហើយ" **ចំរៀងសាឡូម៉ូន 2:10-12**

នៅប្រទេសនេះ ព្រះអាទិត្យចែងចាំងទាំងយប់ទាំងថ្ងៃ ដោយសារវានៅខាងលើជ្រលងនៃម្លប់នៃសេចក្ដីស្លាប់ ហើយវាចេញផុតពីកណ្ដាប់ដៃរបស់យក្សនៃសេចក្ដីអស់សង្ឃឹម ហើយពួកគេមិនអាចមើលឃើញវិមាននៃការសង្ស័យពីកន្លែងនេះឃើញឡើយ។ នៅទីនេះពួកគេមើលឃើញទីក្រុងដែលពួកគេកំពុងតែធ្វើដំណើរទៅ ហើយទីនេះពួកគេក៏បានជួបជាមួយនឹងអ្នកស្រុកមួយចំនួននៃទីក្រុងនោះ ដោយសារនៅលើទឹកដីនេះមានមនុស្សដែលភ្លឺចែងចាំងតែងតែដើរកាត់ ដោយសារវានៅក្នុងព្រំប្រទល់នៃស្ថានសួគ៌។ នៅក្នុងទឹកដីនេះហើយ ដែលកិច្ចសន្យារវាងកូនក្រមុំនិងកូនកំលោះត្រូវបានធ្វើជាថ្មីឡើងវិញ។ ហើយនៅទីនេះ "កាលដែលកូនកម្លោះរីករាយនឹងកូនក្រមុំរបស់ខ្លួនដូចដែលព្រះរបស់ពួកគេរីករាយនឹងពួកគេដែរ។" នៅទីនេះពួកគេមិនត្រូវការពោតនិងស្រាទំពាំងបាយជូរទៀតឡើយ ដោយសារនៅលើទឹកដីនេះពួកគេបានជួបនឹងការបរិបូរទៅដោយរបស់ដែលពួកគេបានស្វែងរកហើយក្នុងការធ្វើធម្មយាត្រា។ នៅទីនេះពួកគេបានឮសម្លេងចេញពីទីក្រុងមក សម្លេងឮៗនិយាយថា "ចូរនិយាយទៅកាន់កូនស្រីរបស់ស៊ីយ៉ូន មើលទៅ សេចក្ដីសង្គ្រោះរបស់អ្នកមកដល់ហើយ មើលទៅរង្វាន់របស់គាត់នៅក្នុងជាមួយគាត់ហើយ។" នៅទីនេះ គ្រប់ទាំងអ្នកស្រុកទាំងអស់នៃប្រទេសនោះហៅពួកគេថា "រាស្ត្របរិសុទ្ធ ពួកដែលត្រូវបានរំដោះរួចរបស់ព្រះអម្ចាស់។" និងការផ្សេងៗទៀត។

"ឯងមិនត្រូវគេហៅថា ទីក្រុងចោលបង់ ហើយដីឯងក៏មិនត្រូវហៅថា ទីស្ងាត់ជ្រងំទៀតឡើយ គឺឯងនឹងត្រូវហៅថា ទីស្រឡាញ់ ហើយដីរបស់ឯងថាជាអ្នក

មានប្ដីវិញ ពីព្រោះព្រះយេហូវ៉ាទ្រង់មានសេចក្ដីរីករាយចំពោះឯង ហើយដីឯង នឹងបានរៀបការ។ ដ្បិតដែលមនុស្សកំលោះយកស្រីក្រមុំធ្វើជាប្រពន្ធយ៉ាង ណា នោះពួកកូនប្រុសៗរបស់ឯងនឹងមករួមនឹងឯងយ៉ាងនោះដែរ ហើយ ដែលប្ដីថ្មោងថ្មីមានចិត្តរីករាយចំពោះប្រពន្ធយ៉ាងណា នោះព្រះនៃឯងនឹងមាន សេចក្ដីរីករាយចំពោះឯងយ៉ាងនោះដែរ។ ឱក្រុងយេរូសាឡឹមអើយ អញបាន ដាក់ពួកយាមល្បាតនៅលើកំផែងឯងហើយ គេនឹងមិននៅមាត់ស្ងៀម ទោះ យប់ ឬថ្ងៃផង ឯងរាល់គ្នាដែលជាអ្នករំឭកព្រះយេហូវ៉ាអើយ កុំឲ្យនៅស្ងៀម ឡើយ។ ហើយកុំឲ្យទ្រង់នៅទំនេរឲ្យសោះ ដរាបដល់ទ្រង់បានតាំងក្រុងយេរូ សាឡឹមឡើង ឲ្យជាទីសរសើរនៅលើផែនដី។ ព្រះយេហូវ៉ាទ្រង់បានស្បថ ដោយព្រះហស្តស្តាំទ្រង់ ហើយដោយព្រះពាហុដ៏មានឥទ្ធិឫទ្ធិរបស់ទ្រង់ថា ពិតប្រាកដជាអញនឹងមិនឲ្យស្រូវរបស់ឯងទៅធ្វើជាអាហារដល់ពួកខ្មាំងសត្រូវ ឯងទៀត ហើយពួកសាសន៍ដទៃនឹងមិនផឹកទឹកទំពាំងបាយជូរដែលឯងបានខំ ធ្វើទៀតឡើយ។ គឺពួកអ្នកដែលបានច្រូតផលនោះនឹងស៊ីវិញ ហើយគេនឹង សរសើរដល់ព្រះយេហូវ៉ា ឯពួកអ្នកដែលបានប្រមូលផ្លែនោះ គេនឹងផឹកនៅ ក្នុងទីលាននៃទីបរិសុទ្ធរបស់អញ។ ចូរចូលទៅ ចូរចូលទៅតាមទ្វារចុះ ចូររៀប ផ្លូវសម្រាប់ប្រជាជន ចូរលើក ចូរលើកថ្នល់ឡើង ចូរប្រមូលយកថ្មចេញ ហើយបង្ហូតទង់ជ័យ១សម្រាប់សាសន៍ទាំងឡាយ។ មើល ព្រះយេហូវ៉ាទ្រង់ បានប្រកាសប្រាប់រហូតដល់ចុងផែនដីបំផុត ឲ្យប្រាប់ដល់កូនស្រីស៊ីយ៉ូនថា មើលសេចក្ដីសង្គ្រោះរបស់ឯងបានមកដល់ហើយ មើល ទ្រង់យករង្វាន់មកជា មួយ ហើយសំណងរបស់ទ្រង់ក៏នាំមុខទៅ។ គេនឹងហៅពួកនោះថា ជា សាសន៍បរិសុទ្ធ គឺជាពួកដែលព្រះយេហូវ៉ាទ្រង់ប្រោសលោះ នោះឯងនឹងបាន

ហៅថា ទីក្រុងដែលគេស្វែងរក ជាទីក្រុងដែលមិនត្រូវបង់ចោលឡើយ។" អេសាយ 62:4-12

ពេលនេះ នៅពេលដែលពួកគេដើរនៅក្នុងទឹកដីនេះ ពួកគេមានអំណរច្រើនជាងនៅតំបន់ដែលដាច់ឆ្ងាយចេញពីនគរដែលគេទៅនោះ ហើយការដែលទៅជិតដល់ទីក្រុង ពួកគេក៏បានឃើញទេសភាពយ៉ាងល្អឥតខ្ចោះថែមទៀត ។ វាត្រូវបានសាងសង់ឡើងដោយត្បូងនិងថ្មមានតម្លៃ ហើយផ្លូវនៅទីនោះត្រូវបានសង់ចេញពីមាស។ ដូច្នេះដោយសារតែសិរីល្អពីធម្មជាតិរបស់ទីក្រុង និងពន្លឺចែងចាំងផ្លាតដោយសារពន្លឺព្រះអាទិត្យទៅលើទីក្រុងនោះផង ហើយដោយសារមានបំណងចង់បាននោះគ្រីស្ទានក៏ធ្លាក់ខ្លួនឈឺ ពេញដោយសង្ឃឹមក៏មានជម្ងឺពីរបីមុខដែរ។ ដូច្នេះ នៅទីនេះពួកគេបានសម្រាកក្បែរទីនោះមួយរយៈ ដោយស្រែកចេញមកដោយសារតែការឈឺចាប់តាំងប៉ុន្មានរបស់ពួកគេថា "ប្រសិនបើអ្នកឃើញមនុស្សជាទីស្រឡាញ់របស់ខ្ញុំ សូមប្រាប់ទ្រង់ថាខ្ញុំមានជម្ងឺស្នេហា។"

ប៉ុន្តែបន្ទាប់ពីបានកម្លាំងចម្រើនឡើងបន្តិចមក ហើយបានប្រសើរឡើងដែលអាចនឹងទ្រាំទ្រជម្ងឺរបស់ពួកគេបាន នោះពួកគេបានដើរតាមផ្លូវរបស់ពួកគេទៀត ហើយមកកាន់តែជិតទៅៗ មានដើមផ្លែឈើ ចម្ការទំពាំងបាយជូរ និងសួនច្បារ ហើយឃ្លោងទ្វាររបស់ពួកគេបានបើកទៅកាន់ផ្លូវធំ។ ពេលនេះនៅពេលដែលពួកគេបានមកដល់កន្លែងទាំងនេះ មើលទៅអ្នករក្សាសួនបានឈរនៅផ្លូវ ហើយអ្នកធ្វើធម្មយាត្រានិយាយទៅគាត់ថា "តើចម្ការទំពាំងបាយជូរនិងសួនច្បារយ៉ាងល្អនេះជារបស់អ្នកណាដែរ?" គាត់បានឆ្លើយថា "ទាំងអស់នោះជារបស់ស្តេច ហើយត្រូវបានដាំនៅទីនេះតាមការគាប់ចិត្តដល់ទ្រង់

ហើយក៏សម្រាប់ជាការកំសាន្តដល់អ្នកធ្វើធម្មយាត្រាដែរ។" ដូច្នេះអ្នករក្សាសួនបាននាំពួកគេចូលទៅក្នុងចម្ការទំពាំងបាយជូរ ហើយបានប្រាប់ពួកគេឱ្យបរិភោគផល្លាទាំងនោះផង។

**"កាលណាឯងចូលទៅក្នុងចម្ការទំពាំងបាយជូររបស់អ្នកជិតខាងណា នោះនឹងបរិភោគផលចម្អែតតាមចិត្តបាន ប៉ុន្តែ មិនត្រូវបេះដាក់ក្នុងកញ្ច្រែងឯងទេ" ចោទិយកថា 23:24**

គាត់ក៏បានបង្ហាញពួកគេនូវដំណើររបស់សម្រាប់នៅទីនោះដែរ ហើយនឹងកន្លែងស្នាក់ដែលទ្រង់ចូលចិត្តនៅ ហើយនៅទីនេះពួកគេបានស្នាក់នៅនិងដេកផង។

ពេលនេះខ្ញុំមើលទៅក្នុងសុបិនរបស់ខ្ញុំឃើញថា ពួកគេបាននិយាយច្រើនទៀតក្នុងកាលដែលដេកលក់នៅពេលនេះច្រើនជាងពេលណាទាំងអស់ក្នុងការធ្វើដំណើររបស់ពួកគេ។ ហើយដោយបានកំសាន្តចិត្តនៅទីនោះ អ្នករក្សាសួនបានទាំងនិយាយមកខ្ញុំថា "ដូច្នេះតើអ្នកបានរីករាយនឹងការនេះដែរទេ? វាជាធម្មជាតិរបស់ទំពាំងបាយជូរនៃចម្ការទំពាំងបាយជូរនេះ ដែលវាចូលទៅយ៉ាងផ្អែមល្ហែម ដែលធ្វើឱ្យបបូរមាត់របស់ពួកគេដែលដេកលង់លក់និយាយឡើងផង។"

ដូច្នេះខ្ញុំបានឃើញថា នៅពេលដែលពួកគេភ្ញាក់ឡើង ពួកគេបានរៀបចំខ្លួនដើម្បីនឹងទៅកាន់ទីក្រុងតែម្តង តែដូចដែលខ្ញុំនិយាយអីចឹងថា ការដែលពន្លឺ

ព្រះអាទិត្យចែងចាំងទៅលើទីក្រុង (ដោយសារទីក្រុងធ្វើពីមានសុទ្ធ) នោះវាធ្វើឱ្យមានសិរីល្អចែងចាំងយ៉ាងខ្លាំង ដែលពួកគេមិនអាចនឹងមើលទៅកាន់ទីនោះដោយមុនទទេរផ្ទាល់បាននូវឡើយ តែមានតែតាមរយៈឧបករណ៍ម្យ៉ាងដែលត្រូវបានបង្កើតមកសម្រាប់គោលបំណងនោះ។

**"កំផែងនោះបានធ្វើពីត្បូងមណីជោតិ ហើយទីក្រុងក៏ធ្វើពីមាសសុទ្ធ ដូចជាកែវថ្លាល្អ" វិវរណៈ 21:18**

**"ហើយយើងរាល់គ្នាទាំងអស់ ដែលកំពុងតែរំពឹងមើលសិរីល្អព្រះអម្ចាស់ ទាំងមុខទទេ ដូចជាឆ្លុះមើលទ្រង់ក្នុងកញ្ចក់ យើងកំពុងតែផ្លាស់ប្រែទៅ ឲ្យដូចជារូបឆ្លុះនោះឯង ពីសិរីល្អទៅដល់សិរីល្អ គឺដោយសារព្រះអម្ចាស់ដ៏ជាព្រះវិញ្ញាណ ។" កូរិនថូសទី២ 3:18**

ដូច្នេះខ្ញុំបានឃើញថា ពួកគេបានបន្តទៅមុខទៀត ទីនោះពួកគេបានជួបបុរសពីនាក់នៅក្នុងពន្លឺរស្មីចែងចាំងមកដូចជាមាស ហើយមុខរបស់ពួកគេក៏ចែងចាំងដូចពន្លឺដែរ។

សេចក្តីលំបាកចុងក្រោយ

បុរសពីរនាក់នេះបានសួរទៅកាន់អ្នកធ្វើធម្មយាត្រាថាពួកគេមកពីណា ហើយពួកគេក៏បានប្រាប់ទៅ។ ពួកគេក៏បានសួរថាតើពួកគេបានស្នាក់នៅទីណា តើមានការលំបាកនិងគ្រោះថ្នាក់អ្វីខ្លះ មានការកំសាន្តនិងសេចក្តីអំណារ

អ្វីខ្លះដែលពួកគេបានជួបនៅតាមផ្លូវ។ ហើយពួកគេក៏បានប្រាប់ទៅ។ បន្ទាប់មកបុរសទាំងពីនោះនិយាយថា "អ្នកមានការលំបាកពីរទៀតដែលអ្នកត្រូវជួបប្រទះ ហើយបន្ទាប់មកអ្នកនឹងដល់ទីក្រុងហើយ។"

បន្ទាប់មកគ្រីស្ទាននិងគ្នារបស់គាត់បានសូមឱ្យបុរសទាំងពីរទៅជាមួយពួកគេ ដូច្នេះពួកគេបានប្រាប់ថានឹងទៅជាមួយ។ "តែ" ពួកគេនិយាយថា "តែអ្នកត្រូវតែយកវាបានដោយជំនឿរបស់អ្នកផ្ទាល់។" ដូច្នេះខ្ញុំបានឃើញនៅក្នុងសុបិនរបស់ខ្ញុំបានពួកគេបានទៅជាមួយគ្នា រហូតដល់កន្លែងដែលពួកគេមើលឃើញឃ្លោងទ្វារ។

ពេលនេះខ្ញុំក៏ឃើញទៀតថានៅចន្លោះពួកគេនិងឃ្លោងទ្វារមានទន្លេមួយ តែមិនមានស្ពានឆ្លងទេ។ ទន្លេក៏ជ្រៅខ្លាំង។ ដូច្នេះដោយឃើញបែបនោះ អ្នកធ្វើធម្មយាត្រាបានស្រឡាំងកាំង ប៉ុន្តែបុរសដែលទៅជាមួយពួកគេនិយាយថា "អ្នកត្រូវតែឆ្លងកាត់វា មិនដូច្នោះអ្នកមិនអាចទៅដល់ឃ្លោងទ្វារឡើយ។"

អ្នកធ្វើធម្មយាត្រាក៏ចាប់ផ្តើមសួរថាតើមានផ្លូវណាផ្សេងទៀតទេដើម្បីទៅដល់ឃ្លោងទ្វារ ពួកគេក៏តបថា "មាន តែមិនមានមនុស្សណាម្នាក់ក្រៅពីមនុស្សពីរនាក់គឺ អេណុកនិងអេលីយ៉ា ដែលត្រូវបានអនុញ្ញាតឱ្យដើរឆ្លងកាត់តាមផ្លូវនោះតាំងតែពីការករកើតនៃពិភពលោកនេះម៉្លេះ ក៏មិនមានអ្នកណាម្នាក់ទៀតរហូតដល់សូរត្រែត្រូវបន្លឺឡើង។"

**"នៃ ខ្ញុំប្រាប់អ្នករាល់គ្នាពីសេចក្ដីអាថ៌កំបាំង គឺថាយើងទាំងអស់គ្នានឹងមិនដេកលក់ទៅទេ។ តែទាំងអស់គ្នានឹងបានផ្លាស់ប្រែទៅក្នុង១រំពេចវិញ គឺក្នុង១**

ប៉ប្រិចភ្នែកប៉ុណ្ណោះ ក្នុងកាលដែលឮស្នូរត្រែក្រោយបង្អស់ ដ្បិតត្រែនឹងឮឡើង មែន នោះពួកស្លាប់នឹងរស់ឡើងវិញ មិនពុករលួយទៀតឡើយ រួចយើងរាល់គ្នានឹងបានផ្លាស់ប្រែទៅ″ កូរិនថូសទី១ 15:51, 52

បន្ទាប់មកអ្នកធ្វើធម្មយាត្រា ជាពិសេសគ្រីស្ទាន ចាប់ផ្តើមខូចចិត្តនៅក្នុងគំនិតរបស់ពួកគេ ហើយបានមើលទៅផ្លូវនេះផ្លូវនោះ តែមិនមានឃើញផ្លូវណាសោះ ដែលពួកគេនឹងអាចគេចផុតពីទន្លេ។ បន្ទាប់មកពួកគេបានបុរសទាំងពីរថា តើទឹកនេះមានជម្រៅប៉ុន្មាន? ពួកគេនិយាយថា "ទេ" តែពួកគេមិនអាចជួយបាននៅក្នុងបញ្ហានេះបានឡើយ ដោយពួកគេនិយាយថា ‟អ្នកនឹងរកឃើញថាវាកាន់តែជ្រៅ ឬកាន់តែរាក់អាស្រ័យលើការដែលអ្នកជឿដល់ស្តេចនៃទីនោះ។″

បន្ទាប់មកពួកគេបានរៀបខ្លួនរបស់ពួកគេចូលទៅក្នុងទឹក ហើយកាលដែលចូលទៅគ្រីស្ទានក៏បានលិចចូលទៅ។ ហើយបានស្រែកទៅកាន់មិត្តសំឡាញ់របស់គាត់ពេញដោយសង្ឃឹមថា ‟ខ្ញុំលិចចូលទៅក្នុងទឹកជ្រៅ រលកធំបានគ្របពីលើក្បាលរបស់ខ្ញុំហើយ ហើយរលកទាំងអស់បានគ្របមកលើខ្ញុំ។″

បន្ទាប់មកនិយាយទៀតថា "ចូរមានអំណរចុះបងប្រុសខ្ញុំអើយ ខ្ញុំប៉ះបាតដើយ ហើយវាល្អទេ។" បន្ទាប់មកគ្រីស្ទាននិយាយថា ‟អាហ៍!″ សំឡាញ់ខ្ញុំអើយ ទុក្ខសោកនៃសេចក្តីស្លាប់បានព័ទ្ធជុំវិញខ្ញុំ ខ្ញុំនឹងមិនបានឃើញទឹកដីដែល

ពេញដោយទឹកដោះនិងទឹកឃ្មុំឡើយ។ ហើយដោយមានសេចក្តីងងឹតនិងសេចក្តីផិតភ័យយ៉ាងខ្លាំងបានមកលើគ្រីស្ទាន ដូច្នេះគាត់មិនអាចមើលឃើញនៅខាងមុខគាត់បាន ហើយនៅទីនេះគាត់បានបាត់បង់ញាណរបស់គាត់យ៉ាងធំ ដូច្នេះគាត់មិនអាចទាំងចង់ចាំឬនិយាយតាមលំដាប់លំដោយពីការកំសាន្តចិត្តដ៏ផ្អែមល្ហែមដែលគាត់បានជួបនៅតាមផ្លូវនៃធម្មយាត្រារបស់គាត់បានឡើយ។ តែគ្រប់ទាំងពាក្យដែលគាត់និយាយនៅតែសំដៅបង្ហាញថា គាត់មានការផិតភ័យនៅក្នុងគំនិត និងសេចក្តីភ័យខ្លាចនៅក្នុងចិត្តថាគាត់នឹងស្លាប់នៅក្នុងទន្លេ ហើយនឹងមិនអាចបានទៅដល់ផ្លូវចូលទៅឃ្លោងទ្វារនោះទេ។ ហើយនៅទីនេះអ្នកឈរក្បែរបានឃើញថា គាត់មានគំនិតពេលដោយបញ្ហាពីអំពើបាបដែលគាត់បានធ្វើ ទាំងមុននិងក្រោយដែលគាត់មកធ្វើធម្មយាត្រា។ "គេសង្កេតឃើញថាគាត់មានការលំបាកដោយសារព្រលឹងរបស់ពួកយមបាលនិងវិញ្ញាណអាក្រក់ អស់កល្បជានិច្ចនិងនៅពេលនេះគាត់នឹងស្ថិតនៅជាប់ក្នុងចិត្តដោយពាក្យនោះ។" ដូច្នេះពេញដោយសង្ឃឹមបានធ្វើការជាច្រើនដើម្បីនឹងរក្សាក្បាលរបស់បងប្រុសរបស់គាត់ឱ្យងើបផុតពីទឹក។ ហើយពេលខ្លះគាត់ក៏ត្រូវធ្លាក់ចុះទៅក្រោមយ៉ាងខ្លាំង ហើយបន្តិចក្រោយមកគាត់ក៏បានងើបមកវិញស្ទើតែស្លាប់។ ពេញដោយសង្ឃឹមក៏បានព្យាយាមកំសាន្តចិត្តដល់គាត់និយាយថា "បងអើយ ខ្ញុំឃើញឃ្លោងទ្វារនិងមនុស្សឈរនៅក្បែរនោះដើម្បីទទួលយើង។" តែគ្រីស្ទានឆ្លើយងថា "នោះជាអ្នក ពួកគេរងចាំងអ្នកទេ ដោយសារតែអ្នកតែងតែមានសង្ឃឹមតាំងតែពីពេលដែលខ្ញុំបានស្គាល់អ្នកពីដំបូងមកម្ល៉េះ" "ដូច្នេះអ្នកនៅតែមានសង្ឃឹមដដែល" គ្រីស្ទានបាននិយាយ។ "អាហ៍ ប្អូនប្រុសអើយ" គាត់និយាយថា "ពិតណាស់ ប្រសិនបើខ្ញុំនិយាយត្រូវ នោះគាត់នឹងមកជួយខ្ញុំហើយពេល

នេះ។″ បន្ទាប់មកពេញដោយសង្ឃឹមនិយាយថា "បងប្រុសខ្ញុំអើយ បងពិតជាបានភ្លេចពីអត្ថបទមួយដែលនិយាយពីមនុស្សទុច្ចរិតហើយ គឺមិនមានបក្សពួកនៅពេលដែលគេស្លាប់ឡើយ តែកម្លាំងរបស់ពួកគេរឹងមាំ ពួកគេមិននៅក្នុងបញ្ហាដូចមនុស្សដ៏ទៃឡើយ ហើយពួកគេក៏មិនមានគ្រោះដូចមនុស្សដទៃដែរ។″

**"ពីព្រោះកាលគេស្លាប់ នោះគ្មានឈឺចាប់អ្វីសោះ គឺកម្លាំងគេនៅតែមាំមួនដដែល**
**គេមិនមានទុក្ខដូចជាមនុស្សធម្មតាឡើយ ក៏មិនត្រូវវេទនាដូចមនុស្សដទៃដែរ″**
**ទំនុកដំកើង 73:4, 5**

បញ្ហានិងសេចក្តីវេទនាទាំងនេះដែលអ្នកបានឆ្លងកាត់នៅក្នុងទឹកនេះមិនមែនជាសញ្ញាថា ព្រះបានបដិសេធអ្នកនោះទេ តែវាត្រូវបានបញ្ជូនមកដើម្បីនឹងសាកល្បងអ្នក ថាតើអ្នកនឹងមាននៅក្នុងគំនិតថា ដោយការនេះអ្នកនឹងបានទទួលសេចក្តីសប្បុរសរបស់ទ្រង់ដែរទេ ហើយនឹងរស់នៅដោយពឹងលើទ្រង់នៅក្នុងសេចក្តីលំបាកវេទនារបស់អ្នកដែរទេ។"

បន្ទាប់មកខ្ញុំបានឃើញនៅក្នុងសុបិនរបស់ខ្ញុំថា គ្រីស្ទានត្រូវបានកំសាន្តចិត្តមួយរយៈ ពេញដោយសង្ឃឹមក៏និយាយពាក្យនេះទៅគាត់ថែមទៀតថា "ចូរអរសប្បាយឡើង ព្រះយេស៊ូវគ្រីស្ទបានធ្វើឱ្យអ្នកបានបរិសុទ្ធ។" ហើយដោយសារការនោះ គ្រីស្ទានបានស្រែកយំយ៉ាងខ្លាំងថា "ឱ ខ្ញុំមើលឃើញ

ទ្រង់ម្តងទៀតហើយ! ហើយទ្រង់ប្រាប់ខ្ញុំថា នៅពេលដែលអ្នកឆ្លងកាត់ទឹក ខ្ញុំនឹងនៅជាមួយអ្នក ហើយឆ្លងកាត់ទន្លេ នោះវានឹងមិនត្រូវពន្លិចអ្នកឡើយ។"

**"កាលណាឯងដើរកាត់ទឹកធំ នោះអញនឹងនៅជាមួយ កាលណាដើរកាត់ទន្លេ នោះទឹកនឹងមិនលិចឯងឡើយ កាលណាឯងលុយកាត់ភ្លើង នោះឯងនឹងមិនត្រូវរលាក ហើយអណ្តាតភ្លើងក៏មិនឆាប់ឆេះឯងដែរ" អេសាយ 43:2**

បន្ទាប់មកពួកគេទាំងពីរបានមានចិត្តក្លាហានឡើយ ហើយសត្រូវបាននៅត្រឹងដូចជាដុំថ្ម រហូតទាល់តែពួកគេបានឆ្លងផុត។ ដូច្នេះគ្រីស្ទានពេលនេះបានរកឃើញដីដើម្បីនឹងឈរ ហើយដូច្នេះវានៅជាប់រហូតដល់ផុតទន្លេនៅតែរាក់ៗដដែល។ ដូច្នេះពួកគេក៏បានឆ្លងផុត។ ពេលនេះនៅមាត់ទន្លេ នៅម្ខាងទៀត ពួកគេបានឃើញបុរសពីរនាក់ដែលចែងចាំងម្តងទៀត ដែលនៅទីនោះរងចាំងពួកគេ។ ដូច្នេះ ដោយបានឡើងចេញពីទន្លេមក ពួកគាត់បានស្វាគមន៍គ្នាថា "ពួកគេជាវិញ្ញាណដែលចាំជួយ ត្រូវបានបញ្ជូនមកដើម្បីនឹងបម្រើដល់អស់អ្នកដែលជាអ្នកស្នងមរតកនៃសេចក្តីសង្គ្រោះ។" ដូច្នេះពួកគេបានបន្តទៅជាមួយគ្នារហូតដល់ឃ្លោងទ្វារ។ ពេលនេះអ្នកត្រូវតែសម្គាល់ថាទីក្រុងឈរនៅលើកំពូលភ្នំដ៏មានអំណាច តែអ្នកធ្វើធម្មយាត្រាបានដើរឡើងទៅលើកំពូលភ្នំដោយងាយ ពីព្រោះពួកគេមានបុរសពីរនេះនាំពួកគេលើងដោយដឹកដៃ ពួកគេក៏បានទុកសំលៀកបំពាក់មនុស្សចោលពីក្រោយនៅក្នុងទន្លេនោះទៅ ដោយសារបើទោះជាពួកគេទៅជាមួយសំលៀកបំពាក់នោះក៏ដោយ ក៏ពួកគេបានមកដោយគ្មានសំលៀកបំពាក់នោះដែរ។ ដូច្នេះពួកគេបានឡើងមកទីនេះដោយវាងវៃនិងល្បឿនលឿនខ្លាំង បើទោះជាគ្រឹះដែលទី

ក្រុងនៅខាងលើនោះមានគែមនៅខ្ពស់ជាងពពកក៏ដោយ។ ដូច្នេះពួកគេបាន លើងទៅដោយឆ្លងកាត់តំបន់នៃខ្យល់ ជជែកគ្នាយ៉ាងផ្អែមល្ហែមក្នុងកាល ដែលទៅ ត្រូវបានកំសាន្តចិត្ត ដោយសារពួកគេបានឆ្លងផុតទន្លេដោយសុវត្ថិភាព ហើយទាំងមានគ្នីគ្នាដែលពេញដោយសិរីល្អទៅជាមួយពួកគេ។

## ស្វាគមន៍

ការជជែករបស់ពួកគេជាមួយនឹងអស់អ្នកដែលមានពន្លឺចែងចាំងនោះគឺ ពីសិរីល្អនៃទីកន្លែងនោះ ពួកគេបានប្រាប់ពីសម្រស់និងសិរីល្អរបស់វាដែលត្រូវបានបង្ហាញមកឱ្យឃើញ។ "មាន" ពួកគេនិយាយថា "ជាភ្នំស៊ីយ៉ូន យេរូសាឡិមស្ថានសួគ៌ មានបរិវារទេវតាពាប់មិនអស់ និងវិញ្ញាណរបស់មនុស្សសុចរិតដែលត្រូវបានធ្វើឱ្យបានល្អឥតខ្ចោះ។"

"គឺអ្នករាល់គ្នាបានមកដល់ភ្នំស៊ីយ៉ូនវិញ ជាទីក្រុងនៃព្រះដ៏មានព្រះជន្មរស់ គឺក្រុងយេរូសាឡឹមនៃស្ថានសួគ៌ ហើយដល់ពួកទេវតាទាំងសល់សែន។ ដល់ទីប្រជុំរបស់មនុស្សទាំងឡាយ និងជំនុំពួកកូនច្បងដែលកត់ទុកនៅស្ថានសួគ៌ ដល់ព្រះដ៏ជាចៅក្រមនៃមនុស្សទាំងអស់ ដល់អស់ទាំងវិញ្ញាណនៃពួកសុចរិតដែលបានគ្រប់លក្ខណ៍ហើយ។ ដល់ព្រះយេស៊ូវ ដែលជាអ្នកកណ្តាលនៃសេចក្តីសញ្ញាថ្មី ហើយដល់ព្រះលោហិត ដែលសម្រាប់នឹងប្រោះ ជាព្រះលោហិត ដែលសម្តែងពីសេចក្តីប្រសើរ ជាជាងឈាមរបស់អេបិលទៅទៀតផង។" **ហេព្រើរ 12:22-24 ~**

ពេលនេះអ្នកកំពុងទៅ" ពួកគេនិយាយថា "ទៅកាន់ស្ថានសួគ៌របស់ព្រះជាម្ចាស់ នៅទីនោះអ្នកនឹងឃើញដើមឈើជីវិត និងបានបរិភោគផ្លែឈើដែលមិនចេះសាបសូន្យនៅទីនោះផង។ ហើយពេលដែលអ្នកចូលដល់ទីនោះនឹងមានសំលៀកបំពាក់សឱ្យមកដល់អ្នក ហើយការដើរហើរនិងការនិយាយរាល់ថ្ងៃជាមួយនឹងស្តេច នៅគ្រប់ថ្ងៃនៅអស់កល្បជានិច្ច។"

"អ្នកណាដែលមានត្រចៀក ឲ្យអ្នកនោះស្តាប់សេចក្តី ដែលព្រះវិញ្ញាណមានព្រះបន្ទូល ដល់ពួកជំនុំទាំងប៉ុន្មានចុះ ឯអស់អ្នកណាដែលឈ្នះ នោះអញនឹងឲ្យបរិភោគផ្លែរបស់ដើមជីវិត ដែលនៅស្ថានបរមសុខ របស់ព្រះ។" **វិវរណៈ 2:7**

"ប៉ុន្តែ នៅក្រុងសើដេស ឯងក៏មានអ្នកខ្លះ ដែលមិនបានធ្វើឲ្យសម្លៀកបំពាក់ខ្លួនស្មោកគ្រោកដែរ អ្នកទាំងនោះនឹងស្លៀកពាក់ស ដើរជាមួយនឹងអញ ដ្បិតគេបានគួរហើយ" **វិវរណៈ 3:4**

"កំផែងនៃទីក្រុងក៏មានជើង១២ ដែលមានឆ្លាក់ឈ្មោះ ជាឈ្មោះពួកសាវករបស់ពួកកូនចៀមទាំង១២នាក់។" **វិវរណៈ 21:14**

នៅទីនោះអ្នកនឹងមិនឃើញការអ្វីដែលអ្នកបានឃើញក្នុងកាលដែលអ្នករស់នៅតំបន់ទាបក្នុងផែនដីទៀតឡើយគឺមាន សេចក្តីសោកសង្រេង ជម្ងឺ ការធ្វើទុក្ខ និងសេចក្តីស្លាប់ ដោយសារការពីដើមត្រូវកន្លងផុតទៅ។

"បានជាអ្នកណានៅផែនដីដែលចង់បានពរ នោះនឹងរកពរដោយព្រះនៃសេចក្តីពិត ហើយអ្នកណានៅផែនដីដែលស្បថ នោះនឹងស្បថដោយព្រះនៃសេចក្តីពិតដែរ ពីព្រោះសេចក្តីវេទនាពីជាន់មុនបានភ្លេចទៅហើយ ក៏បានកំបាំងពីភ្នែកអញផង។" **អេសាយ 65:16**

អ្នកកំពុងតែទៅកាន់លោក អ័ប្រាហាំ អ៊ីសាក់ និងយ៉ាកុប និងទៅកាន់ពួកហោរា ពួកមនុស្សដែលព្រះបានយកចេញពីអាអាក្រក់ដែលនឹងត្រូវមក

ហើយថាពួកគេកំពុងតែសម្រាកនៅលើគ្រែរបស់ពួកគេ ម្នាក់ៗកំពុងដើរនៅក្នុងសេចក្ដីសុចរិតរបស់ខ្លួន។

**"មនុស្សសុចរិតគេវិនាសទៅ ឥតមានអ្នកណាយកចិត្តទុកដាក់ឡើយ ហើយមនុស្សចិត្តល្អ គេត្រូវយកទៅឥតមានអ្នកណាពិចារណាថា មនុស្សសុចរិតបានដកចេញឲ្យរួចពីចំពោះការអាក្រក់នោះទេ។ អ្នកនោះចូលទៅក្នុងសេចក្ដីសុខសាន្ត គេសម្រាកនៅលើដំណេករបស់ខ្លួន គឺគ្រប់ទាំងមនុស្សដែលដើរតាមផ្លូវទៀងត្រង់។" អេសាយ 57:1, 2**

បន្ទាប់មកពួកគេសួរថា "តើយើងត្រូវធ្វើអ្វីនៅទីបរិសុទ្ធ?" ដែលមានចម្លើយមកថា "អ្នកនឹងត្រូវទទួលបានការកំសាន្តបីគ្រប់ទាំងការនឿយហត់ទាំងប៉ុន្មាន ហើយនឹងមានអំណរដោយសារទាំងសេចក្ដីសោកសង្រេងទាំងប៉ុន្មានរបស់អ្នក អ្នកនឹងត្រូវប្រមូលផលអ្វីដែលអ្នកបានសាបព្រោះ ទាំងផលផ្លែនៃគ្រប់ទាំងការអធិស្ឋាន និងទឹកភ្នែករបស់អ្នកផង និងទុក្ខវេទនាដោយសារស្ដេចនៅតាមផ្លូវផង។"

**"កុំឲ្យច្រឡំឡើយ និងបញ្ឆោតព្រះមិនបានទេ ដ្បិតពូជណាដែលមនុស្សព្រោះចុះ នោះនឹងច្រូតបានពូជនោះឯងវិញ" កាឡាទី 6:7**

នៅទីនោះអ្នកនឹងពាក់មកុដមាស និងរីករាយនឹងទស្សនីយភាពនិងរូបភាព

ដែលមិនសាបសូន្យនៃព្រះអង្គដែលបរិសុទ្ធ ដោយសារនៅទីនោះអ្នកនឹងបានឃើញទ្រង់បែបជាទ្រង់តែម្តង។

**"ពួកស្ងួនភ្ងាអើយ ឥឡូវនេះ យើងរាល់គ្នាជាកូនព្រះហើយ តែដែលយើងរាល់គ្នានឹងបានទៅជាយ៉ាងណាទៀត នោះមិនទាន់សម្តែងមកនៅឡើយ ប៉ុន្តែយើងដឹងថា កាលណាទ្រង់លេចមក នោះយើងនឹងបានដូចជាទ្រង់ ដ្បិតដែលទ្រង់យ៉ាងណា នោះយើងនឹងឃើញទ្រង់យ៉ាងនោះឯង" យ៉ូហានទី១ 3:2**

នៅទីនោះអ្នកនឹងបម្រើទ្រង់ជាបន្តដោយមានការសរសើរ ដោយការស្រែកនិងការអរព្រះគុណ ជាមួយអង្គដែលអ្នកប្រាថ្នានឹងបម្រើនៅក្នុងផែនដី បើទោះជាមានការលំបាកខ្លាំងក៏ដោយ ដោយសារភាពមិនរឹងមាំខាងសាច់ឈាមរបស់អ្នក។ នៅទីនោះភ្នែករបស់អ្នកនឹងមានអំណរជាមួយនឹងការមើល ហើយត្រចៀករបស់អ្នកមានអំណរដោយការស្តាប់សម្លេងដែលជាទីគាប់ចិត្តនៃព្រះអង្គដែលមានអំណាចចេស្តា។ នៅទីនោះអ្នកនឹងបានរីករាយនឹងមិត្តសំឡាញ់របស់អ្នកម្តងទៀត ដែលពួកគេបានទៅដល់ទីនោះមុនអ្នក ហើយនៅទីនោះអ្នកនឹងមានអំណរដោយទទួលអ្នកគ្រប់គ្នាដែលមកដល់តាមក្រោយអ្នកផង។ ហើយនៅទីនោះអ្នកនឹងត្រូវបំពាក់ដោយសិរីល្អនិងអំណាចចេស្តា ហើយនឹងត្រូវដាក់ឱ្យជិះនៅយានចេញទៅជាមួយនឹងស្តេចនៃសិរីល្អផង។ នៅពេលដែលទ្រង់នឹងយាងមកជាមួយនឹងសូរត្រែនៅក្នុងពពក ដូចជានៅលើស្លាបខ្យល់ អ្នកនឹងមកជាមួយទ្រង់ ហើយនៅពេលដែលទ្រង់នឹងប្រថាប់នៅលើបល្ល័ង្កនៃការជំនុំជំរះ អ្នកនឹងអង្គុយនៅក្បែរទ្រង់។ ពិតណាស់ ហើយនៅពេលដែលទ្រង់នឹងធ្វើការកាត់ទោសដល់អ្នកបម្រើ

ខាងសេចក្តីទុច្ចរិត មិនថាជាទេវតាឬជាមនុស្សទេ អ្នកនឹងអាចនិយាយនៅក្នុងការជំនុំជំរះនោះដែរ ពីព្រោះពួកគេជាសត្រូវរបស់ទ្រង់និងរបស់អ្នកដែរ។ ហើយនៅពេលដែលទ្រង់នឹងត្រឡប់មកទីក្រុងវិញ អ្នកនឹងទៅដែរ ដោយមានសម្លេងត្រែនិងនៅជាមួយទ្រង់រហូត។"

"បងប្អូនអើយ ខ្ញុំមិនចង់ឲ្យអ្នករាល់គ្នាឥតដឹង ពីពួកអ្នកដែលដេកលក់ ទៅហើយទេ ក្រែងអ្នករាល់គ្នាកើតទុក្ខព្រួយ ដូចជាអ្នកឯទៀត ដែលគ្មានសង្ឃឹម។ ដ្បិតបើយើងជឿថា ព្រះយេស៊ូវបានសុគត ព្រមទាំងរស់ឡើងវិញហើយ នោះត្រូវជឿថា ព្រះទ្រង់នឹងនាំអស់អ្នកដែលដេកលក់ទៅក្នុងព្រះយេស៊ូវ ឲ្យបានមកជាមួយនឹងទ្រង់ដែរ។ ដ្បិតយើងខ្ញុំប្រាប់មកអ្នករាល់គ្នា តាមព្រះបន្ទូលនៃព្រះអម្ចាស់ដូច្នេះថា យើងដែលរស់នៅជាប់ ដរាបដល់ព្រះអម្ចាស់យាងមក នោះយើងមិនទៅមុនពួកអ្នក ដែលបានដេកលក់ទៅហើយនោះទេ។ ព្រោះព្រះអម្ចាស់ទ្រង់នឹងយាងចុះពីស្ថានសួគ៌មក ដោយស្រែកបង្គាប់១ព្រះឱស្ឋ ទាំងមានឮសំឡេងមហាទេវតា និងត្រែរបស់ព្រះផង នោះពួកស្លាប់ក្នុងព្រះគ្រីស្ទនឹងរស់ឡើងវិញជាមុនបង្អស់" ថែស្សាឡូនិចទី១ 4:13-16

"ឯហេណុក ជាជំណាទី៧ពីលោកអ័ដាមមក គាត់បានទាយពីមនុស្សទាំងនោះថា មើល ព្រះអម្ចាស់ទ្រង់យាងមក នៅកណ្តាលពួកបរិសុទ្ធទ្រង់ទាំងសល់សែន" យូដាស 14

"ខ្ញុំក៏គន់មើល ទាល់តែមានគេយកបល្ល័ង្កមកតាំង ហើយព្រះដ៏មានព្រះជន្មពីចាស់បុរាណ ទ្រង់ក៏គង់លើ ព្រះពស្ត្រទ្រង់សស្គុសដូចហិមៈ ហើយព្រះកេសនៅព្រះសិរទ្រង់ ក៏សដូចរោមចៀមយ៉ាងស្អាត ឯបល្ល័ង្កទ្រង់ នោះសុទ្ធតែជាអ

ណ្ដាតភ្លើង ហើយកង់នៃបល្ល័ង្កនោះ ក៏ជាភ្លើងឆេះដែរ។ មានដូចជាភ្លើងហូរចេញពីចំពោះទ្រង់មក មានទាំងពាន់ទាំងពាន់ដែលគោរពដល់ទ្រង់ ហើយទាំង ម៉ឺនទាំងសែនក៏ឈរនៅចំពោះទ្រង់ នោះការវិនិច្ឆ័យបានរៀបចំជាស្រេច ឯបញ្ជីទាំងប៉ុន្មានបានបើកឡើងហើយ” **ដានីយ៉ែល 7:9, 10**

“តើមិនដឹងថា ពួកបរិសុទ្ធនឹងជំនុំជម្រះលោកីយ៍ដែរទេឬ ដូច្នេះ បើអ្នករាល់គ្នានឹងជំនុំជម្រះលោកីយ៍បាន នោះតើមិនគួរនឹងជំនុំជម្រះការណ៍តូចបំផុតនេះបានដែរទេឬអី។ តើមិនដឹងថា យើងរាល់គ្នានឹងជំនុំជម្រះ ដល់ទាំងពួកទេវតាផងទេឬអី ដូច្នេះ ចំណងបើការណ៍នៅជីវិតនេះ តើលើសជាងអម្បាលម៉ានទៅទៀត” **កូរិនថូសទី១ 6:2, 3**

ពេលនេះ ក្នុងកាលដែលពួកគេខិតមកជិតឃ្លោងទ្វារ មើលទៅមានបក្សពួកនៃបរិវារស្ថានសួគ៌ចេញមកជួបពួកគេ ដែលត្រូវបាននិយាយទៅកាន់ពួកគេដោយអ្នកដែលភ្លឺចែងចាំងថា “ទាំងនេះជាមនុស្សដែលបានស្រឡាញ់ព្រះអម្ចាស់របស់យើង ក្នុងកាលដែលពួកគេនៅលើផែនដី ហើយបានបោះបង់ចោលទាំងអស់ដោយសារព្រះនាមបរិសុទ្ធរបស់ទ្រង់ ហើយទ្រង់បានបញ្ជូនយើងមកនាំយកពួកគេទៅ ហើយយើងបាននាំពួកគេមកដល់គោលដៅដែលពួកគេប្រាថ្នាហើយ ដែលពួកគេនឹងចូលទៅក្នុង ហើយមើលទៅកាន់ព្រះអង្គសង្គ្រោះរបស់ពួកគេដោយផ្ទាល់មុខដោយអំណរផង។” បន្ទាប់មកពួកបរិវារស្ថានសួគ៌បានស្រែកយ៉ាងខ្លាំងថា “មានពរហើយអស់អ្នកណាដែលត្រូវបានហៅមកកាន់អាហារនៃមង្គលការរបស់កូនចៀម។”

**"ទេវតាក៏ប្រាប់មកខ្ញុំថា ចូរសរសេរថា មានពរហើយ អស់អ្នកដែលព្រះបាន ហៅមកបរិភោគការកូនចៀម ក៏និយាយមកខ្ញុំទៀតថា នេះជាព្រះបន្ទូលពិត របស់ព្រះ" វិវរណៈ 19:9 ~**

នៅទីនោះមានអ្នកផ្លុំត្រែមួយចំនួនរបស់ស្ដេចបានចេញមកជួបពួកគេ ដែលមានស្លៀកពាក់សនិងរស្មីចែងចាំង ដោយសម្លេងពិរោះរណ្ដំរបស់ពួកគេៗ ដែលធ្វើឱ្យទាំងស្ថានសួគ៌បានបន្ទរដោយសម្លេងរបស់ពួកគេ។ អ្នកផ្លុំត្រែទាំងនេះស្វាគមន៍ដល់គ្រីស្ទាននិងគ្នារបស់គាត់ដោយការស្វាគមន៍មួយម៉ឺនចេញពីផែនដី ហើយដោយមានការស្រែកហោរនិងសម្លេងនៃត្រែ។

រួចមក ក៏នាំពួកគេទៅក្រឡឹងគ្រប់ជ្រុងជ្រោយ អ្នកខ្លះដើរទៅមុខ ខ្លះទៀតទៅពីក្រោយ ហើយខ្លះនៅខាងស្ដាំ ខ្លះនៅខាងឆ្វេង (ដែលនៅទីនោះដើម្បីនឹងដឹកនាំពួកគេកាត់តំបន់ដែលនៅខាងលើ)។ គេនៅតែបន្តបង្កើតសម្លេងក្នុងកាលដែលដើរទៅផង ដោយសម្លេងយ៉ាងរណ្ដំ នៅក្នុងខ្ទង់សម្លេងយ៉ាងខ្ពស់ ដូច្នេះគ្រប់ទាំងទស្សនីយភាពពួកគេអាចមើលឃើញ ប្រៀបដូចជាស្ថានសួគ៌ផ្ទាល់ត្រូវបានចុះមកក្រោយជួបនឹងពួកគេអីចឹង។ ដូច្នេះ ពួកគេបន្តដើរជាមួយគ្នា ហើយពេលដែលពួកគេដើរ បន្តិចក្រោយមកអ្នកផ្លុំត្រែទាំងនេះបានលាយសម្លេងអរសប្បាយជាមួយនឹងទឹកមុខនិងកាយវិការតន្ត្រីទៅដល់គ្រីស្ទាននិងបងប្អូនរបស់គាត់ ថាពួកគេស្វាគមន៍ខ្លាំងប៉ុណ្ណាដែលពួកគេបានមកចូលរួម និងដោយសេចក្ដីត្រេកអរដែលពួកគេបានមកជួបគ្នា។ ហើយពេលនេះបុរសទាំងពីរបានមកដល់ស្ថានសួគ៌ មុនពេលដែលពួកគេចូលមកដល់ផង ដោយការភ្ញាក់ផ្អើលនឹងទស្សនីយភាពរបស់ទេវតា និង

ដោយស្តាប់សូរសម្លេងពិរោះរណ្តំផង។ នៅទីនេះពួកគេក៏បានឃើញទេសភាពនៃទីក្រុងផ្ទាល់ផងដែរ ហើយពួកគេគិតថាពួកគេបានឮសម្លេងកណ្តឹងរោទ៍នៅក្នុងទីនោះផង ដែលស្វាគមន៍ពួកគេចូលទៅ តែលើសពីនោះទៅទៀត គំនិតដែលកក់ក្តៅនិងពេញដោយអំណរដែលពួកគេមានក្នុងកាលដែលត្រូវស្នាក់នៅទីនោះ ជាមួយនឹងមនុស្សម្នាបែបនោះ ហើយត្រូវនៅជានិរន្តន៍ផង។ អូ តើមានអណ្តាតនិងប៊ិចអ្វីដែលនឹងអាចរៀបរាប់បង្ហាញពីសេចក្តីអំណរពេញដោយសិរីល្អរបស់ពួកគេបានទៅ! ហើយដូច្នេះពួកគេក៏មកដល់ឃ្លោងទ្វារ។

ពេលនេះនៅពេលដែលពួកគេមកដល់ឃ្លោងទ្វារ មានពាក្យសរសេរនៅលើនោះដោយតួអក្សរមាសថា "មានពរហើយអស់អ្នកដែលធ្វើតាមបញ្ញាត្តិទ្រង់ ដែលពួកគេនឹងមានសិទ្ធិចូលដល់ដើមជីវិត ហើយនឹងចូលទៅក្នុងតាមឃ្លោងទ្វារទៅកាន់ទីក្រុងផង។"

**"មានពរហើយអស់អ្នកណាដែលលាងអាវខ្លួន ដើម្បីឲ្យបានច្បាប់ដល់ដើមជីវិត ហើយឲ្យបានចូលទៅក្នុងក្រុងតាមទ្វារ" វិវរណៈ 22:14**

បន្ទាប់មកខ្ញុំឃើញនៅក្នុងសុបិនរបស់ខ្ញុំថា មនុស្សដែលចែងចាំងប្រាប់ពួកគេឱ្យហៅនៅត្រង់ឃ្លោងទ្វារ ហើយកាលដែលពួកគេធ្វើតាម មានអ្នកខ្លះមើលមកពីលើឃ្លោងទ្វារ ដូចជាលោកអេណុក ម៉ូសេ និងអេលីយ៉ា ដែលត្រូវបាននិយាយទៅកាន់ពួកគេថា "អ្នកធ្វើធម្មយាត្រាទាំងនេះមកបីទីក្រុងនៃសេចក្តីវិនាស ដោយសារសេចក្តីស្រឡាញ់ដែលពួកគេមានដល់ស្តេចនៃទីនេះ

។" ហើយបន្ទាប់មកអ្នកធ្វើធម្មយាត្រាផ្តល់សញ្ញាបត្ររបស់ពួកគេផ្ទាល់ខ្លួនម្នាក់ៗទៅ ដែលពួកគេបានទទួលតាំងពីដើមមក។ ហើយសញ្ញាបត្រទាំងនោះត្រូវបានយកទៅកាន់ស្តេច កាលដែលទ្រង់បានអាននោះក៏មានបន្ទូលថា "តើពួកគេនៅទីណា?" ដែលគេបានឆ្លើយដល់ទ្រង់ថា "ពួកគេកំពុងឈរនៅក្រៅឃ្លោងទ្វារ។" "ជាពួកសាសន៍ដែលសុចរិត" ទ្រង់មានបន្ទូលថា "ដែលបានរក្សាសេចក្តីពិត នឹងអាចចូលមកបាន។"

**"ចូរបើកទ្វារ ដើម្បីឲ្យសាសន៍សុចរិតដែលរក្សាសេចក្តីស្មោះត្រង់បានចូលមកចុះ" អេសាយ 26:2**

ពេលនេះខ្ញុំបានឃើញនៅក្នុងសុបិនរបស់ខ្ញុំថា បុរសទាំងពីរបានចូលតាមឃ្លោងទ្វារ ហើយមើលទៅកាលដែលពួកគេចូលទៅ ពួកគេត្រូវបានប្រែរូបរាង ហើយពួកគេមានរស្មីចែងចាំងពាក់ដូចជាមាស។ ក៏មានមនុស្សដែលបានជួបនឹងពួកគេដោយមានចាប់ស៊ុងនិងមកុដផង ហើយបានជូនដល់ពួកគេ។ ចាប់ស៊ុងដើម្បីនឹងសរសើរ ហើយមកុដជាគ្រឿងសម្គាល់នៃកិត្តិយស។ បន្ទាប់មកខ្ញុំបានឮនៅក្នុងសុបិនរបស់ខ្ញុំថា គ្រប់ទាំងកណ្តឹងនៅក្នុងទីក្រុងបានរោទិ៍ដោយអំណរម្តងទៀត ហើយដែលមាននិយាយទៅកាន់ពួកគេថា "ចូរអ្នកចូលទៅក្នុងសេចក្តីអំណររបស់ព្រះអម្ចាស់របស់អ្នកចុះ។" ខ្ញុំក៏បានឮបុរសទាំងពីរផ្ទាល់ច្រៀងដោយសម្លេងឮៗថា "ព្រះពរ កិត្តិយស សិរីល្អ និងចេស្តា ដល់ទ្រង់ដែលគង់លើបល្ល័ង្គ និងទៅដល់កូនចៀមអស់កល្បជានិច្ចទៅ។"

"នោះខ្ញុំក៏ឮគ្រប់ទាំងអស់ ដែលមានជីវិត នៅស្ថានសួគ៌នៅផែនដី នៅក្រោមដី ហើយនៅក្នុងសមុទ្រ និងគ្រប់ទាំងអស់ដែលនៅស្ថានទាំងនោះនិយាយថា សូមថ្វាយព្រះពរ កិត្តិនាម សិរីល្អ និងព្រះចេស្តា ដល់ព្រះអង្គដែលគង់លើបល្ល័ង្ក ហើយដល់កូនចៀម នៅអស់កល្បជានិច្ចរៀងរាបតទៅ។ រួចតួមានជីវិតទាំង៤ក៏ទទួលថា អាម៉ែន ហើយពួកចាស់ទុំក៏ទម្លាក់ខ្លួនក្រាបចុះថ្វាយបង្គំ។"
**វិវរណៈ 5:13, 14**

ពេលនេះ កាលដែលឃ្លោងទ្វារបានបើកឡើងដើម្បីឱ្យបុរសទាំងពីរចូល ខ្ញុំបានមើលទៅពីក្រោយពួកគេ បានឃើញ ទីក្រុងចែងចាំងដូចជាព្រះអាទិត្យ ផ្លូវត្រូវបានសាងដោយមាស ហើយមានមនុស្សដើរជាច្រើន មានមកុដនៅលើក្បាលរបស់ពួកគេ ធាងស្លានៅដៃរបស់ពួកគេ និងចាប់ស៊ុងមាសដើម្បីនឹងច្រៀងសរសើរ។

ក៏មានពួកអ្នកដែលមានស្លាប ហើយឆ្លើយទៅកាន់គ្នាដោយឥតឈប់ឈរថា "បរិសុទ្ធ បរិសុទ្ធ បរិសុទ្ធ ជាព្រះអម្ចាស់!" ហើយបន្ទាប់មកពួកគេបានបិទឃ្លោងទ្វារ ដែលខ្ញុំបានឃើញនោះ ខ្ញុំប្រាថ្នាថាខ្ញុំជាម្នាក់ក្នុងចំណោមពួកគេដែរ។

ភាពល្ងង់ខ្លៅបានមកដល់ទីបញ្ចប់របស់គេ

ពេលនេះ នៅពេលដែលខ្ញុំសម្លឹងមើលទៅលើការទាំងនេះ ខ្ញុំបានបែរក្បាលរបស់ខ្ញុំមើលមកក្រោយ ហើយបានឃើញល្ងង់ខ្លៅមកដល់ក្បែរទន្លេ តែភ្លាម

នោះក៏បានចេញផុត ហើយដោយគ្មានការលំបាកស្មើនឹងពាក់កណ្ដាលនៃបុរសពីនាក់ទៀតបានជួបនោះឡើយ។ ដោយសារចៃដន្យមានម្នាក់នៅទីនោះឈ្មោះ សង្ឃឹមឥតប្រយោជន៍ ជាអ្នកបើកទុកសន្ដោង ដែលបានជួយគាត់ដោយប្រើទូកនោះឆ្លង។ ដូច្នេះគាត់ក៏បានឡើងមកលើកំពូលភ្នំដូចអ្នកផ្សេងទៀតដែរតាមដែលខ្ញុំបានឃើញបានមកកាន់ឃ្លោងទ្វារ តែគាត់មកតែម្នាក់ឯង គ្មាននរណាម្នាក់មកជាមួយគាត់ដោយការលើកទឹកចិត្តឡើយ។ នៅពេលដែលគាត់មកដល់ឃ្លោងទ្វារ គាត់បានមើលទៅកាន់ពាក្យសរសេរដែលនៅខាងលើ ហើយក៏ចាប់ផ្ដើមគោះទ្វារ ដោយសង្ឃឹមថានឹងបានបើកទ្វារឱ្យគាត់បានចូលភ្លាម តែត្រូវមនុស្សដែលនៅលើឃ្លោងទ្វារសួរមកគាត់ថា "តើអ្នកមកពីណា? ហើយតើអ្នកចង់បានអ្វី?" គាត់បានឆ្លើយថា "ខ្ញុំបានបរិភោគនិងផឹកនៅក្នុងវត្តមានរបស់ស្ដេច ហើយទ្រង់បានបង្រៀននៅតាមផ្លូវរបស់យើង។" បន្ទាប់មកពួកគេបានសួររកសញ្ញាបត្ររបស់គាត់ ដែលពួកគេនឹងអាចចូលទៅបង្ហាញដល់ស្ដេចបាន។ គាត់ក៏ស្ទាបនៅនឹងទ្រូងរបស់គាត់រកវា ហើយរកមិនឃើញសោះ។ បន្ទាប់មកពួកគេនិយាយថា "តើអ្នកមិនមានទេឬអី?" ប៉ុន្តែបុរសនោះមិនអាចឆ្លើយបានសូម្បីតែមួយម៉ាត់។ ដូច្នេះពួកគេក៏បានប្រាប់ដល់ស្ដេច តែទ្រង់មិនបានចុះមកមើលគាត់ឡើយ តែបានបង្គាប់បុរសដែលចែងចាំងពីរនាក់ឱ្យហែរហាមគ្រីស្ទាននិងពេញដោយសង្ឃឹមទៅកាន់ទីក្រុង ហើយឱ្យចេញទៅក្រៅនិងនាំយកល្វង់ខ្លៅ ហើយចងដៃជើងគាត់ ហើយយកគាត់ចេញទៅ។ បន្ទាប់មកពួកគេបានលើកគាត់ឡើង ហើយនាំគាត់ឆ្លងកាត់ខ្យល់ទៅកាន់ទ្វារដែលខ្ញុំបានឃើញនៅខាងភ្នំនោះ ហើយបានទុកគាត់នៅទីនោះ។ បន្ទាប់មកខ្ញុំបានឃើញនៅទីនោះមានផ្លូវទៅកាន់ស្ថាននរក ដែលជាផ្លូវចេញពីឃ្លោងទ្វារស្ថានសួគ៌ ក៏ដូច

ជាចេញពីទីក្រុងនៃសេចក្តីវិនាសអន្តរាយ។ ដូច្នេះខ្ញុំក៏ភ្ញាក់ឡើង ហើយមើល វាគឺជាសុបិនប៉ុណ្ណោះ!

## សេចក្ដីសរុប

ពេលនេះ អ្នកអានអើយ ខ្ញុំបានប្រាប់ពីសុបិនរបស់ខ្ញុំដល់អ្នកហើយ។ ចូរមើលតើអ្នកអាចបកស្រាយវាដល់ខ្ញុំទេ ឬទៅដល់ខ្លួនអ្នកផ្ទាល់ ឬអ្នកជិតខាងនោះ។ តែត្រូវប្រយ័ត្ននឹងការបកប្រែខុស ដោយសារ ជំនួសអោយការធ្វើល្អ បែរជាធ្វើដោយបំពានដោយខ្លួនអ្នកវិញ ដោយការបកប្រែខុសដែលអារក្សវាធ្វើសម្រេច។ ចូរប្រយ័ត្នថានឹងមិនជ្រុលពេកនៅក្នុងការបកស្រាយដោយអ្វីដែលនៅក្រៅពីសុបិនរបស់ខ្ញុំ ក៏មិនត្រូវឱ្យរូបភាព និងរូបតំណាងធ្វើឱ្យអ្នកសើចនិងមានជំលោះនោះឡើយ។ ទុកការនោះឱ្យដល់ក្មេងៗនិងមនុស្សល្ងីល្ងើវិញ តែសម្រាប់អ្នកវិញ សូមអ្នកមើលទៅកាន់ធាតុនៃបញ្ហារបស់ខ្ញុំវិញ។ ចូរដាក់នៅក្បែរវាំងនន មើលទៅខាងក្នុងកន្សែងគ្រប ចូរបើកការប្រៀបប្រដូចរបស់ខ្ញុំកុំខានឱ្យសោះ។ ប្រសិនបើអ្នកស្វែងការទាំងនោះ ការទាំងនោះនឹងត្រូវបានរកឃើញ ហើយនឹងមានប្រយោជន៍ដល់គំនិតដែលស្មោះត្រង់ផង។ ការដែលជាសម្រាមដែលអ្នករកឃើញនៅទីនោះ ចូរអ្នកក្លាហាននឹងបោះវាចោលទៅ តែចូររក្សាអ្វីដែលជាមាសទុកវិញ។ ចុះប្រសិនបើមាសត្រូវខ្ញុំត្រូវរុំនឹងថ្មនោះ? គ្មានអ្នកណានឹងបោះផ្លែប៉មចោលហើយទៅយកស្នូលវានោះឡើយ។ តែប្រសិនបើអ្នកនឹងបោះចោលទាំងអស់ជាឥតប្រយោជន៍នោះ  ខ្ញុំមិនដឹងទេ តែវានឹងធ្វើឱ្យខ្ញុំសុបិនម្ដងទៀត។

ទីបញ្ចប់នៃផ្នែកទីមួយ